

អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

LOLC (Cambodia) Plc.

គំនិតរីកចម្រើន *Ideas for Growth*

# របាយការណ៍ប្រចាំឆ្នាំ

# ២០២៣

www.lolc.com.kh

# មាតិកា


ទិន្នន័យហិរញ្ញវត្ថុ និងប្រតិបត្តិការសំខាន់ៗ
មតិយោបល់របស់ប្រធានក្រុមប្រឹក្សាភិបាល
របាយការណ៍របស់ប្រធាននាយកប្រតិបត្តិ

## ០១

### អំពី អិលអូអិលស៊ី (ខេមបូឌា)

- ទិដ្ឋភាពទូទៅអំពីប្រទេសកម្ពុជា (២០)
- ទិដ្ឋភាពទូទៅអំពី អិលអូអិលស៊ី (ខេមបូឌា) (២២)
- វិញ្ញាបនបត្រ និងពានរង្វាន់ (២៩)
- ដៃគូហិរញ្ញប្បទាន និងអាជីវកម្ម (៣២)

## ០២

### អំពីអាជីវកម្ម

- សមិទ្ធផលអាជីវកម្ម (៣៦)
- របាយការណ៍ហិរញ្ញវត្ថុសង្ខេប ៣ឆ្នាំ (៤២)
- សមិទ្ធផលសំខាន់ៗដែលសម្រេចបាន ក្នុងឆ្នាំ២០២៣ (៤៦)
- ទស្សនវិស័យឆ្នាំ២០២៤ (៤៨)

## ០៣

### អភិបាលកិច្ច

- រចនាសម្ព័ន្ធនៃការគ្រប់គ្រង (៥២)
- គោលនយោបាយ និងគោលការណ៍ណែនាំសម្រាប់ អភិបាលកិច្ចសាជីវកម្ម (៥៤)
- របាយការណ៍ក្រុមប្រឹក្សាភិបាល (៦៦)
- ក្រមសីលធម៌ (៦៨)
- ការគ្រប់គ្រងហានិភ័យ និងការគ្រប់គ្រងផ្ទៃក្នុង (៧០)
- ការអភិវឌ្ឍធនធានមនុស្ស (៧៨)
- គណៈគ្រប់គ្រង (៨០)

## ០៤

### ការប្តេជ្ញាចិត្តឆ្ពោះទៅរកនិរន្តរភាព បរិស្ថាន និងសង្គម

- តួនាទី និងទំនួលខុសត្រូវនៃផ្នែកគ្រប់គ្រង និរន្តរភាព បរិស្ថាន និងសង្គម (៩២)
- សមិទ្ធផលបរិស្ថាន សង្គម និងអភិបាលកិច្ចក្នុងឆ្នាំ២០២៣ និងគោលដៅឆ្នាំ២០២៤ (៩៤)
- តារាងសកម្មភាពដែលត្រូវហាមឃាត់ដោយ អិលអូអិលស៊ី (៩៦)
- ការវាយតម្លៃ និងការយល់ដឹងពីហានិភ័យលើ បរិស្ថាន និងសង្គម (៩៨)
- សិទ្ធិរបស់អតិថិជន (១០០)
- យន្តការនៃការដោះស្រាយបណ្តឹងតវ៉ា (១០១)
- ការបណ្តុះវិន័យឥណទានតាមរយៈ A4 Metacard (១០២)
- ការប្តេជ្ញាចិត្តរបស់ អិលអូអិលស៊ី ក្នុងការផ្តល់ប្រាក់កម្ចីប្រកបដោយ ទំនួលខុសត្រូវ (១០២)
- ការចូលរួមជាមួយ UNITED NATIONS GLOBAL COMPACT (UNGC) (១០៣)
- ការអនុលោមតាមគោលការណ៍ការពារអតិថិជន (១០៤)
- ការយល់ដឹងអំពីការអប់រំផ្នែកហិរញ្ញវត្ថុ (១០៦)
- ទំនួលខុសត្រូវសង្គម និងសកម្មភាពសង្គមផ្សេងៗទៀត (១១០)
- យន្តការត្រួតពិនិត្យ និងតាមដានផលប៉ះពាល់លើបរិស្ថាន (១១២)
- ផលិតផលដែលជួយលើកកម្ពស់បរិស្ថាន និងសង្គម (១១៤)
- ការចូលរួមលើកកម្ពស់សង្គម (១១៦)
- អភិបាលកិច្ច (១១៨)
- ការវាយតម្លៃផលប៉ះពាល់របស់ អិលអូអិលស៊ី (ខេមបូឌា) ទៅលើបរិស្ថាន និងសង្គម (១២០)
- អតិថិជនជោគជ័យ (១២៦)

## ០៥

### របាយការណ៍ហិរញ្ញវត្ថុ និង របាយការណ៍សវនករឯករាជ្យ

- របាយការណ៍ក្រុមប្រឹក្សាភិបាល (១២៤)
- របាយការណ៍សវនករឯករាជ្យ (១២៨)
- របាយការណ៍ហិរញ្ញវត្ថុ (១៣១)




# ការទូទាត់សម្រាប់ យុគសម័យថ្មី

**iPay Cambodia** គឺជាកម្មវិធីធនាគារចល័តតាមរយៈទូរសព្ទដៃ ដែលបង្កើតឡើងដោយ អិលអូអិលសុី (ខេមបូឌា)។ តាមរយៈកម្មវិធីនេះ អនុញ្ញាតឱ្យអតិថិជន ធ្វើប្រតិបត្តិការនានានៅលើគណនីសំចៃរបស់ខ្លួន បានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ អតិថិជនអាចធ្វើប្រតិបត្តិការដែលរួមមានដូចជា៖ ពិនិត្យមើលសមតុល្យគណនី ផ្ទេរប្រាក់ (ក្នុងរង្វង់ អិលអូអិលសុី (ខេមបូឌា) ឬឆ្លងធនាគារ) បើកគណនីប្រាក់បញ្ញើមានកាលកំណត់ បញ្ចូលទឹកប្រាក់ក្នុងទូរសព្ទ ទូទាត់វិក្កយបត្រ និងប្រតិបត្តិការជាច្រើនទៀត បានយ៉ាងឆាប់រហ័ស និងមានសុវត្ថិភាព។




# ទិន្នន័យហិរញ្ញវត្ថុ និងប្រតិបត្តិការសំខាន់ៗ

| ទ្រព្យសកម្មសរុប | ផលប័ត្រឥណទានសរុប | ចំនួនអតិថិជនដាក់ប្រាក់បញ្ញើ | ប្រាក់ចំណេញសុទ្ធ |
|---|---|---|---|
| ១,៥៦ ពាន់លានដុល្លារ | ១,២៤ ពាន់លានដុល្លារ | ៩០៤ លានដុល្លារ | ៦៥,៧១ លានដុល្លារ |

| ចំនួនអតិថិជនកម្ចី | ចំនួនអតិថិជនដាក់ប្រាក់បញ្ញើ | ចំនួនបុគ្គលិក |
|---|---|---|
| ៣៣៥.០៨៩ | ៥១០.៩៧២ | ៣.៥៩០ |

| ម៉ាស៊ីនអេធីអឹម (ស៊ីអេសអេស) | ប័ណ្ណអេធីអឹម | អ្នកប្រើប្រាស់អាយផេ | អាជីវករអាយផេ | បណ្តាញសាខា |
|---|---|---|---|---|
| ៤.០០០+ | ៥៦.៨២១ | ៨០.៤៨៦ | ២២.៨៨០ | ៨៣ សាខា |



លោក BRINDLEY DE ZYLVA

ប្រធានក្រុមប្រឹក្សាភិបាល

# ចំណាប់អារម្មណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល

## លោក BRINDLEY DE ZYLVA

ប្រធានក្រុមប្រឹក្សាភិបាល

**សេដ្ឋកិច្ចសាកល** បានបន្តងើបឡើងប៉ុន្តែក្នុងល្បឿនយឺតជាងឆ្នាំមុន ដោយសារការអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ការរឹតបន្តឹងនយោបាយរូបិយវត្ថុនៅប្រទេសអភិវឌ្ឍចម្បងៗ និងការកើនឡើងភាពតានតឹងភូមិសាស្ត្រនយោបាយនៅមជ្ឈិមបូព៌ា។ តាមការព្យាកររបស់មូលនិធិរូបិយវត្ថុអន្តរជាតិ កំណើនសេដ្ឋកិច្ចពិភពលោកនៅឆ្នាំ២០២៣ អាចសម្រេចបានក្នុងអត្រា ៣% ធៀបនឹង ៣,៥% នៅឆ្នាំមុន។ សេដ្ឋកិច្ចប្រទេសអភិវឌ្ឍរំពឹងថានឹងកើនឡើង ១,៥% ខណៈប្រទេសកំពុងលូតលាស់ និងប្រទេសកំពុងអភិវឌ្ឍនឹងកើនឡើងក្នុងអត្រា ៤%។ ទន្ទឹមនឹងនេះ អតិផរណាពិភពលោកបានថយចុះពី ៨,៧% នៅឆ្នាំ២០២២ មកត្រឹម ៦,៨% ប៉ុន្តែបន្តមានអត្រាខ្ពស់ជាងកម្រិតគោលដៅ ដែលធ្វើឱ្យធនាគារកណ្តាលបន្តអនុវត្តនយោបាយរូបិយវត្ថុរឹតបន្តឹងបន្ថែមទៀត។

**សេដ្ឋកិច្ចកម្ពុជា** ត្រូវបានប៉ាន់ស្មានថាបន្តងើបឡើងក្នុងអត្រា ៥,៥% ខ្ពស់ជាងឆ្នាំមុនបន្តិច (៥,២%) ដែលគាំទ្រជាចម្បងដោយកំណើនវិស័យទេសចរណ៍ និងផលិតផលកម្មន្តសាលមិនមែនកាត់ដេរ បើទោះបីជាវិស័យកាត់ដេរ សំណង់ អចលនទ្រព្យ និងកសិកម្មមានកំណើនទាបក៏ដោយ។ វិស័យទេសចរណ៍បានកើនឡើងជាលំដាប់ និងបានចូលរួមចំណែកជំរុញការងើបឡើងនៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកដែលពាក់ព័ន្ធដូចជា៖ ការដឹកជញ្ជូន ពាណិជ្ជកម្ម និងទូរគមនាគមន៍ជាដើម។ ការនាំចេញផលិតផលមិនមែនកាត់ដេរដូចជា៖ គ្រឿងអេឡិចត្រូនិក គ្រឿងបន្លាស់រថយន្ត និងបន្ទះសូឡាទទួលបានកំណើនល្អ ខណៈដែលការនាំចេញសម្លៀកបំពាក់ និងស្បែកជើងបានទទួលរងផលប៉ះពាល់ពីការធ្លាក់ចុះតម្រូវការនៃប្រទេសដៃគូពាណិជ្ជកម្មចម្បងៗ ជាពិសេសសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក។ វិស័យសំណង់ទទួលបានកំណើនទាប ដែលជាចម្បងត្រូវបានជំរុញដោយការវិនិយោគ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ខណៈដែលការ វិនិយោគបរទេសនៅក្នុងវិស័យអចលនទ្រព្យបានថយចុះ។ វិស័យកសិកម្មបានកើនឡើងបន្តិច ដែលគាំទ្រដោយកំណើនតម្រូវការក្រៅប្រទេស និងភាពអំណោយផលនៃកត្តាអាកាសធាតុ។ ចំណែកឯអត្រាអតិផរណាកម្ពុជាបានថមថយមកកម្រិតជាមធ្យម ២,១% នាឆ្នាំ២០២៣ ពី ៥,៤% នាឆ្នាំ២០២២ ដោយសារការធ្លាក់ថ្លៃលើក្រុមទំនិញ និងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ និងការថយល្បឿននៃកំណើនថ្លៃម្ហូបអាហារនេះ បើយោងតាមរបាយការណ៍ប្រចាំឆ្នាំ២០២៣ ដែលចេញដោយធនាគារជាតិនៃកម្ពុជា។

**អិលអូអិលស៊ី** បានអនុវត្តប្រតិបត្តិការប្រកបដោយការប្រុងប្រយ័ត្ន ដើម្បីធានានូវគុណភាព និងនិរន្តរភាព។ អតិថិជនដែលប្រាក់ចំណូលបានរងផលប៉ះពាល់ពីកូវីដ១៩ និងគ្រោះទឹកជំនន់ នៅមិនទាន់ទទួលបានប្រាក់ចំណូលពេញលេញនៅឡើយទេ បើប្រៀបធៀបទៅនឹងស្ថានភាពមុនកូវីដ១៩។ ជាមួយនឹងការគាំទ្រផ្នែកបទបញ្ញត្តិពីធនាគារជាតិនៃកម្ពុជា អិលអូអិលស៊ី (ខេមបូឌា) អាចបន្តផ្តល់ការអនុគ្រោះដល់អតិថិជន តាមរយៈការផ្តល់រយៈពេលអនុគ្រោះដល់ពួកគាត់ ដើម្បីឱ្យពួកគាត់មានពេលវេលាក្នុងការចាប់ផ្តើមអាជីវកម្មឡើងវិញ ជាពិសេសក្នុងវិស័យទេសចរណ៍។

ក្នុងយុគសម័យឌីជីថល ប្រជាជនបានបង្កើនតម្រូវការក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុឌីជីថល (DFS)។ ទន្ទឹមនឹងនេះ អិលអូអិលស៊ី បានសម្របខ្លួនយ៉ាងឆាប់រហ័សទៅនឹងការប្រើប្រាស់សេវាហិរញ្ញវត្ថុតាមបែបឌីជីថល និងបានផ្តល់ជូននូវដំណោះស្រាយធនាគារឌីជីថលយ៉ាងសម្បូរបែប ដើម្បីបំពេញតាមកំណើននៃតម្រូវការរបស់អតិថិជន ដែលរួមមាន កម្មវិធីធនាគារចល័ត iPay Cambodia Mobile App ដែលផ្តល់មុខងារកាន់តែប្រសើរជាងមុនក្នុងការធ្វើប្រតិបត្តិការសេវាធនាគារតាមអ៊ីនធើណែត សេវាផ្ទេរមូលនិធិភ្លាមៗ (RFT) សេវាទូទាត់រហ័ស (FAST) និងប្រព័ន្ធបាគង ជាដើម។ តាមរយៈបណ្តាញធនាគារឌីជីថលទាំងនេះ អតិថិជនរបស់យើងអាចធ្វើប្រតិបត្តិការធនាគារដោយខ្លួនឯងយ៉ាងងាយស្រួល ពីទូរសព្ទដៃបានគ្រប់ពេលវេលាដោយពុំចាំបាច់ធ្វើដំណើរទៅធ្វើប្រតិបត្តិការនៅការិយាល័យសាខា។ ចាប់តាំងពីឆ្នាំ២០២២ អិលអូអិលស៊ីបានដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធធនាគារតាម Tablets សម្រាប់បុគ្គលិកនៅសហគមន៍ ដែលបង្កើនផលិតភាពការងារ និងកាត់បន្ថយការងារដោយដៃ រួមមានការ វាយតម្លៃប្រាក់កម្ចី ការប្រមូលប្រាក់កម្ចី និងការបើកគណនីបញ្ញើសំចៃ។ អិលអូអិលស៊ី នឹងបន្តកែលម្អសេវាហិរញ្ញវត្ថុ ឌីជីថលឱ្យកាន់តែល្អប្រសើរជាលំដាប់ និងទាន់សម័យកាល ដើម្បីផ្តល់នូវបទពិសោធន៍ដ៏ល្អប្រសើរជូនដល់អតិថិជន។

យើងកំពុងរៀបចំយុទ្ធសាស្ត្រក្នុងការប្រើប្រាស់ប្រព័ន្ធអេកូឌីជីថលដែលមានការវិវត្តយ៉ាងឆាប់រហ័សនៅក្នុងប្រទេសកម្ពុជា ដើម្បីផ្តល់លទ្ធភាពឱ្យសហគ្រិនខ្នាតមីក្រូអាចផ្លាស់ប្តូរពីការប្រើប្រាស់សេវាហិរញ្ញវត្ថុក្រៅផ្លូវការ មកប្រើប្រាស់ សេវាហិរញ្ញវត្ថុផ្លូវការ។ បច្ចុប្បន្ន អិលអូអិលស៊ី កំពុងផ្តល់សេវាដល់សហគ្រិនខ្នាតមីក្រូប្រមាណ ២៦០.០០០នាក់ (៦៦% នៃអតិថិជនសរុប) ដែលក្នុងនោះ ៧០% ជាស្ត្រីដែលភាគច្រើនមកពីតំបន់ជនបទនៃប្រទេសកម្ពុជា។ កម្ចីដល់សហគ្រិនខ្នាតមីក្រូរួមចំណែកត្រឹមតែ ២០% នៃផលប័ត្រឥណទានសរុប ដែលក្នុងនោះ ៨១% នៃគណនីកម្ចីមិនមាន ដាក់អចលនទ្រព្យជាទ្រព្យធានា។ ទំហំឥណទានជាមធ្យមសម្រាប់កម្ចីខ្នាតមីក្រូមានចំនួនត្រឹមតែ ៩៦៥ ដុល្លារអាមេរិក។ កម្ចីដល់សហគ្រិនខ្នាតតូច មធ្យម និងធំ ដែលរួមចំណែក ៨០% នៃផលប័ត្រឥណទានសរុបបានរួមចំណែកយ៉ាងធំក្នុងការគាំទ្រដល់វិស័យខ្នាតមីក្រូ ដែលបានជួយយើងក្នុងការបន្តផ្តល់នូវបរិយាបន្នសម្រាប់ម៉ូដែលអាជីវកម្មរបស់យើង។

នៅឆ្នាំបន្តបន្ទាប់ខាងមុខនេះ អិលអូអិលស៊ី (ខេមបូឌា) នឹងបន្តកែលម្អ និងពង្រីកសេវាហិរញ្ញវត្ថុឌីជីថលរបស់ខ្លួន ព្រមទាំងអភិវឌ្ឍផលិតផលដែលត្រូវបានរចនាឡើងដើម្បីបំពេញតាមតម្រូវការអាជីវកម្មរបស់អតិថិជន។ ទន្ទឹមគ្នានេះផងដែរ អិលអូអិលស៊ី នឹងបន្តពង្រីកសកម្មភាពសង្គម ការយល់ដឹងផ្នែកហិរញ្ញវត្ថុ និងសកម្មភាពដែលជួយគាំទ្រដល់បរិស្ថានសង្គម និងអភិបាលកិច្ចល្អ ដើម្បីឱ្យសមស្របទៅតាមតម្រូវការអាជីវកម្មដែលកំពុងតែរីកចម្រើន។

គណៈគ្រប់គ្រង និងបុគ្គលិក អិលអូអិលស៊ី បានបង្ហាញនូវភាពរឹងមាំ និងសមត្ថភាពក្នុងការសម្របខ្លួនទៅនឹងការផ្លាស់ប្តូរ នៃម៉ាក្រូសេដ្ឋកិច្ច និងផលលំបាកនានា ទន្ទឹមគ្នានឹងការធានាបាននូវអនុលោមភាពលើរាល់ច្បាប់ និងបទបញ្ញត្តិទាំងឡាយ។ អិលអូអិលស៊ី (ខេមបូឌា) អនុលោមតាមរាល់បទបញ្ញត្តិ និងអនុបាតដ៏រឹងមាំ ដែលចេញដោយធនាគារជាតិនៃកម្ពុជា។ យើងនឹងបន្តរក្សានូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ដើម្បីធានាបាននូវនិរន្តរភាពដ៏យូរអង្វែងរបស់ក្រុមហ៊ុន។

ជាចុងក្រោយ ខ្ញុំបាទសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់អ្នកដែលពាក់ព័ន្ធទាំងអស់រួមមាន អតិថិជន វិនិយោគិន និយ័តករ ធនាគារ និងដៃគូម្ចាស់កម្ចីទាំងក្នុង និងក្រៅប្រទេស សម្រាប់ការជឿជាក់ ការជឿទុកចិត្ត និងការគាំទ្រចំពោះ ការរីកចម្រើនរបស់ អិលអូអិលស៊ី ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ។

ខ្ញុំបាទក៏សូមកោតសរសើរចំពោះក្រុមប្រឹក្សាភិបាលទាំងអស់សម្រាប់ការណែនាំនិងការគាំទ្រក៏ដូចជា ចំពោះបុគ្គលិក អិលអូអិលស៊ី ទាំងអស់ដែលស្ថិតនៅក្រោមការដឹកនាំរបស់គណៈគ្រប់គ្រងដែលមានសមត្ថភាព និងការប្តេជ្ញាចិត្ត សម្រាប់ការខិតខំប្រឹងប្រែងក្នុងការបំពេញការងារបានយ៉ាងល្អ។

យើងសូមបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់យើងចំពោះអតិថិជន និងភាគទុនិកទាំងអស់របស់យើងថា នៅឆ្នាំ២០២៤ យើងនឹងបន្តផ្តោតសំខាន់លើវិស័យដែលផ្តល់នូវឱកាសដ៏ល្អបំផុតសម្រាប់អិលអូអិលស៊ី (ខេមបូឌា) និងគាំទ្រអាជីវកម្មដែលមាន ភាពធន់ដោយប្រកាន់ខ្ជាប់ជានិច្ចនូវទំនួលខុសត្រូវរបស់យើងក្នុងការការពារបរិស្ថាន និងសង្គម។




លោក Brindley de Zylva
ប្រធានក្រុមប្រឹក្សាភិបាល



**លោក សុខ រឿន**

ប្រធាននាយកប្រតិបត្តិ

# របាយការណ៍របស់ប្រធាននាយកប្រតិបត្តិ

## លោក សុខ រឿន

### ប្រធាននាយកប្រតិបត្តិ

វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុបន្តរក្សាបានភាពធន់ និងមានវឌ្ឍនភាពជាលំដាប់ ដែលធានាដល់ការរក្សាចីរភាព ហិរញ្ញប្បទាន និងសេវាហិរញ្ញវត្ថុចាំបាច់នានា និងបានដើរតួនាទីយ៉ាងសកម្មក្នុងការគាំទ្រដល់វិស័យសេដ្ឋកិច្ចចម្បងៗផងដែរ បើទោះបីល្បឿនកំណើនឥណទានបានថមថយក៏ដោយ។ គិតត្រឹមដំណាច់ឆ្នាំ២០២៣ ទំហំផលប័ត្រឥណទាននៃវិស័យមីក្រូហិរញ្ញវត្ថុមានចំនួន ៥,៤ ពាន់លានដុល្លារអាមេរិក ដែលមានគណនីឥណទានចំនួន ១,៦ លានគណនី។ ឥណទានរបស់វិស័យមីក្រូហិរញ្ញវត្ថុ ត្រូវបានផ្តល់ទៅកាន់វិស័យសំខាន់ៗក្នុងសេដ្ឋកិច្ចរួមមាន ក្រុមគ្រួសារមានចំណែក ៣០,៨% កសិកម្ម ២២,២% ពាណិជ្ជកម្មនិងជំនួញ ២០,៣% សេវាកម្ម ១១,៥% សំណង់ ៧,១% ដឹកជញ្ជូន ២,៩% កម្មន្តសាល ២,៩% និងផ្សេងៗ ២,៣%។ ទន្ទឹមនឹងនេះ វិស័យមីក្រូហិរញ្ញវត្ថុបានទទួលប្រាក់បញ្ញើពីអតិថិជនប្រមាណ ២,២ ពាន់លានដុល្លារអាមេរិក ស្មើនឹង ១,៩ លានគណនី។ ជារួមគ្រឹះស្ថានមីក្រូ ហិរញ្ញវត្ថុភាគច្រើនមានភាពរឹងមាំ និងអាចធន់នឹងហានិភ័យនានា ដោយគ្រឹះស្ថានបានបន្តអនុវត្តយ៉ាងខ្ជាប់ខ្ជួន អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិប្រុងប្រយ័ត្ន សេចក្តីណែនាំនិងវិធានការនានាដែលបានដាក់ចេញដោយធនាគារជាតិនៃកម្ពុជា នេះបើយោងតាមរបាយការណ៍ប្រចាំឆ្នាំ២០២៣ ដែលចេញដោយធនាគារជាតិនៃកម្ពុជា។

នៅក្នុងឆ្នាំ២០២៣ អិលអូអិលស៊ី ធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួនដោយការប្រុងប្រយ័ត្ន និងរក្សាបាននូវកំណើន ផលប័ត្រឥណទានប្រកបដោយគុណភាព និងការគ្រប់គ្រងផ្ទៃក្នុងដ៏រឹងមាំ។ ការងើបឡើងវិញនៃប្រាក់ចំណូលរបស់អតិថិជនដែលរងផលប៉ះពាល់ពី កូវីដ១៩ និងគ្រោះទឹកជំនន់នៅមិនទាន់វិលត្រឡប់មកធម្មតាទាំងស្រុង វិញនៅឡើយទេ។ ជាមួយនឹងការគាំទ្រផ្នែកបទបញ្ញត្តិពីធនាគារជាតិនៃកម្ពុជា អិលអូអិលស៊ី អាចបន្តផ្តល់ការអនុគ្រោះដល់អតិថិជនតាមរយៈការផ្តល់ពេលអនុគ្រោះដល់ពួកគាត់ ដើម្បីឱ្យពួកគាត់មានពេលវេលាក្នុងការចាប់ផ្តើមសកម្មភាពអាជីវកម្មឡើងវិញ ជាពិសេសក្នុងវិស័យទេសចរណ៍។

# សមិទ្ធផលសំខាន់ៗក្នុងឆ្នាំ២០២៣

### ផលប័ត្រឥណទាន

អិលអូអិលស៊ី ធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួនដោយការប្រុងប្រយ័ត្ន ដើម្បីធានាបាននូវគុណភាព និងនិរន្តរភាព។ គិតត្រឹមដំណាច់ឆ្នាំ ២០២៣ ផលប័ត្រឥណទានមានចំនួន ១.២៤៧ លានដុល្លារអាមេរិក ដែលមានអតិថិជនប្រមាណ ៣៣៥.០០០នាក់ ខណៈដែលហានិភ័យផលប័ត្រឥណទាន៣០ថ្ងៃ មានចំនួនត្រឹម ២,៧%។ ចំនួនអតិថិជនរួមមាន អតិថិជនក្រុម ៤៣% និងអតិថិជនឯកត្តជន ៥៧%។ ប្រាក់កម្ចី ៦៦% ត្រូវបានផ្តល់ទៅកាន់សហគ្រិនខ្នាតមីក្រូ (ដែលមានទំហំកម្ចី ≤ ៣.០០០ ដុល្លារអាមេរិក) ដែលក្នុងនោះ ៨១% មិនមានដាក់អចលនទ្រព្យជាទ្រព្យធានា។ ផលប័ត្រឥណទាននៃកម្ចីខ្នាតមីក្រូមានចំនួនត្រឹមតែ ២០% នៃទំហំផលប័ត្រឥណទានសរុប ដែលទំហំឥណទាន ជាមធ្យមមានចំនួន ៩៦៥ ដុល្លារអាមេរិក ខណៈដែល ៨០% នៃផលប័ត្រឥណទានត្រូវបានផ្តល់ទៅកាន់វិស័យឥណទានខ្នាតតូច មធ្យម និងខ្នាតធំ។

### គុណភាពផលប័ត្រឥណទាន

ជាមួយនឹងការសម្របខ្លួនទៅនឹងការផ្លាស់ប្តូរនៃម៉ាក្រូសេដ្ឋកិច្ច និងការលំបាកនានា អិលអូអិលស៊ី បានត្រៀមខ្លួនរួចជាស្រេចក្នុងការប្រឈមមុខនឹងស្ថានភាពអវិជ្ជមានទាំងនេះ និងអាចរក្សាបាននូវកំណើនផលប័ត្រឥណទានប្រកបដោយគុណភាព និងការត្រួតពិនិត្យផ្ទៃក្នុងដ៏រឹងមាំ។ ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង អិលអូអិលស៊ី បានសហការគ្នាយ៉ាងជិតស្និទ្ធិដើម្បីពង្រឹងលើការគ្រប់គ្រងហានិភ័យឥណទាន និងការត្រួតពិនិត្យផ្ទៃក្នុងដោយអនុវត្តវិធានការដូចខាងក្រោមៈ

- ការសិក្សា និងវាយតម្លៃឥណទានត្រូវបានធ្វើឡើងដោយផ្អែកជាមូលដ្ឋានលើការវិភាគលំហូរសាច់ប្រាក់។
- ការបែងចែកកម្រិតសិទ្ធិក្នុងការត្រួតពិនិត្យ និងការអនុម័តលើឥណទាន។
- ការត្រួតពិនិត្យជាញឹកញាប់លើគោលនយោបាយនីតិវិធី និងគោលការណ៍ណែនាំ ព្រមទាំងការអនុវត្តលើគោលនយោបាយនីតិវិធី និងគោលការណ៍ណែនាំទាំងនោះ។
- ការគាំទ្រពីប្រព័ន្ធក្នុងការរកឃើញ និងបង្ការការអនុវត្តដែលមិនត្រឹមត្រូវ ខុសពីគោលនយោបាយ និងនីតិវិធី។
- បន្តពង្រឹងការត្រួតពិនិត្យឥណទានបន្ទាប់ពីទម្លាក់ទុនរួចតាមរយៈវិធីសាស្រ្តផ្សេងៗគ្នា។
- ការបញ្ជ្រាបវប្បធម៌នៃការគ្រប់គ្រងហានិភ័យនៅទូទាំង អិលអូអិលស៊ី។
- បន្តពង្រឹងក្រុមការងារធានាគុណភាពឥណទាន ដើម្បីធានាបានប្រសិទ្ធភាពនៃការអនុវត្ត និងការត្រួតពិនិត្យផ្ទៃក្នុង។
- នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុង។
- កែលម្អរចនាសម្ព័ន្ធនៃការលើកទឹកចិត្តមន្រ្តីប្រឹក្សាលក់សេវាហិរញ្ញវត្ថុ និងបុគ្គលិកសហគមន៍ផ្សេងទៀត ដោយផ្អែកលើគុណភាពឥណទានជាចម្បង។
- ការត្រួតពិនិត្យការិយាល័យឥណទាននៃកម្ពុជាឱ្យបាន ១០០% ចំពោះអ្នកខ្ចី និងអ្នករួមខ្ចី មុនពេលទម្លាក់ទុន ដើម្បីវាយតម្លៃឥណទានរបស់អតិថិជនម្នាក់ៗឱ្យបានហ្មត់ចត់ (វាយតម្លៃដោយផ្អែកលើលំហូរសាច់ប្រាក់)។
- បន្តផ្តល់វគ្គបណ្តុះបណ្តាល និងកម្មវិធីរក្សាបុគ្គលិក ដើម្បីពង្រឹងសមត្ថភាព និងចំណេះជំនាញរបស់បុគ្គលិក និងធានាការអនុវត្តប្រកបដោយភាពត្រឹមត្រូវ។
- ការអនុវត្តគោលការណ៍ការពារអតិថិជន ដែលជាផ្នែកមួយដ៏សំខាន់ក្នុងការគ្រប់គ្រងហានិភ័យ។
- រក្សាឱ្យបាននូវអនុលោមភាពតាមគោលការណ៍ផ្តល់កម្ចីរបស់សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ទាក់ទងនឹងកម្ចីត្រួតគ្នា និងការផ្តល់ហិរញ្ញប្បទានឡើងវិញ។

### លទ្ធផលប្រាក់បញ្ញើ

សមតុល្យប្រាក់បញ្ញើកើនឡើងយ៉ាងឆាប់រហ័សដល់ជាង ៩០៤ លានដុល្លារអាមេរិក ត្រឹមដំណាច់ឆ្នាំ២០២៣ ដែលមានកំណើន ១៨% ធៀបនឹងដំណាច់ឆ្នាំ២០២២។ ចំនួនអតិថិជនប្រាក់បញ្ញើមានចំនួនជាង ៥១១.០០០នាក់។ កំណើនយ៉ាងឆាប់រហ័សនៃសមតុល្យប្រាក់បញ្ញើ និងចំនួនអតិថិជនប្រាក់បញ្ញើ បង្ហាញឱ្យឃើញថា អិលអូអិលស៊ី គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលគួរឱ្យទុកចិត្តខ្ពស់ ដែលផ្តល់នូវសេវាហិរញ្ញវត្ថុដ៏ល្អប្រសើរដល់អតិថិជន ការការពារអតិថិជន និងផ្តល់នូវផលិតផលប្រាក់បញ្ញើ និងផលិតផលឥណទានថ្មីៗ ដែលមានលក្ខណៈប្រកួតប្រជែង។

### សេវាធនាគារឌីជីថល

ដើម្បីគាំទ្រដល់ការអភិវឌ្ឍអាជីវកម្ម និងឆ្លើយតបទៅនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនៃតម្រូវការសេវាហិរញ្ញវត្ថុឌីជីថល អិលអូអិលស៊ី បន្តវិនិយោគលើគម្រោងធនាគារឌីជីថលយ៉ាងសម្បូរបែប ដើម្បីផ្តល់នូវបទពិសោធន៍ដ៏ល្អប្រសើរជូនដល់អតិថិជន។

- អិលអូអិលស៊ី បានធ្វើទំនើបកម្មលើកម្មវិធីធនាគារចល័តរបស់ខ្លួន iPay Cambodia Mobile App ជាមួយនឹងមុខងារកាន់តែងាយស្រួលជាងមុន ដែលអតិថិជនអាចធ្វើប្រតិបត្តិការធនាគារយ៉ាងសម្បូរបែប ដោយមិនគិតកម្រៃសេវា ដូចជា ទូទាត់ទំនិញនៅប្រទេសថៃតាមរយៈ Thai QR, ស្កេន និងទូទាត់ថ្លៃទំនិញទៅកាន់ម្ចាស់អាជីវកម្ម/អ្នកប្រើប្រាស់តាមរយៈ KHQR ផ្ទេរប្រាក់ឆ្លងធនាគារតាមរយៈប្រព័ន្ធ FAST RFT និងបាគង ផ្ទេរប្រាក់ក្នុងរង្វង់ អិលអូអិលស៊ី ទូទាត់វិក្កយប័ត្រ បញ្ចូលទឹកប្រាក់ក្នុងទូរស័ព្ទដៃ បើកគណនីបញ្ញើសំចៃឌីជីថល បើក/ផ្លាស់ប្តូរលក្ខខណ្ឌ/បិទគណនីបញ្ញើមានកាលកំណត់ ពិនិត្យសមតុល្យសាច់ប្រាក់ ទាញយករបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ និងទាញយកវិញ្ញាបនប័ត្របញ្ញើមានកាលកំណត់។
- អិលអូអិលស៊ី បានធ្វើទំនើបកម្មប័ណ្ណ CSS ATM Card របស់ខ្លួនជាមួយនឹងមុខងារស្តង់ដារ EMV Standard Chip ដើម្បីពង្រឹងសុវត្ថិភាពប័ណ្ណ ATM ឱ្យកាន់តែប្រសើរជាងមុនមួយកម្រិតទៀត។ ជាមួយនឹងប័ណ្ណ CSS ATM Card របស់ អិលអូអិលស៊ី អតិថិជនអាចធ្វើប្រតិបត្តិការធនាគារបានដោយខ្លួនឯងនៅតាមម៉ាស៊ីន ATM របស់គ្រឹះស្ថានជាសមាជិក CSS ដូចជា ប្រតិបត្តិការដកប្រាក់ ពិនិត្យសមតុល្យគណនី ប្តូរលេខកូដសម្ងាត់ ទាញយករបាយការណ៍ហិរញ្ញវត្ថុ និងផ្ទេរប្រាក់ក្នុងរង្វង់ អិលអូអិលស៊ី ឬផ្ទេរប្រាក់ឆ្លងធនាគារ នៅលើម៉ាស៊ីន ATM ជាង ៤.០០០ ម៉ាស៊ីននៅទូទាំងប្រទេស ដោយមិនគិតកម្រៃសេវា។
- អិលអូអិលស៊ី បានដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធធនាគារតាមរយៈឧបករណ៍ Tablet Devices ទៅគ្រប់សាខាទាំង អស់ក្នុងឆ្នាំ២០២៣។ តាមរយៈប្រព័ន្ធធនាគារតាមឧបករណ៍ Tablet Devices បុគ្គលិករបស់យើងអាចធ្វើប្រតិបត្តិការការងារ (ដូចជាការវាយតម្លៃឥណទាន ការប្រមូលប្រាក់កម្ចី និងការបើកគណនីបញ្ញើសំចៃ) យ៉ាងងាយស្រួលពីឧបករណ៍ Tablet Devices ដែលបានកាត់បន្ថយការងារដោយដៃ បង្កើនផលិតភាព និងប្រសិទ្ធភាពការងារឱ្យកាន់តែល្អប្រសើរ។
- បន្ថែមលើនេះផងដែរ អិលអូអិលស៊ី ក៏បាននឹងកំពុងធ្វើសមាហរណកម្មជាមួយភាគីទីបី ដើម្បីផ្តល់នូវបណ្តាញចែកចាយកាន់តែច្រើន និងបទពិសោធន៍ដ៏ល្អប្រសើរដល់អតិថិជនរបស់យើង។

### អាជីវកម្មប៉េងកាស្សូរេន

អិលអូអិលស៊ី បានចាប់ដៃគូជាមួយក្រុមហ៊ុន ស៊ិរិនឌីប ម៉ាយក្រូអ៊ិនស្សូរេន ភីអិលស៊ី ជាដៃគូអាជីវកម្មប៉េងកាស្សូរេន ម៉ូដែលភ្ជាក់ងារ។ ការចាប់ដៃគូនេះធ្វើឡើងក្នុងគោលបំណងពង្រឹងបរិយាបន្នហិរញ្ញវត្ថុតាមរយៈការបង្កើនលទ្ធភាពទទួលបានសេវាធានារ៉ាប់រងដល់អតិថិជន និងបណ្តាញប្រតិបត្តិការ និងពង្រឹងលើការការពារអតិថិជន ដោយផ្តល់ឱ្យអតិថិជននូវការធានារ៉ាប់រងអាយុជីវិត ដើម្បីសម្រាលបន្ទុករបស់ពួកគេនៅក្នុងគ្រួសារ ក្នុងករណីដែលអ្នកខ្ចី និង/ឬ អ្នករួមខ្ចីជួបឧបទ្ទវហេតុ និង/ឬបញ្ហាសុខភាព ដែលនាំទៅដល់ការបាត់បង់ជីវិត ឬពិការភាពអចិន្ត្រៃយ៍។

### ការគ្រប់គ្រងនិរន្តរភាពសង្គម និងបរិស្ថាន

អិលអូអិលស៊ី បន្តផ្តល់សេវាហិរញ្ញវត្ថុដែលមានភាពសម្បូរបែបមានការទទួលខុសត្រូវសង្គម និងបរិស្ថាន ដល់ប្រជាជនកម្ពុជានៅជនបទ។ គិតត្រឹមខែធ្នូ ឆ្នាំ២០២៣ អតិថិជនឥណទានប្រមាណ ៧៩% រស់នៅតំបន់ជនបទ, ជាង ៧០% ជាអតិថិជនស្រ្តី, ៤៩% នៃអតិថិជនមានមុខរបរក្នុងវិស័យកសិកម្ម ដែលមិនមានហានិភ័យប៉ះពាល់ទៅលើបរិស្ថានគួរឱ្យកត់សម្គាល់ឡើយ, អតិថិជនប្រមាណ ១.៩០០នាក់ មានថាមពលស្អាតសម្រាប់ប្រើប្រាស់, អតិថិជនប្រមាណ ៩.៣០០នាក់កំពុងប្រើប្រាស់ឥណទានកែលម្អគេហដ្ឋាន អតិថិជន ៤.៩០០នាក់ កំពុងប្រើប្រាស់ឥណទានសម្រាប់ ទឹកស្អាត និងអនាម័យ ដើម្បីលើកកម្ពស់អនាម័យ និងការប្រើប្រាស់ទឹកស្អាត អតិថិជន ៥១១.០០០នាក់ ទទួលបាន សេវាប្រាក់បញ្ញើសំចៃ ហើយអតិថិជនប្រមាណ ៧៤% រស់នៅក្រោមបន្ទាត់ភាពក្រីក្រ ១៥០% (ដោយប្រើប្រាស់ សន្ទស្សន៍នៃការចាកផុតពីភាពក្រីក្រ PPI ដើម្បីវាស់វែងកម្រិតនៃភាពក្រីក្រ)។

ស្របតាមយុទ្ធសាស្រ្តរបស់ក្រុមហ៊ុនស្តង់ដារនៃការគ្រប់គ្រងបរិស្ថានសកម្មភាពសង្គម និងអភិបាលកិច្ចល្អរួមមាន គោលការណ៍ការពារអតិថិជន (CPP) ស្តង់ដារជាសាកលនៃការគ្រប់គ្រងសកម្មភាពសង្គម (USSPM) ការអនុវត្តល្អបំផុតនៃការគ្រប់គ្រងបរិស្ថានសកម្មភាពសង្គម និងអភិបាលកិច្ចល្អជាដើម ត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយនីតិវិធីការបណ្តុះបណ្តាល វិធីសាស្រ្តក្នុងការផ្តល់ផលិតផលនិងសេវាកម្មជូនអតិថិជន និងឧបករណ៍ត្រួតពិនិត្យរបស់គ្រឹះស្ថាន។ ទាំងនេះដោយសារតែគណៈគ្រប់គ្រងនិងក្រុមប្រឹក្សាភិបាលយល់ច្បាស់អំពី ទស្សនវិស័យដែលថា "ក្រុមហ៊ុនទទួលបានជោគជ័យ លុះត្រាតែអតិថិជនជោគជ័យ" ។ ជាលទ្ធផល អិលអូអិលស៊ី ទទួលបានវិញ្ញាបនបត្រគោលការណ៍ការពារអតិថិជនកម្រិតមាស ពីគ្រឹះស្ថានវាយតម្លៃអន្តរជាតិ Cerise និង SPTF។ នេះបង្ហាញឱ្យឃើញថា អិលអូអិលស៊ី តែងតែការពារ និងគាំទ្រអតិថិជន ដើម្បីពង្រីកអាជីវកម្មឱ្យមានការរីកចម្រើន តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។ បន្ថែមលើនេះ អិលអូអិលស៊ី ទទួលបានវិញ្ញាបនបត្រវាយតម្លៃសកម្មភាពសង្គម កម្រិត sBB+ ដែលបង្ហាញឱ្យឃើញថា អិលអូអិលស៊ី អនុវត្តបានគ្រប់គ្រាន់លើការគ្រប់គ្រងសកម្មភាពសង្គម ប្រព័ន្ធការពារ

អតិថិជន និងអនុលោមតាមបេសកកម្មសង្គម ហើយស្របពេលជាមួយគ្នានេះ អិលអូអិលស៊ី ក៏ទទួលបានវិញ្ញាបនបត្រវាយតម្លៃការអនុវត្តរបស់គ្រឹះស្ថានទាំងមូល កម្រិត æ Medium ដែលនេះបង្ហាញឱ្យឃើញថា អិលអូអិលស៊ី មានទស្សនវិស័យរឹងមាំសម្រាប់និរន្តរភាពហិរញ្ញវត្ថុ មានមូលដ្ឋានរឹងមាំ និងមានស្ថេរភាព។

ដើម្បីគាំទ្រដល់គោលដៅអភិវឌ្ឍប្រកបដោយនិរន្តរភាព ក៏ដូចជាផ្តល់ជាដំណោះស្រាយក្នុងការការពារបរិស្ថាន និងសង្គម អិលអូអិលស៊ី បានខិតខំប្រឹងប្រែងដោយបញ្ចូលទៅក្នុងដំណើរការនៃការវាយតម្លៃកម្ចីនូវចំណុចសំខាន់ៗ ដើម្បីដោះស្រាយការព្រួយបារម្ភទៅលើបរិស្ថាន សង្គម និងអភិបាលកិច្ច ហើយដំណើរការនៃការវាយតម្លៃកម្ចីត្រូវបានបញ្ចូលការវិភាគផលប៉ះពាល់ទៅលើបរិស្ថានសង្គម និងអភិបាលកិច្ចនៅក្នុងការសម្រេចចិត្តអនុម័តឥណទាន។ អិលអូអិលស៊ី មានបញ្ជីអាជីវកម្ម ដែលត្រូវបានហាមឃាត់មិនអនុញ្ញាតឱ្យផ្តល់ហិរញ្ញប្បទានដល់សកម្មភាពដែលមាន ផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងសហគមន៍។ អិលអូអិលស៊ី មានវិធានការដ៏រឹងមាំដើម្បីការពារការផ្តល់ប្រាក់កម្ចី ដល់សកម្មភាពដែលត្រូវបានហាមឃាត់។ គ្រប់កម្ចីទាំងអស់ត្រូវបានវាយតម្លៃដោយបុគ្គលិកសហគមន៍ ត្រួតពិនិត្យ និងអនុម័តដោយប្រធានគ្រប់គ្រង/នាយកសាខា/គណៈកម្មការឥណទាន ដើម្បីធានាថាប្រាក់កម្ចីមិនត្រូវបានផ្តល់ឱ្យ ដល់សកម្មភាពអាជីវកម្មហាមឃាត់ និងមិនមានផលប៉ះពាល់ដល់បរិស្ថាន និងសង្គម។ ការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន និងសង្គមត្រូវបានអនុវត្តចំពោះគ្រប់ទំហំកម្ចីទាំងអស់។ ចំពោះកម្ចីដែលមានទំហំតិចជាង ៣០.០០០ ដុល្លារអាមេរិក ការយល់ដឹងពីផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គមត្រូវបានលើកយកមកពិភាក្សាជាមួយអតិថិជនអំពីបញ្ហាហានិភ័យ និងផ្តល់ជាអនុសាសន៍សម្រាប់កែលម្អឱ្យប្រសើរឡើង។ ចំពោះកម្ចីសហគ្រាសខ្នាតតូច និងមធ្យម ដែលមានទំហំធំជាង ឬស្មើនឹង ៣០.០០០ ដុល្លារអាមេរិក ឧបករណ៍វិភាគដ៏ស៊ីជម្រៅត្រូវបានបញ្ចូលពេញលេញទៅ ក្នុងដំណើរការវាយតម្លៃឥណទាន។ ការវាយតម្លៃដ៏លម្អិតត្រូវបានធ្វើឡើងដើម្បីវិភាគទៅលើផលប៉ះពាល់ថាតើមានកម្រិតទាប មធ្យម ឬ ខ្ពស់ និងផ្តល់អនុសាសន៍ទៅអតិថិជនសម្រាប់ការយល់ដឹង និងធ្វើការកែលម្អ។ ការតាមដានទៅលើវឌ្ឍនភាពនៃការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន និងសង្គមត្រូវបានបន្តត្រួតពិនិត្យជាប្រចាំ។ យ៉ាងហោចណាស់ ចំនួនពីរដង (អំឡុងពេលវាយតម្លៃកម្ចី និងមុនពេលទម្លាក់ទុន) អតិថិជនត្រូវបានជូនដំណឹងអំពីលក្ខណៈនៃផលិតផល ការយកកម្រៃសេវា ចន្លោះពេលរង់ចាំទុន និងលក្ខខណ្ឌផ្សេងៗ ដោយប្រើប្រាស់សម្ភារជារូបភាព (visual aids A4-Metacard)។ បន្ថែមលើនេះ វីដេអូណែនាំស្តីពីការប្រើប្រាស់ visual aids A4-Metacard ត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័ររបស់ អិលអូអិលស៊ី។

នៅក្នុងឆ្នាំ២០២៣ អិលអូអិលស៊ី បានផ្តល់ការបណ្តុះបណ្តាលចំណេះដឹងផ្នែកហិរញ្ញវត្ថុដល់អ្នកចូលរួមជាង ៦៣.០០០នាក់ (៧៤% ឬស្មើនឹង ៤៦.៩២៥ នាក់ជាស្ត្រី) ដែលអ្នកចូលរួមទាំងនោះរួមមានអតិថិជន អ្នកភូមិ និស្សិតសាកលវិទ្យាល័យ និងក្មេងៗ។

- **ការផ្សព្វផ្សាយអំពីចំណេះដឹងផ្នែកហិរញ្ញវត្ថុ៖**
  បដាចំនួន ៧៥ផ្ទាំង ដែលមានសារអប់រំសំខាន់ៗអំពីចំណេះដឹងផ្នែកហិរញ្ញវត្ថុត្រូវបានរចនា ផលិត និងដាក់ដំឡើងនៅកន្លែងដែលបានជ្រើសរើស។

- **កម្មវិធីវិទ្យុ "គំនិតរីកចម្រើន"៖**
  កម្មវិធីនេះបង្កើតឡើងក្នុងគោលបំណងផ្សព្វផ្សាយសារអប់រំអំពីចំណេះដឹង ផ្នែកហិរញ្ញវត្ថុ និងអប់រំប្រជាពលរដ្ឋនៅតំបន់ជនបទអំពីការការពារអតិថិជន និងការលើកទឹកចិត្តខ្លួនឯង។

- **វីដេអូអប់រំចំណេះដឹងផ្នែកហិរញ្ញវត្ថុ៖**
  ត្រូវបានផលិតឡើងដើម្បីផ្តល់សារអប់រំអំពីការគ្រប់គ្រងចាត់ចែងហិរញ្ញវត្ថុទៅដល់សាធារណជន/អតិថិជន។ គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២៣ វីដេអូអប់រំចំនួន២៨ ត្រូវបានផលិតឡើង ហើយក្នុងនោះវីដេអូចំនួន២៦ ត្រូវបានបង្ហោះនៅលើបណ្តាញផ្សព្វផ្សាយល្បីៗ និងនៅលើ Facebook Page របស់អិលអូអិលស៊ី។ ជាលទ្ធផល វីដេអូទាំង២៦ នេះមានអ្នកចូលទស្សនាសរុបជាង ១៦លានដង។

បន្ថែមលើនេះផងដែរ អិលអូអិលស៊ី ក៏បានបែងចែកថវិកាមួយចំនួនដើម្បីចូលរួមក្នុងសកម្មភាពសង្គមផ្សេងៗទៀតដូចជា៖

- ដាក់បង់ថ្មអង្គុយលេងនៅទីសាធារណៈ ដាំដើមឈើ សកម្មភាពនៅតាមសាលារៀន និងបរិច្ចាគធុងសម្រាម ក៏ដូចជាអំពូលភ្លើងសូឡាដល់សហគមន៍ សាលារៀន វត្តអារាម និងទីសាធារណៈ។
- បរិច្ចាគគ្រឿងឧបភោគបរិភោគដល់អតិថិជន និងជនរងគ្រោះដោយសារគ្រោះទឹកជំនន់។
- បរិច្ចាគកង់ និងសម្ភារៈសិក្សាដល់សិស្សានុសិស្ស ដើម្បីលើកកម្ពស់វិស័យអប់រំនៅក្នុងប្រទេសកម្ពុជា និង លើកទឹកចិត្តសិស្សានុសិស្សឱ្យខិតខំរៀនបន្ថែមទៀត។
- ផ្តល់ការអប់រំដល់អ្នកទទួលអត្ថប្រយោជន៍ពីគម្រោងភូមិមួយផលិតផលមួយស្តីពី "វិធីទទួលបានសេវា ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ" នៅក្នុងខេត្តមួយចំនួន។
- ចូលរួមក្នុងកិច្ចការសង្គមតាមរយៈការផ្តល់នូវខិត្តប័ណ្ណផ្សព្វផ្សាយអំពីយុទ្ធនាការប្រឆាំងគ្រឿងញៀន និងសម្ភារផ្សព្វផ្សាយផ្សេងៗទៀតដល់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (NACD) ដើម្បីផ្សព្វផ្សាយចំណេះដឹងទាក់ទងនឹងគ្រឿងញៀនដល់សាធារណជន។
- ចុះកិច្ចព្រមព្រៀងជាមួយ Ecobatt-Energry Cambodia ដើម្បីសហការក្នុងការប្រមូលសំណល់អគ្គិសនី និងឧបករណ៍អេឡិចត្រូនិចដែលជះផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងសុខភាពមនុស្ស។

## យុទ្ធសាស្ត្រអាទិភាពសម្រាប់ឆ្នាំ២០២៤

យើងមើលឃើញឆ្នាំ២០២៤ ពោរពេញទៅដោយឱកាសថ្មីៗ និងការប្រកួតប្រជែងសម្រាប់ អិលអូអិលស៊ី។

**ខាងផ្នែកឥណទាន** យើងនឹងបន្តអនុវត្តតាមយុទ្ធសាស្ត្រដែលមានស្រាប់ និងបន្តផ្តោតការយកចិត្តទុកដាក់លើឥណទាន ខ្នាតតូចមធ្យម និងឥណទានប្រើប្រាស់ផ្ទាល់ខ្លួនដែលទទួលយកទ្រព្យដែលទិញជាទ្រព្យដាក់ធានា/ភតិសន្យាហិរញ្ញវត្ថុ ដែលជាអាជីវកម្មចម្បងរបស់ អិលអូអិលស៊ី។

**ខាងផ្នែកប្រាក់បញ្ញើ** យើងនឹងបន្តពង្រឹងសេវាអតិថិជន និងប្រើប្រាស់បណ្តាញឌីជីថលដ៏សម្បូរបែប ដើម្បីលើកកម្ពស់ការប្រមូលប្រាក់បញ្ញើសំចៃបន្ថែមទៀត។ បន្ថែមលើនេះ យើងនឹងបន្តផ្តល់នូវផលិតផល និងសេវាកម្មថ្មីៗ ដើម្បីបំពេញទៅតាម តម្រូវការរបស់អតិថិជន រួមមានគណនីសន្សំសម្រាប់ប្រើប្រាស់ក្នុងគម្រោងពេលអនាគត គណនីសន្សំសម្រាប់បុត្រធីតា សេវាទូទាត់វិក្កយបត្រ និងសេវាបើកប្រាក់បៀវត្ស។

**ខាងផ្នែកឌីជីថល** អិលអូអិលស៊ី នឹងបន្តអភិវឌ្ឍបរិយាបន្នហិរញ្ញវត្ថុឌីជីថល ដើម្បីបំពេញតាមតម្រូវការរបស់អតិថិជន ជាមួយនឹងបទពិសោធន៍ធនាគារនៅគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា។

**ខាងផ្នែកមូលនិធិ** អិលអូអិលស៊ី នឹងស្វែងរកទុនពីប្រភពផ្សេងៗគ្នាដើម្បីធានាភាពគ្រប់គ្រាន់នៃមូលនិធិសម្រាប់គាំទ្រកំណើន របស់អិលអូអិលស៊ី។ បន្ថែមលើប្រភពទុនពីម្ចាស់ភាគទុនិក កម្ចីពីម្ចាស់កម្ចី និងប្រាក់បញ្ញើរបស់អតិថិជន អិលអូអិលស៊ី បានបោះផ្សាយលក់មូលបត្របំណុលលើកទីមួយ ដើម្បីគាំទ្រនិរន្តរភាពនៃការរីកលូតលាស់របស់ អិលអូអិលស៊ី ហើយកំពុងស្ថិតក្នុងដំណាក់កាលបោះផ្សាយលក់មូលបត្របំណុលលើកទីពីរ ដល់វិនិយោគិនសក្តានុពល។

**ខាងផ្នែកគ្រប់គ្រងបរិស្ថាន សកម្មភាពសង្គម និងអភិបាលកិច្ច** អិលអូអិលស៊ី នឹងបន្តយកចិត្តទុកដាក់លើការអនុវត្តដែលល្អបំផុតក្នុងការគ្រប់គ្រងបរិស្ថាន សកម្មភាពសង្គម និងអភិបាលកិច្ច ដើម្បីសម្រេចឱ្យបានតាមការប្តេជ្ញាចិត្តរបស់ អិលអូអិលស៊ី ក្នុងការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងសម្រេចឱ្យបានតាមគុណតម្លៃរបស់អិលអូអិលស៊ី ដែលចែងថា "អិលអូអិលស៊ី ឱ្យតម្លៃទៅលើទស្សនវិស័យក្នុងការធ្វើឱ្យមានតុល្យភាព រវាងកិច្ចការសង្គម និងផលចំណេញ"។

សរុបជារួមមក យើងនឹងខិតខំប្រឹងប្រែងឱ្យអស់ពីលទ្ធភាពក្នុងការចាប់យកឱកាសជោគជ័យ ហើយយើងជឿជាក់ថា អិលអូអិលស៊ី នឹងអាចនាំមកនូវតម្លៃបន្ថែមទៀតដល់អតិថិជនវិនិយោគិន និងម្ចាស់ភាគទុនិក។

ជាចុងក្រោយ ខ្ញុំបាទសូមថ្លែងអំណរគុណដល់ភាគទុនិកក្រុមប្រឹក្សាភិបាល និងសមាជិកគណៈកម្មាធិការទាំងអស់សម្រាប់ ការដឹកនាំការគាំទ្រ និងការផ្តល់ដំបូន្មានល្អៗក្នុងរយៈពេលមួយឆ្នាំ កន្លងទៅនេះ។ ខ្ញុំបាទក៏សូមបង្ហាញនូវការដឹងគុណយ៉ាងស្មោះស្ម័គ្រចំពោះបុគ្គលិកអិលអូអិលស៊ី ទាំងអស់សម្រាប់ការខិតខំប្រឹងប្រែងបំពេញការងារកម្លាំងកាយចិត្ត និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការបំពេញការងារប្រកបដោយសុចរិតភាព ក្រមសីលធម៌ វិជ្ជាជីវៈ និងការទទួលខុសត្រូវខ្ពស់។ ខ្ញុំបាទក៏សូម ថ្លែងអំណរគុណចំពោះអតិថិជន វិនិយោគិន និងដៃគូពាក់ព័ន្ធដែលតែងតែគាំទ្រ អិលអូអិលស៊ី ដើម្បីភាពរីកចម្រើនទាំងអស់គ្នា។ បន្ថែមលើនេះ ខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាល និងធនាគារជាតិនៃកម្ពុជាសម្រាប់ការគាំទ្រនៅក្នុងឆ្នាំ២០២៣ និងជោគជ័យដែលរំពឹងទុកនៅឆ្នាំបន្តបន្ទាប់ទៀត។




លោក សុខ រឿន
ប្រធាននាយកប្រតិបត្តិ

# ០១.

# អំពី អិលអូអិលស៊ី (ខេមបូឌា)


**ទិដ្ឋភាពទូទៅអំពីប្រទេសកម្ពុជា (២០)**

- ស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រ
- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច
- ស្ថានភាពវិស័យមីក្រូហិរញ្ញវត្ថុ

**ទិដ្ឋភាពទូទៅអំពី អិលអូអិលស៊ី (ខេមបូឌា) (២២)**

- ផែនទីនៃតំបន់ប្រតិបត្តិការ
- ចក្ខុវិស័យ បេសកកម្ម គុណតម្លៃ
- ទិដ្ឋភាពសង្ខេបអំពី អិលអូអិលស៊ី (ខេមបូឌា)
- ប្រវត្តិសង្ខេប
- រចនាសម្ព័ន្ធភាគទុនិក

**វិញ្ញាបនបត្រ និងពានរង្វាន់ (២៩)**

**ដៃគូហិរញ្ញប្បទាន និងអាជីវកម្ម (៣២)**




# យុទ្ធសាស្ត្រអាទិភាពសម្រាប់ឆ្នាំ២០២៤



## ក. ស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រ

ខេត្តទាំង២៥ របស់ព្រះរាជាណាចក្រកម្ពុជា (ដែលមានទីក្រុងភ្នំពេញជារាជធានី) ត្រូវបានតភ្ជាប់ដោយផ្លូវជាតិ និងផ្លូវហាយវេ ដែលក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលបានវិនិយោគលើការកែលម្អផ្លូវល្បឿនលឿន ដោយមានជំនួយពីបរទេស និងកម្ចីពីដៃគូអភិវឌ្ឍរបស់ខ្លួន។ ប្រទេសកម្ពុជាទទួលបានអត្ថប្រយោជន៍តាំងពីទីយុទ្ធសាស្ត្រ ដែលស្ថិតនៅចំកណ្តាលនៃអាស៊ីអាគ្នេយ៍ដីគោក ហើយភ្ជាប់ការទំនាក់ទំនងល្អជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ី ប៉ាស៊ីហ្វិក និងទៅបណ្តាប្រទេសនានា តាមរយៈជើងហោះហើរអន្តរជាតិ ជាច្រើនខ្សែ។

ប្រទេសកម្ពុជាមានប្រជាជនជិត ១៧ លាននាក់ (១៦,៨៣ លាននាក់ គិតត្រឹមខែមករា ឆ្នាំ២០២១ ជាមួយនឹងអត្រា កំណើន ១,៥%)។ ប្រជាជនមានអាយុជាមធ្យម ២៦,៦ឆ្នាំ ហើយ ៨២% នៃប្រជាជនដែលមានអាយុចន្លោះពី ១៥ - ៥៩ ឆ្នាំ ជាប្រជាជនសកម្មពេញកម្លាំងពលកម្ម ជាមួយនឹងអត្រាអត់ការងារធ្វើត្រឹមតែ ១,២%។ ប្រជាជនសកម្មពេញកម្លាំងពលកម្មមានចំណេះជំនាញកាន់តែល្អប្រសើរជាងមុន ដោយសារតែអត្រាអ្នកចេះអក្សរនៅទូទាំងប្រទេស និងអត្រាបញ្ចប់ការសិក្សាមានការកើនឡើងខ្ពស់។ យ៉ាងណាមិញ និយោជកតែងតែជួបការលំបាកក្នុងការស្វែងរកកម្លាំង ពលកម្មជំនាញក្នុងស្រុក ដែលគួរតែរៀបចំកម្មវិធីបណ្តុះបណ្តាលយ៉ាងទូលំទូលាយសម្រាប់បុគ្គលិកក្នុងស្រុក។ ៧០% នៃប្រជាជនកម្ពុជាមានអាយុក្រោម ៣៥ឆ្នាំ។ មានភាពខុសប្លែកគ្នាយ៉ាងខ្លាំងរវាងមនុស្សជំនាន់ក្រោយ និងមនុស្សចាស់ ទាក់ទងនឹងកម្រិតនៃការអប់រំ និងអាកប្បកិរិយានៃការប្រើប្រាស់ផលិតផល។ យុវជនកម្ពុជាមានការយល់ដឹងពីការប្រើប្រាស់ផលិតផល និងអំណាចទិញកាន់តែច្រើនជាងពេលមុនៗ ហើយចំណង់របស់ពួកគេសម្រាប់ការទិញទំនិញ និងសេវាកម្មប្រកបដោយគុណភាព កំពុងត្រូវបានបំពេញនៅក្នុងតំបន់ទីក្រុង ជាមួយនឹងផ្សារទំនើប មជ្ឈមណ្ឌលពាណិជ្ជកម្ម និងយីហោអន្តរជាតិជាច្រើនដែលបើកដំណើរការជារៀងរាល់សប្តាហ៍។ ក្នុងរយៈពេលប៉ុន្មានទសវត្សចុងក្រោយនេះ ការធ្វើចំណាកស្រុកពីជនបទទៅទីក្រុងមានការកើនឡើងដល់ ៤០% នៃប្រជាជនបច្ចុប្បន្នកំពុងរស់នៅតំបន់ទីក្រុង។ ប្រជាជនភាគច្រើននៅជនបទមានមុខរបរពាក់ព័ន្ធនឹងវិស័យកសិកម្ម ហើយអត្រាមានកម្មសិទ្ធិ ផ្ទះសំបែងផ្ទាល់ខ្លួនមានអត្រាដល់ទៅ៩១% ធៀបនឹងប្រជាជននៅទីក្រុងដែលអត្រាមានកម្មសិទ្ធិផ្ទះផ្ទាល់ខ្លួនត្រឹម ៨២%។

*ប្រភព៖ Business Chambers/Associations reported as of 2022.*

## ខ. ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច

ការថមថយកំណើនសេដ្ឋកិច្ចពិភពលោក និងតំបន់ បានដាក់សម្ពាធដល់សេដ្ឋកិច្ចកម្ពុជា ជាពិសេសការនាំចេញ ផលិតផលកាត់ដេរ និងកំណើនវិស័យសំណង់ និងអចលនទ្រព្យ។ ប៉ុន្តែការងើបឡើងនៃវិស័យទេសចរណ៍ កំណើនការនាំចេញផលិតផលមិនមែនកាត់ដេរ និងកំណើនតម្រូវការក្នុងស្រុក បានរួមចំណែកគាំទ្រសេដ្ឋកិច្ចកម្ពុជាឱ្យកើនឡើងក្នុងអត្រា ៥,៥% ខ្ពស់ជាងឆ្នាំ២០២២ បន្តិច (៥,៣%)។ ស្ថិរភាពថ្លៃបានរួមចំណែកយ៉ាងសំខាន់ក្នុងការរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ នាឆ្នាំ២០២៣ អតិផរណាបានថមថយមកក្នុងកម្រិតទាបវិញ ដោយសារការថយចុះនៃថ្លៃប្រេងឥន្ធនៈ និងម្ហូបអាហារ ជាមួយនឹងការរក្សាបានស្ថិរភាពអត្រាប្តូរប្រាក់ និងការគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុក្នុងកម្រិតមួយសមស្រប។

*ប្រភព៖ របាយការណ៍ប្រចាំឆ្នាំ២០២៣ របស់ធនាគារជាតិនៃកម្ពុជា*

## គ. ស្ថានភាពវិស័យមីក្រូហិរញ្ញវត្ថុ

ទ្រព្យសកម្មសរុបរបស់វិស័យមីក្រូហិរញ្ញវត្ថុមានចំនួនប្រមាណ ៦,៤ ពាន់លានដុល្លារអាមេរិក ដែលក្នុងនោះផលប័ត្រឥណទានសរុបមានចំនួនប្រមាណ ៥,៤ ពាន់លានដុល្លារអាមេរិក ស្មើនឹង ១,៦ លានគណនីដែលមានការថយចុះបើប្រៀបធៀបទៅនឹងដំណាច់ឆ្នាំ២០២២ ដោយសារតែគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមួយបានក្លាយខ្លួនទៅ ជាធនាគារពាណិជ្ជនៅក្នុងឆ្នាំ២០២៣។ ចំនួនអ្នកដាក់ប្រាក់បញ្ញើកើនឡើងដល់ជាង ២លាននាក់ជាមួយនឹងសមតុល្យ ប្រាក់បញ្ញើជាង ២,២ ពាន់លានដុល្លារអាមេរិក។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជាផ្តល់សេវាហិរញ្ញវត្ថុជូនអតិថិជននៅទូទាំងប្រទេស និងមានផលិតផលសម្បូរបែបជាច្រើនដូចជាផលិតផលកម្ចីដែលមិនមានទ្រព្យដាក់ធានា ភតិសន្យាហិរញ្ញវត្ថុ ផលិតផលកម្ចីសម្ភារប្រើប្រាស់ផ្ទាល់ខ្លួនដែលទទួលយកសម្ភារដែលទិញជាទ្រព្យដាក់ធានា ផលិតផលកម្ចីសហគ្រាសខ្នាតតូចនិងមធ្យម និងផលិតផលកម្ចីសម្រាប់កសិកម្មជាដើម។ លើសពីនេះទៅទៀត ការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុឌីជីថលក៏មានប្រជាប្រិយភាពផងដែរនៅក្នុងវិស័យនេះដូចជាសេវាធនាគារចល័ត សេវាទូទាត់វិក្កយប័ត្រ និងសេវាប្រាក់កម្ចីតាមបែបឌីជីថល។

បច្ចុប្បន្ន មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណជាង ៨០ គ្រឹះស្ថាន ខណៈដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទទួលប្រាក់បញ្ញើធំៗទាំង៤ ចាប់យកចំណែកទីផ្សារជាង ៧០% នៃទំហំទីផ្សារសរុបបើគិតលើទំហំផលប័ត្រឥណទាន។

ស្ថានភាពទីផ្សារមីក្រូហិរញ្ញវត្ថុនៅកម្ពុជាមានលក្ខណៈចាស់ទុំ ដែលអ្នកវិនិយោគថ្មីៗត្រូវតែមានដើមទុនយ៉ាងរឹងមាំ ដើម្បីចូលរួមប្រកួតប្រជែងក្នុងទីផ្សារនេះបាន។

ជារួម គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុភាគច្រើនមានភាពរឹងមាំ និងអាចធន់នឹងហានិភ័យនានា ដោយគ្រឹះស្ថានបានបន្តអនុវត្ត យ៉ាងខ្ជាប់ខ្ជួនអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិប្រុងប្រយ័ត្នសេចក្តីណែនាំ និងវិធានការនានាដែលបានដាក់ចេញដោយធនាគារជាតិនៃកម្ពុជា។

*ទិន្នន័យយោងទៅលើរបាយការណ៍របស់សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងរបាយការណ៍ប្រចាំឆ្នាំ២០២៣ របស់ធនាគារជាតិនៃកម្ពុជា។

# ទិដ្ឋភាពទូទៅអំពី អិលអូអិលស៊ី (ខេមបូឌា)

## ផែនទីនៃតំបន់ប្រតិបត្តិការ




**សង្ខេប**

ស្កេនទីនេះ ដើម្បីចូលមើលព័ត៌មានទំនាក់ទំនងសាខា

**៨៣**
ចំនួនសាខា

**២៥/២៥**
ចំនួនខេត្តប្រតិបត្តិការ

សំគាល់៖ ផែនទីខាងលើ ប្រើប្រាស់សម្រាប់គំរូតាងបង្ហាញពីបណ្ដាញប្រតិបត្តិការរបស់ អិលអូអិលស៊ី (ខេមបូឌា) តែប៉ុណ្ណោះ។

# ទស្សនវិស័យ

ជាស្ថាប័នដែលផ្តល់នូវសេវាហិរញ្ញវត្ថុប្រកបដោយបរិយាបន្ន ដ៏មានទំនុកចិត្តខ្ពស់បំផុតនៅក្នុងប្រទេសកម្ពុជា។

# បេសកកម្ម

បង្កើតនូវលទ្ធផលវិជ្ជមានយូរអង្វែងដល់សហគមន៍ តាមរយៈការផ្តល់នូវបរិយាបន្នហិរញ្ញវត្ថុ និងការយកចិត្តទុកដាក់ខ្ពស់ចំពោះអតិថិជនប្រកបដោយនិរន្តរភាព ព្រមទាំងបង្កើតតម្លៃដល់គ្រប់ភាគីពាក់ព័ន្ធ។

# គុណតម្លៃ

### ការទំនាក់ទំនងជាមួយអតិថិជន
អាទិភាពទីមួយរបស់យើងគឺធានាថា មានការពេញចិត្តទាំងស្រុង ចំពោះការបម្រើសេវារបស់យើង។

### គុណភាព
យើងនឹងខិតខំបម្រើអតិថិជនរបស់យើងឱ្យអស់លទ្ធភាព និងមានប្រសិទ្ធភាពបំផុត។

### សុចរិត យុត្តិធម៌ និងភាពស្មោះត្រង់
ការទុកចិត្តគឺជាមូលដ្ឋានគ្រឹះនៃអាជីកម្មរបស់យើងហើយយើងនឹងមិនផ្លាស់ប្តូរទស្សនៈនេះឡើយ។

### ភាពទីទៃគ្នា និងអព្យាក្រឹត
យើងបម្រើប្រជាជនក្រីក្រទៅតាមតម្រូវការជាមូលដ្ឋាន ដោយមិនប្រកាន់ជាតិសាសន៍ សាសនា ឬនិន្នាការនយោបាយឡើយ។

### តុល្យភាពសង្គម និងផលចំណេញរបស់ស្ថាប័ន
តុល្យភាពនេះធានាអនាគតរបស់អតិថិជនយើង និងខ្លួនយើង។

### ការគោរពវិន័យ
យើងមានជំនឿលើការគោរពច្បាប់របស់ក្រុមហ៊ុន អ្នកដែលពាក់ព័ន្ធ និងប្រទេស។

### ការខិតខំប្រឹងប្រែងធ្វើការងារ
យើងមានជំនឿថា ការជឿជាក់លើអនាគតរបស់យើងនឹងត្រូវបានធានា តាមរយៈការខិតខំប្រឹងប្រែងជាអតិបរមាចំពោះការទទួលខុសត្រូវរបស់យើង។

### ការអប់រំ
យើងមានជំនឿថា ការអប់រំគឺជាមូលដ្ឋានគ្រឹះនៃភាពជ័យជម្នះយូរអង្វែង។

# អំពី អិលអូអិលស៊ី (ខេមបូឌា)




អិលអូអិលស៊ី ទទួលបានអាជ្ញាប័ណ្ណប្រកបអាជីវកម្មទទួលប្រាក់បញ្ញើពីធនាគារជាតិនៃកម្ពុជា ដើម្បីផ្តល់នូវផលិតផល ឥណទាន និងប្រាក់បញ្ញើ។ បន្ថែមលើនេះ អិលអូអិលស៊ី ក៏ទទួលបានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ក្នុងការផ្តល់នូវសេវាភតិសន្យាហិរញ្ញវត្ថុ ការអនុញ្ញាតក្នុងការចាប់ដៃគូជាមួយក្រុមហ៊ុន ស៊ិរិនឌីបម៉ាយក្រូអ៊ិនសួរេន ភីអិលស៊ី ជាដៃគូអាជីវកម្មបេឡងកាសួរេនតាមម៉ូដែលភ្នាក់ងារ និងការអនុញ្ញាតមួយចំនួនផ្សេងទៀតផងដែរ ក្នុងការផ្តល់នូវសេវា យ៉ាងសម្បូរបែបដល់អតិថិជន រួមមានសេវាឥណទាន សេវាប្រាក់បញ្ញើ សេវាភតិសន្យាហិរញ្ញវត្ថុ សេវាផ្ទេរប្រាក់ក្នុងស្រុក សេវាធនាគារចល័ត សេវាទូទាត់វិក្កយប័ត្រ និងសេវាធានារ៉ាប់រងខ្នាតតូចតាមរយៈអាជីវកម្មបេឡងកាសួរេន។ ជាមួយនឹងបដិវត្តនៃបច្ចេកវិទ្យា អិលអូអិលស៊ី បាន និងកំពុងផ្តល់សេវាហិរញ្ញវត្ថុឌីជីថល ដើម្បីពង្រីកបណ្តាញចែកចាយបន្ថែមទៀតដូចជា កម្មវិធីធនាគារចល័ត iPay Mobile Application សេវាធនាគារតាមអ៊ីនធើណែត សេវាផ្ទេរប្រាក់តាមប្រព័ន្ធបាគង សេវាទូទាត់រហ័ស (FAST) សេវាទូទាត់សងប្រាក់តម្លៃរាយ (RFT) និងសេវាអេធីអឹមកាតតាមប្រព័ន្ធ CSS ដើម្បីផ្តល់នូវសេវាអតិថិជនដ៏ល្អប្រសើរជូនអតិថិជន។




## ប្រវត្តិសង្ខេប

អិលអូអិលស៊ី (ខេមបូឌា) ត្រូវបានបង្កើតឡើងដោយអង្គការ Catholic Relief Services ហៅកាត់ថា ("CRS") ក្នុងឆ្នាំ១៩៩៤ និងត្រូវបានចុះបញ្ជីក្រោមឈ្មោះ ធនាគារភូមិ (ខេមបូឌា) អិលធីឌី ក្នុងឆ្នាំ២០០២។ បន្ទាប់មកធនាគារជាតិនៃកម្ពុជាបានផ្តល់អាជ្ញាប័ណ្ណដល់ធនាគារភូមិជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្នុងឆ្នាំ២០០៣។ នៅឆ្នាំ ២០០៧ TPC-ESOP ត្រូវបានបង្កើតឡើង និងបានក្លាយជាផ្នែកមួយនៃរចនាសម្ព័ន្ធភាគហ៊ុន។ ក្នុងឆ្នាំ ២០១៤ ក្រុមហ៊ុន LOLC Micro Investment Ltd. ("LOMI") បានចូលរួមជាម្ចាស់ភាគហ៊ុនម្នាក់ក្នុងចំណោមភាគទុនិកនានា។ បន្ទាប់មកនៅឆ្នាំ ២០១៥ ក្រុមហ៊ុនបានប្តូរឈ្មោះទៅជា អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី ("LOLC") ហើយក៏បានទទួលអាជ្ញាប័ណ្ណប្រកបអាជីវកម្មទទួលប្រាក់បញ្ញើពីធនាគារជាតិនៃកម្ពុជាក្នុងឆ្នាំនោះផងដែរ។ ចាប់ពីឆ្នាំ ២០១៨ មក ក្រុមហ៊ុន LOLC Asia Private Limited (ពីមុនមានឈ្មោះថា LOLC Private Limited) បានទិញភាគហ៊ុនទាំងអស់របស់ DWM និង LOMI ដែលកាន់កាប់ ភាគហ៊ុនសរុបចំនួន ៩៦,៩៧% នៃភាគហ៊ុនរបស់ អិលអូអិលស៊ី (ខេមបូឌា) ខណៈដែលភាគហ៊ុន ៣,០៣% ផ្សេងទៀត ត្រូវបានកាន់កាប់ដោយបុគ្គលិក អិលអូអិលស៊ី (ខេមបូឌា) តាមរយៈក្រុមហ៊ុន TPC-ESOP CO., LTD។

ទាក់ទងនឹងផលិតផល និងសេវាកម្មរបស់ខ្លួន កាលពីដំបូង អិលអូអិលស៊ី (ខេមបូឌា) បានផ្តល់សេវាកម្ចី ហើយចាប់តាំងពីឆ្នាំ២០១៥ មក អិលអូអិលស៊ី (ខេមបូឌា) ផ្តល់សេវាប្រាក់បញ្ញើជូនដល់អតិថិជនបន្ថែមទៀត រួមជាមួយនឹងកម្មវិធីធនាគារចល័ត សេវាធនាគារតាមអ៊ិនធឺណិត និងការផ្ទេរប្រាក់ក្នុងស្រុកទាំងនៅក្នុង អិលអូអិលស៊ី (ខេមបូឌា) និងការផ្ទេរប្រាក់អន្តរធនាគារ តាមរយៈគម្រោងរបស់ធនាគារជាតិនៃកម្ពុជា (FAST, RFT និងបាគង)។

លើសពីនេះ អិលអូអិលស៊ី (ខេមបូឌា) ក៏បានបោះផ្សាយប័ណ្ណ CSS ATM ដែលអនុញ្ញាតឱ្យអតិថិជនដកប្រាក់ពីម៉ាស៊ីន ATM ជាង ៤.000 របស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុដែលជាសមាជិករបស់ CSS ។ ចាប់ពីឆ្នាំ ២០១៧ មក អិលអូអិលស៊ី (ខេមបូឌា) ក៏ទទួលបានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ដើម្បីផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុ ហើយនៅឆ្នាំ ២០២២ អិលអូអិលស៊ី (ខេមបូឌា) ទទួលបានការអនុញ្ញាតឱ្យធ្វើអាជីវកម្មបេឡងកាសួរេន (ម៉ូដែលភ្នាក់ងារ)។



# រចនាសម្ព័ន្ធភាគទុនិក



## LOLC ASIA PRIVATE LIMITED

ជាក្រុមហ៊ុនសាអាជីវកម្មដ៏ធំមួយក្នុងប្រទេសសិង្ហបុរី ដែលមានភាគហ៊ុនចំនួន ៩៦,៩៧% នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុន។

**៩៦,៩៧%**

## TPC-ESOP CO., LTD.

ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតមានភាគហ៊ុនចំនួន ៣,០៣% នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុន ដែលកាន់កាប់ដោយបុគ្គលិករបស់ អិលអូអិលស៊ី (ខេមបូឌា)។

**៣,០៣%**

# វិញ្ញាបនបត្រ និងពានរង្វាន់




## វិញ្ញាបនបត្រគោលការណ៍ការពារអតិថិជន (CPC)

នៅឆ្នាំ ២០២២ LOLC បានទទួលវិញ្ញាបនប័ត្រការពារអតិថិជនកម្រិតមាសពី Cerise និង SPTF ហើយវិញ្ញាបនបត្រត្រូវបានធានា នៅខែកុម្ភៈ ឆ្នាំ២០២៥។ នេះបញ្ជាក់ថា LOLC Cambodia តែងតែការពារ និងគាំទ្រអតិថិជន ដើម្បីពង្រីកអាជីវកម្មរបស់ពួកគេ។ តាមរយៈប្រសិទ្ធភាពនិងនិរន្តរភាពសេវាកម្មហិរញ្ញវត្ថុ។




## ចំណាត់ថ្នាក់ផ្នែកសង្គម ២០២៣

អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី ដែលជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើឈានមុខគេមួយនៅព្រះរាជាណាចក្រកម្ពុជា បានទទួលនូវការវាយតម្លៃចំណាត់ថ្នាក់ផ្នែកសង្គម ក្នុងកម្រិតពិន្ទុ "BB +" ដែលជាកម្រិតពិន្ទុដ៏ខ្ពស់មួយ បន្ទាប់ពីបញ្ចប់ការវាយតម្លៃក្នុងខែកុម្ភៈ ឆ្នាំ២០២៣ ថ្មីៗនេះពីស្ថាប័ន MicroFinanza។ ការវាយតម្លៃនេះគឺធ្វើឡើងដោយផ្អែកលើចំណុចសំខាន់ៗមួយចំនួនដូចជា៖ ការគ្រប់គ្រងសកម្មភាពសង្គម គោលការណ៍ការពារអតិថិជន ទំនួលខុសត្រូវសង្គម វិសាលភាពនៃប្រតិបត្តិការ និងគុណភាពនៃសេវាកម្ម។




## ចំណាត់ថ្នាក់ហិរញ្ញវត្ថុ ២០២៣

ទន្ទឹមនឹងសមិទ្ធផលដ៏គួរឱ្យស្ញប់ស្ញែងមួយនេះ អិលអូអិលស៊ី ក៏ទទួលបានការវាយតម្លៃ ដ៏ពិសេសមួយទៀតក្នុងកម្រិតពិន្ទុខ្ពស់ "α Medium" ទៅលើការវាយតម្លៃចំណាត់ថ្នាក់ហិរញ្ញវត្ថុ ដែលធ្វើដោយផ្អែកទៅលើចំណុចមួយចំនួនដូចជា៖ បរិបទខាងក្រៅ អភិបាលកិច្ច និងយុទ្ធសាស្ត្រ ស្ថានភាពហិរញ្ញវត្ថុ គុណភាពផលបត្រឥណទាន និងប្រព័ន្ធគ្រប់គ្រង។ កម្រិតពិន្ទុខ្ពស់ α Medium ពីការវាយតម្លៃចំណាត់ថ្នាក់ផ្នែកហិរញ្ញវត្ថុគឺជាលំដាប់ពិន្ទុខ្ពស់ដូចគ្នា។



## លិខិតថ្លែងអំណរគុណ

លិខិតនេះត្រូវបានផ្តល់ជូនអិលអូអិលស៊ី (ខេមបូឌា) សម្រាប់ការអនុលោមពេញលេញតាមកាតព្វកិច្ចសារពើពន្ធ។ អិលអូអិលស៊ី (ខេមបូឌា) ទទួលបានចំណាត់ថ្នាក់លេខ ១៣ ក្នុងចំណោមសហគ្រាសដែលបានបង់ពន្ធច្រើនជាងគេ និងទទួលបានអនុលោមភាពសារពើពន្ធប្រភេទមាស។

## វិញ្ញាបនបត្រ ISO ស្តីពីសន្តិសុខបច្ចេកវិទ្យាព័ត៌មានពីក្រុមហ៊ុន Bureau Veritas ដែលទទួលស្គាល់អិលអូអិលស៊ី (ខេមបូឌា) ចំពោះ

សុវត្ថិភាពខ្ពស់នៃបច្ចេកវិទ្យាព័ត៌មាន និងសុវត្ថិភាពខ្ពស់ក្នុងការការពារទិន្នន័យរបស់អតិថិជន។






## វិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទមាសពីអគ្គនាយកដ្ឋានពន្ធដារ

មិនមែនគ្រប់អាជីវកម្មដែលបានបង្កើតឡើងក្នុងប្រទេសកម្ពុជាមានសិទ្ធិទទួលបានវិញ្ញាបនប័ត្របែបនេះនោះទេ។ វិញ្ញាបនប័ត្រនេះត្រូវបានផ្តល់ឱ្យ អិលអូអិលស៊ី (ខេមបូឌា) សម្រាប់អនុលោមភាពសារពើពន្ធ ក្នុងឆ្នាំ២០២២ និងឆ្នាំ២០២៣។

## ពានរង្វាន់គ្រឹះស្ថានដែលសម្រេចបាននូវសមិទ្ធផលកម្ចីមានការធានាច្រើនជាងគេ ប្រចាំឆ្នាំ ២០២៣

អិលអូអិលស៊ី(ខេមបូឌា)ទទួលបានពានរង្វាន់ជាគ្រឹះស្ថានដែលសម្រេចបាននូវសមិទ្ធផលខ្ពស់ Outstanding Performance in Number of Guaranteed Account ២០២៣ ដែលបានបញ្ចេញកម្ចីមានការធានាបានច្រើនជាងគេ ក្នុងសន្និបាតប្រចាំឆ្នាំរបស់សាជីវកម្មធានាឥណទានកម្ពុជា (CGCC) ស្តីពី "ពិពិធកម្មយន្តការធានាឥណទាន ដើម្បីហិរញ្ញប្បទានប្រកបដោយចីរភាព របស់សហគ្រាសខ្នាតតូច និងមធ្យម"។



# ដៃគូហិរញ្ញប្បទាន និងអាជីវកម្ម

## ដៃគូហិរញ្ញប្បទានក្នុងប្រទេស

| | |
|---|---|
| Bank of China | Cathay United Bank |
| Bred Bank Cambodia | Industrial and Commercial Bank of China Limited |
| KB Daehan Special Bank Plc | SME Bank |
| Mega International Commercial Bank | Sathapana Bank Plc. |
| Union Commercial Bank Plc. | |

## ភ្នាក់ងារបង់ប្រាក់កម្ចី

| | |
|---|---|
| Wing Bank (Cambodia) Plc. | Ly Hour Pay Pro Plc. |
| True Money | E-Money |

## ជំនួយបច្ចេកទេស

| | |
|---|---|
| OikoCredit | Aqua for All |
| Global Climate Partnership Fund (GCPF) | Proparco |

## ដៃគូហិរញ្ញប្បទានក្រៅអន្តរជាតិ

| | |
|---|---|
| Alterfin c.v.b.a | NMI |
| BlueOrchard | Oikocredit |
| BANK IM BISTUM ESSEN eG | DFC (Former OPIC) |
| Developing World Market | Proparco |
| Enabling Qapital | BlueEarth (Former PG Impact) |
| Frankfurt School | responsAbility |
| Incofin | Symbiotics |
| MCE Social Capital | Triple Jump |
| Microvest | WLB |
| Bred Bank Cambodia | WaterCredit |

## ការធានាឥណទាន

| | |
|---|---|
| USAID | CGCC |

# ០២.

# អំពីអាជីវកម្ម

## សមិទ្ធផលអាជីវកម្ម ( ៣៦ )

- សមិទ្ធផលប្រាក់កម្ចី
- សមិទ្ធផលប្រាក់បញ្ញើ
- សេវាធនាគារចល័ត (iPAY Cambodia)
- សេវាប័ណ្ណអេធីអឹម ស៊ីអេសអេស
- សេវាផ្ទេរប្រាក់ក្នុងស្រុក

## របាយការណ៍ហិរញ្ញវត្ថុសង្ខេប ៣ឆ្នាំ ( ៤២ )

- របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ
- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
- អនុបាតសំខាន់ៗ

## សមិទ្ធផលសំខាន់ៗដែលសម្រេចបានក្នុងឆ្នាំ២០២៣ ( ៤៦ )

## ទស្សនវិស័យឆ្នាំ២០២៤ ( ៤៨ )



# សមិទ្ធផលអាជីវកម្ម



## សមិទ្ធផលប្រាក់កម្ចី

### ផលិតផលប្រាក់កម្ចី

- **ប្រាក់កម្ចីក្រុម** (GL)៖ គឺជាប្រាក់កម្ចីដែលបង្កើតឡើងដោយមានក្រុមធានា និងមានសមាជិកក្នុងសហគមន៍ចាប់ពី ២ ដល់ ៧នាក់ ជាមួយទំហំប្រាក់កម្ចីជាអតិបរមាចំនួន ២.០០០ដុល្លារអាមេរិក សមមូលនឹងរូបិយប័ណ្ណផ្សេងទៀតដោយពុំចាំបាច់មានទ្រព្យធានាឡើយ។
- **ប្រាក់កម្ចីឯកត្តជន** (IL)៖ គឺជាប្រាក់កម្ចីសម្រាប់បុគ្គល ឬម្ចាស់អាជីវកម្ម ជាមួយទំហំប្រាក់កម្ចីជាអតិបរមាចំនួន ១០.០០០ ដុល្លារអាមេរិក ឬសមមូលនឹងរូបបិយប័ណ្ណផ្សេងទៀត ដោយមាន ឬគ្មានទ្រព្យធានា។
- **ប្រាក់កម្ចីសហគ្រាសខ្នាតតូច និងមធ្យម** (SME)៖ គឺជាប្រាក់កម្ចីដែលផ្តល់ឯកត្តជន ម្ចាស់អាជីវកម្ម ឬសហគ្រិន ដែលមានទំហំប្រាក់កម្ចីជាអតិរមាចំនួន ២០០.០០០ ដុល្លារអាមេរិក ឬសមមូលនឹងរូបបិយប័ណ្ណផ្សេងទៀតដោយមានទ្រព្យធានា។
- **ប្រាក់កម្ចីតាមរដូវកាល** (SNL)៖ គឺជាប្រាក់កម្ចីដែលរៀបចំឡើងសម្រាប់ឱ្យអ្នកខ្ចី ប្រើប្រាស់ប្រាក់កម្ចីក្នុងសកម្មភាពកសិកម្មរបស់ពួកគេ ដែលមានទំហំប្រាក់កម្ចីជាអតិបរមាចំនួន ៣០.០០០ ដុល្លារអាមេរិក ឬសមមូលនឹងរូបិយប័ណ្ណផ្សេងទៀត។
- **ប្រាក់កម្ចីកែលម្អគេហដ្ឋាន** (HIL)៖ គឺជាប្រាក់កម្ចីដែលផ្តល់ជូនអតិថិជនដើម្បីកែលម្អ និងសាងសង់ផ្ទះរបស់ពួកគេជាមួយប្រាក់កម្ចីជាអតិបរមាចំនួន ៣០.០០០ដុល្លារអាមេរិក ឬសមមូលនឹងរូបិយប័ណ្ណផ្សេងទៀត។
- **ប្រាក់កម្ចីប្រើប្រាស់ផ្ទាល់ខ្លួន** (LIL)៖ គឺជាប្រាក់កម្ចីដែលផ្តល់ជូនអតិថិជន ដើម្បីលើកកម្ពស់ជីវភាពរស់នៅ ជាមួយនឹងទំហំកម្ចីជាអតិរមាចំនួន ១០.០០០ដុល្លារអាមេរិក ឬសមមូលនឹងរូបិយប័ណ្ណផ្សេងទៀត។
- **ប្រាក់កម្ចីទឹកស្អាត និងអនាម័យ** (WIL)៖ គឺជាប្រាក់កម្ចីដែលផ្តល់ជូនអតិថិជន ដើម្បីមានលទ្ធភាពទទួលបានទឹកស្អាត និងអនាម័យ ជាមួយនឹងទំហំកម្ចីអតិបរមាចំនួន ៣.០០០ដុល្លារអាមេរិក ឬសមមូលនឹងរូបិយប័ណ្ណផ្សេងទៀត។
- **ភតិសន្យាហិរញ្ញវត្ថុ** (FL)៖ រចនាឡើងសម្រាប់អតិថិជនដែលចង់ប្រើប្រាស់ចលនចលនវត្ថុ ដែលមានទំហំកម្ចីអតិបរមា ចំនួន ៥០.០០០ដុល្លារអាមេរិក ឬសមមូលនឹងរូបិយប័ណ្ណផ្សេងទៀត ហើយអតិថិជនអាចក្លាយជាម្ចាស់កម្មសិទ្ធិស្របច្បាប់នៅពេលបញ្ចប់កិច្ចសន្យាភតិសន្យា។

### សមិទ្ធផលប្រាក់កម្ចីតាមផលិតផល

| | ២០២២ | | | | ២០២៣ | | | |
|---|---|---|---|---|---|---|---|---|
| ផលិតផល | ចំនួនគណនី | % គណនី | ផលប័ត្រឥណទាន (ពាន់ដុល្លារ) | % ផលប័ត្រឥណទាន | ចំនួនគណនី | % គណនី | ផលប័ត្រឥណទាន (ពាន់ដុល្លារ) | % ផលប័ត្រឥណទាន |
| ប្រាក់កម្ចីក្រុម | ១៩២.៦៣១ | ៤៦,៥% | ១៧៤.៥៣០ | ១៣,៩% | ១៦៨.៧៩២ | ៤២,៥% | ១៩០.៦១២ | ១១,៣% |
| ប្រាក់កម្ចីឯកត្តជន | ១១២.៣៦២ | ២៧,១% | ៣៦២.០១៥ | ២៨,៩% | ១២២.២៦៦ | ៣០,៨% | ៣៦៩.២១៧ | ២៩,៦% |
| ប្រាក់កម្ចីសហគ្រាសខ្នាតតូច និងមធ្យម | ៣២.៥៧១ | ៧,៩% | ៤៣៦.៥១២ | ៣៤,៨% | ៣៥.៥៤៨ | ៩,០% | ៤៧៤.២២៣ | ៣៨,០% |
| ប្រាក់កម្ចីតាមរដូវកាល | ២៤.៨៩៥ | ៦,០% | ១១៦.៩៧១ | ៩,៣% | ២៥.៥០៦ | ៦,៤% | ១១៧.៣៣៥ | ៩,៤% |
| ប្រាក់កម្ចីកែលម្អគេហដ្ឋាន | ៩.៨២៣ | ២,៤% | ៥៧.៧៦៤ | ៤,៦% | ៩.៣៦៦ | ២,៤% | ៥៦.៧៣៤ | ៤,៦% |
| ប្រាក់កម្ចីប្រើប្រាស់ផ្ទាល់ខ្លួន | ៣៧.២៧៤ | ៩,០% | ១០៣.៣០៩ | ៨,៣% | ៣២.៤៧៥ | ៨,២% | ៨៧.៣០៤ | ៧,០% |
| ប្រាក់កម្ចីទឹកស្អាត និងអនាម័យ | ៤.៥៨៥ | ១,១% | ១.៧១៦ | ០,២% | ២.៩៣១ | ០,៧% | ១.០៣៥ | ០,១% |
| ភតិសន្យាហិរញ្ញវត្ថុ | ១១៩ | ០,០% | ២០៥ | ០,០% | ៣៥ | ០,០% | ៤៧ | ០,០% |
| **សរុប** | **៤១៤.២៦០** | **១០០%** | **១.២៥៣.០២២** | **១០០%** | **៣៩៦.៩១៩** | **១០០%** | **១.២៤៦.៥០៧** | **១០០%** |

ផលិតផលកម្ចីក្រុម និងកម្ចីឯកត្តជននៅតែជាអាជីវកម្មស្នូលរបស់ អិលអូអិលស៊ី ដែលមានចំនួនច្រើនជាង ៧០% នៃអតិថិជនកម្ចីសរុប។

### សមិទ្ធផលប្រាក់កម្ចីតាមវិស័យ

| | ២០២២ | | | | ២០២៣ | | | |
|---|---|---|---|---|---|---|---|---|
| វិស័យ | ចំនួនគណនី | % គណនី | ផលប័ត្រឥណទាន (ពាន់ដុល្លារ) | % ផលប័ត្រឥណទាន | ចំនួនគណនី | % គណនី | ផលប័ត្រឥណទាន (ពាន់ដុល្លារ) | % ផលប័ត្រឥណទាន |
| កសិកម្ម | ១៩៤.២២២ | ៤៦,៩% | ៤៤៨.១៨៦ | ៣៥,៨% | ១៩៦.២២៨ | ៤៩,៤% | ៤៤៦.៨២៧ | ៣៥,៨% |
| ផលិតកម្ម | ២.៥១១ | ០,៦% | ៨.៦៣៤ | ០,៧% | ២.៦៧៩ | ០,៧% | ១០.០៣៧ | ០,៨% |
| ពាណិជ្ជកម្ម និងជំនួញ | ៥៩.៧៨៧ | ១៤,៤% | ៣៤៤.៤៨៩ | ២៧,៤% | ៦២.៨៤៤ | ១៥,៨% | ៣៩២.៣១៩ | ៣១,៥% |
| សេវាកម្ម | ២៤.៣២៤ | ៥,៩% | ១០៦.៦១៧ | ៨,៥% | ២២.២៦៣ | ៥,៦% | ១០៥.៥៦៥ | ៨,៥% |
| ដឹកជញ្ជូន | ២.៧៥៩ | ០,៧% | ១៧.៤៣០ | ១,៤% | ២.៦១៨ | ០,៧% | ១៦.៨៤០ | ១,៣% |
| សំណង់ | ៤៥.២៥១ | ១០,៩% | ១២៥.០៨៦ | ១០,០% | ៤៤.៥៥៨ | ១១,២% | ១២៦.៨៤០ | ១០,២% |
| ផ្សេងៗ | ៨៥.៤០៦ | ២០,៦% | ២០២.៥៧០ | ១៦,២% | ៦៥.៧២៩ | ១៦.៦% | ១៤៨.០៣៩ | ១១,៩% |
| **សរុប** | **៤១៤.២៦០** | **១០០%** | **១.២៥៣.០២២** | **១០០%** | **៣៩៦.៩១៩** | **១០០%** | **១.២៤៦.៥០៧** | **១០០%** |

ក្នុងឆ្នាំ២០២៣ ប្រមាណជិត ៣៦% នៃផលប័ត្រឥណទានសរុបត្រូវបានផ្តល់ជូនអតិថិជនក្នុងវិស័យកសិកម្ម ខណៈដែលវិស័យពាណិជ្ជកម្ម និងជំនួញ និងវិស័យសេវាកម្ម មានចំនួន ៣១,៥% និង ៨,៥% រៀងគ្នា។

### សមិទ្ធផលប្រាក់កម្ចីតាមកម្រិតចំណូលរបស់អតិថិជន

| | | ២០២២ | | | | ២០២៣ | | | |
|---|---|---|---|---|---|---|---|---|---|
| ប្រភេទអតិថិជន | ទំហំកម្ចី | ចំនួនគណនី | % គណនី | ផលប័ត្រឥណទាន (ពាន់ដុល្លារ) | % ផលប័ត្រឥណទាន | ចំនួនគណនី | % គណនី | ផលប័ត្រឥណទាន (ពាន់ដុល្លារ) | % ផលប័ត្រឥណទាន |
| ទំនងជារស់នៅក្រោមបន្ទាត់ភាពក្រីក្រ | ≤ $៧៥០ | ៥២.១៩៦ | ១២,៦% | ១៩.៩៤៥ | ១,៦% | ៤៣.០៥៨ | ១០,៨% | ១៥.៦០១ | ១,៣% |
| ទំនងជារស់នៅលើបន្ទាត់ភាពក្រីក្រ ទៅក្រោមបន្ទាត់ភាពក្រីក្រ ១៥០% | > $៧៥០ to ≤ $១.៥០០ | ១១៦.០៨៣ | ២៨,០% | ៩៦.៤១៦ | ៧,៧% | ១០៩.៥៧២ | ២៧,៦% | ៨៥.៥៦៧ | ៦,៩% |
| ទំនងជារស់នៅលើបន្ទាត់ភាពក្រីក្រ ១៥០% ទៅចំណូល $៥/ថ្ងៃ/២០០៥ PPP | > $១.៥០០ to ≤ $៣.០០០ | ១១០.៩៧១ | ២៦,៨% | ១៦៦.៧៩០ | ១៣,៣% | ១០៧.៩០១ | ២៧,២% | ១៥០.៣៣៩ | ១២,១% |
| ទំនងជារស់នៅលើចំណូលខ្ពស់ជាង $៥/ថ្ងៃ/២០០៥ PPP | > $៣.០០០ to ≤ $១០.០០០ | ៩៣.៣៤៤ | ២២,៥% | ៤១៦.៦៩៥ | ៣៣,៣% | ៩១.៥៨២ | ២៣,១% | ៤០៦.៧០០ | ៣២,៦% |
| ទំនងជារស់នៅលើចំណូលខ្ពស់ជាង $៥/ថ្ងៃ/២០០៥ PPP | > $ ១០.០០០ to ≤ $៣០.០០០ | ៤១.២៨២ | ១០,០% | ៥៣៧.៨៥២ | ៤២,៩% | ៤៤.៤៣៧ | ១១,២% | ៥៧៣.០០០ | ៤៦,០% |
| ទំនងជារស់នៅលើចំណូលខ្ពស់ជាង $៥/ថ្ងៃ/២០០៥ PPP | > $៣០.០០០ | ៣៨៤ | ០,១% | ១៥.៣២៤ | ១,២% | ៣៦៩ | ០,១% | ១៥.៣០០ | ១,២% |
| **សរុប** | | **៤១៤.២៦០** | **១០០%** | **១.២៥៣.០២២** | **១០០%** | **៣៩៦.៩១៩** | **១០០%** | **១.២៤៦.៥០៧** | **១០០%** |

** ដើម្បីការវិភាគនេះត្រឹមត្រូវ ការកត់ត្រាទិន្នន័យចំណូលរបស់អតិថិជនឱ្យបានត្រឹមត្រូវនៅក្នុងប្រព័ន្ធធនាគារស្នូលពិតជាចាំបាច់។ ប៉ុន្តែដោយសារទិន្នន័យឌីជីថលបច្ចុប្បន្ននៅមានកម្រិតនៅឡើយ ការវិភាគសមិទ្ធផលប្រាក់កម្ចីតាមចំណូលរបស់អតិថិជនដោយប្រើទិន្នន័យទំហំឥណទានជាមធ្យម ដើម្បីប៉ាន់ស្មានជំនួសឱ្យទិន្នន័យចំណូលរបស់អតិថិជន និងអនុវត្តទៅតាមនិយមន័យសន្ទស្សន៍នៃការចាកផុតពីភាពក្រីក្រ (PPI) ដូចដែលបានឃើញក្នុងតារាងខាងលើ។*

នៅក្នុងឆ្នាំ២០២៣ ចំនួនគណនីភាគច្រើនមានទំហំប្រាក់កម្ចីតិចជាង ១.៥០០ ដុល្លារ ដែលស្មើនឹង ៤០%។

### សមិទ្ធផលប្រាក់កម្ចីតាមប្រភេទទ្រព្យធានា

| | ២០២២ | | | | ២០២៣ | | | |
|---|---|---|---|---|---|---|---|---|
| ប្រភេទទ្រព្យធានា | ចំនួនគណនី | % គណនី | ផលប័ត្រឥណទាន (ពាន់ដុល្លារ) | % ផលប័ត្រឥណទាន | ចំនួនគណនី | % គណនី | ផលប័ត្រឥណទាន (ពាន់ដុល្លារ) | % ផលប័ត្រឥណទាន |
| មិនមានទ្រព្យធានា | ២៣៩.៧២២ | ៥៧,៩% | ២៨៨.៧៧០ | ២៣,០% | ២២១.៣៤៩ | ៥៥,៨% | ២៥៤.៦៤៧ | ២០,៤% |
| មានទ្រព្យធានា | ១៧៤.៥៣៨ | ៤២,១% | ៩៦៤.២៥២ | ៧៧,០% | ១៧៥.៥៧០ | ៤៤,២% | ៩៩១.៨៦០ | ៧៩,៦% |
| **សរុប** | **៤១៤.២៦០** | **១០០%** | **១.២៥៣.០២២** | **១០០%** | **៣៩៦.៩១៩** | **១០០%** | **១.២៤៦.៥០៧** | **១០០%** |

នៅឆ្នាំ២០២៣ គណនីប្រាក់កម្ចីគ្មានទ្រព្យធានាមានចំនួនជិត ៥៦% ដែលប្រាក់កម្ចីត្រូវបានផ្តល់ទៅឱ្យអតិថិជនកម្ចីក្រុម និងអតិថិជនកម្ចីឯកត្តជន ដែលមានទំហំប្រាក់កម្ចីតិចជាង ៣.០០០ ដុល្លារអាមេរិក។

### សមិទ្ធផលប្រាក់កម្ចីតាមប្រភេទរូបិយប័ណ្ណ

| | ២០២២ | | | | ២០២៣ | | | |
|---|---|---|---|---|---|---|---|---|
| ប្រភេទរូបិយប័ណ្ណ | ចំនួនគណនី | % គណនី | ផលប័ត្រឥណទាន (ពាន់ដុល្លារ) | % ផលប័ត្រឥណទាន | ចំនួនគណនី | % គណនី | ផលប័ត្រឥណទាន (ពាន់ដុល្លារ) | % ផលប័ត្រឥណទាន |
| ខ្មែររៀល | ២៣៣.៦១៧ | ៥៦,៤% | ៣៥៤.៨៦៣ | ២៨,៣% | ២២៩.៣៥៣ | ៥៧,៨% | ៣៧០.០៤៥ | ២៩,៧% |
| ដុល្លារអាមេរិក | ១៥៤.៦០៧ | ៣៧,៣% | ៨៣៨.១៥០ | ៦៦,៩% | ១៥០.០៧០ | ៣៧,៨% | ៨៣៨.៩៣០ | ៦៧,៣% |
| ថៃបាត | ២៦.០៣៦ | ៦,៣% | ៦០.០០៩ | ៤,៨% | ១៧.៤៩៦ | ៤,៤% | ៣៧.៥៣២ | ៣,០% |
| **សរុប** | **៤១៤.២៦០** | **១០០%** | **១.២៥៣.០២២** | **១០០%** | **៣៩៦.៩១៩** | **១០០%** | **១.២៤៦.៥០៧** | **១០០%** |

ប្រមាណជិត ៣០% នៃផលប័ត្រឥណទានសរុបត្រូវបានផ្តល់ជូនអតិថិជនជារូបិយប័ណ្ណរៀល។





## សមិទ្ធផលប្រាក់បញ្ញើ

**គណនីបញ្ញើសំចៃ៖ ងាយស្រួល និងមានសុវត្ថិភាព!**
គណនីបញ្ញើសំចៃ ផ្តល់ជូនអតិថិជននូវភាពងាយស្រួល និងសាមញ្ញក្នុងការដក ដាក់ ឬផ្ទេរប្រាក់។ គណនីប្រភេទនេះជាជម្រើសដ៏ប្រសើរបំផុតសម្រាប់អតិថិជនដែលមានបំណងរក្សាប្រាក់របស់ខ្លួនឱ្យមានសុវត្ថិភាព ក៏ដូចជាសម្រាប់អតិថិជនដែលមានបំណងប្រើប្រាស់សាច់ប្រាក់ប្រចាំថ្ងៃ។

**គណនីបញ្ញើសំចៃឌីជីថល៖ បើកគណនីភ្លាមៗតាមរយៈឌីជីថល!**
កម្មវិធី អាយផេខេមបូឌា អាចឱ្យអ្នកប្រើប្រាស់បង្កើតគណនីបញ្ញើសំចៃឌីជីថលបានយ៉ាងឆាប់រហ័ស និងសាមញ្ញ ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ធ្វើប្រតិបត្តិការតាមរយៈកម្មវិធីធនាគារចល័ត iPay Cambodia។

**គណនីកុមារ៖ សន្សំប្រាក់សម្រាប់សម្រេចក្តីស្រមៃ និងអនាគតរបស់កូនៗគឺជារឿងដែលសំខាន់បំផុត!**
គណនីកុមារផ្តល់ឱ្យឪពុកម្តាយ និងអាណាព្យាបាល កាន់តែងាយស្រួលសម្រាប់ការសន្សំប្រាក់រយៈពេលវែង ដែលមានអត្រាការប្រាក់ខ្ពស់ ដើម្បីបំពេញតម្រូវការហិរញ្ញវត្ថុរបស់កូនពួកគេនាពេលអនាគត។

**ប្រាក់បញ្ញើមានកាលកំណត់៖ សន្សំប្រាក់ដើម្បីទទួលបានចំណូលការប្រាក់ខ្ពស់!**
ប្រាក់បញ្ញើមានកាលកំណត់ផ្តល់អត្រាការប្រាក់ខ្ពស់ជាថ្នូរនឹងការប្តេជ្ញាចិត្តរបស់អតិថិជនក្នុងការសន្សំប្រាក់ជាមួយ អិលអូអិលស៊ី ក្នុងរយៈពេលជាក់លាក់ណាមួយ។

### សមិទ្ធផលប្រាក់បញ្ញើតាមប្រភេទរូបិយប័ណ្ណ

| | ២០២២ | | | | ២០២៣ | | | |
|---|---|---|---|---|---|---|---|---|
| ប្រភេទប្រាក់បញ្ញើ | ចំនួនគណនី | % គណនី | សមតុល្យ ពាន់ដុល្លារ | % សមតុល្យ | ចំនួនគណនី | % គណនី | សមតុល្យ ពាន់ដុល្លារ | % សមតុល្យ |
| គណនីបញ្ញើសំចៃ | ៥៨៧.៧៩០ | ៩៦,៤១% | ៤៦.៥៥១ | ៦,០៧% | ៥៨១.៣៦១ | ៩៣.៦% | ៤៩.៤១១ | ៥,៤៧% |
| គណនីប្រាក់បញ្ញើមានកាលកំណត់ | ២១.៣១៤ | ៣,៥០% | ៧២០.៦០៩ | ៩៣,៩៣% | ៣២.៥២៤ | ៥.២% | ៨៥៤.០៥៨ | ៩៤,៤៨% |
| គណនីកុមារ | ៤៧៩ | ០,០៨% | ១៤ | ០,០០២% | ៥.៨៧៣ | ០.៩% | ៤២៦ | ០,០៥% |
| គណនីឌីជីថល | ៦៨ | ០,០១% | ១ | ០,០០០១% | ១,០៨២ | ០.២% | ២៣ | ០.០០% |
| **សរុប** | **៦០៩.៦៥១** | **១០០%** | **៧៦៧.១៧៤** | **១០០%** | **៦២០.៨៤០** | **១០០%** | **៩០៣.៩១៨** | **១០០%** |

សមតុល្យប្រាក់បញ្ញើសរុបកើនឡើងចំនួន ១៨% ដល់ជាង ៩០៤ លានដុល្លារអាមេរិក ត្រឹមដំណាច់ឆ្នាំ២០២៣។

### សមិទ្ធផលប្រាក់បញ្ញើតាមប្រភេទរូបិយប័ណ្ណ

| | ២០២២ | | | | ២០២៣ | | | |
|---|---|---|---|---|---|---|---|---|
| ប្រភេទប្រាក់បញ្ញើ | ចំនួនគណនី | % គណនី | សមតុល្យ ពាន់ដុល្លារ | % សមតុល្យ | ចំនួនគណនី | % គណនី | សមតុល្យ ពាន់ដុល្លារ | % សមតុល្យ |
| ខ្មែររៀល | ៣៤៨.២០៧ | ៥៧,១% | ៨២.១០៣ | ១០,៧% | ៣៥១.៦៣១ | ៥៦,៦% | ៩៤.១៧៣ | ១០,៤% |
| ដុល្លារអាមេរិក | ២២៦.៩១៥ | ៣៧,២% | ៦៧៨.៥២៣ | ៨៨,៤% | ២៤១.៤១០ | ៣៨,៩% | ៨០៧.៨៦០ | ៨៩,៤% |
| ថៃបាត | ៣៤.៥២៩ | ៥,៧% | ៦.៥៤៨ | ០,៩% | ២៧.៧៩៩ | ៤,៥% | ១.៨៨៥ | ០,២% |
| **សរុប** | **៦០៩.៦៥១** | **១០០%** | **៧៦៧.១៧៤** | **១០០%** | **៦២០.៨៤០** | **១០០%** | **៩០៣.៩១៨** | **១០០%** |

គណនីប្រាក់បញ្ញើចំនួន ៥៧% គឺជាគណនីប្រាក់រៀល។ ចំណែកសមតុល្យប្រាក់បញ្ញើ ៨៩% គឺជារូបិយប័ណ្ណដុល្លារអាមេរិក។




## សេវាធនាគារចល័ត (IPAY CAMBODIA)

**iPay Cambodia (សម្រាប់អតិថិជនទូទៅ)៖** គឺជាសេវាធនាគារចល័ត ដែលមានមុខងារលើសពីការទូទាត់ដោយនាំមកជូនអ្នកប្រើប្រាស់របស់ខ្លួននូវភាពងាយស្រួលក្នុងការធ្វើប្រតិបត្តិការធនាគារឌីជីថល ដែលផ្តល់នូវបទពិសោធន៍ទូទាត់ដោយគ្មានសាច់ប្រាក់ និងមានភាពរលូន។ តាមរយៈកម្មវិធី iPay Cambodia អតិថិជនអាចធ្វើប្រតិបត្តិការធនាគារ ផ្សេងៗ ពោលគឺ ការត្រួតពិនិត្យសមតុល្យ ការផ្ទេរប្រាក់ទៅកាន់គណនី អិលអូអិលស៊ី (ខេមបូឌា) ដទៃទៀត ក៏ដូចជាការផ្ទេរប្រាក់អន្តរធនាគារតាមរយៈ សេវាទូទាត់រហ័ស (FAST) សេវាផ្ទេរមូលនិធិភ្លាមៗ (RFT) និងបាគង ទូទាត់វិក្កយបត្រ បញ្ចូលទឹកប្រាក់ក្នុងទូរសព្ទ បើកគណនីប្រាក់បញ្ញើមានកាលកំណត់ បើកគណនីសំចៃឌីជីថល ហើយស្កែន និងបង់ប្រាក់ទៅឱ្យអាជីវករទាំងអស់តាមរយៈ អិលអូអិលស៊ី KHQR ដោយមិនគិតថ្លៃសេវា។

**iPay Cambodia (សម្រាប់អាជីវករ)៖** អិលអូអិលស៊ី (ខេមបូឌា) បានណែនាំកម្មវិធី Merchant App ដល់ម្ចាស់អាជីវកម្ម ដើម្បីគាំទ្រការរីកចម្រើនរយៈពេលវែង។ តាមរយៈការចុះឈ្មោះតាមកម្មវិធី iPay Merchant Cambodia ម្ចាស់អាជីវកម្មអាចគ្រប់គ្រងសាច់ប្រាក់ និងប្រតិបត្តិការគណនីរបស់ពួកគេបានយ៉ាងងាយស្រួល។

## សេវាប័ណ្ណអេធីអឹម (CSS)

អិលអូអិលស៊ី (ខេមបូឌា) ផ្តល់ប័ណ្ណអេធីអឹម (ស៊ីអេសអេស) ជាមួយបន្ទះឈីប EMV ដើម្បីឱ្យកាន់តែមានសុវត្ថិភាពដល់អតិថិជន ដើម្បីធ្វើប្រតិបត្តិការធនាគារដោយខ្លួនឯងជាមួយសមាជិក ស៊ីអេសអេស ដូចជាការដកសាច់ប្រាក់ ការត្រួតពិនិត្យសមតុល្យទឹកប្រាក់ ការផ្លាស់ប្តូរលេខសម្ងាត់ របាយការណ៍សង្ខេប និងការផ្ទេរប្រាក់ក្នុងរង្វង់ អិលអូអិលស៊ី ឬ ការផ្ទេរប្រាក់ឆ្លងធនាគារ ជាមួយម៉ាស៊ីនអេធីអឹមដែលមានជាង ៤.000 កន្លែងទូទាំងប្រទេសដោយមិនគិតថ្លៃ។

## សេវាផ្ទេរប្រាក់ក្នុងស្រុក

ដើម្បីបំពេញតម្រូវការរបស់អតិថិជនដែលកំពុងកើនឡើង អិលអូអិលស៊ី (ខេមបូឌា) បានចូលរួមជាមួយគម្រោងរបស់ធនាគារជាតិនៃកម្ពុជា ដូចជា សេវាទូទាត់រហ័ស, សេវាផ្ទេរមូលនិធិភ្លាមៗ និងបាគង ដើម្បីឱ្យអតិថិជនរបស់ អិលអូអិលស៊ី (ខេមបូឌា) អាចធ្វើការផ្ទេរប្រាក់ក្នុងស្រុកទៅកាន់គណនីនានានៅក្នុង អិលអូអិលស៊ី (ខេមបូឌា) ក៏ដូចជាការផ្ទេរប្រាក់អន្តរធនាគារតាមរយៈបញ្ជរ សេវាធនាគារតាមអ៊ិនធឺណែត និងសេវាធនាគារចល័តនានា ដោយមិនគិតថ្លៃ។



# របាយការណ៍ហិរញ្ញវត្ថុសង្ខេប ៣ឆ្នាំ

## របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ

| | ២០២១ បានធ្វើសវនកម្ម | ២០២២ បានធ្វើសវនកម្ម | ២០២៣ បានធ្វើសវនកម្ម |
|---|---|---|---|
| **ចំណូល** | | | |
| ចំណូលការប្រាក់ | ១៧៥.៥៤៥.៣៤០ | ២១១.៥៦១.៨១១ | ២១៦.៨១៤.០៩៨ |
| ចំណាយការប្រាក់ | (៦១.៥៤៩.០៤៤) | (៧៤.៩៤៦.៨៧៥) | (៨៦.១៨៤.០៤៨) |
| ចំណូលការប្រាក់សុទ្ធ | **១១៣.៩៩៦.២៩៦** | **១៣៦.៦១៤.៩៣៦** | **១៣០.៦៣០.០៥០** |
| សំវិធានធនឥណទានអាក្រក់ និងសង្ស័យឧបករណ៍ហិរញ្ញវត្ថុ | (៥.៨១២.៦២០) | (១៨.០៨២.៨៤៨) | (២.៤៩៣.៧៥៣) |
| ចំណូលការប្រាក់សុទ្ធ ក្រោយពីផ្តល់សំវិធានធន | **១០៨.១៨៣.៦៧៦** | **១១៨.៥៣២.០៨៨** | **១២៨.១៣៦.២៩៧** |
| ប្រាក់ចំណេញ/(ខាត) សុទ្ធពីការប្តូររូបិយប័ណ្ណ | ២៩៦.៧៤៤ | (៤៥៣.១៤៧) | ៧០៣.៨៧២ |
| ប្រាក់ចំណូលផ្សេងៗ | ៥.៩៦៤.៤៤០ | ៧.៣១៤.៣៤០ | ៦.៥៨៤.៤០៧ |
| ចំណាយលើបុគ្គលិក | (៣២.៦៣៨.១៦៧) | (៣៥.២៥៤.៩៩០) | (៣៦.១២៤.៤៩៦) |
| ចំណាយលើការរំលស់ | (២.៩៩៣.៥៨០) | (៣.០៦១.២១៥) | (៣.៤៥៥.២៧២) |
| ចំណាយរដ្ឋបាលផ្សេងៗ | (១០.៨៣៤.៩៩៧) | (១៣.៤៣៧.២៩៥) | (១៣.៣៤០.៨៨៦) |
| **ប្រាក់ចំណេញពីប្រតិបត្តិការ** | **៦៧.៩៧៨.១១៦** | **៧៣.៦៣៩.៧៨១** | **៨២.៥០៣.៩២២** |
| ចំណាយពន្ធលើប្រាក់ចំណូល | (១៣.៣២៦.១៩២) | (១៤.៩៤៤.៥០១) | (១៦.៧៨៩.៥៦៥) |
| ប្រាក់ចំណេញសុទ្ធក្នុងឆ្នាំ | **៥៤.៦៥១.៩២៤** | **៥៨.៦៩៥.២៨០** | **៦៥.៧១៤.៣៥៧** |
| លម្អៀងពីការប្តូរបិយប័ណ្ណ | (១.៣៧០.១៥៨) | (២.៨៧៦.៥០១) | ២.៦៧៦.០៦១ |
| ចំណូលលម្អិតសរុបក្នុងឆ្នាំ | **៥៣.២៨១.៧៦៦** | **៥៥.៨១៨.៧៧៩** | **៦៨.៣៩០.៤១៨** |

នៅឆ្នាំ ២០២៣ អិលអូអិលស៊ី (ខេមបូឌា) អាចសម្រេចបានប្រាក់ចំណេញសុទ្ធចំនួន ៦៥,៧១ លានដុល្លារអាមេរិក ដែលមានកំណើនស្មើនឹង ១១,៩៦% ធៀបទៅនឹងឆ្នាំមុន។

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

| | ២០២១ បានធ្វើសវនកម្ម | ២០២២ បានធ្វើសវនកម្ម | ២០២៣ បានធ្វើសវនកម្ម |
|---|---|---|---|
| **ទ្រព្យសកម្ម** | | | |
| សាច់ប្រាក់ និងការដាក់ប្រាក់នៅធនាគារ | ១៧៤.២៣៧.៩៤៨ | ២៣៤.២៦៤.០៧៤ | ៣១៨.៨៤០.៥០៩ |
| ប្រាក់កម្ចីដល់អតិថិជន | ១.០៣៦.២៨០.៨៧៥ | ១.២៥៣.០២២.២៥៥ | ១,២៤៦.៥០៧.១១៤ |
| ទុនបម្រុងខាតឥណទាន | (២១.៣២៩.១៥៩) | (៣៦.៩១២.៣៥១) | (២១.៧៤៨.៣៩៣) |
| ទ្រព្យសម្បត្តិ និងបរិក្ខារ (សុទ្ធ) | ១០.៩៨២.១៥៨ | ១០.៥៦៥.៨២៤ | ១១.៩០៣.២១១ |
| ទ្រព្យសកម្មផ្សេងៗ | ១១.១៨៣.៣៣៤ | ១៤.៧២៣.៧៥៤ | ១២.៣៣០.០៦១ |
| **ទ្រព្យសកម្មសរុប** | **១.២១១.៣៥៥.១៥៦** | **១.៤៧៥.៦៦៣.៥៥៦** | **១.៥៦៧.៨៣២.៥០២** |
| | | | |
| **បំណុល** | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | ៥៨១.៩៣៧.១២១ | ៧៦៧.១៧៤.៤៩៨ | ៩០៣.៩១៧.៨៥៥ |
| ប្រាក់កម្ចី | ៣៤៤.៧៩៩.៤២៦ | ៣៨៤.៧០៤.៨៣៦ | ២៧៨.៥៤៣.២៧៤ |
| បំណុលផ្សេងៗ | ៥០.១៦០.៦២៧ | ៣៣.៥០៧.៤៦១ | ២៩.១៧៥.៩១៥ |
| បំណុលសរុប | ៩៧៦.៨៩៧.១៧៤ | ១.១៨៥.៣៨៦.៧៩៥ | ១.២១១.៦៣៧.០៤៤ |
| | | | |
| **មូលធន** | | | |
| ដើមទុន | ៥៥.៤៦០.៨៥០ | ៥៥.៥៦០.៨៥០ | ១០៣.៩៦៩.២១៨ |
| ទុនបម្រុងទូទៅ | ៩៣.៧៦៨.៩៥១ | ៩៣.៧៦៨.៩៥១ | ៩៣.៧៦៨.៩៥១ |
| ទុនបម្រុងតាមបទបញ្ញត្តិ និងទុនបម្រុងផ្សេងៗ | (១.០១៣.៣៦៤) | (៣.៨៨៩.៨៦៥) | ៥.៤០៨.៤៥៩ |
| ប្រាក់ចំណេញរក្សាទុក | ៨៦.២៤១.៥៤៥ | ១៤៤.៩៣៦.៨២៥ | ១៥៣.០៤៨.៨៣០ |
| មូលធនសរុប | ២៣៤.៤៥៧.៩៨២ | ២៩០.២៧៦.៧៦១ | ៣៥៦.១៩៥.៤៥៨ |
| **បំណុល និងមូលធនសរុប** | **១.២១១.៣៥៥.១៥៦** | **១.៤៧៥.៦៦៣.៥៥៦** | **១.៥៦៧.៨៣២.៥០២** |

ទ្រព្យសកម្មរបស់ អិលអូអិលស៊ី កើនឡើងចំនួន ៦,២% ដែលមានចំនួន ១,៥៦៧.៨៣ លានដុល្លារអាមេរិក គិតត្រឹមថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០២៣ ទោះបីជាផលប័ត្រឥណទានមានការធ្លាក់ចុះតិចតួច ដែលមានអត្រា ០,៥% ធៀបនឹងឆ្នាំមុន និងចំនួនផលប័ត្រឥណទានចំនួនជិត ១,២៤៦.៥១លានដុល្លារអាមេរិក។

## អនុបាតសំខាន់ៗ

| សូចនាករអនុបាតសំខាន់ៗ | ដំណាច់ឆ្នាំ ២០២១ | ដំណាច់ឆ្នាំ ២០២២ | ដំណាច់ឆ្នាំ ២០២៣ |
|---|---|---|---|
| អត្រាចំណេញមូលធនភាគទុនិក | ២៦,៣% | ២២,៤% | ២០,៣% |
| អត្រាចំណេញលើទ្រព្យសកម្ម | ៤,៨% | ៤,៤% | ៤,៣% |
| ការចំណាយប្រតិបត្តិការទៅផលប័ត្រឥណទានដុលជាមធ្យម | ៤,៩% | ៤,៦% | ៤,២% |
| អនុបាតចំណាយធៀបចំណូល (រួមបញ្ចូលសំវិធានធន) | ៤៣,៣% | ៤៨,៨% | ៣៩,៩% |
| ប្រាក់បញ្ញើធៀបឥណទាន | ៥៦,២% | ៦១,២% | ៧២,៥% |
| អនុបាតគ្របខណ្ឌសន្ទនីយភាព | ២២៧,៥% | ៣៣៤,៧% | ២៧៣,៥% |
| អនុបាតសោធនភាព | ២៦,៨% | ២៣,១% | ២៤,៧% |
| ឥណទានមិនដំណើរការធៀបទៅផលប័ត្រឥណទានដុល | ១,៨% | ២,៣% | ២,២% |
| អនុបាតបំណុលធៀបមូលធនភាគទុនិក | ៤,២x | ៤,១x | ៣,៤x |
| ហានិភ័យឥណទានធំជាង ៣០ ថ្ងៃ | ២,១% | ២,៩% | ២,៧% |
| អនុបាតឥណទានលុបចេញពីបញ្ជី | ០,២% | ០,៣% | ១,៤% |
| ចំនួនការិយាល័យ (រួមបញ្ចូលការិយាល័យកណ្ដាល) | ៨១ | ៨៣ | ៨៣ |
| ចំនួនបុគ្គលិក | ៣.២៩៧ | ៣.៥៣៥ | ៣.៥៩០ |
| ចំនួនអតិថិជនឥណទាន | ៣១៨.៣៥៤ | ៣៤១.៧៥៣ | ៣៣៥.០៨៩ |
| ចំនួនអតិថិជនដាក់ប្រាក់បញ្ញើ | ៤៦២.១២៥ | ៥១៧.៣៤៩ | ៥១០.៩៧២ |

អិលអូអិលស៊ី រក្សាបាននូវលទ្ធផលយ៉ាងល្អប្រសើរ ដោយធ្វើឱ្យប្រសើរឡើងនូវអនុបាតចំណាយប្រតិបត្តិការធៀបនឹងផលប័ត្រឥណទានជាមធ្យម មកត្រឹមតែ ៤,២% (ដែលឆ្នាំ ២០២២ មានចំនួន ៤,៦%) ទោះបីជាមានការកើនឡើងតិចតួចដោយសារតែបម្រែបម្រួលអត្រាប្តូរប្រាក់ក្នុងគ្រា។ ខណៈដែលអនុបាតចំណាយធៀបនឹងចំណូល (រួមបញ្ចូលសំវិធានធន) មានភាពល្អប្រសើរជាងមុន មកត្រឹម៣៩,៩% (ដែលឆ្នាំ ២០២២ មានចំនួន ៤៨,៨%)។

បន្ថែមលើនេះ អិលអូអិលស៊ី រក្សាបាននូវអនុបាតគ្របខណ្ឌសន្ទនីយភាពខ្ពស់ ដែលមានអត្រា ២៧៣,៥% ខណៈដែលតម្រូវការរបស់ធនាគារជាតិនៃកម្ពុជាមានចំនួន១០០% ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២០។ លើសពីនេះទៅទៀត អនុបាតសាធនភាព ក៏ត្រូវបានគ្រប់គ្រងយ៉ាងល្អដែលមានចំនួន ២៤,៧% ខណៈដែលតម្រូវការអប្បបរមារបស់ធនាគារជាតិនៃកម្ពុជាគឺមិនត្រូវតិចជាង ១៥%។

គុណភាពទ្រព្យសកម្មគឺជាចំណុចចម្បងដែលគណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាល ផ្តោតការយកចិត្តទុកដាក់ផងដែរ។ គុណភាពទ្រព្យសកម្មមានភាពល្អជាងមុន ដែលមានអត្រា ២,២% (ដែលឆ្នាំ ២០២២ មានចំនួន ២,៣%)។



# សមិទ្ធផលសំខាន់ៗដែលសម្រេចបានក្នុងឆ្នាំ២០២៣




## អតិថិជន

នៅក្នុងឆ្នាំ២០២៣ មានអតិថិជនថ្មីប្រមាណ ៦០.០០០ នាក់ កំពុងប្រើប្រាស់ផលិតផល និងសេវាកម្មរបស់ អិលអូអិលស៊ី ៦២% នៃអតិថិជនថ្មីជាស្ត្រី ហើយ ៦៩% កំពុងរស់នៅតំបន់ជនបទ។ ភាគច្រើននៃអតិថិជនថ្មីទាំងនោះមានមុខរបរជាកសិករ អ្នកជំនួញ កម្មករ និងបុគ្គលិកបម្រើការងារ ដែលមានអាយុចន្លោះពី ១៨ ដល់ ៥៩ឆ្នាំ។

អិលអូអិលស៊ី (ខេមបូឌា) បន្តផ្តល់នូវផលិតផល និងបរិយាបន្នហិរញ្ញវត្ថុ ដល់ប្រជាជនកម្ពុជាទាំងអស់ ដើម្បីឱ្យពួកគាត់មានលទ្ធភាពទទួលបាននូវសេវាហិរញ្ញវត្ថុផ្លូវការ ដែលនឹងលើកកម្ពស់សកម្មភាពអាជីវកម្ម រកចំណូលបានបន្ថែម និងលើកកម្ពស់គុណភាពជីវិត។

## សកម្មភាព និងផលិតផលថ្មីៗ

នៅក្នុងឆ្នាំ២០២៣ អិលអូអិលស៊ី បន្តធ្វើទំនើបកម្ម និងបានអភិវឌ្ឍផលិតផល និងសេវាហិរញ្ញវត្ថុរបស់ខ្លួន ដូចខាងក្រោម៖

**ការធ្វើទំនើបកម្មលើកម្មវិធីធនាគារចល័ត iPay ជំនាន់ទី៣៖** ដើម្បីធ្វើឱ្យអតិថិជនកាន់តែមានភាពងាយស្រួល អិលអូអិលស៊ី បានបន្តធ្វើទំនើបកម្មលើកម្មវិធីធនាគារចល័ត iPay Cambodia App ជាបន្តបន្ទាប់ដល់ជំនាន់ទី៣ ដែលទំនើបកម្មទាំងនោះត្រូវបានធ្វើទៅលើប្រព័ន្ធសុវត្ថិភាព លក្ខណៈរូបរាង និងមុខងារ ដូចជា៖

- ការទូទាត់ឆ្លងប្រទេស (តាមរយៈ Thai QR)
- អនុញ្ញាតឱ្យអ្នកប្រើប្រាស់ទាញយករូបភាព QR Code ពីរូបថត ដើម្បីធ្វើការទូទាត់
- អាចធ្វើប្រតិបត្តិការផ្ញើប្រាក់ទៅលេខទូរស័ព្ទ
- អាចទាញយកវិញ្ញាបនបត្របញ្ញើមានកាលកំណត់
- បន្ថែមស្លាកយីហោរបស់ អិលអូអិលស៊ី នៅកណ្តាល QR Code ដើម្បីងាយស្រួលចំណាំ
- អនុញ្ញាតឱ្យលេខទូរស័ព្ទនៅក្រៅប្រទេសអាចចុះឈ្មោះប្រើ iPay Cambodia App បាន
- រឹតបន្តឹងមិនអនុញ្ញាតឱ្យ Login ប្រើ iPay Cambodia App ក្នុងឧបករណ៍ច្រើន
- កំណត់តម្រូវឱ្យជ្រើសរើសគោលបំណងសម្រាប់ការធ្វើប្រតិបត្តិការផ្ទេរប្រាក់

**ការជូនដំណឹងអំពីប្រតិបត្តិការតាមរយៈ Telegram៖** ឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជន អិលអូអិលស៊ី បានអភិវឌ្ឍមុខងារការជូនដំណឹងប្រតិបត្តិការតាមរយៈ Telegram ដែលអនុញ្ញាតឱ្យអតិថិជន អិលអូអិលស៊ី អាចប្រើប្រាស់ LOLC Telegram bot ដើម្បីទទួលបានការជូនដំណឹងនៅពេលដែលមានប្រតិបត្តិការចូលក្នុងគណនី។ មុខងារនេះត្រូវបានដាក់ឱ្យអតិថិជនប្រើប្រាស់នៅក្នុងខែមីនា ឆ្នាំ២០២៣។

**ការដាក់ប្រាក់បញ្ញើ/ដកប្រាក់ តាមរយៈការចាប់ដៃគូជាមួយក្រុមហ៊ុន លី ហួរ ផេប្រូ៖** ដើម្បីឱ្យអតិថិជនកាន់តែ មានភាពងាយស្រួល ក៏ដូចជាកាត់បន្ថយការធ្វើដំណើរមកធ្វើប្រតិបត្តិការដោយផ្ទាល់នៅការិយាល័យសាខា អិលអូអិលស៊ី បានសហការជាមួយក្រុមហ៊ុន លី ហួរ ផេប្រូ ក្នុងការអនុញ្ញាតឱ្យអតិថិជនអាចដាក់ប្រាក់បញ្ញើ ចូលទៅក្នុងគណនី អិលអូអិលស៊ី ក៏ដូចជាអាចដកប្រាក់ពីគណនី អិលអូអិលស៊ី របស់ខ្លួន តាមរយៈភ្នាក់ងារ លី ហួរ នៅទូទាំងប្រទេសដោយ អិលអូអិលស៊ី ចេញថ្លៃសេវាប្រតិបត្តិការដាក់ប្រាក់/ដកប្រាក់បញ្ញើជំនួសអតិថិជន។

**សេវាបើកប្រាក់បៀវត្ស៖** សេវាបើកប្រាក់បៀវត្សត្រូវបានដាក់ឱ្យប្រើប្រាស់នៅក្នុងខែឧសភា ឆ្នាំ២០២៣ ដែលអនុញ្ញាតឱ្យម្ចាស់អាជីវកម្ម ក្រុមហ៊ុន ឬគ្រឹះស្ថានអាចគ្រប់គ្រងបៀវត្សបុគ្គលិករបស់ខ្លួនបានដោយខ្លួនឯង តាមរយៈប្រព័ន្ធរបស់ អិលអូអិលស៊ី ហៅថា iPay Enterprise System។ ប្រតិបត្តិការប្រាក់បៀវត្សត្រូវបានធ្វើឡើងដោយមានកាលវិភាគច្បាស់លាស់ ដោយផ្ទេរប្រាក់ពីគណនីចម្បងរបស់ក្រុមហ៊ុន ឬគ្រឹះស្ថាន ទៅគណនីរបស់បុគ្គលិកដែលមាននៅ អិលអូអិលស៊ី។

**ប័ណ្ណ CSS ATM Card៖** នៅក្នុងឆ្នាំ២០២៣ អិលអូអិលស៊ី បានបញ្ចប់គម្រោង CSS EMV ដែលជាគម្រោងមួយជាមួយធនាគារជាតិនៃកម្ពុជា។ មុខងារសំខាន់ៗបីយ៉ាងដែលបានបញ្ចប់ក្នុងគម្រោងនេះ រួមមាន៖

- មុខងារបន្ទះឈីបស្តង់ដារ EMV (ទម្រង់ថ្មី) ដែល CSS CPV ផ្តល់សុពលភាពដោយ FIME បានបន្ថែមទៅក្នុងកាតអេធីអឹមថ្មី ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវសុវត្ថិភាពកាត។
- កាតប្រភេទ Classic និង Premium ត្រូវបានបង្កើតជាកាតពីរប្រភេទដាច់ពីគ្នា ដែលកាតទាំងពីរប្រភេទត្រូវ បានបំពាក់មុខងារឈីបស្តង់ដារ EMV។
- ជម្រើសនៃការស្នើសុំកាតភ្លាមៗត្រូវបានផ្តល់ជូនដើម្បីបំពេញតម្រូវការរបស់អតិថិជន ដូច្នេះអតិថិជន អាចទទួលយកកាត CSS ATM Card របស់ពួកគេភ្លាមៗនៅសាខា អិលអូអិលស៊ី ណាមួយដែលនៅជិតពួកគេបំផុត។

**Chatbot៖** មុខងារសាកសួរព័ត៌មាន និងវិវាទ ត្រូវបានដាក់ឱ្យប្រើប្រាស់នៅលើទំព័រ Facebook, Telegram និងគេហទំព័ររបស់ អិលអូអិលស៊ី។ Chatbot អាចឆ្លើយតបទាំងជាអក្សរ និងសម្លេង ដែលផ្តល់ភាពងាយស្រួល ដល់អតិថិជនក្នុងការសាកសួរព័ត៌មានអំពីផលិតផល សេវាកម្ម ឬក្នុងករណីមានបណ្តឹងតវ៉ាផ្សេងៗ។

# ទស្សនវិស័យសម្រាប់ឆ្នាំ ២០២៤



អិលអូអិលស៊ី (ខេមបូឌា) រំពឹងថានឹងអាចបង្កើនលទ្ធផលការងារសម្រាប់ឆ្នាំ ២០២៤ ដូចមានបង្ហាញខាងក្រោម៖

| | ២០២១ | ២០២២ | ២០២៣ | ប៉ាន់ស្មាន ២០២៤ |
|---|---|---|---|---|
| ផលប័ត្រឥណទានសរុប (ពាន់ដុល្លារ) | ១.០៣៦.២៨០ | ១.២៥៣.០២២ | ១.២៤៦.៥០៧ | ១.៤៤៥.០០០ |
| ចំនួនគណនីប្រាក់កម្ចី | ៣៧៩.៩០៨ | ៤១៤.២៦០ | ៣៩៦.៩១៩ | ៤៣២.៣០០ |
| សមតុល្យប្រាក់បញ្ញើ (ពាន់ដុល្លារ) | ៥៨១.៩៣៧ | ៧៦៧.១៧៤ | ៩០៣.៩១៨ | ១.១៨០.០០០ |
| ចំនួនគណនីប្រាក់បញ្ញើ | ៥៣២.១៦៩ | ៦០៩.៦៥១ | ៦២០.៨៤០ | ៧៥៤.៦៥០ |
| ចំនួនការិយាល័យ (រួមទាំងការិយាល័យកណ្តាល) | ៨១ | ៨៣ | ៨៣ | ៨៤ |
| ចំនួនបុគ្គលិក | ៣.២៩៧ | ៣.៥៣៥ | ៣.៥៩០ | ៣.៧៣២ |



# ០៣.

# អភិបាលកិច្ច


## រចនាសម្ព័ន្ធនៃការគ្រប់គ្រង ( ៥២ )

## គោលនយោបាយ និងការអនុវត្តសម្រាប់ អភិបាលកិច្ចសាជីវកម្ម ( ៥៤ )

- ក្រុមប្រឹក្សាភិបាល
- គណៈកម្មាធិការសវនកម្ម
- គណៈកម្មាធិការគ្រប់គ្រងហានិភ័យសហគ្រាស និងប្រតិបត្តិតាម
- គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការ
- គណៈកម្មាធិការ IT STEERING

## របាយការណ៍ក្រុមប្រឹក្សាភិបាល ( ៦៦ )

## ក្រមសីលធម៌ ( ៦៨ )

## ការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង ( ៧០ )

## ការអភិវឌ្ឍធនធានមនុស្ស ( ៧៨ )

- សារៈសំខាន់នៃកសាងសមត្ថភាពបុគ្គលិក
- គោលការណ៍បរិយាប័ន្ន
- ការលើកទឹកចិត្ត និងរង្វាន់
- ការវាយតម្លៃការអនុវត្តការងារ

## គណៈគ្រប់គ្រង ( ៨០ )




# រចនាសម្ព័ន្ធនៃការគ្រប់គ្រង



# គោលនយោបាយ និងការអនុវត្តសម្រាប់អភិបាលកិច្ចសាជីវកម្ម



## ក្រុមប្រឹក្សាភិបាល

### សមាសភាព

ក្រុមប្រឹក្សាភិបាលបច្ចុប្បន្នមានសមាជិកចំនួន ០៥រូប ក្នុងនោះមានអភិបាលឯករាជ្យចំនួន ០២រូប។ ក្រុមប្រឹក្សាភិបាល (BOD) របស់ អិលអូអិលស៊ី (ខេមបូឌា) គឺជាក្រុមដែលមានភាពស្វាហាប់ និងមានសមត្ថភាព ហើយពោរពេញទៅ ដោយបទពិសោធន៍ និងជំនាញផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ និងជំរុញកំណើនអាជីវកម្ម។ ក្រុមប្រឹក្សាភិបាលបានអះអាងទៅលើចំនួនអភិបាលឯករាជ្យដែលនាំមកនូវការវិនិច្ឆ័យរឹងមាំ និងមានភាពឯករាជ្យដល់ការពិភាក្សារបស់ក្រុមប្រឹក្សាភិបាលលើយុទ្ធសាស្ត្រ សវនកម្ម សមិទ្ធផលការងារ និងហានិភ័យ។

រចនាសម្ព័ន្ធ និងសមាសភាពនៃក្រុមប្រឹក្សាភិបាល គឺស្របតាមប្រកាសដែលចេញដោយធនាគារជាតិនៃកម្ពុជា។ ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម៖

| ឈ្មោះ | មុខតំណែង |
|---|---|
| លោក Brindley Chrishantha Gajanayake de Zylva (Brindley de Zylva) | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក Francisco Kankanamalage Conrad Prasad Nirosh Dias (Conrad Dias) | អភិបាល |
| លោក Dulip Rasika Samaraweera (Dulip Samaraweera) | អភិបាល |
| លោក Hans Michael Theodor Moormann (Michael Moormann) | អភិបាលឯករាជ្យ<br>- លាលែងតំណែងមានប្រសិទ្ធភាព ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ |
| លោក Indrajith Wijesiriwardana | អភិបាលឯករាជ្យ |
| លោក Chitral Nalin Wijesinha | អភិបាលឯករាជ្យ<br>- តែងតាំងនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤ |





## ប្រវត្តិរូប



### លោក BRINDLEY DE ZYLVA

**ប្រធានក្រុមប្រឹក្សាភិបាល**

លោក de Zylva ជាប្រធានក្រុមប្រឹក្សាភិបាលរបស់ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី និង អិលអូអិលស៊ី ហ្វាយនែន ភីអិលស៊ី នៅប្រទេសស្រីលង្កា។ លោកក៏ជាអគ្គនាយកគ្រប់គ្រងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលធីឌី មីយ៉ាន់ម៉ា ផងដែរ។ មុនពេលទទួលតំណែងជាប្រធានក្រុមប្រឹក្សាភិបាលរបស់ អិលអូអិលស៊ី (ខេមបូឌា) លោកមានបទពិសោធន៍ជាច្រើននៅក្រៅប្រទេសក្នុងមុខតំណែងជាក្រុមប្រឹក្សាភិបាល និងអគ្គនាយកគ្រប់គ្រងទូទៅរយៈពេល ៣៧ឆ្នាំ ដែលបានបម្រើការក្នុងវិស័យសេវាហិរញ្ញវត្ថុមិនមែនធនាគារ ទាំងនៅក្រុមហ៊ុនហិរញ្ញវត្ថុមានអាជ្ញាបណ្ណ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនឯកទេសភតិសន្យា។ លោកមានបទពិសោធន៍ទូលំទូលាយ និងមានឯកទេសជុំវិញវិស័យសេវាហិរញ្ញវត្ថុមិនមែនធនាគារដូចជា ការគ្រប់គ្រងឥណទាន និងដោះស្រាយបំណុល ហិរញ្ញវត្ថុ ទីផ្សារ និងការលក់។ លោក de Zylva ជាសមាជិកម្នាក់នៃវិទ្យាស្ថានគ្រប់គ្រងឥណទានស្រីលង្កា ហើយក្រោយមកលោកត្រូវបានជ្រើសតាំងជាលេខាធិការកិត្តិយសក្នុងការបោះឆ្នោតនៅវិទ្យាស្ថាននៅឆ្នាំ២០១០។ ជាមួយគ្នានេះផងដែរ លោកក៏ធ្លាប់ជាសមាជិកក្រុមប្រឹក្សាគ្រប់គ្រងសមាគមហិរញ្ញប្បទានលំនៅស្ថាននៅប្រទេសស្រីលង្កាអស់រយៈពេល ៩ឆ្នាំ ដែលក្នុងនោះរយៈពេល៤ឆ្នាំ លោកបានកាន់តំណែងជាអនុប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលរបស់ក្រុមហ៊ុន Financial Ombudsman Sri Lanka (Guarantee) Limited នៅក្នុងប្រទេសស្រីលង្កា។ នៅឆ្នាំ២០១៥ លោក de Zylva ត្រូវបានតែងតាំងតំណែងទាំងអស់នេះ ដើម្បីមើលការខុសត្រូវការងារប្រចាំតំបន់សម្រាប់ក្រុមហ៊ុនរបស់ អិលអូអិលស៊ី គ្រុបនៅប្រទេសមីយ៉ាន់ម៉ា និងកម្ពុជា។



### លោក CONRAD DIAS

**អភិបាល**

មុនពេលទទួលបានមុខតំណែងបច្ចុប្បន្ន លោក Dias ធ្លាប់ជាអតីតនាយកបច្ចេកវិទ្យាព័ត៌មាន និងអភិបាលនៃក្រុមហ៊ុន អិលអូអិលស៊ី ហូលឌីង ភីអិលស៊ី ជាអភិបាល/អគ្គនាយកគ្រប់គ្រងនៃក្រុមហ៊ុន អិលអូអិលស៊ី ហ្វាយនែន ភីអិលស៊ី និងជាស្ថាបនិកនៃកម្មវិធីទូរសព្ទចល័តអាយផេ។ លោកបានបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ Leicester។ លោកជាសមាជិកនៃ Chartered Institute of Management Accountants ដែលជា Chartered Global Management Account ជាសមាជិកនៃ British Computer Society និងជាសមាជិកនៃ Certified Management Accountant ក្នុងប្រទេសស្រីលង្កា។ លោក Dias បានចូលរួមចំណែកជាមួយ អិលអូអិលស៊ី គ្រុប និងវិស័យព័ត៌មានវិទ្យាក្នុងស្រុកជាមួយនឹងបទពិសោធន៍ ៣០ឆ្នាំ របស់គាត់ ហើយលោកមានជំនាញទៅលើវិស័យជាច្រើនដូចជា ពាណិជ្ជកម្ម ធនាគារ និងហិរញ្ញវត្ថុ ការគ្រប់គ្រងទ្រព្យសកម្ម និងផលិតកម្ម។ ដោយមានការទទួលស្គាល់នូវស្នាដៃរបស់លោកក្នុងការរួមចំណែកជាមួយក្រុមហ៊ុន លោកទទួលបានពានរង្វាន់ CSSL CIO Award នៅក្នុងឆ្នាំ២០១៦ និងពានរង្វាន់ Professional Excellence Avard នៅក្នុងឆ្នាំ២០១៧ ក្នុងព្រឹត្តិការណ៍ដែលរៀបចំឡើងដោយ Certified I Management Accountants នៃប្រទេសស្រីលង្កា។ នៅក្នុងឆ្នាំ២០២០ ជាឆ្នាំដែលលោកមានកិត្តិយសបំផុត ដោយលោកត្រូវបានអញ្ជើញឱ្យចូលរួមកម្មវិធី Global CIO Hall of Fame ២០២០ និងជាអ្នកឈ្នះពានរង្វាន់ Global CIO100 ប្រចាំឆ្នាំ២០២០ ពីអាយឌីជីសហរដ្ឋអាមេរិក (IDG USA)។



## លោក DULIP SAMARAWEERA

**អភិបាល**

លោក Samaraweera ជាអភិបាលនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី។ លោកមានសញ្ញាបត្រវិទ្យាសាស្ត្របរិទ្យាជំនាញឯកទេសផ្នែកស្ថិតិពីសកលវិទ្យាល័យ Sri Jayavardenepura។ លោកក៏បានប្រលងបញ្ចប់ការសិក្សាពីវិទ្យាស្ថាន Chartered Institute of Accountant នៅចក្រភពអង់គ្លេស។ ក្នុងឆ្នាំ២០១៤ លោក Samaraweera បានចាប់ផ្តើមអាជីពរបស់ខ្លួនលើការស្រាវជ្រាវការវិនិយោគ និងបានចូលបម្រើការជាមួយ អិលអូអិលស៊ី គ្រុប នៅ៣ឆ្នាំក្រោយ។ ក្រោយមកលោកបានបម្រើការជាអភិបាលនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី មីយ៉ាន់ម៉ា។ លោកមានជំនាញ និងបទពិសោធន៍ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ ការកែលម្អដំណើរការផ្សេងៗ ការធ្វើផែនការយុទ្ធសាស្ត្រការវិនិយោគ និងការទិញយកភាគហ៊ុនក្រុមហ៊ុន។



## លោក INDRAJITH WIJESIRIWARDANA

**អភិបាលឯករាជ្យ**

លោក Wijesiriwardana បច្ចុប្បន្នជាអភិបាលឯករាជ្យរបស់ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី។ ជាមួយបទពិសោធន៍ជាង២០ឆ្នាំ មកពីជិត ៣០ប្រទេស លោក Wijesirivardana ក៏ជាទីប្រឹក្សាផ្តល់យោបល់មានជំនាញខ្ពស់លើផ្នែកអភិវឌ្ឍហិរញ្ញវត្ថុអន្តរជាតិផងដែរ។ បទពិសោធន៍របស់គាត់គ្របដណ្តប់លើជំនាញនៃផ្នែកសំខាន់ៗរួមទាំងការកសាងសមត្ថភាព ក្នុងវិស័យហិរញ្ញវត្ថុ និងហិរញ្ញប្បទានសម្រាប់សហគ្រាសមីក្រូខ្នាតតូច និងមធ្យម (MSME)។ មិនត្រឹមតែប៉ុណ្ណោះ លោកមានជំនាញច្បាស់លាស់លើការរៀបចំអាជីវកម្ម និងយុទ្ធសាស្ត្រ ការអភិវឌ្ឍប្រព័ន្ធបរិយាប័ន្ន ហិរញ្ញវត្ថុ ការអភិវឌ្ឍសមត្ថភាពការងារក្នុងស្ថាប័នហិរញ្ញវត្ថុ ដោយផ្តោតទៅលើសហគ្រាសមីក្រូខ្នាតតូច និងមធ្យម បរិវត្តកម្មស្ថាប័ន ការរចនាផលិតផល និងការកែលម្អដំណើរការ។ អំឡុងពេលលោកបម្រើការនៅក្នុងវិស័យធនាគារ លោកធ្លាប់បានរៀបចំ និងវាយតម្លៃសំណើគម្រោង និងត្រួតពិនិត្យគម្រោងនានាមុនពេលលោកបម្រើការជាទីប្រឹក្សាផ្តល់យោបល់។ ក្នុងអំឡុងពេលនោះ លោកមានការទទួលខុសត្រូវចំពោះហិរញ្ញប្បទានឥណទានសម្រាប់សហគ្រាសខ្នាតតូច មធ្យម និងខ្នាតធំ ហិរញ្ញប្បទានពាណិជ្ជកម្ម ហិរញ្ញប្បទានមូលធន ការរៀបចំឥណទានឡើងវិញ ការប្រមូលផ្តុំ ប្រាក់កម្ចីពីម្ចាស់កម្ចីផ្សេងៗ និងការធ្វើភតិសន្យាហិរញ្ញវត្ថុ។ លោកក៏ទទួលបន្ទុកការងារទៅលើការគ្រប់គ្រង និងបង្កើតសេវាគាំទ្រហិរញ្ញវត្ថុរួមមាន គ្រប់គ្រងថវិកា ការត្រួតពិនិត្យ ការរៀបចំគម្រោង ការត្រួតពិនិត្យគណនេយ្យ និងប្រព័ន្ធគ្រប់គ្រងព័ត៌មាន (MIS) ។ គាត់ក៏បានទទួលបន្ទុកគ្រប់គ្រង និងអភិវឌ្ឍសេវាកម្មជំនួយហិរញ្ញវត្ថុរួមទាំងថវិកា និងការធ្វើផែនការគណនេយ្យ និងMIS។ លោក Wijesiriwardana បានចូលបម្រើការជាមួយ LOLC (Cambodia) Plc ក្នុងខែមករា ឆ្នាំ២០១៥។



## លោក CHITRAL NALIN WIJESINHA - តែងតាំងនៅថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០២៤

**អភិបាលឯករាជ្យ**

លោក Wijesinha ជាអភិបាលឯករាជ្យរបស់ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី។ លោកមានបទពិសោធន៍ជាង ២៧ឆ្នាំ នៅក្នុងវិស័យសេវាកម្មហិរញ្ញវត្ថុ និងគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់អតិថិជន ទាំងការវិនិយោគចំនួនតិច និងចំនួនច្រើន។ លោកមានចំណេះដឹង និងជំនាញយ៉ាងទូលំទូលាយក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ ដែលមានជំនាញឯកទេសផ្នែកវិនិយោគ និងការរៀបចំផែនការចូលនិវត្តន៍ ប្រាក់សោធននិវត្តជាក្រុម និងប្រាក់សោធននិវត្តដោយស្ម័គ្រចិត្ត (KiwiSaver - Superannuation)។ ចំណេះដឹងរបស់លោកលើវិស័យសហគ្រាសបច្ចុប្បន្ន បទប្បញ្ញត្តិ/ច្បាប់ និងតម្រូវការទីផ្សារ គួបផ្សំនឹងការយល់ដឹងច្រើនអំពីទីផ្សារបច្ចុប្បន្ន អាចឱ្យលោកអនុវត្តការងាររបស់លោកបានស្តង់ដារខ្ពស់។ បច្ចុប្បន្នលោកកំពុងបម្រើការជាអភិបាល/ម្ចាស់ភាគហ៊ុន និងជាទីប្រឹក្សាផ្នែកហិរញ្ញវត្ថុសំខាន់នៅក្រុមហ៊ុន Trilogy Financial Solutions NZ Limited (TFS)។ ក្រៅពីនេះ លោកក៏ជាសមាជិកនៃ Wealthpoint Financial Adviser Provider (FAP) ដែលជាបណ្តាញអ្នកផ្តល់ប្រឹក្សាផ្នែកហិរញ្ញវត្ថុ ហើយលោកក៏មានអាជ្ញាប័ណ្ណក្នុងការផ្តល់ប្រឹក្សានៅក្នុងប្រទេសនូវែលសេឡង់។ លោកក៏ជាសមាជិកយ៉ាងសកម្មនៃគណៈកម្មាធិការវិនិយោគ របស់ Wealthpoint ផងដែរ។ មុនពេលបម្រើការជាអ្នកផ្តល់ប្រឹក្សាហិរញ្ញវត្ថុ លោក Chitral ធ្លាប់បម្រើការនៅធនាគារ Citibank ជាភ្នាក់ងារជួញដូររូបិយប័ណ្ណ ទីផ្សារវិនិយោគសាច់ប្រាក់ និងប័ណ្ណបំណុល នៅក្នុងការចូលទីផ្សារមូលដ្ឋាន និងទីផ្សារជួញដូរ។ លោកធ្លាប់បម្រើការក្នុងមុខតំណែងជាហេរញ្ញិកប្រចាំប្រទេស នៅធនាគារ Citibank ក្នុងប្រទេសស្រីលង្កា និងជាសមាជិកនៃគណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងបំណុល (ALCO) ដែលទទួលខុសត្រូវលើការគ្រប់គ្រងសន្ទនីយភាព មូលធន និងតារាងតុល្យការរបស់ធនាគារ (ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ ២០០៣)។



## លោក MICHAEL MOORMANN - លាលែងតំណែងមានប្រសិទ្ធភាពចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤

**អភិបាលឯករាជ្យ**

លោក Moormann ជាអភិបាលឯករាជ្យរបស់ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី។ លោកមានបទពិសោធន៍ចម្រុះក្នុងមុខតំណែងផ្សេងៗ និងបានធ្វើការនៅតាមប្រទេសផ្សេងៗជាច្រើនមុនពេលទទួលបានមុខតំណែងគ្រប់គ្រងជាន់ខ្ពស់របស់លោក។ លោកមានជំនាញរឹងមាំក្នុងការគ្រប់គ្រងការផ្លាស់ប្តូរ ការគ្រប់គ្រងធនធានមនុស្ស និងជំនាញ សវនកម្មផ្ទៃក្នុង។ នៅឆ្នាំ១៩៧១ លោកបានចាប់ផ្តើមអាជីពរបស់គាត់នៅផ្នែកបរទេសជាមួយធនាគារ ABN AMRO ប្រទេសហូឡង់។ ២ឆ្នាំក្រោយមកនៅឆ្នាំ១៩៧៣ លោកបានផ្លាស់ការងារទៅប្រទេសឥណ្ឌូនេស៊ី។ នៅឆ្នាំ១៩៩២ លោកបានចាប់ផ្តើមការងារជាប្រធានគ្រប់គ្រងប្រចាំតំបន់នៃធនាគារឯកជនរបស់AB AMRO នៅអាមេរិកឡាទីន បន្ទាប់មកចាប់តាំងពីឆ្នាំ១៩៩៤ លោកបានក្លាយទៅជាប្រធានគ្រប់គ្រងប្រចាំប្រទេសនៃធនាគារ AB AMRO នៅក្នុងប្រទេសផ្សេងៗទៀតមួយចំនួនដូចជា ស្រីលង្កា ហ្វីលីពីន និងវៀតណាម។ បន្ទាប់ពីបទពិសោធន៍ការងាររយៈពេល ១១ ឆ្នាំនេះមក លោកបានបន្តបំពេញការងារប្រឹក្សាយោបល់ផ្សេងៗក្នុងវិស័យមីក្រូហិរញ្ញវត្ថុចាប់ពីឆ្នាំ២០០៥ ។ នៅខែកុម្ភៈ ឆ្នាំ២០១៣ លោកបានចូលបម្រើការងារជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី។

## ការជ្រើសរើសក្រុមប្រឹក្សាភិបាល

អភិបាលអាចជារូបវន្តបុគ្គលដែលមានសមត្ថភាព មានអាយុយ៉ាងតិច ១៨ ឆ្នាំ។ អភិបាលមិនចាំបាច់ជាម្ចាស់ភាគហ៊ុនទេ។

នៅក្នុងមហាសន្និបាតម្ចាស់ភាគហ៊ុនគ្រប់រូបត្រូវបោះឆ្នោតជ្រើសតាំងអភិបាល។ អភិបាលត្រូវបានតែងតាំងតាមរយៈសេចក្ដីសម្រេចរបស់ម្ចាស់ភាគហ៊ុនដែលអនុម័តដោយសម្លេងភាគច្រើន។ សមាជិកម្នាក់ក្នុងចំណោមសមាជិករបស់ខ្លួននឹងត្រូវតែងតាំងជាប្រធាន ក្រុមប្រឹក្សាភិបាល ដោយធ្វើតួនាទីដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងមហាសន្និបាតប្រចាំឆ្នាំ។

រាល់សមាជិកនៃក្រុមប្រឹក្សាភិបាលទាំងអស់ ត្រូវទទួលបាននូវការអនុម័តពីធនាគារជាតិនៃកម្ពុជា។

### ដំណើរការតែងតាំង




*(១) - MOC - ក្រសួងពាណិជ្ជកម្ម*
*(២) - GDT - អគ្គនាយកដ្ឋានពន្ធដារ*
*(៣) - NBC -ធនាគារជាតិនៃកម្ពុជា។*

### កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

ជាទូទៅកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ប្រព្រឹត្តទៅរៀងរាល់ត្រីមាស។ នៅក្នុងកិច្ចប្រជុំនីមួយៗ ក្រុមប្រឹក្សាភិបាលត្រួតពិនិត្យលទ្ធផលការងាររបស់ក្រុមហ៊ុន។ ក្រុមប្រឹក្សាភិបាលក៏ត្រូវបានជូនដំណឹងអំពីការអភិវឌ្ឍនៅក្នុងវិស័យហិរញ្ញវត្ថុ ដូចជា ការផ្លាស់ប្ដូរលក្ខន្តិកៈ ឬ បទប្បញ្ញត្តិ និងសក្ដានុពលនៃផលប៉ះពាល់ពីការផ្លាស់ប្ដូរទាំងនោះមកលើក្រុមហ៊ុន។

បន្ថែមពីលើការពិនិត្យឡើងវិញ និងពិភាក្សាជាទៀងទាត់ លើឯកសារក្រុមប្រឹក្សាភិបាល ដែលរាយការណ៍អំពី លទ្ធផលការងារ និងអនុលោមភាព ក្រុមប្រឹក្សាភិបាលក៏ពិនិត្យ និងពិភាក្សារបាយការណ៍ពិសេសរបស់ក្រុមប្រឹក្សាភិបាលដែលដោះស្រាយបញ្ហាដែលមិនមែនជាប្រតិបត្តិការប្រចាំថ្ងៃផងដែរ។

### ការទទួលខុសត្រូវចម្បងរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវពេញលេញក្នុងការដឹកនាំ គ្រប់គ្រង ណែនាំ និងត្រួតពិនិត្យការអនុវត្តជារួមរបស់គ្រឹះស្ថាន និងពង្រឹងស្តង់ដារគណនេយ្យភាពផងដែរ ដែលទាំងអស់នេះមានគោលដៅអាចអនុញ្ញាតឱ្យគណៈគ្រប់គ្រងអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយប្រសិទ្ធភាព។

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវសំខាន់បំផុតក្នុងការបង្កើតក្របខណ្ឌអភិបាលកិច្ចសាជីវកម្មល្អសម្រាប់គ្រឹះស្ថាន រួមទាំងរបាយការណ៍ផ្នែកហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យ និងដំណើរការអនុលោមភាព។

ទាក់ទងនឹងយុទ្ធសាស្ត្រ ការអនុវត្ត ធនធាន និងការប្រព្រឹត្តទៅនៃអាជីវកម្ម សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់រួមចំណែកហើយផ្ដល់នូវការវិនិច្ឆ័យឯករាជ្យ ជំនាញនិងបទពិសោធន៍ទូលំទូលាយរបស់ខ្លួនសម្រាប់ក្រុមប្រឹក្សាភិបាលទាំងមូល។

- អនុម័តផែនការអាជីវកម្ម និងយុទ្ធសាស្ត្រអាជីវកម្មសម្រាប់គ្រឹះស្ថាន។
- ត្រួតពិនិត្យវិធានការលើការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (AML/CFT)។
- អនុម័តការបើក និងបិទគណនីធនាគារ និងកំណត់ទំហំទឹកប្រាក់ដែលអនុញ្ញាត និងហត្ថលេខីប្រតិស្រុតសម្រាប់គណនីធនាគារ។
- អនុម័តលើគោលនយោបាយលាភការសម្រាប់គណៈគ្រប់គ្រង និងនិយោជិត។
- ជ្រើសរើស ត្រួតពិនិត្យ និងស្វែងរកបេក្ខជនដើម្បីជំនួសនាយកប្រតិបត្តិសំខាន់ៗដែលលាលែងតំណែង។
- ជ្រើសតាំងសមាជិកក្រុមប្រឹក្សាភិបាល។
- អនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មប្រចាំឆ្នាំ។
- អនុម័តលើប្រាក់កម្ចីដែល អិលអូអិលស៊ី (ខេមបូឌា) ខ្ចីពីម្ចាស់កម្ចី។
- ស្នើដល់ម្ចាស់ភាគហ៊ុនក្នុងការៈ
  - បង្កើន ឬបន្ថយដើមទុន
  - ជ្រើសរើស និងតែងតាំងសវនករឯករាជ្យ
  - កែប្រែអនុស្សរណៈ និងលក្ខន្តិកៈក្រុមហ៊ុន
  - រំលាយ ឬជម្រះបញ្ជីក្រុមហ៊ុន
  - ប្រកាសភាគលាភ
  - ទិញ លក់ ឬដោះដូរ អចលនទ្រព្យ ឬការទិញម៉ាកពាណិជ្ជកម្ម (Franchise) ដែលមានតម្លៃលើសពី ៥00.000 ដុល្លារអាមេរិក
  - ដាក់បញ្ចាំនូវអចលនវត្ថុរបស់ក្រុមហ៊ុន ឬបន្ទុកលើទ្រព្យ ឬការជួលសិទ្ធិប្រើប្រាស់ម៉ាកពាណិជ្ជកម្ម ឬមូលនិធិពាណិជ្ជកម្ម។

### កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

| សមាជិក | កាលបរិច្ឆេទនៃការតែងតាំង | ចំនួនកិច្ចប្រជុំ | |
|---|---|---|---|
| | | បានចូលរួម | ប្រារព្ធឡើង |
| លោក Brindley de Zylva<br>ប្រធានក្រុមប្រឹក្សាភិបាល | ១៥ តុលា ២០១៥ | ៤ | ៤ |
| លោក Conrad Dias<br>អភិបាល | ១២ កុម្ភៈ ២០១៨ | ៤ | ៤ |
| លោក Dulip Samaraweera<br>អភិបាល | ០២ កក្កដា ២០១៨ | ៤ | ៤ |
| លោក Michael Moormann<br>អភិបាលឯករាជ្យ | ០១ កុម្ភៈ ២០១៣ | ៤ | ៤ |
| លោក Indrajith Wijesiriwardana<br>អភិបាលឯករាជ្យ | ០១ មករា ២០១៥ | ៤ | ៤ |

### កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

| ល.រ | សមាជិក | នីតិវិធីវាយតម្លៃ | លក្ខណៈវិនិច្ឆ័យ |
|---|---|---|---|
| ១ | ក្រុមប្រឹក្សាភិបាល | អភិបាលនីមួយៗត្រូវវាយតម្លៃការអនុវត្តរបស់ក្រុមប្រឹក្សាភិបាល ដោយផ្ដល់ពិន្ទុ (១-៥) ចំពោះលក្ខណៈវិនិច្ឆ័យនីមួយៗ ហើយចុះហត្ថលេខាលើទម្រង់វាយតម្លៃ។ បន្ទាប់ពីការវាយតម្លៃលេខាធិការក្រុមហ៊ុននឹងចងក្រងលទ្ធផលនៃការវាយតម្លៃទាំងអស់សម្រាប់ការពិភាក្សាក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។ | • សមាសភាពក្រុមប្រឹក្សាភិបាល<br>• ការត្រួតពិនិត្យគណៈគ្រប់គ្រង<br>• ស្វែងយល់ពីវប្បធម៌ និងអាជីវកម្មរបស់ក្រុមហ៊ុន<br>• ការប្រព្រឹត្តទៅនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាល |
| ២ | អភិបាល | អភិបាលម្នាក់ៗត្រូវវាយតម្លៃដោយខ្លួនឯង ដោយផ្ដល់ពិន្ទុ (១-៥) ចំពោះលក្ខណៈវិនិច្ឆ័យនីមួយៗ ហើយចុះហត្ថលេខាលើទម្រង់វាយតម្លៃ។ លេខាធិការក្រុមហ៊ុននឹងទទួលបានទម្រង់វាយតម្លៃទាំងអស់ ដើម្បីចងក្រង លទ្ធផលសម្រាប់ពិភាក្សានៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។ | គុណភាពការងាររបស់អភិបាល |

## ឯករាជ្យភាព និងតម្លាភាព

ក្រុមប្រឹក្សារបស់ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី ជាអភិបាលមិនប្រតិបត្តិ ហើយអភិបាល ២រូបក្នុងចំណោម ៥រូបជាអភិបាលឯករាជ្យ។ រចនាសម្ព័ន្ធ និងសមាសភាព នៃក្រុមប្រឹក្សាភិបាលអនុលោមតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ប្រកាសស្តីពីអភិបាលកិច្ចសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ប្រកាសស្តីពីការគ្រប់គ្រងផ្ទៃក្នុង សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងប្រកាសស្តីពី លក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្របសម្រាប់បុគ្គល ដាក់ពាក្យស្នើសុំ និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ។

| ក្រុមប្រឹក្សាភិបាលឯករាជ្យដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងសកម្ម | ប្រតិបត្តិតាម |
|---|---|
| វិនិច្ឆ័យត្រឹមត្រូវ និងសមស្រប ដោយធនាគារជាតិនៃកម្ពុជា ឆ្លងកាត់ដំណើរការលក្ខខណ្ឌ | ✓ |
| សមាជិកក្រុមប្រឹក្សាភិបាលត្រូវចូលរួមប្រជុំយ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ | ✓ |
| សមាជិកក្រុមប្រឹក្សាភិបាលត្រូវធ្វើការវិនិច្ឆ័យប្រកបដោយភាពត្រឹមត្រូវ | ✓ |
| គណៈកម្មាធិការសវនកម្មត្រូវដឹកនាំដោយសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យដែលមានជំនាញផ្នែកហិរញ្ញវត្ថុ និងគណនេយ្យ | ✓ |
| **តម្លាភាព** | **សមាជិក** |
| ការបង្ហាញដល់សាធារណជន៖<br>• រចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង<br>• រចនាសម្ព័ន្ធកម្មសិទ្ធិជាមូលដ្ឋាន<br>• រចនាសម្ព័ន្ធក្រុមហ៊ុនមេ និងកម្មសិទ្ធិភាគហ៊ុនប្រសិនបើមាន<br>• ក្រមប្រតិបត្តិ ឬក្រមសីលធម៌<br>• របាយការណ៍ប្រចាំឆ្នាំ<br>• របាយការណ៍ដែលបានធ្វើសវនកម្ម | ✓ |
| **ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម** | **ប្រតិបត្តិតាម** |
| អភិបាលក្រុមហ៊ុនត្រូវអនុម័តរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ហើយការអនុម័តត្រូវបង្ហាញតាមរយៈហត្ថលេខារបស់ក្រុមប្រឹក្សាភិបាលមួយរូប ឬច្រើនរូប។ | ✓ |
| ក្រុមហ៊ុនមិនត្រូវចេញផ្សាយ បោះពុម្ព ឬចែករំលែកច្បាប់ចម្លងនៃរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឡើយ លុះត្រាតែរបាយការណ៍ហិរញ្ញវត្ថុនោះត្រូវបានអនុម័តរួចរាល់ ដោយអភិបាលភ្ជាប់ជាមួយរបាយការណ៍របស់សវនករ។ | ✓ |
| ការកោះប្រជុំ៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងយ៉ាងហោចណាស់ម្តងក្នុងមួយត្រីមាស (៣ ខែ)។ ការអនុម័តរបស់ក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងតាមរយៈការបោះឆ្នោតសំឡេងភាគច្រើននៃសមាជិកក្រុមប្រឹក្សាភិបាល ឬអ្នកតំណាងដែលមានវត្តមាននៅក្នុងកិច្ចប្រជុំ។ | ✓ |

## គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលបានតែងតាំងគណៈកម្មាធិការចំនួន ៤ ដូចខាងក្រោម៖
- គណៈកម្មាធិការសវនកម្ម
- គណៈកម្មាធិការគ្រប់គ្រងហានិភ័យសហគ្រាស និងប្រតិបត្តិតាម
- គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការ
- គណៈកម្មាធិការ IT Steering

គណៈកម្មាធិការទាំងបួនអនុវត្តតាមគោលការណ៍ណែនាំរបស់ខ្លួន ឬលក្ខខណ្ឌ និងទំនួលខុសត្រូវដែលបានអនុម័ត ហើយប្រើប្រាស់របៀបវារៈដែលបានអនុម័តជាមុនដើម្បីគ្របដណ្តប់ចំណុចសំខាន់ៗទាំងអស់ ក៏ដូចជាលើកទឹកចិត្តដល់សមាជិកគណៈកម្មាធិការឱ្យពិភាក្សាអំពីកង្វល់បន្ថែមណាមួយ។

ក្រុមប្រឹក្សាភិបាលបានផ្តល់សិទ្ធិអំណាចដល់គណៈកម្មាធិការក្នុងការស្នើសុំព័ត៌មានបន្ថែម និងអាចសាកសួរគណៈគ្រប់គ្រង ឬបុគ្គលិកផ្សេងទៀតឱ្យផ្តល់ព័ត៌មានលម្អិត ឬដើម្បីពិភាក្សាអំពីសកម្មភាពដែលបានណែនាំ។ ដូច្នេះ ការងារនេះផ្តល់ទំនុកចិត្តដល់ក្រុមប្រឹក្សាភិបាលថាបញ្ហាទាក់ទងនឹងប្រតិបត្តិការ ហានិភ័យ អភិបាលកិច្ច ឬបទប្បញ្ញត្តិនឹងត្រូវបានពិភាក្សាយ៉ាងហ្មត់ចត់ ហើយកំណត់រកដំណោះស្រាយល្អបំផុត។

កំណត់ហេតុកិច្ចប្រជុំរបស់គណៈកម្មាធិការត្រូវបានកត់ត្រាក្នុងអំឡុងពេលកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។ ហេតុនេះ ក្រុមប្រឹក្សាភិបាលទាំងអស់បានដឹងអំពីកិច្ចពិភាក្សានៅក្នុងគណៈកម្មាធិការនីមួយៗ ហើយអាចចូលរួមគំនិតយោបល់នៅពេល និងកន្លែងដែលចាំបាច់។

## ការវាយតម្លៃគណៈកម្មាធិការនីមួយៗ

| តម្លាភាព | សមាជិក |
|---|---|
| សមាជិកគណៈកម្មាធិការនីមួយៗវាយតម្លៃការងាររបស់គណៈកម្មាធិការដែលខ្លួនជាសមាជិក ដោយផ្តល់ពិន្ទុ (១-៥) ចំពោះលក្ខណៈវិនិច្ឆ័យនីមួយៗហើយចុះហត្ថលេខាលើទម្រង់វាយតម្លៃ។ លេខាធិការក្រុមហ៊ុននឹងចងក្រងលទ្ធផលទាំងនោះសម្រាប់ពិភាក្សានៅក្នុងកិច្ចប្រជុំគណៈកម្មាធិការនីមួយៗបន្ទាប់ពីការពិនិត្យ។ | • ដែនសមត្ថកិច្ចនៃគណៈកម្មាធិការ<br>• ធនធាន និងការរៀបចំ<br>• គុណភាពនៃកាតព្វកិច្ច |

## គណៈកម្មាធិការសវនកម្ម

### សមាសភាព

គណៈកម្មាធិការសវនកម្មត្រូវបានដឹកនាំដោយអភិបាលឯករាជ្យ មានបទពិសោធន៍ផ្នែកហិរញ្ញវត្ថុ គណនេយ្យ និងច្បាប់។ ប្រធានគណៈកម្មាធិការសវនកម្ម មិនអាចជាប្រធានក្រុមប្រឹក្សាភិបាលទេ។ ដែលការអនុវត្តនេះ ធ្វើឡើងដើម្បីជំរុញក្រុមប្រឹក្សាភិបាលឱ្យមានការពិភាក្សាយ៉ាងសកម្ម និងបើកចំហលើប្រធានបទដែលគណៈកម្មាធិការសវនកម្មបានផ្តល់ឱ្យ។

ចំណេះដឹងទូលំទូលាយរបស់ លោក Moormann ក្នុងកិច្ចការហិរញ្ញវត្ថុ គឺជាលក្ខណសម្បត្តិដ៏មានតម្លៃ សម្រាប់ការដឹកនាំ គណៈកម្មាធិការសវនកម្ម និងស្របតាមការអនុវត្តដ៏ល្អនៃអភិបាលកិច្ចសាជីវកម្មរបស់យើង។

### ភារកិច្ចចម្បង៖

- ធានាឱ្យបាននូវសុក្រឹត្យភាពនៃរបាយការណ៍ហិរញ្ញវត្ថុ។
- ធានាឱ្យបាននូវប្រសិទ្ធិភាពនៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង។
- ពិនិត្យឡើងវិញលើការបំពេញភារកិច្ចរបស់សវនករផ្ទៃក្នុង និងនាយកសវនកម្មផ្ទៃក្នុង។
- ត្រួតពិនិត្យឡើងវិញលើទំហំនៃភារកិច្ច និងការបំពេញតួនាទីរបស់សវនករឯករាជ្យ។
- ត្រួតពិនិត្យឡើងវិញលើប្រសិទ្ធិភាពនៃប្រព័ន្ធគ្រប់គ្រងដោយអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ។
- ធ្វើរបាយការណ៍ទៅកាន់ក្រុមប្រឹក្សាភិបាល។
- ប្រជុំយ៉ាងតិចណាស់រៀងរាល់មួយត្រីមាសម្តង។

### ចំនួននៃកិច្ចប្រជុំ

គណៈកម្មាធិការសវនកម្មបានជួបប្រជុំចំនួន៤ ដងក្នុងឆ្នាំ ២០២៣ ហើយការចូលរួមពីសមាជិកគណៈកម្មាធិការសវនកម្មមានដូចខាងក្រោម៖

| សមាជិក | កាលបរិច្ឆេទនៃការតែងតាំង | ចំនួនកិច្ចប្រជុំ | |
|---|---|---|---|
| | | បានចូលរួម | ប្រារព្ធឡើង |
| លោក Michael Moormann<br>ប្រធានគណៈកម្មាធិការ/អភិបាលឯករាជ្យ | ១៧ កក្កដា ២០១៣ | ៤ | ៤ |
| លោក Brindley de Zylva<br>សមាជិក/ប្រធានក្រុមប្រឹក្សាភិបាល | ១៥ តុលា ២០១៥ | ៤ | ៤ |
| លោក Indrajith Wijesiriwardana<br>សមាជិក/អភិបាលឯករាជ្យ | ០១ មករា ២០១៥ | ៤ | ៤ |

## គណៈកម្មាធិការគ្រប់គ្រងហានិភ័យ សហគ្រាស និងប្រតិបត្តិតាម

### សមាសភាព

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ សហគ្រាស និងប្រតិបត្តិតាមដឹកនាំដោយអភិបាលឯករាជ្យ ដែលមានជំនាញការគ្រប់គ្រងហិរញ្ញវត្ថុ និងហានិភ័យ ហើយមានភាពឯករាជ្យពីប្រតិបត្តិការប្រចាំថ្ងៃតាមការតម្រូវរបស់ច្បាប់ និងបទប្បញ្ញត្តិ។

លោក Michael Moormann ជាប្រធានគណៈកម្មាធិការនេះ ដោយសារភាពខ្លាំងរបស់គាត់លើផ្នែកសវនកម្មផ្ទៃក្នុង ហិរញ្ញវត្ថុ និងវិស័យជាច្រើនទៀតក្នុងផ្នែកធនាគារ និងមីក្រូហិរញ្ញវត្ថុ។

### ភារកិច្ចចម្បង៖

- ធានាឱ្យបាននូវប្រព័ន្ធគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធិភាពសម្រាប់ដំណើរការអាជីវកម្ម។
- ធានាឱ្យមាននូវគោលនយោបាយដែលសមស្រប។
- ត្រួតពិនិត្យលើរបាយការណ៍ប្រតិបត្តិតាម រួមមាន របាយការណ៍ស្តីពីការប្រឆាំងការសម្អាតសាច់ប្រាក់/ហិរញ្ញប្បទានភេរវកម្ម ដើម្បីធានាឱ្យបានអនុលោមភាពស្របតាមច្បាប់ និងបទប្បញ្ញត្តិ។
- ធ្វើរបាយការណ៍ទៅកាន់ក្រុមប្រឹក្សាភិបាល។
- ប្រជុំយ៉ាងហោចណាស់រៀងរាល់មួយត្រីមាសម្តង។

### ចំនួនកិច្ចប្រជុំ

គណៈកម្មាធិការគ្រប់គ្រងហានិភ័យសហគ្រាស និងប្រតិបត្តិតាមបានជួបប្រជុំចំនួន ៤ ដង ក្នុងឆ្នាំ២០២៣។ ការចូលរួមពីសមាជិកគណៈកម្មាធិការនេះមានដូចខាងក្រោម៖

| សមាជិក | កាលបរិច្ឆេទនៃការតែងតាំង | ចំនួនកិច្ចប្រជុំ | |
|---|---|---|---|
| | | បានចូលរួម | ប្រារព្ធឡើង |
| លោក Michael Moormann<br>ប្រធានគណៈកម្មាធិការ/អភិបាលឯករាជ្យ | ០២ វិច្ឆិកា ២០១៦ | ៤ | ៤ |
| លោក Brindley de Zylva<br>សមាជិក/ប្រធានក្រុមប្រឹក្សាភិបាល | ០៦ កុម្ភៈ ២០១៦ | ៤ | ៤ |
| លោក Conrad Dias<br>សមាជិក/អភិបាល | ១២ កុម្ភៈ ២០១៨ | ៤ | ៤ |

## គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការ

### សមាសភាព

គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការត្រូវបានដឹកនាំដោយអភិបាលឯករាជ្យដែលមានជំនាញផ្នែកច្បាប់ និងធនាគារ។

លោក Indrajith Wijesiriwardana ដឹកនាំគណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការ ដោយសារលោកមានជំនាញក្នុងការប្រឹក្សាយោបល់ស្ទាត់ជំនាញ ជាមួយនឹងបទពិសោធន៍ ក្នុងវិស័យហិរញ្ញវត្ថុអភិវឌ្ឍន៍អន្តរជាតិនៅតាមស្ថាប័នហិរញ្ញវត្ថុជាច្រើន និងផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាពទាក់ទងនឹងការរៀបចំផែនការ និងថវិកានៃប្រាក់លាភការសម្រាប់អភិបាលនានា។

### ភារកិច្ចចម្បង៖

- ពិនិត្យរាល់ទិដ្ឋភាពនៃគោលការណ៍គ្រប់គ្រងធនធានមនុស្ស រួមទាំងបញ្ហាផ្តល់លាភការ។
- ធានានូវប្រសិទ្ធិភាព និងភាពពេញលេញ នៃការអនុវត្តគោលការណ៍គ្រប់គ្រងធនធានមនុស្ស។
- ដាក់សំណើសុំទៅម្ចាស់ភាគហ៊ុនដើម្បីផ្តល់ការទូទាត់ដល់អភិបាល និងធានាចំណាត់ការដែលយុត្តិធម៌ ចំពោះរាល់និយោជិក។
- ធានាការអនុលោមតាមយ៉ាងពេញលេញរវាងគោលការណ៍គ្រប់គ្រងធនធានមនុស្សជាមួយនឹងច្បាប់និងបទបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា។
- ធ្វើរបាយការណ៍ទៅកាន់ក្រុមប្រឹក្សាភិបាល។
- ប្រជុំយ៉ាងតិចរៀងរាល់មួយត្រីមាសម្តង។

### ចំនួននៃកិច្ចប្រជុំ

គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការ បានជួបប្រជុំចំនួន ៤ ដងក្នុងឆ្នាំ ២០២៣។ ការចូលរួមពីសមាជិកគណៈកម្មាធិការមានដូចខាងក្រោម៖

| សមាជិក | កាលបរិច្ឆេទនៃការតែងតាំង | ចំនួនកិច្ចប្រជុំ | |
|---|---|---|---|
| | | បានចូលរួម | ប្រារព្ធឡើង |
| លោក Indrajith Wijesiriwardana<br>ប្រធានគណៈកម្មាធិការ/អភិបាលឯករាជ្យ | ០២ វិច្ឆិកា ២០១៦ | ៤ | ៤ |
| លោក Conrad Dias<br>សមាជិក/អភិបាល | ១២ កុម្ភៈ ២០១៨ | ៤ | ៤ |
| លោក Dulip Samaraweera<br>សមាជិក/អភិបាល | ០២ កក្កដា ២០១៨ | ៤ | ៤ |

## គណៈកម្មាធិការ IT Steering

### សមាសភាព

គណៈកម្មាធិការ IT Steering ដឹកនាំដោយអភិបាលដែលមានជំនាញផ្នែកឌីជីថល និងព័ត៌មានវិទ្យា សម្រាប់វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ។

លោក Conrad Dias ត្រូវបានតែងតាំងជាប្រធានគណៈកម្មាធិការនេះ ដោយសារលោកជាអ្នកដឹកនាំដែលមានគំនិតសំខាន់ៗ និងមានភាពស្ទាត់ជំនាញ និងមានកេរ្តិ៍ឈ្មោះ ល្បីល្បាញនៅក្នុងវិស័យព័ត៌មានវិទ្យា។

### ភារកិច្ចចម្បង៖

- ធានាថាការវិនិយោគលើបច្ចេកវិទ្យាព័ត៌មាន ធ្វើឡើងដោយមានតុល្យភាពរវាងហានិភ័យ និងអត្ថប្រយោជន៍ទទួលបាន ហើយថវិកាមានគ្រប់គ្រាន់សម្រាប់ប្រើប្រាស់។
- ផ្តល់អនុសាសន៍ជាអាទិភាព ទៅលើគំនិតផ្តួចផ្តើមបច្ចេកវិទ្យាថ្មីៗ ដែលផ្តល់អត្ថប្រយោជន៍ដល់ប្រតិបត្តិការអាជីវកម្មរបស់ អិលអូអិលស៊ី (ខេមបូឌា)។
- ធានាថាផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មាន ដើរស្របគ្នាទៅនឹងផែនការអាជីវកម្ម។
- ត្រួតពិនិត្យ និងតាមដានការអនុវត្តយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មាន។
- ធ្វើរបាយការណ៍ទៅកាន់ក្រុមប្រឹក្សាភិបាល។
- ប្រជុំយ៉ាងតិចរៀងរាល់មួយត្រីមាសម្តង។

### ចំនួននៃកិច្ចប្រជុំ

គណៈកម្មាធិការ IT Steering បានជួបប្រជុំចំនួន ៤ ដងក្នុងឆ្នាំ២០២៣។ ការចូលរួមពី សមាជិកគណៈកម្មាធិការមានដូចខាងក្រោម៖

| សមាជិក | កាលបរិច្ឆេទនៃការតែងតាំង | ចំនួនកិច្ចប្រជុំ | |
|---|---|---|---|
| | | បានចូលរួម | ប្រារព្ធឡើង |
| លោក Conrad Dias<br>ប្រធានគណៈកម្មាធិការ/អភិបាល | ០៦ កុម្ភៈ ២០២០ | ៤ | ៤ |
| លោក Brindley de Zylva<br>សមាជិក/ប្រធានក្រុមប្រឹក្សាភិបាល | ០៦ កុម្ភៈ ២០២០ | ៤ | ៤ |
| លោក Indrajith Wijesiriwardana<br>សមាជិក/អភិបាលឯករាជ្យ | ០៦ កុម្ភៈ ២០២០ | ៤ | ៤ |

# របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រៅពីរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មសម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ក្រុមប្រឹក្សាភិបាលមានសេចក្តីសោមនស្សរីករាយក្នុងការប្រកាសដូចខាងក្រោម៖

## ទំនាស់ផលប្រយោជន៍

អភិបាលទាំងអស់បានធ្វើសេចក្តីប្រកាសអំពីទំនាស់ផលប្រយោជន៍តាមកិច្ចតម្រូវរបស់ក្រុមហ៊ុន។ កិច្ចការទាំងនេះត្រូវកត់សម្គាល់ដោយក្រុមប្រឹក្សាភិបាលកត់ត្រាក្នុងកំណត់ហេតុ និងបានដាក់បញ្ចូលក្នុងបញ្ជីផលប្រយោជន៍ (Interest Register) ដែលត្រូវបានក្រុមហ៊ុនរក្សាទុក។

ទោះជាយ៉ាងណាក្តី មកទល់ពេលនេះគ្មានអភិបាលរូបណាមានទំនាស់ផលប្រយោជន៍ជាមួយក្រុមហ៊ុនឡើយ។

## ការកាន់កាប់ភាគហ៊ុនរបស់អភិបាល

បច្ចុប្បន្ន មិនមានអភិបាលណាម្នាក់មានភាគហ៊ុននៅក្នុងក្រុមហ៊ុន អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី ឡើយ។ លើសពីនេះ គ្រឹះស្ថានមិនមានកិច្ចព្រមព្រៀងណាមួយដែលខ្លួនជាភាគីក្នុងអំឡុង ឬក្រោយឆ្នាំសារពើពន្ធ ដែលអាចឱ្យអភិបាលទទួលបាន អត្ថប្រយោជន៍តាមរយៈការទទួលបានភាគហ៊ុននៅក្នុង ឬប័ណ្ណបំណុលរបស់គ្រឹះស្ថាន ឬអង្គភាពសាជីវកម្មផ្សេងទៀតឡើយ។

## អាណត្តិនៃអភិបាល

អភិបាលបម្រើការងារដោយមិនមានរយៈពេលកំណត់ និងអាចស្នើសុំលាឈប់ ឬ ត្រូវបានបណ្តេញចេញដោយម្ចាស់ភាគហ៊ុន។ អភិបាលអាចនឹងត្រូវដកចេញពីតំណែងដោយការបោះឆ្នោតរបស់ម្ចាស់ភាគហ៊ុននៅក្នុងមហាសន្និបាត។ តំណែងទំនេរនៅក្នុងក្រុមប្រឹក្សាភិបាលអាចត្រូវបានជំនួសដោយសេចក្តីសម្រេចដែលត្រូវបានអនុម័តដោយសំឡេងភាគច្រើនដាច់ខាតគឺ ២/៣ (ពីរភាគបី) នៃសម្លេងឆ្នោតដែលបោះដោយម្ចាស់ភាគហ៊ុនទាំងអស់នៅក្នុងមហាសន្និបាត។

អភិបាលអាចលាលែងពីតួនាទីរបស់ខ្លួន ដោយផ្តល់ការជូនដំណឹងយ៉ាងហោចណាស់មួយខែជាមុន ទៅលេខាធិការក្រុមហ៊ុន ក្នុងទម្រង់ជាលិខិតចុះបញ្ជី ជាមួយនឹងបង្កាន់ដៃទទួលស្គាល់ ។

## អនុលោមភាពជាមួយច្បាប់ និងបទប្បញ្ញត្តិ

អិលអូអិលស៊ី (ខេមបូឌា) គោរពតាមច្បាប់ និងបទប្បញ្ញត្តិទាំងអស់របស់ធនាគារកណ្តាល និងនិយ័តករពាក់ព័ន្ធ។

## អភិបាលកិច្ចសាជីវកម្ម

ក្រុមប្រឹក្សាភិបាលជឿជាក់ថា អភិបាលកិច្ចសាជីវកម្មល្អផ្តល់អត្ថប្រយោជន៍ដល់ភាគីពាក់ព័ន្ធទាំងអស់។
របាយការណ៍នៃអភិបាលកិច្ចសាជីវកម្មបង្ហាញអំពីសារៈសំខាន់ៗ ដូចខាងក្រោម៖

- របាយការណ៍ប្រចាំឆ្នាំបានបង្ហាញអំពីទស្សនៈត្រឹមត្រូវ និងមានតុល្យភាពរបស់ស្ថាប័ន។
- របាយការណ៍បញ្ជាក់ថា ស្ថាប័នបានអនុលោមទៅតាមច្បាប់, បទប្បញ្ញត្តិអភិបាលកិច្ច និងក្រុមប្រតិបត្តិទាំងអស់។
- របាយការណ៍បានផ្តល់នូវការបង្ហាញជាក់លាក់អំពីក្រុមប្រឹក្សាភិបាល ការត្រួតពិនិត្យផ្ទៃក្នុង ប្រតិបត្តិការអាជីវកម្ម និងទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធ។

## ការគ្រប់គ្រងផ្ទៃក្នុង

អិលអូអិលស៊ី (ខេមបូឌា) គ្រប់គ្រងហានិភ័យបានទូលំទូលាយ និងគ្រប់ផ្នែកផ្សេងៗផ្អែកលើទំហំ និងភាពស្មុគស្មាញនៃអាជីវកម្ម។ ប៉ុន្តែជាធម្មតាអ្វីៗអាចកើតឡើងដោយមិនបានគិតទុកជាមុន ឬមិនអាចចៀសផុត។

ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងបង្កើតឡើងក្នុងបំណងផ្តល់ការធានាក្នុងកម្រិតសមរម្យដើម្បីកាត់បន្ថយបញ្ហាសំខាន់ៗដែលអាចកើតមានលទ្ធភាពកើតឡើងនូវកំហុសធំៗ ការក្លែងបន្លំ ឬការខាតបង់ ប៉ុន្តែមិនមែនជាការធានាដាច់ខាតនោះទេ។ ជំនួសឱ្យការលុបបំបាត់ហានិភ័យ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងជួយគ្រឹះស្ថានគ្រប់គ្រងហានិភ័យនានា ដើម្បីបំពេញតាមលក្ខណៈវិនិច្ឆ័យជាក់លាក់នៃការត្រួតពិនិត្យផ្ទៃក្នុង និងកាត់បន្ថយការបរាជ័យនៃគោលដៅ អាជីវកម្ម។

នាយកដ្ឋានគ្រប់គ្រងហានិភ័យ និងនាយកដ្ឋានច្បាប់ និងប្រតិបត្តិតាម ពិនិត្យនីតិវិធី ការអនុវត្ត និងគោលនយោបាយនានាជាប្រចាំ ហើយបើចាំបាច់ បង្ហាញរបាយការណ៍ជូនគណៈកម្មាធិការសវនកម្ម និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យសហគ្រាស និងប្រតិបត្តិតាម តាមការចាំបាច់។

ដើម្បីធានាថាគ្រប់គ្នាដឹងពីបញ្ហាធ្ងន់ធ្ងរ និងដើម្បីពន្លឿនការអនុវត្តសកម្មភាពកែតម្រូវបុគ្គលិកពាក់ព័ន្ធត្រូវពិភាក្សាស្វែងរកចំណុចខ្វះខាត ឬចំណុចខ្សោយ។ ការតាមដានលើសេចក្តីសម្រេចត្រូវបានធ្វើឡើងនៅកិច្ចប្រជុំគណៈកម្មាធិការ ឬកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។

## និរន្តរភាពអាជីវកម្ម

ក្នុងរយៈពេលពេញមួយឆ្នាំ ក្រុមប្រឹក្សាភិបាលបានវាយតម្លៃទាំងរបាយការណ៍ហិរញ្ញវត្ថុប្រចាំគ្រា និងរបាយការណ៍ហិរញ្ញវត្ថុដំណាច់ឆ្នាំ។ លើសពីនេះទៀត ក្រុមប្រឹក្សាភិបាលបានវាយតម្លៃជាបន្តបន្ទាប់ នូវប្រតិបត្តិការ និងបរិយាកាសប្រតិបត្តិការរបស់ក្រុមហ៊ុន ដែលរួមមានបរិបទម៉ាក្រូហានិភ័យដែលអាចកើតមាន និងការបែងចែកធនធាន។ ក្រុមប្រឹក្សាភិបាលបានកំណត់ថាក្រុមហ៊ុនអាចរក្សាកម្រិតប្រតិបត្តិការបច្ចុប្បន្នរបស់ខ្លួនសម្រាប់អនាគតដ៏ខ្លីខាងមុខដោយផ្អែកលើព័ត៌មានដែលមាន។ ជាលទ្ធផលក្រុមហ៊ុនត្រូវបានសន្មត់ថាអាចដំណើរការបន្តបាន តាមរយៈការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## សវនករ

យោងតាមបទប្បញ្ញត្តិរបស់ធនាគារកណ្តាល អិលអូអិលស៊ី (ខេមបូឌា) ត្រូវផ្លាស់ប្តូរសវនករឯករាជ្យរបស់ខ្លួនរៀងរាល់ ៣ ឆ្នាំម្តង។

សវនករឯករាជ្យរបស់ អិលអូអិលស៊ី (ខេមបូឌា) គឺ ក្រុមហ៊ុន ខេភីអឹមជី ខេមបូឌា (KPMG) ត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាលសម្រាប់រយៈពេល ៣ ឆ្នាំសារពើពន្ធ ចាប់ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៥។ អភិបាលទាំងអស់ទទួលស្គាល់ថាសវនករផ្ទៃឯករាជ្យគ្មានទំនាក់ទំនងជាមួយក្រុមហ៊ុនឡើយ ហើយក៏គ្មានផលប្រយោជន៍ណាមួយទទួលបានពី អិលអូអិលស៊ី (ខេមបូឌា) ដែរ។

អិលអូអិលស៊ី (ខេមបូឌា) បានអនុវត្តត្រឹមត្រូវក្នុងការផ្លាស់ប្តូរដៃគូសវនកម្មដែលការអនុលោមនេះស្របតាមអភិបាលកិច្ចល្អ។

កម្រៃដែលទាក់ទិននឹងសេវាកម្មសវនកម្ម និងសេវាកម្មមិនមែនសវនកម្ម (NAS) ជាមួយក្រុមហ៊ុន ខេភីអឹមជី ខេមបូឌា សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ មានដូចខាងក្រោម៖

| | ពាន់រៀល | ដុល្លារអាមេរិក |
|---|---|---|
| កម្រៃលើសេវាសវនកម្ម | ៤៧២.៦៥០ | ១១៥.០០០ |
| កម្រៃលើសេវាកម្មមិនមែនសវនកម្ម | ២៤៨.៦៥៥ | ៦០.៥០០ |
| | **៧២១.៣០៥** | **១៧៥.៥០០** |

# ក្រមសីលធម៌

អាកប្បកិរិយារបស់បុគ្គលិកទាំងក្នុង និងក្រៅកន្លែងធ្វើការ អាចប៉ះពាល់ដល់វិជ្ជាជីវៈ និងកេរ្តិ៍ឈ្មោះរបស់ អិលអូអិលស៊ី (ខេមបូឌា)។ ដូច្នេះ បុគ្គលិករបស់ អិលអូអិលស៊ី (ខេមបូឌា) ទាំងអស់ត្រូវគោរពយ៉ាងម៉ឺងម៉ាត់តាមក្រមសីលធម៌របស់ក្រុមហ៊ុន។

## ក្រមសីលធម៌វិជ្ជាជីវៈ

បុគ្គលិក អិលអូអិលស៊ី (ខេមបូឌា) ទាំងអស់ត្រូវមានកាតព្វកិច្ចរក្សាវិជ្ជាជីវៈ សុជីវធម៌ និងសុចរិតភាពឱ្យបានជិតដល់បំផុត។ អាទិភាពចម្បងរបស់ស្ថាប័ននៅពេលនេះ គឺការប្រតិបត្តិការងារដោយឧស្សាហ៍ព្យាយាម និងស្មោះត្រង់ដោយបុគ្គលិក និងអ្នកគ្រប់គ្រងរបស់ខ្លួន។ លើសពីនេះ អ្នកគ្រប់គ្រង និងនិយោជិតទាំងអស់ត្រូវតែយល់ ទទួលយក និងប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ ខាងក្រោម៖

- រក្សាខ្លួនឱ្យស្របតាមគុណតម្លៃស្នូលរបស់ក្រុមហ៊ុន។
- ធានានូវវិជ្ជាជីវៈស្របជាមួយនឹងភាពស្មោះត្រង់ និងសុចរិតភាព។
- ប្រើប្រាស់ភាសាឱ្យត្រឹមត្រូវជាមួយក្រុមការងារ និងអតិថិជន។
- អនុវត្តទំនួលខុសត្រូវប្រកបដោយវិជ្ជាជីវៈ ភាពជឿជាក់ និងភាពស្មោះត្រង់។
- ធ្វើការប្រុងប្រយ័ត្នទាំងអស់ដើម្បីការពារភាពឯកជន និងប្រតិបត្តិការរបស់ក្រុមហ៊ុន។
- មកបំពេញការងារឱ្យទាន់ពេលវេលា ស្លៀកពាក់ឯកសណ្ឋានឱ្យបានខ្ជាប់ខ្ជួន ឧស្សាហ៍ព្យាយាម និងសន្សំសំចៃធនធានរបស់ក្រុមហ៊ុន។
- មិនត្រូវបង្ហាញអតិថិជននូវ ការរើសអើងដោយផ្អែកលើមូលដ្ឋាននៃជំនឿ នយោបាយ ជាតិសាសន៍ ឬឋានៈសង្គម។
- រក្សាទំនាក់ទំនងវិជ្ជមានជាមួយអតិថិជន។ បុគ្គលិកផ្នែកឥណទានត្រូវតែ ឆ្លើយតបជាមួយអតិថិជន។
- អនុវត្តតាមសិទ្ធិរបស់អតិថិជន៖
    - សិទ្ធិក្នុងការយល់ដឹងអំពីលក្ខខណ្ឌផលិតផល និងការចំណាយទាំងអស់មុនពេលទូទាត់។
    - សិទ្ធិក្នុងការបដិសេធមិនទទួលយកផលិតផលណាមួយ។
    - សិទ្ធិក្នុងការតវ៉ា ឬសួរសំណួរអំពីសេវាកម្ម ឬផលិតផលដែលផ្តល់ដោយ អិលអូអិលស៊ី (ខេមបូឌា)។
    - សិទ្ធិក្នុងការទទួលបានកាលវិភាគប្រាក់កម្ចី និងឯកសារសំខាន់ៗផ្សេងទៀតនៅពេល (ឬមុន)ទូទាត់ និងការទទួលវិក្កយបត្រផ្លូវការក្នុងអំឡុងពេលសងប្រាក់កម្ចី។
    - សិទ្ធិក្នុងការទទួលបានការផ្តល់ដោយយុត្តិធម៌ និងការគោរព ដោយគ្មានការរើសអើងពីបុគ្គលិករបស់ក្រុមហ៊ុន និង
    - សិទ្ធិក្នុងការរំពឹងថាក្រុមហ៊ុននឹងរក្សាព័ត៌មានហិរញ្ញវត្ថុផ្ទាល់ខ្លួនជាការសម្ងាត់។
- អានដោយលឺៗជូនអតិថិជននូវមាត្រាពាក់ព័ន្ធនឹងភាពឯកជននៅក្នុងកិច្ចសន្យា និងកិច្ចព្រមព្រៀងសម្ងាត់ មុនពេលប្រមូលទិន្នន័យ និងការទូទាត់របស់អតិថិជន។
- អានទទួលស្គាល់ និងអនុវត្តក្រមសីលធម៌របស់ អិលអូអិលស៊ី (ខេមបូឌា) ការបំពានលើក្រមសីលធម៌នឹងអាចឈានទៅដល់ការពិន័យ ឬការបញ្ចប់ពីការងារ។
- អនុវត្តតាមការណែនាំរបស់អ្នកគ្រប់គ្រងផ្ទាល់ និងអនុវត្តភារកិច្ចចាំបាច់ទាំងអស់ដោយអនុលោមតាមគោលការណ៍ នីតិវិធី និងបទប្បញ្ញត្តិរបស់ អិលអូអិលស៊ី (ខេមបូឌា)។
- រាយការណ៍មកកាន់ប្រធានផ្ទាល់ នាយក ឬនាយិកាសាខា ឬនាយក ឬនាយិកានាយកដ្ឋាន ប្រសិនបើសង្កេតឃើញមានករណីបំពានលើក្រមសីលធម៌ ឬគោលនយោបាយផ្សេងៗ។

## សកម្មភាពហាមឃាត់

និយោជិត**មិនត្រូវ**៖

- ធ្វើរបាយការណ៍មិនពិត ឬបំភាន់ ក្លែងបន្លំផ្លាស់ប្តូរឯកសារ ឬលាក់ទិន្នន័យមានអត្ថប្រយោជន៍ ឬបង្កគ្រោះថ្នាក់ដល់ក្រុមហ៊ុន។
- មានការរើសអើងនឹងអ្នកដទៃលើជាតិសាសន៍ ពណ៌សម្បុរ ភេទ អាយុ។ល។ និយោជិតត្រូវបានហាមឃាត់មិនឱ្យ បៀតបៀនអ្នកដទៃ ឬប្រព្រឹត្តអំពើអានាចារ និងមិនត្រូវបើកមើល ឬបង្ហោះចែកចាយរូបភាពអាភាសឡើយ ។
- ប្រើប្រាស់តួនាទីរបស់ខ្លួនដើម្បីទទួលយកកម្រៃជើងសារ និងអត្ថប្រយោជន៍ផ្ទាល់ខ្លួនឡើយ។ បុគ្គលិក និងសាច់ញាតិដែលជាប់ពាក់ព័ន្ធនឹងការដាក់លក់ទ្រព្យសម្បត្តិរបស់អតិថិជន មិនត្រូវបានអនុញ្ញាតឱ្យចូលរួមដេញថ្លៃទិញទ្រព្យនោះឡើយ។
- ប្រើប្រាស់សំដីគំរោះគំរើយដល់អតិថិជនដែលមានការបង់សងយឺត ប៉ុន្តែត្រូវស្តាប់ហេតុផលរបស់អតិថិជន និងកសាងនូវវប្បធម៌ជួយគ្នា និងពិភាក្សាគ្នា។ នៅពេលដោះស្រាយបំណុលជាមួយអតិថិជន ជាពិសេសអតិថិជនដែលបង់ប្រាក់យឺត មន្ត្រីឥណទានត្រូវពិភាក្សាជាមួយអតិថិជន ដើម្បីដោះស្រាយ និងផ្តល់ដំបូន្មានដល់គាត់។ បុគ្គលិកមិនត្រូវបង្ខំប្រមូលប្រាក់កម្ចីភ្លាមៗ ដោយគ្មានអនុគ្រោះចំពោះការយឺតយ៉ាវរបស់អតិថិជនដែលជួបបញ្ហាលំបាកខ្លាំង និងជួបវិបត្តិសាច់ប្រាក់នោះឡើយ។
- លេងតុងទីននៅកន្លែងធ្វើការ សេពគ្រឿងស្រវឹងក្នុងម៉ោងការងារ សេពគ្រឿងញៀន លេងល្បែងស៊ីសង ប្រើប្រាស់អាវុធជាតិផ្ទុះ ឬសារធាតុដែលច្បាប់ហាមឃាត់ បន្លំ ឯកសារ។ ប្រើប្រាស់អំពើហិង្សា ជេរប្រមាថ គំរាបកំហែង ឬរំលោភបំពានផ្លូវភេទលើអ្នកដទៃ ។
- បញ្ចេញ ឬប្រើប្រាស់ឯកជនភាពរបស់អតិថិជន និងក្រុមហ៊ុន អិលអូអិលស៊ី (ខេមបូឌា) ទៅកាន់ភាគីទីបី ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរ លុះត្រាតែតម្រូវដោយច្បាប់ក្នុងអំឡុងពេលបំពេញការងារជាមួយ អិលអូអិលស៊ី (ខេមបូឌា) ឬនៅពេល និងក្រោយពេលបញ្ចប់ការងារ។

# ការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង




ការគ្រប់គ្រងហានិភ័យ តែងតែផ្សារភ្ជាប់ទៅនឹងយុទ្ធសាស្ត្រអាជីវកម្មរបស់ស្ថាប័នហិរញ្ញវត្ថុនីមួយៗ រួមទាំង អិលអូអិលស៊ី (ខេមបូឌា) ផងដែរ។ ការគ្រប់គ្រងហានិភ័យ ចូលរួមចំណែកលើកកម្ពស់គុណភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ អិលអូអិលស៊ី (ខេមបូឌា) និងគាំទ្រដល់ការសម្រេចបាននូវគោលដៅរបស់ស្ថាប័ន ដោយផ្អែកលើកត្តាពីរយ៉ាងគឺៈ ហានិភ័យ និងប្រាក់ចំណេញ។

ការគ្រប់គ្រងហានិភ័យ ដើរតួជាខ្សែបន្ទាត់ការពារទីពីរ ដោយផ្តល់នូវទស្សនៈវិភាគហានិភ័យប្រកបដោយវិជ្ជាជីវៈ ដើម្បីការពារ ផលប្រយោជន៍របស់ អិលអូអិលស៊ី (ខេមបូឌា)។ នាយកដ្ឋានគ្រប់គ្រងហានិភ័យនឹងធានាថា អិលអូអិលស៊ី (ខេមបូឌា) ត្រូវបានការពារពីហានិភ័យដែលលេចឡើងពីគំនិតផ្តួចផ្តើមអាជីវកម្ម កត្តាប្រព័ន្ធបច្ចេកវិទ្យា កត្តាដំណើរការត្រួតពិនិត្យផ្ទៃក្នុងមិនបានគ្រប់គ្រាន់ និងកត្តាមនុស្សនៅក្នុងខ្សែសង្វាក់អាជីវកម្ម។

ទស្សនៈនៃការគ្រប់គ្រងហានិភ័យរបស់ អិលអូអិលស៊ី (ខេមបូឌា) គឺបង្កើនប្រសិទ្ធភាពត្រួតពិនិត្យ និងចូលរួមចំណែកធ្វើឱ្យសម្រេចបាននូវគោលដៅរបស់ស្ថាប័ន ជួយក្នុងដំណើរការសម្រេចចិត្ត និងយុទ្ធសាស្ត្រអាជីវកម្ម។

**ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យរបស់ អិលអូអិលស៊ី ( ខេមបូឌា ) មានគោលបំណងៈ**

- ពង្រឹងសមត្ថភាពអាជីវកម្មក្នុងការកំណត់អត្តសញ្ញាណ វាយតម្លៃ និងកាត់បន្ថយហានិភ័យ ដើម្បីបង្កើនតម្លៃរបស់ភាគទុនិក។
- ផ្គូផ្គងកម្រិតអប្បបរមានៃហានិភ័យទៅនឹងយុទ្ធសាស្ត្រអាជីវកម្ម។
- វាយតម្លៃផលប៉ះពាល់នៃហានិភ័យដែលកំពុងកើតមានឡើង។
- បង្កើតយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យ ដែលឆ្លុះបញ្ចាំងពីអភិបាលកិច្ចដ៏រឹងមាំរបស់ស្ថាប័ន។

**អិលអូអិលស៊ី ( ខេមបូឌា ) អនុវត្តគោលការណ៍គ្រប់គ្រងហានិភ័យនៅក្នុងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃដូចខាងក្រោមៈ**

- លើកកម្ពស់ប្រាក់ចំណេញ និងពង្រីកអាជីវកម្មរយៈពេលវែង ប្រកបដោយចីរភាពដោយអនុវត្តការគ្រប់គ្រងហានិភ័យ និងអភិបាលកិច្ចដោយការប្រុងប្រយ័ត្ន។
- ជួយ អិលអូអិលស៊ី (ខេមបូឌា) ក្នុងការបង្កើតប្រាក់ចំណេញដែលមានស្ថិរភាព និងនិរន្តរភាពសម្រាប់ម្ចាស់ភាគទុនិក។
- ធានាថាយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យរបស់ អិលអូអិលស៊ី (ខេមបូឌា) គឺផ្អែកលើការយល់ដឹងច្បាស់ពីហានិភ័យដែលកំពុងប្រឈម ការវាយតម្លៃ វាស់វែង និងតាមដានហានិភ័យដែលមានបែបបទត្រឹមត្រូវ។

អិលអូអិលស៊ី បានអនុវត្តប្រព័ន្ធគ្រប់គ្រងហានិភ័យនៅទូទាំងស្ថាប័នទាំងមូល ឈ្មោះថាការគ្រប់គ្រងហានិភ័យតាមបែបម៉ាទ្រីស ដើម្បីធានាថាការពង្រីកសកម្មភាព និងប្រតិបត្តិការអាជីវកម្មនៅក្នុងបរិយាកាសវិវឌ្ឍន៍ទៅមុខដ៏ឆាប់រហ័សនេះ នៅតែរក្សាបានកម្រិតហានិភ័យដែលអាចទទួលយកបាន និងអនុលោមពេញលេញតាមច្បាប់ និងបទប្បញ្ញត្តិនានា ទាំងបទប្បញ្ញត្តិខាងក្នុង និងខាងក្រៅ។

ប្រព័ន្ធគ្រប់គ្រងហានិភ័យនេះធ្វើការត្រួតពិនិត្យនូវរាល់សកម្មភាពដែលមានហានិភ័យទាំងអស់ដោយប្រាកដថាការអនុវត្តប្រកាន់ខ្ជាប់នូវ វីសអាប់ភៃថាយ និងវីសថលើផែន។

រាល់គោលនយោបាយ នីតិវិធី និងគោលការណ៍ណែនាំ ត្រូវបានបង្កើតឡើង ផ្សព្វផ្សាយ និងបន្តតាមដាន ដើម្បីធ្វើឱ្យប្រសើរឡើងនូវការយល់ដឹងអំពីហានិភ័យ និងវប្បធម៌ត្រួតពិនិត្យផ្ទៃក្នុង សម្រាប់គ្រប់មុខងារនៃនាយកដ្ឋានទាំងអស់។

## អភិបាលកិច្ចគ្រប់គ្រងហានិភ័យ




គណៈកម្មាធិការគ្រប់គ្រងហានិភ័យសហគ្រាស និងប្រតិបត្តិតាម ត្រូវបានបង្កើតឡើង និងដឹកនាំដោយសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យមួយរូប។ គណៈកម្មាធិការនេះជួបប្រជុំរៀងរាល់បីខែម្តង។ បេសកកម្មរបស់គណៈកម្មាធិការនេះ គឺត្រួតពិនិត្យមើលហានិភ័យនានា ដែលកើតឡើងទាំងខាងក្នុង និងខាងក្រៅដែលទាក់ទងនឹងប្រតិបត្តិការឥណទាន និងហិរញ្ញវត្ថុ ដើម្បីធានាថា ការអនុវត្តលើគោលការណ៍ និងនីតិវិធី មានប្រសិទ្ធភាពក្នុងការកំណត់ហានិភ័យ និងគ្រប់គ្រងហានិភ័យ ដោយអនុលោមតាមសេចក្តីណែនាំផ្ទៃក្នុង ក៏ដូចជាតម្រូវការពីខាងក្រៅ។ បន្ថែមលើនេះទៀត គណៈកម្មាធិការនេះនឹងត្រួតពិនិត្យមើលលើការគ្រប់គ្រងហានិភ័យរបស់ក្រុមហ៊ុន និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដើម្បីធានាសុវត្ថិភាពទ្រព្យសកម្ម និងធនធានហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម មានគោលបំណងចម្បងក្នុងការវាយតម្លៃ តាមដាន និងអនុម័តលើការអនុវត្តទាក់ទងនឹង ហានិភ័យសន្ទនីយភាព ហានិភ័យអត្រាការប្រាក់ ហានិភ័យបទប្បញ្ញត្តិនានា ហានិភ័យរូបិយប័ណ្ណ និងហានិភ័យហិរញ្ញវត្ថុផ្សេងៗទៀត ដើម្បីបង្កើននូវ ប្រសិទ្ធភាពប្រាក់ចំណេញ ទន្ទឹមនឹងនេះក៏ធានាថា សាច់ប្រាក់ត្រូវបានរក្សាទុកយ៉ាងមានសុវត្ថិភាព។ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម ត្រូវបានជួបប្រជុំរៀងរាល់មួយខែម្តង និងត្រូវបានដឹកនាំដោយអនុប្រធាននាយកប្រតិបត្តិ/ប្រធាននាយកហិរញ្ញវត្ថុ។

## វិធីសាស្ត្រខ្សែបន្ទាត់ការពារ ៣ កម្រិត

អិលអូអិលស៊ី (ខេមបូឌា) អនុវត្តវិធីសាស្ត្រខ្សែបន្ទាត់ការពារ ៣ កម្រិត ដោយអនុលោមតាមស្តង់ដារអន្តរជាតិ និងការអនុវត្តដែលល្អបំផុតរួមមាន៖

### ខ្សែបន្ទាត់ការពារទី១

(ផ្នែកជួរមុខ)



ផ្នែកជួរមុខ (នាយកដ្ឋាន, ផ្នែក, សាខា) ទទួលខុសត្រូវចំពោះ ប្រតិបត្តិការប្រចាំថ្ងៃ ដោយធានាថា រាល់ហានិភ័យក្នុងអាជីវកម្ម ត្រូវបានកំណត់ វាយតម្លៃ និងត្រួតពិនិត្យបានត្រឹមត្រូវ។

### ខ្សែបន្ទាត់ការពារទី២

(មុខងារគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម)



មុខងារគ្រប់គ្រងហានិភ័យរួមមានៈ ធានានូវប្រសិទ្ធភាព នៃដំណើរការត្រួតពិនិត្យផ្ទៃក្នុង និងប្រព័ន្ធបច្ចេកវិជ្ជា តាមដានសារៈតារហានិភ័យនៅ អិលអូអិលស៊ី និងធានាថា សកម្មភាពអាជីវកម្មស្របតាម វិសអាប់ភែថាយ របស់ក្រុមប្រឹក្សាភិបាល។ មុខងារប្រតិបត្តិតាមរួមមានៈ ទទួលខុសត្រូវក្នុងការតាមដាន និងត្រួតពិនិត្យឡើងវិញ នូវរាល់គោលនយោបាយ នីតិវិធី និងគោលការណ៍ប្រតិបត្តិទាំងអស់ ដើម្បីធានានូវការធ្វើបច្ចុប្បន្នភាព និងការអនុលោមតាមច្បាប់ បទប្បញ្ញត្តិនានា រួមទាំងតម្រូវការដែលពាក់ព័ន្ធទាំងអស់។

### ខ្សែបន្ទាត់ការពារទី៣

(ផ្នែកសវនកម្មខាងក្នុង)



ផ្នែកសវនកម្មផ្ទៃក្នុង ផ្តល់នូវការធានាប្រកបដោយ ឯករាជ្យភាព ដល់ក្រុមប្រឹក្សាភិបាល និងម្ចាស់ភាគហ៊ុនថា អិលអូអិលស៊ី (ខេមបូឌា) កំពុងរក្សាបាននូវ ដំណើរការរបស់ខ្លួន ការត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហានិភ័យ ការប្រតិបត្តិតាម និងការអនុវត្តអភិបាលកិច្ចក្រុមហ៊ុនប្រកបដោយភាពត្រឹមត្រូវ និងប្រសិទ្ធភាព។



## ការគ្រប់គ្រងហានិភ័យឥណទាន

**ហានិភ័យឥណទាន** គឺជាការខាតបង់ផ្នែកហិរញ្ញវត្ថុចំពោះ អិលអូអិលស៊ី (ខេមបូឌា) ប្រសិនបើអ្នកខ្ចីប្រាក់ខកខានមិនបានបំពេញកាតព្វកិច្ចតាមកិច្ចសន្យាខ្ចីប្រាក់។ សកម្មភាពបង្កើតប្រាក់ចំណូលសំខាន់របស់ អិលអូអិលស៊ី (ខេមបូឌា) គឺការផ្តល់ប្រាក់កម្ចីជូនអតិថិជន ដូច្នេះហានិភ័យឥណទាន គឺជាហានិភ័យចម្បង។ ហានិភ័យឥណទាន ត្រូវបានគ្រប់គ្រង ដោយការអនុវត្តនូវរចនាសម្ព័ន្ធល្អនៃគោលនយោបាយហានិភ័យឥណទាន គោលការណ៍ណែនាំស្តីពីប្រតិបត្តិការឥណទាន និង បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀត ដែលត្រូវបានអនុវត្ត ដើម្បីគ្រប់គ្រងគុណភាពផលប័ត្រឥណទានរបស់ អិលអូអិលស៊ី (ខេមបូឌា)។

**ហានិភ័យឥណទាន** ត្រូវបានត្រួតពិនិត្យជាប្រចាំ តាមដានយ៉ាងសកម្ម និងរាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងហានិភ័យជារៀងរាល់ខែ។ ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ និងនាយកដ្ឋានពាក់ព័ន្ធ បានធ្វើការពិភាក្សា វិភាគ និងកំណត់នូវបញ្ហាផ្សេងៗ ដោយមានចំណាត់ការសមស្រប និងទាន់ពេលវេលា។

## ការគ្រប់គ្រងហានិភ័យសន្ទនីយភាព

**ហានិភ័យសន្ទនីយភាព** កើតឡើងពីការអសមត្ថភាពរបស់ស្ថាប័នក្នុងការបំពេញកាតព្វកិច្ច ដើម្បីឆ្លើយតបតាមតម្រូវការថវិកាទាំងក្នុងពេលបច្ចុប្បន្ន និងអនាគត ប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។
គណៈកម្មាធិការគ្រប់គ្រង់ទ្រព្យសកម្ម និងទ្រព្យអកម្ម (ALCO) ដែលមានអនុប្រធាននាយកប្រតិបត្តិ/ប្រធាននាយកហិរញ្ញវត្ថុជាប្រធាន ទទួលខុសត្រូវក្នុងការពិភាក្សារាល់បញ្ហាដែលទាក់ទងទៅនឹងហានិភ័យរតនាគារ។ បន្ថែមពីនេះ ក្របខណ្ឌគ្រប់គ្រងហានិភ័យសន្ទនីយភាព ត្រូវបានបង្កើតឡើង ដើម្បីលើកកម្ពស់ការគ្រប់គ្រងហានិភ័យសន្ទនីយភាព។

**ហានិភ័យសន្ទនីយភាព** ត្រូវបានតាមដានជាចម្បង និងគ្រប់គ្រងជាទៀងទាត់ ផ្អែកលើមូលដ្ឋាននៃការព្យាករណ៍លំហូរសាច់ប្រាក់ ដែលជាទូទៅកើតឡើងពី កាលកំណត់នៃទ្រព្យសកម្ម ទ្រព្យអកម្ម តារាងតុល្យការខាងក្រៅ និងស្ថានភាពស្ត្រេសផ្សេងៗ។ អិលអូអិលស៊ី (ខេមបូឌា) តែងតែធ្វើស្ត្រេសតេស្តលើសាច់ប្រាក់ងាយស្រួលជារៀងរាល់ឆ្នាំ ដើម្បីកំណត់តំបន់ដែលងាយរងគ្រោះ ទៅលើផលប័ត្រឥណទានរបស់ខ្លួន តាមដានផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុដែលបានរំពឹងទុក និងជួយដល់គណៈគ្រប់គ្រង ក្នុងការចាត់វិធានការទុកជាមុន។

## ការគ្រប់គ្រងហានិភ័យដើមទុន

**ហានិភ័យដើមទុន** កើតឡើងប្រសិនបើ អិលអូអិលស៊ី (ខេមបូឌា) មិនមានធនធានដើមទុនគ្រប់គ្រាន់ សម្រាប់បំពេញតាមតម្រូវការ និយ័តកម្មអប្បបរមា ដើម្បីគាំទ្រដល់ការវាយតម្លៃចំណាត់ថ្នាក់ឥណទានរបស់ខ្លួន និងដើម្បីគាំទ្រដល់កំណើន និងជម្រើសយុទ្ធសាស្ត្រ។ ដូច្នេះការមាននូវមូលដ្ឋានធនធានដើមទុនរឹងមាំ គឺជាយុទ្ធសាស្ត្រចម្បងរបស់ អិលអូអិលស៊ី (ខេមបូឌា) ដើម្បីរក្សាបាននូវទំនុកចិត្តទីផ្សារ និងទ្រទ្រង់ការអភិវឌ្ឍអាជីវកម្មបន្តទៀត។ និយតករនាំមុខរបស់ អិលអូអិលស៊ី (ខេមបូឌា) គឺធនាគារជាតិនៃកម្ពុជា ដែលជាអ្នកកំណត់ និងត្រួតពិនិត្យតម្រូវការដើមទុនសម្រាប់ អិលអូអិលស៊ី (ខេមបូឌា) ទាំងមូល។

គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម ទទួលខុសត្រូវលើការធានាប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យដើមទុននៅទូទាំង អិលអូអិលស៊ី (ខេមបូឌា) ស្របជៀងគ្នាទៅនឹងហានិភ័យទីផ្សារ និងហានិភ័យសន្ទនីយភាពផងដែរ។ ហានិភ័យដើមទុនត្រូវបានវាស់វែង និងតាមដាន ដោយប្រើកម្រិតកំណត់ដែលត្រូវបានគណនាទៅតាមតម្រូវការរបស់ធនាគារជាតិនៃកម្ពុជា។

## ការគ្រប់គ្រងហានិភ័យប្រតិបត្តិការ

**ហានិភ័យប្រតិបត្តិការ** គឺផ្សារភ្ជាប់ទៅនឹងការភាន់ច្រឡំរបស់បុគ្គលិក បរាជ័យប្រព័ន្ធបច្ចេកវិជ្ជា កង្វះនូវនីតិវិធី និងការត្រួតពិនិត្យពុំទាន់មានភាពគ្រប់គ្រាន់។ ហានិភ័យនេះអាចបណ្តាលឱ្យមានការខាតបង់នឹកស្មានពុំដល់ ឬការប៉ះពាល់ដល់កេរ្តិ៍ឈ្មោះដោយសារតែ បញ្ហាចម្បងៗដូចជា ប្រព័ន្ធបច្ចេកវិជ្ជាមានភាពខ្វះខាត ការបរាជ័យនៃបច្ចេកវិជ្ជា ការបំពានលើការត្រួតពិនិត្យផ្ទៃក្នុង ការគៃបន្លំ ឬបញ្ហាប្រតិបត្តិការផ្សេងៗទៀត។ ហានិភ័យប្រតិបត្តិការ តែងផ្សារភ្ជាប់ជាមួយគ្រប់ប្រតិបត្តិការ ដំណើរការ លំហូរការងារ ផលិតផល និងរាល់សកម្មភាពអាជីវកម្មទាំងអស់ របស់ស្ថាប័ន។

អិលអូអិលស៊ី (ខេមបូឌា) បានធ្វើការកំណត់នូវអត្តសញ្ញាណ និងវាយតម្លៃហានិភ័យប្រតិបត្តិការ ដែលមាននៅក្នុងគ្រប់ផលិតផល រាល់សកម្មភាព ដំណើរការ និងប្រព័ន្ធបច្ចេកវិជ្ជាទាំងអស់ និងភាពងាយរងគ្រោះ ដោយសារហានិភ័យទាំងនេះ។ អិលអូអិលស៊ី (ខេមបូឌា) តែងតែធានាថាមុនពេលដែលផលិតផល សកម្មភាព ដំណើរការ និងប្រព័ន្ធបច្ចេកវិជ្ជាថ្មីៗត្រូវបានអនុវត្ត ឬដាក់ឱ្យប្រើប្រាស់ ហានិភ័យប្រតិបត្តិការដែលពាក់ព័ន្ធត្រូវបានត្រួតពិនិត្យត្រឹមត្រូវតាមនីតិវិធី។

## ការគ្រប់គ្រងហានិភ័យទីផ្សារ

**ហានិភ័យទីផ្សារ** សំដៅដល់ការខាតបង់ផ្នែកហិរញ្ញវត្ថុនៅក្នុងបញ្ជីជួញដូររបស់ អិលអូអិលស៊ី (ខេមបូឌា) ដោយសារការផ្លាស់ប្តូរអត្រាការប្រាក់ ថ្លៃមូលធន អត្រាប្តូររូបិយប័ណ្ណបរទេស និងសូចនាករផ្សេងៗទៀត ដែលតម្លៃទាំងនោះត្រូវបានកំណត់នៅក្នុងទីផ្សារសាធារណៈ។

**ហានិភ័យអត្រាប្តូររូបិយប័ណ្ណបរទេស** គឺជាហានិភ័យហិរញ្ញវត្ថុមួយប្រភេទដែលបណ្តាលមកពីការប្រែប្រួលអវិជ្ជមាននៃអត្រាប្តូររូបិយប័ណ្ណ។ ហានិភ័យនេះកើតឡើងនៅពេលដែលប្រតិបត្តិការហិរញ្ញវត្ថុត្រូវបានប្តូរជារូបិយប័ណ្ណផ្សេងទៀត (ប្រាក់បាត ប្រាក់ដុល្លារ) ខុសពី រូបិយប័ណ្ណក្នុងស្រុក (ប្រាក់រៀល)។ ហានិភ័យនេះ បណ្តាលមកពីការប្រែប្រួលអវិជ្ជមាននៃអត្រាប្តូររូបិយប័ណ្ណ ហើយមានឥទ្ធិពលទៅលើ តម្លៃដោយស្ថានភាពចំហនៃរូបិយប័ណ្ណបរទេស (Open Foreign Currency Position)។ ស្ថានភាពរូបិយប័ណ្ណចំហសុទ្ធ (Net Open Position) ត្រូវបានប្រើប្រាស់ក្នុងការវិភាគលើភាពប្រែប្រួលអត្រាប្តូរប្រាក់ ដើម្បីវាយតម្លៃហានិភ័យរូបិយប័ណ្ណ។

**ហានិភ័យអត្រាការប្រាក់** គឺបណ្តាលមកពីឥណប្រតិទានខុសៗគ្នា និងការប្តូរតម្លៃក្នុងលំហូរសាច់ប្រាក់។ បច្ចុប្បន្ននេះ ហានិភ័យអត្រាការប្រាក់ ត្រូវបានវាស់វែងដោយការវិភាគលើគម្លាតនៃការប្រែប្រួលអត្រាការប្រាក់។ ការផ្តល់ប្រាក់កម្ចី ប្រាក់បញ្ញើ ប្រភពមូលនិធិ និងសកម្មភាពវិនិយោគរបស់ អិលអូអិលស៊ី (ខេមបូឌា) ធ្វើឱ្យមាននូវហានិភ័យអត្រាការប្រាក់កើតឡើង។ គណៈកម្មាធិការ គ្រប់គ្រងទ្រព្យសកម្ម និងអកម្ម (ALCO) ជាអ្នកទទួលខុសត្រូវក្នុងការតាមដានហានិភ័យអត្រាការប្រាក់របស់ អិលអូអិលស៊ី (ខេមបូឌា) ដោយផ្អែកលើការវិភាគគម្លាតនៃការប្រែប្រួលអត្រាការប្រាក់។

## ការគ្រប់គ្រងហានិភ័យកេរ្តិ៍ឈ្មោះ

**ហានិភ័យកេរ្តិ៍ឈ្មោះ** ទាក់ទងទៅនឹងការធ្លាក់ចុះនៃកេរ្តិ៍ឈ្មោះលើទីផ្សារ ពាក្យចចាមអារ៉ាម គុណភាពមិនល្អនៃសេវាកម្ម បណ្តឹងតវ៉ាពីអតិថិជន ការរក្សាការសម្ងាត់នៃព័ត៌មានអតិថិជន អាកប្បកិរិយារបស់បុគ្គលិកជាមួយអតិថិជន និងសាធារណជន។ល។ ហានិភ័យនេះកើតឡើងតាមរយៈ សាធារណជន អតិថិជន សមភាគី វិនិយោគិន អ្នកវិភាគ និងនិយតករ គិតអវិជ្ជមាន ឬខ្វះទំនុកចិត្តលើ អិលអូអិលស៊ី (ខេមបូឌា) ដែលអាចឈានទៅដល់ការបាត់បង់ប្រាក់ចំណូល និង/ឬមូលធនរបស់ស្ថាប័ន ទាំងពេលបច្ចុប្បន្ន និងអនាគត។
អិលអូអិលស៊ី (ខេមបូឌា) ផ្តល់នូវបរិយាបន្នហិរញ្ញវត្ថុ និងការយកចិត្តទុកដាក់ខ្ពស់ចំពោះអតិថិជនប្រកបដោយនិរន្តរភាព។ អិលអូអិលស៊ី (ខេមបូឌា) ប្រកាន់ខ្ជាប់នូវគោលការណ៍ការពារអតិថិជន និងការផ្តល់ប្រាក់កម្ចីប្រកបដោយទំនួលខុសត្រូវ ជាមួយនឹងការវាយតម្លៃឥណទានត្រឹមត្រូវមុនពេលផ្តល់ប្រាក់កម្ចីដល់អតិថិជន ដើម្បីការពារអតិថិជនពីបំណុលវ័ណ្ឌក។

## ការគ្រប់គ្រងហានិភ័យផ្នែកច្បាប់ និងការប្រតិបត្តិតាម

ហានិភ័យនេះបណ្តាលមកពីការផ្លាស់ប្តូរ ឬការល្មើស ឬមិនអនុលោមតាមច្បាប់ បទប្បញ្ញត្តិ គោលនយោបាយ និងស្តង់ដារវិជ្ជាជីវៈ (បទប្បញ្ញត្តិ ម្ចាស់កម្ចី និង/ឬបទប្បញ្ញត្តិផ្ទៃក្នុង) ដែលអាចនាំឱ្យខាតបង់ដល់ អិលអូអិលស៊ី (ខេមបូឌា)។

## ការគ្រប់គ្រងហានិភ័យយុទ្ធសាស្រ្ត

**ហានិភ័យយុទ្ធសាស្រ្ត** ជាហានិភ័យនៃការរៀបចំយុទ្ធសាស្រ្តពុំបានត្រឹមត្រូវ ឬបរាជ័យក្នុងការអនុវត្តយុទ្ធសាស្រ្តស្របតាមបេសកកម្ម ទស្សនវិស័យ ផែនការយុទ្ធសាស្រ្ត និងប្រតិបត្តិការរបស់ស្ថាប័ន។ ហានិភ័នេះក៏ជាប់ពាក់ព័ន្ធទៅនឹងការវាយតម្លៃព្រឹត្តិការណ៍ និងសេណារីយ៉ូដែលអាចកើតឡើង ដោយនឹងប៉ះពាល់ដល់យុទ្ធសាស្រ្ត ប្រតិបត្តិការ តម្លៃរបស់ក្រុមហ៊ុន ប្រាក់ចំណូលដើមទុន និងវត្តមានអាជីវកម្ម។

ដើម្បីធានានូវការគ្រប់គ្រងហានិភ័យយុទ្ធសាស្រ្តបានត្រឹមត្រូវ អិលអូអិលស៊ី (ខេមបូឌា) ដាក់បញ្ចូលហានិភ័យយុទ្ធសាស្រ្ត ទៅក្នុងដំណើរការនៃការរៀបចំផែនការ និងធ្វើការសម្រេចលើសូចនាករសម្រាប់ការអនុវត្តសំខាន់ៗ ដើម្បីវាស់វែងនូវហានិភ័យយុទ្ធសាស្រ្ត។ ក្រុមប្រឹក្សាភិបាល និងថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ចូលរួមយ៉ាងសកម្មក្នុងការត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យយុទ្ធសាស្រ្ត។ ថ្នាក់គ្រប់គ្រង ត្រូវត្រួតពិនិត្យលទ្ធផលប្រតិបត្តិការ ធានាបាននូវកំណើន គុណភាព ប្រាក់ចំណេញ ផ្តល់នូវរបាយការណ៍រួម សម្រាប់តាមដាន ជំនះភាពមិនប្រាកដប្រជា ចាប់យកឱកាស និងសម្រេចបាននូវគោលដៅយុទ្ធសាស្រ្តរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ គណៈកម្មាធិការគ្រប់គ្រងមានច្រើន ដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងយុទ្ធសាស្រ្តពាក់ព័ន្ធ ហើយពិភាក្សាជាទៀងទាត់អំពីលទ្ធផល និងវឌ្ឍនភាព។

## ការគ្រប់គ្រងហានិភ័យបរិស្ថាន

ហានិភ័យនៃសកម្មភាពអាជីវកម្មរបស់ អិលអូអិលស៊ី (ខេមបូឌា) ដែលពាក់ព័ន្ធនឹងទីតាំងភូមិសាស្រ្ត អាកាសធាតុ និងកត្តាស្ថានភាពប្រជាសាស្រ្ត (ជំងឺ និងមរណភាព ការចំណាកស្រុករបស់ប្រជាជន ឆន្ទៈក្នុងការជួយគាំទ្រសហការពីសំណាក់អាជ្ញាធរដែនដី អំពើពុករលួយ ភាពគ្មានតឹងផ្នែកនយោបាយជាដើម)។

## ការគ្រប់គ្រងហានិភ័យព័ត៌មានវិជ្ជា

នៅក្នុងសង្គមសម័យទំនើប ផ្នែកសុវត្ថិភាពព័ត៌មានដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាលើប្រព័ន្ធសុវត្ថិភាព នៃផលិតផលសេវាកម្មឌីជីថល ដោយអនុលោមទៅតាមតម្រូវការបទប្បញ្ញត្តិ និងបទដ្ឋានស្តង់ដារអន្តរជាតិ។ ដោយមានជំនួយពីផ្នែកសុវត្ថិភាពព័ត៌មាន អិលអូអិលស៊ី (ខេមបូឌា) សូមធានាការពារសុវត្ថិភាពទិន្នន័យ និងព័ត៌មានរបស់អតិថិជន រួមមានទិន្នន័យផ្ទាល់ខ្លួន របាយការណ៍ហិរញ្ញវត្ថុ ក៏ដូចជាទិន្នន័យសម្ងាត់របស់ក្រុមហ៊ុន។ ផ្នែកសុវត្ថិភាពព័ត៌មាន ផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការក្សាសុវត្ថិភាពទិន្នន័យ ឯកជនភាពនៃទិន្នន័យដែលធ្វើឱ្យ អិលអូអិលស៊ី (ខេមបូឌា) ទទួលបាននូវទំនុកចិត្តខ្ពស់ពីអតិថិជនរបស់ខ្លួន និងមានកេរ្តិ៍ឈ្មោះល្អប្រសើរ។ អិលអូអិលស៊ី (ខេមបូឌា) យល់ច្បាស់ពីសារៈសំខាន់នៃការគ្រប់គ្រងសន្តិសុខព័ត៌មាន ការត្រួតពិនិត្យ និងការពារទិន្នន័យ ដោយធានាថាប្រព័ន្ធដំណើរការដោយរលូន មានសុវត្ថិភាព និងមានភាពត្រឹមត្រូវ។ គណៈកម្មាធិការ IT Steering Committee (ITSC) កម្រិតក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការ IT Strategy and Steering Committee (ITSSC) កម្រិតគណៈគ្រប់គ្រង ត្រូវបានបង្កើតឡើង និងបានបើកកិច្ចប្រជុំជាទៀងទាត់។ គណៈកម្មាធិការទាំងនេះ នឹងទទួលខុសត្រូវក្នុងការកំណត់ និងតាមដានយុទ្ធសាស្រ្តបច្ចេកវិជ្ជាព័ត៌មាន អនុវត្តយុទ្ធសាស្រ្តបច្ចេកវិជ្ជាព័ត៌មាន និងការគ្រប់គ្រងហានិភ័យបច្ចេកវិជ្ជាព័ត៌មាន។

# ការអភិវឌ្ឍធនធានមនុស្ស

អិលអូអិលស៊ី (ខេមបូឌា) ផ្តល់ការងារដល់ប្រជាជនកម្ពុជាជាង ៣.៥០០នាក់។ ការបម្រើការងារជាមួយ អិលអូអិលស៊ី (ខេមបូឌា) មិនត្រឹមតែទទួលបានអត្ថប្រយោជន៍ហិរញ្ញវត្ថុសមរម្យក្នុងនាមនិយោជិក និងការអភិវឌ្ឍធនធានមនុស្ស និងវិជ្ជាជីវៈជាបន្តប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរួមចំណែកក្នុងការបម្រើអតិថិជននៅទូទាំងប្រទេសជាមួយនឹងសេវាកម្មហិរញ្ញវត្ថុដែលមានតម្លៃសមរម្យផងដែរ។ អាស្រ័យហេតុនេះ និយោជិកម្នាក់ៗសុទ្ធតែចូលរួមលើកស្ទួយពលរដ្ឋរួមជាតិរបស់ខ្លួន ក៏ដូចជារួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៃប្រទេសរបស់ខ្លួនផងដែរ។

## សារៈសំខាន់នៃការកសាងសមត្ថភាពបុគ្គលិក

ក្នុងឆ្នាំ២០២៣ អិលអូអិលស៊ី (ខេមបូឌា) បានរៀបចំវគ្គបណ្តុះបណ្តាល និងអភិវឌ្ឍន៍ជាច្រើនដល់បុគ្គលិកជាង ៣.៥០០នាក់ ដែលរួមមានជាអាទិ៍៖

- វគ្គបណ្តុះបណ្តាលតម្រង់ទិស
- ការហ្វឹកហាត់ការងារ
- ការហ្វឹកហ្វឺនបំប៉ន
- វគ្គបណ្តុះបណ្តាលរំលឹកឡើងវិញសម្រាប់បុគ្គលិកសាខានៅការិយាល័យកណ្តាល
- វគ្គសិក្សាតាមតម្រូវការ
- ការបណ្តុះបណ្តាលក្នុងតំបន់
- កម្មវិធីផ្លាស់ប្តូរការងារ
- វីដេអូបណ្តុះបណ្តាល
- វគ្គបណ្តុះបណ្តាលរំលឹកឡើងវិញនៅសាខា
- ការបណ្តុះបណ្តាលនៅនឹងកន្លែង
- វគ្គបណ្តុះបណ្តាលតាមអនឡាញ
- វគ្គបណ្តុះបណ្តាលប្រព័ន្ធTablet
- វគ្គបណ្តុះបណ្តាលអ្នកហាត់ការខាងគ្រប់គ្រងសាខា និងគណនេយ្យ
- វគ្គបណ្តុះបណ្តាលឆ្លងផ្នែកនីមួយៗ
- ការសិក្សាជំនាញតាម e-Learning
- វគ្គបណ្តុះបណ្តាលខាងក្រៅ រួមទាំងវគ្គបណ្តុះបណ្តាលក្នុងស្រុក និងក្រៅប្រទេស និង
- ការចុះជួបផ្ទាល់ដើម្បីផ្លាស់ប្តូរចំណេះដឹង និងការអនុវត្តការងារ រវាងដៃគូសហការ។

## គោលការណ៍បរិយាប័ន្ន

ដោយសារភាពសម្បូរបែប និងអព្យាក្រឹតភាពគឺជាផ្នែកនៃគុណតម្លៃស្នូលរបស់យើង យើងខ្ញុំអាចធានាបានថា កន្លែងធ្វើការរបស់យើងអាចប្រកាន់យកគោលនយោបាយធនធានមនុស្សដូចដែលមាននៅក្នុងលក្ខខណ្ឌ និងការអនុវត្តដូចខាងក្រោម៖

- ការមិនរើសអើងជំនឿ៖ មិនថាបុគ្គលិករបស់យើងគោរពសាសនាអ្វីនោះទេ អិលអូអិលស៊ី (ខេមបូឌា) បានសម្របសម្រួលដល់ការយល់ដឹង និងផ្តល់ការអប់រំដល់មិត្តរួមការងាររបស់ខ្លួន។
- ក្រមសីលធម៌វិជ្ជាជីវៈ៖ យើងឃើញថានៅកន្លែងធ្វើការបុគ្គលិករបស់យើងមានការគោរពគ្នាទៅវិញទៅមកក្នុងការអភិវឌ្ឍការអនុវត្តកិច្ចការងារ និងអាជីពរបស់ពួកគេជាពិសេស ដោយមានគោលនយោបាយប្រឆាំងនឹងការបៀតបៀនដែលបានបង្ហាញឱ្យឃើញ ពីប្រសិទ្ធភាពអនុវត្តនៅគ្រប់សាខាទាំងអស់។
- យេនឌ័រ និងភាពទីទៃគ្នា៖ ទាំងជនពិការ និងបេក្ខជនជាស្ត្រីតែងតែត្រូវបានលើកទឹកចិត្តឱ្យដាក់ពាក្យសម្រាប់តំណែងទំនេរដែលយើងខ្ញុំមាន។
- គ្រឿងបរិក្ខារសម្រួល៖ អគារ អិលអូអិលស៊ី (ខេមបូឌា) ទាំងអស់បានផ្តល់ភាពងាយស្រួលដល់ជនពិការ។

## ការលើកទឹកចិត្ត និងរង្វាន់

អិលអូអិលស៊ី (ខេមបូឌា) ផ្តល់អត្ថប្រយោជន៍ដែលមានលក្ខណៈប្រកួតប្រជែងដល់បុគ្គលិក មិនថាផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ៖

### អត្ថប្រយោជន៍ហិរញ្ញវត្ថុ៖

- ប្រាក់ខែដែលមានលក្ខណៈប្រកួតប្រជែង
- ប្រាក់ដំណាច់អតីតភាពការងារដែលផ្តល់ជូនដោយអនុលោមតាមច្បាប់ការងារ
- ប្រាក់រង្វាន់សម្រាប់បុណ្យចូលឆ្នាំខ្មែរ ភ្ជុំបិណ្ឌ និងប្រាក់រង្វាន់ចុងឆ្នាំ
- ការដំឡើងប្រាក់បៀវត្សរ៍ប្រចាំឆ្នាំ
- មូលនិធិសោធននិវត្តន៍
- មូលនិធិប្រាក់សន្សំប្រចាំខែរបស់បុគ្គលិក
- ប្រាក់ឧបត្ថម្ភសម្រាប់សកម្មភាពបុគ្គលិកប្រចាំខែ
- ប្រាក់ឧបត្ថម្ភសម្រាប់ដំណើរកំសាន្តប្រចាំឆ្នាំរបស់បុគ្គលិក
- ប្រាក់ឧបត្ថម្ភសម្រាប់ទូរស័ព្ទប្រចាំខែ
- ប្រាក់ឧបត្ថម្ភសម្រាប់ឯកសណ្ឋាន
- ប្រាក់រង្វាន់ប្រចាំខែ

### អត្ថប្រយោជន៍មិនមែនហិរញ្ញវត្ថុ៖

- ប្រាក់ឧបត្ថម្ភពិនិត្យព្យាបាលជំងឺសម្រាប់បុគ្គលិក និងសមាជិកគ្រួសាររបស់ខ្លួន
- ប្រាក់ឧបត្ថម្ភសម្រាកព្យាបាលនៅមន្ទីរពេទ្យសម្រាប់បុគ្គលិក និងសមាជិកគ្រួសាររបស់ខ្លួន
- ឱកាសបណ្តុះបណ្តាល និងការអភិវឌ្ឍន៍
- ឱកាសសម្រាប់ការឡើងតំណែង
- ការឈប់សម្រាកប្រចាំឆ្នាំ និងថ្ងៃបុណ្យជាតិស្របតាមប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- សេវាធានារ៉ាប់រងសុខភាព និងគ្រោះថ្នាក់២៤ម៉ោង
- ច្បាប់ឈប់សម្រាកដោយសារជំងឺ និងសម្រាលកូន
- ទទួលបានឥណទានបុគ្គលិក និងឥណទានគេហដ្ឋានជាមួយការប្រាក់ទាបសមរម្យ និង
- អត្ថប្រយោជន៍ផ្សេងៗទៀត។

### អត្ថប្រយោជន៍សម្រាប់អ្នកហាត់ការ៖

- ប្រាក់ឧបត្ថម្ភប្រចាំខែ
- មូលនិធិសោធននិវត្តន៍
- ការធានារ៉ាប់រងសុខភាព និងគ្រោះថ្នាក់ទាក់ទងនឹងការងារពីបេឡាជាតិរបបសន្តិសុខសង្គម
- ការបណ្តុះបណ្តាល
- ឱកាសក្លាយជាបុគ្គលិកពេញសិទ្ធិ។

## ការវាយតម្លៃបុគ្គលិក៖

ការវាយតម្លៃការអនុវត្តការងារត្រូវបានវាយតម្លៃពីរដងក្នុងមួយឆ្នាំ។ កិច្ចការនេះផ្តល់ប្រយោជន៍ដល់ទាំងបុគ្គលិកក្រោមបង្គាប់ផង និងអ្នកគ្រប់គ្រង។ ថ្នាក់គ្រប់គ្រងអាចប្រើការវាយតម្លៃការអនុវត្តការងារដើម្បីកំណត់គោលដៅពាក់កណ្តាលឆ្នាំ និងដំណាច់ឆ្នាំតាមដានវឌ្ឍនភាពរបស់និយោជិត និងជាការផ្តល់មតិត្រលប់ដើម្បីកែលម្អការងាររបស់ខ្លួន។ ទន្ទឹមនឹងនោះដែរ និយោជិតក៏ទទួលបានអត្ថប្រយោជន៍ពីការវាយតម្លៃនៃការអនុវត្តការងារនេះ ដោយដឹងពីគោលដៅដែលខ្លួនត្រូវសម្រេច ទទួលមតិស្ថាបនាពីអ្នកគ្រប់គ្រងទាក់ទងនឹងចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្លួន និងធ្វើការជាមួយអ្នកគ្រប់គ្រងដើម្បីរៀបផែនការសម្រាប់ផ្នែកដែលខ្លួនត្រូវអភិវឌ្ឍបន្ថែម។

# គណៈគ្រប់គ្រង





## លោក សុខ រឿន
### ប្រធាននាយកប្រតិបត្តិ

លោក សុខ រឿន ទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ គ្រប់គ្រងអាជីវកម្ម ជំនាញហិរញ្ញវត្ថុ និងធនាគារ នៅសាកលវិទ្យាល័យបៀលប្រាយ ប្រទេសកម្ពុជាក្នុងឆ្នាំ២០០៥។ លោកទទួលបានបរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញគ្រប់គ្រងសហគ្រាសនៅអតីតមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងឆ្នាំ២០០០។ លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើននៅក្នុង ប្រទេសកម្ពុជា និងនៅក្រៅប្រទេស ទាក់ទងនឹងជំនាញដូចជា វិស័យមីក្រូហិរញ្ញវត្ថុ ការគ្រប់គ្រងឥណទាន ការគ្រប់គ្រងធនធានមនុស្ស ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យ ភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចល្អ។ លោកបានចូលរួមវគ្គបណ្តុះបណ្តាលមីក្រូហិរញ្ញវត្ថុ នៅវិទ្យាស្ថាន Boulder នៅក្នុងប្រទេស អ៊ីតាលី សហរដ្ឋអាមេរិក ឥណ្ឌា ថៃ បង់ក្លាដែស និងអាហ្វ្រិក ខាងត្បូង។

លោកបានចាប់ផ្តើមបម្រើការជាមន្ត្រីឥណទាននៅ ធនាគារអេស៊ីលីដា ភីអិលស៊ី។ បន្ទាប់មកលោកត្រូវបានដំឡើងតំណែងជាប្រធានផ្នែកគ្រប់គ្រងឥណទាន នៅការិយាល័យកណ្តាលអស់រយៈពេល ៤ឆ្នាំ ឆ្នាំ២០០៥ ដល់ឆ្នាំ២០១០ លោកបានផ្លាស់ការងារទៅបម្រើការ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្ថាបនា លីមីតធីត ក្នុងមុខតំណែងជានាយកប្រតិបត្តិការ ដែលទទួលខុសត្រូវលើប្រតិបត្តិការប្រចាំថ្ងៃរួមមានការគ្រប់គ្រងឥណទាន ប្រាក់បញ្ញើ ប្រតិបត្តិការផ្ទេរសាច់ប្រាក់ និងការពង្រីកទីផ្សារ។

លោកចាប់ផ្តើមបម្រើការងារនៅ អិលអូអិលស៊ី (ខេមបូឌា) ជាប្រធាននាយកប្រតិបត្តិការ នៅក្នុង ខែមេសា ឆ្នាំ២០១០ ហើយលោកត្រូវបានដំឡើងតំណែង ជាអនុប្រធាននាយកប្រតិបត្តិនៅ ខែធ្នូ ឆ្នាំ២០១២។ បច្ចុប្បន្ន លោកត្រូវបានក្រុមប្រឹក្សាភិបាលតែងតាំងជាប្រធាននាយកប្រតិបត្តិ ចាប់តាំងពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៤។



## លោក សុខ សុផល
### អនុប្រធាននាយកប្រតិបត្តិ/ប្រធាននាយកហិរញ្ញវត្ថុ

លោក សុខ សុផល ទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ ជំនាញហិរញ្ញវត្ថុនៅសាកលវិទ្យាល័យជាតិគ្រប់គ្រងក្នុងឆ្នាំ២០០៧។ លោកបានទទួលបានបរិញ្ញាបត្រភាសាអង់គ្លេស ជំនាញពាណិជ្ជកម្មអន្តរជាតិ នៅវិទ្យាស្ថានភាសាបរទេសក្នុងឆ្នាំ២០០៥ និងបរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញគ្រប់គ្រងសហគ្រាស នៅអតីតមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងឆ្នាំ២០០០។ លោកក៏បានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនដូចជា៖ បានចូលរួម Global Climate Partnership Fund Academy ២០២២ ក្នុងប្រទេសស្វីស និងកម្មវិធី ២១ Century Board Leadership Model Masterclass ដែលរៀបចំដោយ CA Sri Lanka Business School ក្នុងឆ្នាំ២០២២។ Boulder Program នៅប្រទេសអ៊ីតាលី ដែលផ្តោតលើការគ្រប់គ្រង និងភាពជាអ្នកដឹកនាំក្នុងឆ្នាំ២០១៩។ Certified Management Accountant Program ដែលផ្តោតលើយុទ្ធសាស្ត្រគ្រប់គ្រងការចំណាយ និងយុទ្ធសាស្ត្រវិភាគអាជីវកម្ម និង Board Leadership Program ដែលរៀបចំដោយ Thai Institute of Directors ក្នុងឆ្នាំ២០១៨។ កម្មវិធីភាពជាអ្នកដឹកនាំ និងការបង្កើតថ្មីរៀបចំដោយ Women World Banking (USA) ក្នុងឆ្នាំ២០១៦។ កម្មវិធីគ្រប់គ្រងជាន់ខ្ពស់រៀបចំដោយ Cornell University (Sri Lanka) ក្នុងឆ្នាំ២០១៤ និង Syndication Loan Pricing & Structuring រៀបចំដោយ Universal Network Intelligence (Malaysia) ក្នុងឆ្នាំ២០១៣ ។ ជាងនេះទៅទៀត លោកបានចូលរួមសិក្ខាសាលា ក៏ដូចជាវគ្គបណ្តុះបណ្តាលជាច្រើនទៀតផងដែរ។ ទាក់ទងនឹងបទពិសោធន៍ការងារលោកបានបម្រើការងារនៅ ធនាគារអេស៊ីលីដា ភីអិលស៊ី ដោយចាប់ផ្តើមជាបុគ្គលិកផ្នែកគណនេយ្យគ្រប់គ្រង បន្ទាប់មកតំឡើងតំណែងជាប្រធានផ្នែកគណនេយ្យគ្រប់គ្រង ក្រោមនាយកដ្ឋានហិរញ្ញវត្ថុ (អំឡុងឆ្នាំ២០០១ ដល់ ២០០៨)។ នៅក្នុងឆ្នាំ២០០៨ លោកត្រូវបានតំឡើងតំណែងជាជំនួយការនាយកប្រតិបត្តិជាន់ខ្ពស់ (ទទួលបន្ទុកការងារវិនិយោគ) នៃនាយកដ្ឋានកិច្ចការច្បាប់ និងកិច្ចការសាជីវកម្មនៃធនាគារអេស៊ីលីដា។ ចាប់ពីខែមករា ឆ្នាំ២០០៩ លោកត្រូវបានដំឡើងតំណែងជានាយករងនៃនាយកដ្ឋានផ្សារមូលធននៃធនាគារ អេស៊ីលីដា។ លោកបានចាប់ផ្តើមបម្រើការងារជាមួយ អិលអូអិលស៊ី (ខេមបូឌា) នៅក្នុងខែសីហា ឆ្នាំ២០១០ ជាប្រធាននាយកហិរញ្ញវត្ថុ ហើយលោកត្រូវបានដំឡើងតំណែងជាអនុប្រធាននាយកប្រតិបត្តិ នៅក្នុងខែមីនា ឆ្នាំ២០១៩។



## លោកស្រី ស៊ឹយ សុឌីណា
### ប្រធាននាយិកាគ្រប់គ្រងហានិភ័យ

លោកស្រី ស៊ឹយ សុឌីណា ទទួលបានសញ្ញាបត្រវិជ្ជាជីវៈគណនេយ្យ (FCCA) ដែលទទួលស្គាល់ជាសាធារណៈពី វិទ្យាស្ថានអាជីពផ្នែកគណនេយ្យធំជាងគេរបស់ចក្រភពអង់គ្លេស។ លោកស្រីទទួលបានសញ្ញាបត្របរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម ជំនាញគណនេយ្យពីសាកលវិទ្យាល័យជាតិគ្រប់គ្រងក្នុងឆ្នាំ២០០៦។ បន្ថែមលើនេះ លោកស្រី ទទួលបានសញ្ញាបត្រជាន់ខ្ពស់ផ្នែកគណនេយ្យពី CamEd Business School នៅដើមឆ្នាំ ២០១៣។ លោកស្រីបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនពាក់ព័ន្ធនឹងវិស័យនេះ ដូចជា ការគ្រប់គ្រងហានិភ័យ ការគ្រប់គ្រងហិរញ្ញវត្ថុ ការរៀបចំគម្រោងយុទ្ធសាស្ត្រ និងវគ្គបណ្តុះបណ្តាលផ្សេងទៀត។ លោកស្រីក៏ធ្លាប់បានបម្រើការក្នុងក្រុមហ៊ុនគណនេយ្យអន្តរជាតិធំមួយ ក្នុងចំណោមក្រុមហ៊ុនធំៗទាំងបួន ដែលមានតួនាទីជាសវនករជាន់ខ្ពស់ អស់រយៈពេលជិត ៤ឆ្នាំ ដែលលោកស្រីទទួលខុសត្រូវក្នុងតួនាទីជាអ្នកដឹកនាំក្រុមសវនករ ចុះធ្វើសវនកម្មក្នុងវិស័យជាច្រើនរួមមាន ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ លោកស្រីបានចាប់ផ្តើមបម្រើការឱ្យអិលអូអិលស៊ី (ខេមបូឌា) នៅក្នុង ខែឧសភាឆ្នាំ២០១១ និងត្រូវបានដំឡើងតំណែងជាប្រធាននាយិការគ្រប់គ្រងហានិភ័យ នៅក្នុងខែមីនា ឆ្នាំ២០១៨។



## លោក ROMESH PERERA
### ប្រធាននាយកបណ្តាញចែកចាយ

លោក Romesh Perera ធ្លាប់បានបម្រើការនៅ LOLC Finance Plc. (LOFC) ក្នុងប្រទេសស្រីលង្ការយៈពេល ១៣ឆ្នាំ មុនពេលលោកចាប់ផ្តើមធ្វើការងារ នៅ អិលអូអិលស៊ី (ខេមបូឌា) ក្នុងតំណែងជាប្រធាននាយកបណ្តាញចែកចាយ។ លោកមានបទពិសោធន៍ការងារដ៏រឹងមាំជាមួយសេវាកម្មហិរញ្ញវត្ថុមិនមែនធនាគារ (NBFI) រួមទាំងក្រុមហ៊ុនហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ និងធនាគារឯកទេស នៅក្នុងប្រទេសស្រីលង្កា ដោយកាន់មុខតំណែងជា អ្នកគ្រប់គ្រងជាន់ខ្ពស់អស់រយៈពេល ២១ឆ្នាំ។

លោកមានជំនាញ និងបទពិសោធន៍ជាច្រើនឆ្នាំ ទាំងនៅក្នុងវិស័យធនាគារឯកទេស និងគ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ ដោយគ្រប់គ្រងទៅលើផ្នែកលក់ និងទីផ្សារ ផ្នែកហានិភ័យឥណទាន ផ្នែកហិរញ្ញប្បទាន និងគ្រប់គ្រងការប្រមូលឥណទានត្រឡប់មកវិញ។ លោកមានបទពិសោធន៍ក្នុងការផ្តល់ហិរញ្ញប្បទានធម្មតា និងបែបឥស្លាម ហិរញ្ញប្បទានពាណិជ្ជកម្ម សេវាភតិសន្យា ហិរញ្ញប្បទានលើសម្ភារៈប្រើប្រាស់ កំណើនប្រាក់បញ្ញើសន្សំ ប្រតិបត្តិការបញ្ចាំ និងប្រតិបត្តិការឆ្លងតំបន់។ លើសពីនេះ លោកបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈជាច្រើនទាក់ទងនឹងវិស័យនេះដោយជោគជ័យ ដែលធ្វើឱ្យលោកទទួលបានភារកិច្ចថ្មីនៅប្រទេសកម្ពុជា ពីក្រុមហ៊ុនមេ (LOLC Group) នៅ អិលអូអិលស៊ី (ខេមបូឌា)។ ហេតុដូច្នេះ លោកបានចាប់ផ្តើមជាមួយ អិលអូអិលស៊ី (ខេមបូឌា) ក្នុងខែមិថុនា ឆ្នាំ២០១៧ ហើយត្រូវបានតែងតាំងជាប្រធាននាយកបណ្តាញចែកចាយនៅខែសីហា ឆ្នាំ ២០១៨។



## លោកស្រី ឈាង កញ្ញា
### ប្រធាននាយិកាប្រាក់បញ្ញើ

លោកស្រី ឈាង កញ្ញា បានទទួលបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអាជីវកម្ម នៅសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជាក្នុងឆ្នាំ២០១២។ លោកស្រីបានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកគ្រប់គ្រងសហគ្រាស នៅសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងឆ្នាំ២០០០ និងបរិញ្ញាបត្រអក្សរសាស្ត្រអង់គ្លេស នៅសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជាក្នុងឆ្នាំ២០១០។លោកស្រីបានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាជាច្រើន ទាំងក្នុង និងក្រៅប្រទេសដូចជា ការគ្រប់គ្រងកំណើន និងផលប៉ះពាល់នៃអាជីវកម្មមីក្រូហិរញ្ញវត្ថុ ផលិតផលសេវាធនាគារឌីជីថល ការលក់ និងការទំនាក់ទំនង សេវាអតិថិជន ការអភិវឌ្ឍផលិតផល ប្រតិបត្តិការធនាគារ និងភាពជាអ្នកដឹកនាំ។ លោកស្រីមានបទពិសោធន៍ការងារគួរឱ្យកត់សម្គាល់នៅក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុរយៈពេល ២៤ឆ្នាំ។ លោកស្រីបានចាប់ផ្តើមធ្វើការជាមួយ ធនាគារ អេស៊ីលីដា និងបានបន្តទៅបម្រើការនៅ ធនាគារស្ថាបនា ភីអិលស៊ី កន្លែងដែលលោកស្រីបានបង្កើតគំនិត ណែនាំ និងប្រមូលភាពជោគជ័យនៃផលិតផលប្រាក់បញ្ញើ និងសេវាកម្មហិរញ្ញវត្ថុរបស់ធនាគារ ស្ថាបនា ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១៦។ នៅខែមករាឆ្នាំ២០១៦ លោកស្រីបានចូលបម្រើការជាមួយក្រុមហ៊ុន អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី នាយិកានាយកដ្ឋានគ្រប់គ្រងប្រាក់បញ្ញើ និងសេវាហិរញ្ញវត្ថុ ហើយលោកស្រីត្រូវបានដំឡើងឋានៈជាប្រធាននាយិកាប្រាក់បញ្ញើសន្សំនៅខែមីនា ឆ្នាំ២០១៩។



## លោក DULEEP LIYANAGE
### ប្រធាននាយកបច្ចេកវិជ្ជាព័ត៌មាន

លោក Duleep Liyanage ទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអាជីវកម្ម ជំនាញហិរញ្ញវត្ថុពី Postgraduate Institute of Management នៃសាកលវិទ្យាល័យ Sri Jayewardenepura នៅប្រទេសស្រីលង្កា។ លោកបានទទួលវិញ្ញាបនបត្រជាច្រើនក្នុងអំឡុងឆ្នាំដែលលោកកំពុងសិក្សា។ ដំបូងលោកបានទទួលបរិញ្ញាបត្រ (ថ្នាក់ខ្ពស់កម្រិត២) ផ្នែកកុំព្យូទ័រពាណិជ្ជកម្ម ដែលផ្តល់ដោយសាកលវិទ្យាល័យ Wolverhampton (ចក្រភពអង់គ្លេស)។ បន្ថែមពីលើនោះ លោកបានបញ្ចប់វគ្គសិក្សាផ្នែកសុវត្ថិភាពព័ត៌មាន និងការគ្រប់គ្រងជំនាញព័ត៌មានវិទ្យាក្នុងនោះរួមមាន៖ Certified Payment Card Industry Security Implementer (CPISI), Certified Android Security Specialist និង បានបញ្ចប់ ISO 27001:2013 Lead Auditor។ លោក Liyanage មានបទពិសោធន៍ជាង ១៩ឆ្នាំ លើបច្ចេកវិទ្យាព័ត៌មាន និងការគ្រប់គ្រង។ លោកបានបម្រើការនៅប្រទេសស្រីលង្កា នៅ LankaPay (LankaClear (Pvt) Ld.) ដែលជាស្ថាប័នផ្តល់សេវារចនាសម្ព័ន្ធទូទាត់ជាតិ ក្រោមការត្រួតពិនិត្យពី ធនាគារជាតិ នៃប្រទេសស្រីលង្កា។ ក្រៅពីនេះ លោកមានបទពិសោធន៍ និងជំនាញទៅលើបច្ចេកវិទ្យាព័ត៌មាន ការគ្រប់គ្រងគម្រោង បច្ចេកវិទ្យាចល័តកម្មវិធីទូទាត់កាត និងមានឯកទេសទៅលើផ្នែកសុវត្ថិភាពព័ត៌មានផងដែរ។ ក្នុងអំឡុងពេលដែលលោកកាន់ការងារនៅ LankaPay លោកបានបង្ហាញសមត្ថភាពការងាររបស់លោក ក្នុងនាមជាអ្នកផ្តល់ដំណោះស្រាយលើសុវត្ថិភាពព័ត៌មាន ដោយគ្រប់គ្រងប្រព័ន្ធទូទាត់ជាតិ រួមមាន Cheque Image and truncation System (CITS), Just Pay ដែលជាប្រព័ន្ធទូទាត់រាយតាមទូរស័ព្ទ LankaSign: PKI based Digital Certification Authority និងប្រព័ន្ធផ្សេងៗទៀត។ លោក Liyanage ក៏ធ្លាប់បម្រើការងារជាសាស្ត្រាចារ្យរងនៅសាកលវិទ្យាល័យ Open នៅប្រទេសអង់គ្លេស សកលវិទ្យាល័យ Sri Jayewardenepura និងសាកលវិទ្យាល័យ Wayamba នៅប្រទេសស្រីលង្កាផងដែរ។



## លោក តេង ភាព
### នាយកនាយកដ្ឋានសវនកម្មផ្ទៃក្នុង

លោក តេង ភាព បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម ជំនាញគណនេយ្យ និងហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យវេសស្ទើនក្នុងឆ្នាំ២០០៨។ លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្មជំនាញ គណនេយ្យនៅវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រក្នុងឆ្នាំ២០០៤ និងបរិញ្ញាបត្ររងធនាគារ ជំនាញ គណនេយ្យ និងហិរញ្ញវត្ថុ ក្នុងឆ្នាំ២០២០។ លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនទាក់ទងនឹងទម្រង់នីតិវិធីនៃការអនុវត្តវិជ្ជាជីវៈអន្តរជាតិជាលក្ខណៈអាជីពនៅប្រទេសម៉ាឡេស៊ី ផែនការអាជីវកម្ម និងការគ្រប់គ្រងភាពរីកចម្រើន ក្នុងប្រទេសហ្វីលីពីន ការគ្រប់គ្រងផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាពក្នុងប្រទេស ម៉ុងហ្គោលី ការចែក រំលែកបទពិសោធន៍ធនាគារក្នុងប្រទេសស្រីលង្កា និងវគ្គបណ្តុះបណ្តាលផ្សេងៗទៀតជាច្រើនក្នុងប្រទេសកម្ពុជា មានដូចជាការគ្រប់គ្រងហានិភ័យសវនកម្មផ្ទៃក្នុងកម្រិតខ្ពស់ របៀបសរសេររបាយការណ៍ជំនាញភាពជាអ្នកដឹកនាំ និងប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មាន។ ក្នុងរយៈពេល១៥ឆ្នាំកន្លងមក លោកមានបទពិសោធន៍បម្រើការងារក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងស្ថាប័នក្រៅរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា រួមមាន បម្រើការងារនៅCatholic Relief Services ចាប់ពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០៣ ក្នុងមុខតំណែងជាសវនករផ្ទៃក្នុង និងជានាយកសាខា។ បន្ទាប់មក លោកបានបម្រើការងារឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អង្គរកម្ពុជា ក្នុងមុខតំណែងជាប្រធានក្រុមសវនករផ្ទៃក្នុង និងជាប្រធានភូមិភាគ ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៨។ លោកចាប់ផ្តើមបម្រើការឱ្យ អិលអូអិលស៊ី (ខេមបូឌា) ជានាយកនាយកដ្ឋានសវកម្មផ្ទៃក្នុង នៅខែធ្នូ ឆ្នាំ២០០៨។



## លោកស្រី ឡេង ថាវី
### នាយិកានាយកដ្ឋានធនធានមនុស្ស

លោកស្រី ឡេង ថាវី បានបញ្ចប់ថ្នាក់អនុបណ្ឌិត (ឧបត្ថម្ភទាំងស្រុងដោយអាហារូបករណ៍អភិវឌ្ឍន៍អូស្ត្រាលី) ផ្នែកគ្រប់គ្រងធនធានមនុស្សពីសាកលវិទ្យាល័យម៉ូណាស់ ប្រទេសអូស្ត្រាលី នៅចុងឆ្នាំ ២០១៣ និងបរិញ្ញាបត្រផ្នែកគ្រប់គ្រងអាជីវកម្មពីវិទ្យាស្ថានជាតិគ្រប់គ្រងក្នុងប្រទេសកម្ពុជា ក្នុងឆ្នាំ ២០០២។ លោកស្រីក៏បានចូលរួមវគ្គបណ្តុះ បណ្តាលនិងសិក្ខាសាលាផ្សេងៗពាក់ព័ន្ធការគ្រប់គ្រងធនធានមនុស្ស និងភាពជាអ្នកដឹកនាំ នៅប្រទេសជាច្រើនដូចជា៖ ប្រទេសថៃ ប្រទេសសឹង្ហបុរី ប្រទេសស្រីលង្កា ប្រទេសឡាវ ប្រទេសហ្វីលីពីន ប្រទេសម៉ាឡេស៊ី ចក្រភពអង់គ្លេស ប្រទេសបារាំង ប្រទេសអ៊ីតាលី និងប្រទេសអូស្ត្រាលី។ លោកស្រី ថាវី មាន បទពិសោធន៍ជាង ១៥ឆ្នាំ ជាប្រធាននាយកដ្ឋានធនធានមនុស្ស ជាមួយអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ និងស្ថាប័នមីក្រូហិរញ្ញវត្ថុកំពូលៗនៅកម្ពុជា។ បន្ថែមពីនេះទៀត លោកស្រីក៏មានបទពិសោធន៍បម្រើការងារផ្នែកធនធានមនុស្សនៅក្រៅប្រទេសដែលមានដូចជានៅប្រទេសស្រីលង្កាចំនួន៣ខែ និងការងារក្រៅម៉ោងនៅប្រទេសអូស្ត្រាលីរយៈពេល១ឆ្នាំ។ លោកស្រីមានបទពិសោធន៍ធ្វើការនៅបរទេសក្នុងបរិបទវប្បធម៌ចម្រុះ ជាអាទិ៍ ធ្វើការ ៣ខែ នៅប្រទេសស្រីលង្កា និងបទពិសោធន៍ក្រៅម៉ោង ១ឆ្នាំ នៅប្រទេសអូស្ត្រាលី។ លោកស្រីបានចូលបម្រើការងារនៅ អិលអូអិលស៊ី (ខេមបូឌា) ជានាយិកានាយកដ្ឋានធនធានមនុស្សនៅខែសីហា ឆ្នាំ២០១៤។



### លោកស្រី ទ្រី សូឡា
**នាយិកានាយកដ្ឋានរតនាគារ**

លោកស្រី ទ្រី សូឡា បច្ចុប្បន្នកំពុងបន្តការសិក្សាយកសញ្ញាបត្រវិជ្ជាជីវៈគណនេយ្យ ដែលទទួលស្គាល់ជាសាធារណៈ ពីវិទ្យាស្ថានអាជីពផ្នែកគណនេយ្យធំជាង គេរបស់ចក្រភពអង់គ្លេស។ លោកស្រីបានទទួលសញ្ញាបត្របរិញ្ញាបត្រ គ្រប់គ្រងពាណិជ្ជកម្ម ជំនាញគណនេយ្យ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងឆ្នាំ ២០១១។ លោកស្រី បានចូលរួមវគ្គបណ្តុះបណ្តាលអាជីពជាច្រើន ដែលរួមមាន ការគ្រប់គ្រងហិរញ្ញវត្ថុ ការប្រឆាំងការសម្អាតប្រាក់ និងវគ្គបណ្តុះបណ្តាលផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងមីក្រូហិរញ្ញវត្ថុ។ លោកស្រីធ្លាប់បាន បម្រើការក្នុងក្រុមហ៊ុនគណនេយ្យ អន្តរជាតិធំមួយក្នុងចំណោមក្រុម ហ៊ុនធំៗទាំង៤ ដែលមានតួនាទីជាសវនករជាន់ខ្ពស់អស់ រយៈពេលជិត៤ឆ្នាំ ដែលលោកស្រីទទួលខុសត្រូវក្នុងតួនាទីជាអ្នកដឹកនាំក្រុមសវនករ ចុះធ្វើសវនកម្ម នៅក្នុងវិស័យជាច្រើនរួមមាន ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនពាណិជ្ជកម្ម អង្គការក្រៅរដ្ឋាភិបាល និងវិស័យផ្សេងៗទៀត។ លោកស្រីបានចាប់ផ្តើមបម្រើការឱ្យ អិលអូអិលស៊ី (ខេមបូឌា) នៅក្នុងខែ មិថុនា ឆ្នាំ២០១៥ ក្នុងតួនាទី ជានាយិកានាយកដ្ឋានរតនាគារ។



### លោកស្រី កែវ តារាទី
**នាយិកានាយកដ្ឋានហិរញ្ញវត្ថុ**

លោកស្រី កែវ តារាទី បច្ចុប្បន្នកំពុងបន្តការសិក្សាយកសញ្ញាបត្រវិជ្ជាជីវៈគណនេយ្យ ដែលទទួលស្គាល់ជាសាធារណៈ ពីវិទ្យាស្ថានអាជីពផ្នែកគណនេយ្យធំជាងគេរបស់ចក្រភពអង់គ្លេស។ លោកស្រីបានទទួល សញ្ញាបត្របរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម ជំនាញគណនេយ្យ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងឆ្នាំ២០១០ និងបរិញ្ញាបត្រផ្នែកអក្សរសាស្ត្រអង់គ្លេសពីវិទ្យាស្ថានភាសាបរទេសក្នុងឆ្នាំ២០០៩។ លោកស្រីធ្លាប់បាន បម្រើការក្នុងក្រុមហ៊ុនគណនេយ្យអន្តរជាតិធំមួយក្នុងចំណោមក្រុមហ៊ុនធំៗទាំង៤ ដែលមានតួនាទីជាសវនករជាន់ខ្ពស់អស់រយៈពេល ៣ឆ្នាំដែលលោកស្រីទទួលខុសត្រូវក្នុងតួនាទីជាអ្នកដឹកនាំក្រុមសវនករចុះធ្វើសវនកម្ម នៅក្នុងវិស័យជាច្រើនរួមមាន ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនពាណិជ្ជកម្ម អង្គការក្រៅរដ្ឋាភិបាល និងវិស័យផ្សេងៗទៀត។ មុននឹងចូលបម្រើការជាមួយ អិលអូអិលស៊ី (ខេមបូឌា) លោកស្រីធ្លាប់បានបម្រើការជា ប្រធានគណនេយ្យនៅ ធនាគារមេយប៉ែង (ខេមបូឌា) អស់រយៈពេល៤ឆ្នាំ។ លោកស្រីបានចាប់ផ្តើមបម្រើការឱ្យ អិលអូអិលស៊ី (ខេមបូឌា) នៅក្នុងខែមិថុនា ឆ្នាំ២០១៨ ក្នុងតួនាទីជានាយិកានាយកដ្ឋានហិរញ្ញវត្ថុ។



### លោក ប៊ុន បៃលឡា
**នាយកនាយកដ្ឋានបច្ចេកវិជ្ជាព័ត៌មាន**

លោក ប៊ុន បៃលឡា បានទទួលបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្របច្ចេកវិទ្យាព័ត៌មាន (MsIT) ក្នុងឆ្នាំ២០១៥ ពីសាកលវិទ្យាល័យន័រតុន។ មុននោះលោកក៏បានបញ្ចប់បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រពីសាកលវិទ្យាល័យន័រតុនក្នុងឆ្នាំ២០០៩ ផងដែរ។ លោកមានបទពិសោធន៍ការងារទូលំទូលាយជាង ២០ឆ្នាំជាមួយ អិលអូអិលស៊ី (ខេមបូឌា) និងស្ថាប័នដ៏ទៃទៀត។ លោកបានចូលរួមគម្រោងទាក់ទងនឹងបច្ចេកវិជ្ជាព័ត៌មាននៅក្នុង អិលអូអិលស៊ី (ខេមបូឌា) ដូចជាការផ្លាស់ប្តូរប្រព័ន្ធធនាគារស្នូលទៅប្រព័ន្ធ T24 ចូលរួមធ្វើការរៀបចំប្រព័ន្ធ ATM/POS (CSS) និងគម្រោងរបស់ធនាគារជាតិមួយចំនួន (ប្រព័ន្ធ RFT ប្រព័ន្ធ FAST, និងប្រព័ន្ធ Bakong) និងបានចូលរួមវគ្គបណ្តុះបណ្តាលផ្នែកព័ត៌មានវិជ្ជា ដូចជា ITIL® Foundation, ការគ្រប់គ្រងប្រព័ន្ធទិន្នន័យ, ISO-IEC_27001-2013, និងសិក្ខាសាលាមួយចំនួននៅ ក្នុងប្រទេសកម្ពុជា ស្រីលង្កា និងសិង្ហបុរី។ លោកចាប់ផ្តើមអាជីពជាមួយ អិលអូអិលស៊ី (ខេមបូឌា) ក្នុងឆ្នាំ២០០១ ជាអ្នកបញ្ចូលទិន្នន័យក្នុងប្រព័ន្ធ MIS ហើយលោកត្រូវបានតំឡើងឋានៈជាអ្នកត្រួតពិនិត្យប្រព័ន្ធ MIS ក្នុងឆ្នាំ២០០៥។ បន្ទាប់ពីបំពេញការងារបានល្អអស់រយៈពេល ៣ ឆ្នាំ លោកត្រូវបានដំឡើងតំណែងជាប្រធានផ្នែកកាវីកុំព្យូទ័រ (MIS Unit Manager)។ បន្ទាប់មកលោកបានបន្តឡើងតំណែងជានាយករងនាយកដ្ឋានបច្ចេកវិជ្ជាព័ត៌មានក្នុងឆ្នាំ ២០១៥។ បន្ទាប់ពីខិតខំប្រឹងប្រែងអស់ជាច្រើនឆ្នាំ និងភាពស្មោះត្រង់ លោកត្រូវបានដំឡើងតំណែងជានាយកនាយកដ្ឋានបច្ចេកវិជ្ជាព័ត៌មាននៅខែមករា ឆ្នាំ២០២២។



### លោក មុត ពិសី
**នាយកនាយកដ្ឋានឥណទាន**

លោក មុត ពិសី បានទទួលបរិញ្ញាបត្រជាន់ខ្ពស់ជំនាញហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រងនៃប្រទេសកម្ពុជាក្នុងឆ្នាំ២០១៣។ ហើយលោកក៏ទទួលបានបរិញ្ញាបត្រផ្នែកគ្រប់គ្រងអាជីវកម្មជំនាញទេសចរណ៍ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងឆ្នាំ២០០៦។ លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនផងដែរ នៅក្នុងប្រទេសកម្ពុជាដូចជា៖ ការវាយតម្លៃអចលនទ្រព្យ ការចរចា និងការដោះស្រាយវិវាទការងារ ការគ្រប់គ្រងសាខា ការកសាងសមត្ថភាពសវនករផ្ទៃក្នុង ច្បាប់ការងារ ការពង្រឹងអំណាចនៃភាពជាអ្នកដឹកនាំ និងជំនាញផ្សេងៗទៀត។ លោកធ្លាប់បានបម្រើការជាមន្ត្រីឥណទាននៅស្ថាបនាលីមីតធីត ក្នុងឆ្នាំ២០០៦ ហើយនិងត្រូវបានតំឡើងតំណែងជាប្រធានមន្ត្រីឥណទាននៅសាខាស្រុកអង្គស្នួល ក្នុងខែកុម្ភៈ ឆ្នាំ២០០៨ ហើយក្នុងឆ្នាំ២០០៩ លោកត្រូវបានតែងតាំងជានាយកសាខាខេត្តកំពត។ លោកចាប់ផ្តើមបម្រើការងារឱ្យ អិលអូអិលស៊ី (ខេមបូឌា) ជាអ្នកហាត់រៀនការងារគ្រប់គ្រងសាខានៅខែឧសភា ឆ្នាំ២០១០ ហើយត្រូវបានតែងតាំងជានាយកសាខាក្រុងសួងនៅខែកក្កដា ឆ្នាំ២០១០។ នៅក្នុងខែ ឧសភា ឆ្នាំ២០១៤ លោកត្រូវបានតំឡើងតំណែងជានាយកនាយកដ្ឋានរដ្ឋបាល និងលទ្ធកម្ម ហើយបានផ្លាស់ប្តូរការងារមកនាយកដ្ឋានឥណទាន ក្នុងមុខតំណែងជានាយករង នាយកដ្ឋានឥណទាន។ បន្ទាប់មកបានផ្លាស់មកធ្វើជានាយករងនាយកដ្ឋានអាជីវកម្ម ក្នុងខែវិច្ឆិកា ឆ្នាំ២០១៧។ មួយឆ្នាំក្រោយមក លោកត្រូវបានតម្លើងតំណែងជានាយកនាយកដ្ឋានឥណទាន នៅខែសីហា ឆ្នាំ២០១៨។



## លោក ថុង រិទ្ធី
### នាយកនាយកដ្ឋានអាយធេ និងអាជីវកម្មឌីជីថល

លោក ថុង រិទ្ធី បានទទួលសញ្ញាបត្រផ្នែកទំនាក់ទំនងអន្តរជាតិ នៅសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ក្នុងឆ្នាំ២០១១។ មុនពេលចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) លោកធ្លាប់បម្រើការងារទៅលើផ្នែកគ្រប់គ្រងអាជីវករភាពជាដៃគូសាជីវកម្ម គាំទ្រប្រតិបត្តិការ ១៣៨សាខាថ្មី និងគ្រប់គ្រងលើបុគ្គលិកសេវាអតិថិជន ជាង១០០នាក់ ក្នុងតំណែងជាអនុប្រធានចាត់ការទូទៅនៅធនាគារអ៊ូរី។ លោកបានបម្រើការងារក្នុងវិស័យធនាគាររយៈពេល ១៥ឆ្នាំ កន្លងមកហើយ ទាំងធនាគារអន្តរជាតិ និងក្នុងស្រុក និងមានមុខតំណែងជាមន្ត្រីគ្រប់គ្រងជាន់ខ្ពស់មុនពេលចូលកាន់តំណែងជានាយកនាយកដ្ឋានអាយធេ និងអាជីវកម្មឌីជីថលនៅ អិលអូអិលស៊ី (ខេមបូឌា)។

លោកមានជំនាញ និងបទពិសោធន៍ទូលំទូលាយទាក់ទងនឹងការអភិវឌ្ឍ e-Business ការអភិវឌ្ឍន៍ e-Channels banking ភាពជាដៃគូ B2B និងកម្មវិធីសម្ព័ន្ធភាពឆ្លាតវៃ។ លោកបានផ្តល់ការណែនាំទៅលើភាពជាអ្នកដឹកនាំ និងការសម្របសម្រួលរាល់សកម្មភាពនៃការទាក់ទាញអ្នកប្រើប្រាស់ ការទាញយកអាជីវករ ចំនួនប្រតិបត្តិការនៃការប្រើប្រាស់ និងកម្មវិធីរក្សាអតិថិជន។ លោកកំណត់យុទ្ធសាស្ត្រទិសដៅនៃអាជីវកម្មឌីជីថល និងការអភិវឌ្ឍផលិតផលដើម្បីបង្កើនបទពិសោធន៍ដល់អ្នកប្រើប្រាស់តាមរយៈផលិតផល និងសេវាកម្មឌីជីថល។ ចាប់ពីឆ្នាំ២០១០ ដល់ ២០១៨ លោកបានបំពេញការងារយ៉ាងពេញលេញជាមួយ ANZ Group។ លោកបានបម្រើការងារឱ្យក្រុមហ៊ុន Wing (Cambodia) Plc ដោយគ្រប់គ្រងភ្នាក់ងារវីងជាង ១៥០ នាក់ និងគ្រប់គ្រងការអនុវត្តយុទ្ធសាស្ត្រលក់ និងទីផ្សារទៅលើការផ្សព្វផ្សាយ និងការបង្កើតគណនីវីងទូទាំងប្រទេស។ លោកក៏ធ្លាប់បម្រើការងារឱ្យធនាគារ ANZ Royal ដោយគ្រប់គ្រងផលប័ត្រនៃផលិតផលលក់រាយ (កម្ចីទិញ ផ្ទះ ប្រាក់កម្ចីផ្ទាល់ខ្លួន និងប័ណ្ណឥណទាន) តាមដានដំណើរការ និងនិន្នាការរបស់ប័ណ្ណ VISA ដើម្បីកាត់បន្ថយប្រតិបត្តិការក្លែងបន្លំ។ លោកបានចូលបម្រើការជាមួយ អិលអូអិលស៊ី (ខេមបូឌា) ជានាយកនាយកដ្ឋានអាយធេ និងអាជីវកម្មឌីជីថល ក្នុងខែសីហា ឆ្នាំ២០២២។



## កញ្ញា គិត ម៉ារ៉ាឌី
### នាយិកានាយកដ្ឋានច្បាប់ និងអនុលោមភាព

កញ្ញា គិត ម៉ារ៉ាឌី បានបញ្ចប់ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកច្បាប់សិទ្ធិមនុស្សអន្តរជាតិ ពីសកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា នៅឆ្នាំ២០២២។ កញ្ញា ទទួលបានអាហារូបករណ៍ផ្លាស់ប្តូរការសិក្សាផ្នែកធុរកិច្ច និងសិទ្ធិមនុស្សនៅសកលវិទ្យាល័យ LUND ប្រទេសស៊ុយអែត នៅឆ្នាំ២០១៧ និងអាហារូបករណ៍ផ្លាស់ប្តូរការសិក្សារយៈពេល ១ឆ្នាំ នៅ Bowdoin College សហរដ្ឋអាមេរិក នៅឆ្នាំ២០១១។ កញ្ញា ទទួលបានបរិញ្ញាបត្រចំនួន ០២ គឺបរិញ្ញាបត្រនីតិសាស្ត្រពីសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបរិញ្ញាបត្រ អក្សរសាស្ត្រអង់គ្លេស ពីសាកលវិទ្យាល័យន័រតុន។ កញ្ញា ធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនដូចជា ផ្នែកធុរកិច្ច និងសិទ្ធិមនុស្សដែលរៀបចំដោយ UN Global Compact, ការគ្រប់គ្រងការស៊ើបអង្កេតហិរញ្ញវត្ថុ (កម្រិតមធ្យម) ដែលជារៀបចំជាកម្មវិធីសិក្សាអនឡាញដោយ OECD International Academy, វគ្គសិក្សាអំពីការអនុលោមតាមច្បាប់បទប្បញ្ញត្តិ (Regulatory Compliance) ដែលរៀបចំដោយវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ (IBF), វិញ្ញាបនបត្រ ICA-AML International, ស្ត្រីក្នុងភាពជាអ្នកដឹកនាំ (Harpswell ASEAN Women's Leadership) និងកម្មវិធីសិក្ខាសាលាផ្សេងៗ នៅប្រទេស សឹង្ហបុរី ហ្វីលីពីន ម៉ាឡេស៊ីជាដើម។ មុនពេលចូលបម្រើការងារជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) កញ្ញាធ្លាប់កាន់តំណែងជានាយិកាប្រតិបត្តិតាមនៅក្រុមហ៊ុន វីងម៉ាន់នី (ខេមបូឌា) ម.ក, ធនាគារ វីង (ខេមបូឌា) ម.ក, និងធនាគារឯកទេសម៉ារីថាម ម.ក ធ្លាប់កាន់តំណែងជាប្រធានផ្នែកប្រតិបត្តិតាម នៅធនាគារឯកទេសទីមួយ និងជាទីប្រឹក្សាផ្នែកច្បាប់ជាន់ខ្ពស់ ប្រធានការិយាល័យនៅ ក្រុមហ៊ុន អេចប៊ីអេស។ កញ្ញា មានជំនាញជាច្រើនរួមមាន ផ្នែកច្បាប់ ផ្នែកប្រតិបត្តិតាម ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ផ្នែកធុរកិច្ច និងសិទ្ធិមនុស្ស និងការទទួលខុសត្រូវសង្គមរបស់ក្រុមហ៊ុន(CSR)។



## លោកស្រី ខេង ណារី
### លេខាធិការក្រុមហ៊ុន

លោកស្រី ខេង ណារី ទទួលបរិញ្ញាបត្រសេដ្ឋកិច្ច ជំនាញគ្រប់គ្រងសហគ្រាសពីសកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំ២០១០ និងបរិញ្ញាបត្រអក្សរសាស្ត្រអង់គ្លេសជំនាញផ្នែកទំនាក់ទំនងពីវិទ្យាស្ថានភាសាបរទេស នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងឆ្នាំ២០១២។ លោកស្រីបានបញ្ចប់កិច្ចការស្រាវជ្រាវនៅក្រុមហ៊ុន សុខគង់ អាហារ៍ណ និហារ៍ណ ខូអិលធីឌី និងទទួលបានសញ្ញាបត្រ ភាសាអង់គ្លេស (IEAP) ពី វិទ្យាស្ថានភាសាបរទេស បញ្ញាសាស្ត្រ។ លោកស្រីបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងការបណ្តុះបណ្តាលផ្សេងៗ ដូចជាគោលការណ៍គណនេយ្យ ជំនាញសរសេររបាយការណ៍ សិក្ខាសាលាស្តីពីការផ្តល់ប្រាក់កម្ចីលើកកម្ពស់បរិស្ថាន ភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចសាជីវកម្ម។ មុនពេលចូលបម្រើការងារនៅ អិលអូអិលស៊ី (ខេមបូឌា) លោកស្រីបានធ្វើការនៅ វីង (ខេមបូឌា) អិលភីស៊ី ក្នុងនាមជាអ្នកប្រឹក្សាផ្នែកបំរើសេវាកម្មអតិថិជន ក្នុងឆ្នាំ២០១២។ បន្ទាប់មក លោកស្រីបានចាប់ផ្តើមបម្រើការជាមួយ អិលអូអិលស៊ី (ខេមបូឌា) ជាជំនួយការលេខាក្នុងឆ្នាំ២០១៣ ហើយត្រូវបានតំឡើងដំណែងជាលេខាធិការក្រុមហ៊ុននៅខែមិថុនា ឆ្នាំ២០១៤។



## លោក វ៉ា សុខអួន
### នាយកនាយកដ្ឋានរដ្ឋបាល និងធុរកិច្ច

លោក វ៉ា សុខអួន ជាអ្នកជំនាញដែលមានការអប់រំខ្ពស់ បានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងធុរកិច្ច ជំនាញគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យពីសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងប្រទេសកម្ពុជា។ លោកក៏បានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកគ្រប់គ្រងធុរកិច្ចពីសាកលវិទ្យាល័យដូចគ្នានេះ។ លើសពីនេះ លោកបានបញ្ចប់ការសិក្សាថ្នាក់ភាសាអង់គ្លេសទូទៅពី សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ក្នុងឆ្នាំ ២០១៤។ លោក សុខ អួន ក៏បានចូលរួមកម្មវិធីបណ្តុះបណ្តាលជាច្រើនទាក់ទងនឹងជំនាញភាពជាអ្នកដឹកនាំ ជំនាញលើកទឹកចិត្ត ជំនាញគិតពិចារណា ជំនាញដោះស្រាយបញ្ហា ការគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់ ការគ្រប់គ្រងសារពើភ័ណ្ឌ ការគ្រប់គ្រងឃ្លាំងស្តុកទំនិញ និងបរិក្ខារ ការគ្រប់គ្រងអចលនទ្រព្យ និងសន្តិសុខ ផែនការបន្តអាជីវកម្ម និងធ្លាប់ត្រូវបានជ្រើសរើសឱ្យចូលរួមសិក្ខាសាលាខ្សែសង្វាក់ផ្គត់ផ្គង់ក្នុងតំបន់របស់ WVI នៅទីក្រុងបាងកក។ លោក សុខ អួន ក៏ជាអ្នកជំនាញដែលមានបទពិសោធន៍ខ្ពស់ មានចំណេះដឹងច្រើនក្នុងផ្នែកលទ្ធកម្ម រដ្ឋបាល និងធុរកិច្ច។ លោកបានធ្វើការនៅក្នុងអង្គការ ក្រុមហ៊ុនធំៗ និងបានកាន់មុខតំណែងជាច្រើននៅក្នុងអាជីពរបស់លោក។ នៅឆ្នាំ ២០១៥ លោកបានធ្វើការជាមន្ត្រីលទ្ធកម្មនៅធនាគារ Advance Bank of Asia (ធនាគារ ABA)។ នៅខែធ្នូ ឆ្នាំ២០១៨ លោកមានតួនាទីជាអ្នកផ្គត់ផ្គង់លទ្ធកម្ម និងយុទ្ធសាស្ត្រនៅអង្គការទស្សនៈពិភពលោក (World Vision)។ នៅឆ្នាំ ២០២១ លោកគឺជាអ្នកគ្រប់គ្រងផ្នែកលទ្ធកម្មនៅធនាគារ Wing ដែលការងាររបស់លោកភាគច្រើនទទួលបន្ទុកលើសកម្មភាពលទ្ធកម្មប្រចាំថ្ងៃទូទៅ ការជួលអគារ និងជួយគាំទ្រផ្នែកខ្លះនៃការពង្រីកសាខា ឬទីតាំងរបស់ធនាគារវីង (Wing Bank) ជាដើម ។ លោកបានចូលរួមជាមួយ អិលអូអិលស៊ី ជាប្រធានផ្នែកគ្រប់គ្រងលទ្ធកម្មក្នុងឆ្នាំ ២០២២ ហើយត្រូវបានតែងតាំងជាប្រធានស្តីទីនៃនាយកដ្ឋានរដ្ឋបាល និងធុរកិច្ច។ ក្រោយមក លោកត្រូវបានតែងតាំងជានាយកនាយកដ្ឋានរដ្ឋបាល និងធុរកិច្ច។

# ០៤. ការប្តេជ្ញាចិត្តឆ្ពោះទៅរក និរន្តរភាព បរិស្ថាន និងសង្គម


តួនាទី និងទំនួលខុសត្រូវនៃផ្នែកគ្រប់គ្រងនិរន្តរភាព បរិស្ថាន និងសង្គម ( ៩២ )

សមិទ្ធផលបរិស្ថាន សង្គម និងអភិបាលកិច្ចក្នុងឆ្នាំ២០២៣ និងគោលដៅឆ្នាំ២០២៤ ( ៩៤ )

តារាងសកម្មភាពដែលត្រូវហាមឃាត់ដោយ អិលអូអិលស៊ី ( ៩៦ )

ការវាយតម្លៃ និងការយល់ដឹងពីហានិភ័យលើ បរិស្ថាន និងសង្គម ( ៩៨ )

សិទ្ធិរបស់អតិថិជន ( ១០០ )

យន្តការនៃការដោះស្រាយបណ្តឹងតវ៉ា ( ១០១ )

ការបណ្តុះវិន័យឥណទានតាមរយៈ A4 METACARD ( ១០២ )

ការប្តេជ្ញាចិត្តរបស់ អិលអូអិលស៊ី ក្នុងការផ្តល់ប្រាក់កម្ចីប្រកបដោយទំនួលខុសត្រូវ ( ១០២ )

ការចូលរួមជាមួយ UNITED NATIONS GLOBAL COMPACT (UNGC) ( ១០៣ )

ការអនុលោមតាមគោលការណ៍ការពារអតិថិជន ( ១០៤ )

ការយល់ដឹងអំពីការអប់រំផ្នែកហិរញ្ញវត្ថុ ( ១០៦ )

ទំនួលខុសត្រូវសង្គម និងសកម្មភាពសង្គមផ្សេងៗទៀត ( ១១០ )

យន្តការត្រួតពិនិត្យ និងតាមដានផលប៉ះពាល់លើបរិស្ថាន ( ១១២ )

ផលិតផលដែលជួយលើកកម្ពស់បរិស្ថាន និងសង្គម ( ១១៤ )

ការចូលរួមលើកកម្ពស់សង្គម ( ១១៦ )

អភិបាលកិច្ច ( ១១៨ )

ការវាយតម្លៃផលប៉ះពាល់របស់ អិលអូអិលស៊ី (ខេមបូឌា) នៅលើបរិស្ថាន និងសង្គម ( ១២០ )

អតិថិជនជោគជ័យ ( ១២៦ )




# តួនាទី និងទំនួលខុសត្រូវរបស់ក្រុមការងារផ្នែកគ្រប់គ្រងនិរន្តរភាព បរិស្ថាន និងសង្គម



- ដឹកនាំការអភិវឌ្ឍនៃយុទ្ធសាស្ត្រការគ្រប់គ្រងនិរន្តរភាព បរិស្ថាន និងសង្គម (SM) ឬបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) រយៈពេលវែងរបស់ អិលអូអិលស៊ី និងគោលនយោបាយការគ្រប់គ្រងនិរន្តរភាព បរិស្ថាន និងសង្គម (SM) ឬបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ទូទាំងក្រុមហ៊ុន រួមទាំងស្តង់ដានៃការប្រព្រឹត្តសម្រាប់បុគ្គលិក។
- ត្រូវប្រាកដថាគោលនយោបាយ និងការអនុវត្តរបស់ អិលអូអិលស៊ី អនុលោមតាមស្តង់ដានៃគោលការណ៍ការការពារអតិថិជន និងបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ផ្សេងទៀត។
- តាមដាន ត្រួតពិនិត្យ និងរាយការណ៍រាល់សកម្មភាពទាក់ទងនឹងបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG)។
- ប្រមូលផ្តុំ និងផ្សព្វផ្សាយការអនុវត្តដ៏ល្អបំផុត/សម្ភារសិក្សាដែលពាក់ព័ន្ធ ដែលធ្វើឱ្យបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) របស់ អិលអូអិលស៊ី ប្រសើរឡើង។
- ធ្វើយ៉ាងណាដើម្បីបន្តធ្វើឱ្យកាន់តែប្រសើរឡើងនូវការយល់ដឹងពីបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) របស់បុគ្គលិក និងពង្រឹងសមត្ថភាពរបស់ពួកគាត់។
- កែច្នៃ អភិវឌ្ឍ និងអនុវត្តវគ្គសិក្សាតម្រង់ទិសនៃមេរៀនបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) សម្រាប់បុគ្គលិកថ្មី និងរៀបចំធ្វើសិក្ខាសាលាសម្រាប់បុគ្គលិកចាស់ ដែលយើងអាចធានាថាបុគ្គលិករបស់ អិលអូអិលស៊ី ត្រូវបានធ្វើបច្ចុប្បន្នភាពយ៉ាងល្អលើការផ្លាស់ប្តូរទាក់ទងនឹងយុទ្ធសាស្ត្រនៃបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG)។
- ប្រមូល និងវិភាគទិន្នន័យស្ថាប័ន អតិថិជន ឧស្សាហកម្ម ដើម្បីលើកកម្ពស់តម្លាភាព ភាពរឹងមាំ និងវាស់វែងការកែលម្អទៅលើបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG)។
- បង្កើត និងធ្វើការវាយតម្លៃទៅលើបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ប្រចាំឆ្នាំ និងរៀបចំរបាយការណ៍នៃបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) សម្រាប់បោះពុម្ព និងផ្សព្វផ្សាយ។
- ធ្វើការណែនាំដល់គណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាលរបស់ អិលអូអិលស៊ី ដោយផ្អែកលើការរកឃើញនៃការវាយតម្លៃបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) និងអនុវត្តការផ្លាស់ប្តូរគោលនយោបាយ និង/ឬនីតិវិធីតាមការចាំបាច់។

**អ្នកស្រី ណុប សុជាតិ**

ជាប្រធានផ្នែកគ្រប់គ្រងនិរន្តរភាព បរិស្ថាន និងសង្គម បានដឹកនាំក្នុងការលើកកម្ពស់ការអនុវត្តការគ្រប់គ្រងនិរន្តរភាពបរិស្ថាន និងសង្គម (SM/ESG) នៅក្នុង អិលអូអិលស៊ី ដោយបានដាក់បញ្ចូលទៅក្នុងគោលនយោបាយ នីតិវិធី និងការអនុវត្តបានយ៉ាងល្អប្រសើរ។



# សមិទ្ធផលបរិស្ថាន សង្គម និងអភិបាលកិច្ចក្នុងឆ្នាំ២០២៣ និងគោលដៅឆ្នាំ២០២៤




| លក្ខណៈវិនិច្ឆ័យ (ESG) | ផ្នែក | សូចនាករប្រចាំឆ្នាំ (KPIs) | សូចនាករត្រូវបានតាមដាន | ការគណនា/ការវាស់វែងលើសូចនាករ | សមិទ្ធផលឆ្នាំ ២០២៣ | គោលដៅឆ្នាំ ២០២៣ | គោលដៅឆ្នាំ ២០២៤ |
|---|---|---|---|---|---|---|---|
| បរិស្ថាន | ការកាត់បន្ថយការបំភាយឧស្ម័នកាបូនិក | ការកាត់បន្ថយការបំភាយឧស្ម័នកាបូនិកតាមរយៈផលិតផលដែលជួយលើកកម្ពស់បរិស្ថាន (tCO2) | ផលិតផលកម្ចី LIL និង LILAB ក្នុងគោលបំណងទិញម៉ូតូកង់បី LPG ឡាន Prius និងម៉ូតូ PCX | # នៃការបំភាយឧស្ម័ន CO2 ដែលបានកាត់បន្ថយគិតជាតោន ហើយវាត្រូវបានបង្កើត និងផ្តល់ដោយ responsAbility (GCPF) ដែលពឹងផ្អែកលើទិន្នន័យដើមរបស់ អិលអូអិលស៊ី (ខេមបូឌា) ដែលបានផ្តល់ជូនទៅពួកគេ | ១០.១៣៧ | >= ៣.៧៥០ | >= ៥.០០០ |
| | ការទទួលបានកម្ចីដែលជួយលើកកម្ពស់បរិស្ថាន | ចំនួនអតិថិជនទទួលបានកម្ចីដែលជួយលើកកម្ពស់បរិស្ថាន | ផលិតផលកម្ចី IL, GL, SME, WIL, SNL, LILAB និង HIL ជាមួយនឹងគោលបំណងនៃប្រសិទ្ធភាពថាមពល ឬថាមពលកកើតឡើងវិញ | # នៃផលិតផលកម្ចី IL, GL, SME, WIL, SNL, LILAB និង HIL ជាមួយនឹងគោលបំណងនៃប្រសិទ្ធភាពថាមពល ឬថាមពលកកើតឡើងវិញ | ១.០៩៤ | >= ១.០០០ | >= ២.០០០ |
| | ការជួយសង្គ្រោះដើមឈើ | កាត់បន្ថយការប្រើប្រាស់ក្រដាស A4 ក្នុងអតិថិជនម្នាក់ | ការប្រើប្រាស់ក្រដាស A4 ក្នុងដំណើរការផ្តល់កម្ចី ក្នុងអតិថិជនម្នាក់ | កាត់បន្ថយការប្រើប្រាស់ក្រដាស A4 ក្នុងដំណើរការផ្តល់កម្ចី ក្នុងអតិថិជនម្នាក់ | ១១២ | <= ១១៥ | <= ១១០ |
| | | វិភាគលើការកាត់បន្ថយការប្រើប្រាស់ក្រដាស A4 ដោយគម្រោង Tablet & អាយផេ និងប្រតិបត្តិការទូទាត់តាមរយៈ PSPs ដើម្បីជួយសង្គ្រោះដើមឈើ | ដំណើរការផ្តល់ប្រាក់កម្ចីតាមរយៈ Tablet សម្រាប់ការបើកគណនីឌីជីថល និងប្រតិបត្តិការទូទាត់តាមរយៈ PSPs | # នៃក្រដាស A4 ត្រូវបានកាត់បន្ថយគិតជារ៉ាម សម្រាប់ដំណើរការផ្តល់ប្រាក់កម្ចីតាមរយៈ Tablet ការបើកគណនីឌីជីថល និងប្រតិបត្តិការទូទាត់តាមរយៈ PSPs | ៣.៥៣៤ | >= ២.៥០០ | >= ៣.៥០០ |





| លក្ខណៈវិនិច្ឆ័យ (ESG) | ផ្នែក | សូចនាករប្រចាំឆ្នាំ (KPIs) | សូចនាករត្រូវបានតាមដាន | ការគណនា/ការវាស់វែងលើសូចនាករ | សមិទ្ធផលឆ្នាំ២០២៣ | គោលដៅឆ្នាំ២០២៣ | គោលដៅឆ្នាំ២០២៤ |
|---|---|---|---|---|---|---|---|
| សង្គម | ការទទួលបានទឹកស្អាត | ចំនួនអតិថិជនដែលទទួលបានទឹកស្អាតអនាម័យ ផុងចម្រោះទឹក និងទឹកប្រើប្រាស់ក្នុងផ្ទះតាមរយៈកម្ចីទឹកស្អាត និងអនាម័យ | ផលិតផលកម្ចី IL, GL, SME, WIL, SNL, LILAB និង HIL ក្នុងគោលបំណងសម្រាប់ទឹកស្អាត និងអនាម័យ | # នៃការផ្តល់កម្ចីនូវប្រភេទផលិតផល IL, GL, SME, WIL, SNL, LILAB និង HIL ក្នុងគោលបំណងសម្រាប់ទឹកស្អាត និងអនាម័យ | ២.៦៨៥ | >= ២.៥០០ | >= ៣.០០០ |
| | ការបង្កើតការងារ | ចំនួនបុគ្គលិក អិលអូអិលស៊ី សរុប និងការបង្កើតការងារ/កម្មករដោយអតិថិជនរបស់ អិលអូអិលស៊ី (គិតត្រឹមរយៈពេលចុងក្រោយ) | បុគ្គលិក អិលអូអិលស៊ី និង ការបង្កើតការងារដោយអតិថិជនរបស់ អិលអូអិលស៊ី | ចំនួនបុគ្គលិក អិលអូអិលស៊ី និងការបង្កើតការងារដោយអតិថិជន អិលអូអិលស៊ី | ៥៤៨.០៥០ | >=៥០០.០០០ | >= ៥៥០.០០០ |
| | អតិថិជនជាស្ត្រី | ភាគរយនៃអ្នកខ្ចីជាស្ត្រី | អ្នកខ្ចីជាស្ត្រី | ភាគរយនៃអ្នកខ្ចីជាស្ត្រី | ៧០% | >= ៦៥% | >= ៦៥% |
| | ការផ្តល់ប្រាក់កម្ចីដល់ប្រជាជនក្រីក្រ | ភាគរយនៃអ្នកខ្ចីនៅតំបន់ជនបទ | អ្នកខ្ចីនៅតំបន់ជនបទ | ភាគរយនៃអ្នកខ្ចីនៅតំបន់ជនបទដោយទិន្នន័យជំរឿនទូទៅប្រជាជនកម្ពុជាឆ្នាំ២០១៩ | ៧៩% | >= ៧០% | >= ៧០% |
| | | ភាគរយនៃអតិថិជនក្រោមខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ (NPL) ១៥០% | អតិថិជនក្រោមខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ (NPL) ១៥០% | ភាគរយនៃអតិថិជនក្រោមខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ (NPL) ១៥០% ដោយឧបករណ៍ PPI | ២៦,២៤% | >= ២០% | >= ២០% |
| | អតិថិជនចូលរួមក្នុង វិស័យកសិកម្ម | ភាគរយនៃអ្នកខ្ចីដែលយកទៅប្រើប្រាស់ក្នុងវិស័យកសិកម្ម | អ្នកខ្ចីដែលយកទៅប្រើប្រាស់ក្នុងវិស័យកសិកម្ម | ភាគរយនៃអ្នកខ្ចីដែលយកទៅប្រើប្រាស់ក្នុងវិស័យកសិកម្ម | ៤៩% | >= ៤០% | >= ៤០% |
| | ការទទួលការអប់រំ | ផ្តល់ការយល់ដឹងអំពីការអប់រំផ្នែកហិរញ្ញវត្ថុដល់អតិថិជនសហគមន៍ និងយុវជន | ការយល់ដឹងអំពីការអប់រំផ្នែកហិរញ្ញវត្ថុដល់អតិថិជនសហគមន៍ និងយុវជន | ចំនួនវគ្គបណ្តុះបណ្តាលនៃការយល់ដឹងអំពីការអប់រំផ្នែកហិរញ្ញវត្ថុដល់អតិថិជនសហគមន៍ និងយុវជន | ២៤១ | >= ២០០ | >= ២៥០ |
| | | ពង្រឹងការយល់ដឹងផ្នែកហិរញ្ញវត្ថុដល់បុគ្គលិក | វគ្គបណ្តុះបណ្តាលនៃការយល់ដឹងផ្នែកហិរញ្ញវត្ថុដល់បុគ្គលិក | ចំនួនវគ្គបណ្តុះបណ្តាលនៃការយល់ដឹងផ្នែកហិរញ្ញវត្ថុដល់បុគ្គលិក | គ្មាន | គ្មាន | >= ៦ |
| | | ចែករំលែកចំណេះដឹងផ្នែកហិរញ្ញវត្ថុសំខាន់ៗដល់អតិថិជន និងសាធារណជន | ចែករំលែកសារសំខាន់ៗនៃចំណេះដឹងផ្នែកហិរញ្ញវត្ថុ ដល់អតិថិជន និងសាធារណជនតាមរយៈទំព័រហ្វេសប៊ុករបស់ អិលអូអិលស៊ី (LOLC Facebook Page) | ចំនួនផុស (Post) សារសំខាន់ៗនៃចំណេះដឹងផ្នែកហិរញ្ញវត្ថុ ដល់អតិថិជន និងសាធារណជនតាមរយៈទំព័រហ្វេសប៊ុករបស់ អិលអូអិលស៊ី (LOLC Facebook Page) | គ្មាន | គ្មាន | >= ៧០០ |
| | | ចំនួនវគ្គបណ្តុះបណ្តាលខាងក្នុង និងខាងក្រៅសម្រាប់បុគ្គលិក | វគ្គបណ្តុះបណ្តាលខាងក្នុងនិងខាងក្រៅសម្រាប់បុគ្គលិក | ចំនួនវគ្គបណ្តុះបណ្តាលខាងក្នុងនិងខាងក្រៅសម្រាប់បុគ្គលិក | ១.៩៩២ | ១.៣០០ | >= ១.៥០០ |
| | | ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីដំណើរការផ្តល់ប្រាក់កម្ចី/SM/CPP ដល់បុគ្គលិក | វគ្គបណ្តុះបណ្តាលស្តីពីដំណើរការផ្តល់ប្រាក់កម្ចី/SM/CPP សម្រាប់បុគ្គលិក។ | ចំនួនវគ្គបណ្តុះបណ្តាលស្តីពីដំណើរការផ្តល់ប្រាក់កម្ចី/SM/CPP សម្រាប់បុគ្គលិក | គ្មាន | គ្មាន | >= ៦ |
| | | បង្កើតវីដេអូ/ការបង្ហាញការយល់ដឹងអំពីហិរញ្ញវត្ថុដល់អតិថិជន និងសាធារណជន | បង្កើតវីដេអូ/ការបង្ហាញការយល់ដឹងអំពីហិរញ្ញវត្ថុដល់អតិថិជន និងសាធារណជនតាមរយៈទំព័រហ្វេសប៊ុក អិលអូអិលស៊ី (LOLC Facebook Page) | ចំនួនវីដេអូ/ការបង្ហាញការយល់ដឹងអំពីហិរញ្ញវត្ថុដល់អតិថិជននិងសាធារណជនតាមរយៈ ទំព័រហ្វេសប៊ុក អិលអូអិលស៊ី (LOLC Facebook Page) | ៤ | >= ៤ | >= ៦ |
| | ផលប៉ះពាល់ដល់សហគមន៍ | ការចូលរួមចំណែកជួយដល់សហគមន៍ | ព្រឹត្តិការណ៍សហគមន៍ និងសកម្មភាពសង្គមផ្សេងទៀត (CSR) | ចំនួនព្រឹត្តិការណ៍សហគមន៍ និងសកម្មភាពសង្គមផ្សេងទៀត (CSR) | ៣៣ | >= ២៤ | >= ២៤ |
| | លទ្ធភាពទទួលបានហិរញ្ញវត្ថុ | ភាគរយនៃអតិថិជនថ្មីអាចទទួលបានសេវាហិរញ្ញវត្ថុមិនថាប្រាក់បញ្ញើ ឬឥណទាន | អតិថិជនថ្មីអាចទទួលបាន សេវាហិរញ្ញវត្ថុមិនថាប្រាក់បញ្ញើ ឬឥណទាន | ចំនួនអតិថិជនថ្មីអាចទទួលបាន សេវាហិរញ្ញវត្ថុមិនថាប្រាក់បញ្ញើ ឬឥណទាន | ១៣,៤៥% | >= ៧,៥០% | >= ៧,៥% |

| លក្ខណៈវិនិច្ឆ័យ (ESG) | ផ្នែក | សូចនាករប្រចាំឆ្នាំ (KPIs) | សូចនាករត្រូវបានតាមដាន | ការគណនា/ការវាស់វែងលើសូចនាករ | សមិទ្ធផលឆ្នាំ ២០២៣ | គោលដៅឆ្នាំ ២០២៣ | គោលដៅឆ្នាំ ២០២៤ |
|---|---|---|---|---|---|---|---|
| | ស្ថានភាពរស់នៅកាន់តែប្រសើរឡើង | ការវិភាគលើប្រាក់ចំណូលរបស់អតិថិជន | ចំណូលរបស់អតិថិជន | អត្រាកំណើននៃការបង្កើតប្រាក់ចំណូលរបស់អតិថិជន | អត្រាកំណើនប្រាក់ចំណូលជាមធ្យម ៦,៨៩% | >= ទំហំគំរូនៃអតិថិជនយ៉ាងហោចណាស់មាន ចំនួន ៥.០០០ នាក់ | >= ទំហំគំរូនៃអតិថិជនយ៉ាងហោចណាស់មាន ចំនួន ៥.០០០ នាក់ |
| | | ចំនួនអតិថិជនដែលមានស្ថានភាពផ្ទះ កាន់តែប្រសើរឡើងតាមរយៈប្រាក់កម្ចីកែលម្អគេហដ្ឋាន និងប្រាក់កម្ចីគេហដ្ឋាន | ផលិតផលកម្ចី HIL និង HL | ចំនួនកម្ចីសម្រាប់ផលិតផល HIL និង HL | ៣.៦២៨ | >= ៣.៥០០ | >= ៣.៥០០ |
| អភិបាលកិច្ច | អភិបាលឯករាជ្យ | ចំនួនអភិបាលឯករាជ្យ | អភិបាលឯករាជ្យ | ចំនួនអភិបាលឯករាជ្យ | ២ | >= ២ | >= ២ |

# តារាងសកម្មភាពដែលត្រូវហាមឃាត់ដោយ អិលអូអិលស៊ី

អិលអូអិលស៊ី (ខេមបូឌា) បានបង្កើតតារាងសកម្មភាពដែលត្រូវបានហាមឃាត់ ក្នុងការផ្តល់ហិរញ្ញប្បទានចំពោះសកម្មភាពដែលមានផលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថាន និងសង្គម។ ស្ថាប័នមានវិធានការតឹងរឹងដើម្បីទប់ស្កាត់ការផ្តល់កម្ចីសម្រាប់សកម្មភាពដែលត្រូវបានហាមឃាត់ ដោយប្រាក់កម្ចីទាំងអស់ត្រូវបានវាយតម្លៃដោយបុគ្គលិកផ្ទាល់ និងត្រូវបានពិនិត្យដោយថ្នាក់លើធៀបនឹងតារាងសកម្មភាពដែលត្រូវបានហាមឃាត់ និងវាយតម្លៃចុងក្រោយលើផលប៉ះពាល់បរិស្ថាន និងសង្គម។

| លរ | សកម្មភាពដែលត្រូវហាមឃាត់ដោយ អិលអូអិលស៊ី |
|---|---|
| ១ | ការផលិត ឬការជួញដូរដែលផលិតផល ឬសកម្មភាពណាមួយត្រូវចាត់ទុកថាជាសកម្មភាពខុសច្បាប់ចែងដោយច្បាប់ ឬបទប្បញ្ញត្តិរបស់ប្រទេស ឬអនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិរួមបញ្ចូលតែមិនកំណត់លើតម្រូវការរបស់ប្រទេសពាក់ព័ន្ធនឹងបរិស្ថាន សុខភាព សុវត្ថិភាព និងវិស័យការងារ។ |
| ២ | ការផលិត ឬការជួញដូរអាវុធ និងគ្រាប់រំសេវ។ |
| ៣ | ការផលិត ឬការជួញដូរគ្រឿងស្រវឹង (មិនរួមបញ្ចូលស្រាបៀរ និងស្រា)។ |
| ៤ | ការផលិត ឬការជួញដូរថ្នាំជក់។ |
| ៥ | ល្បែងស៊ីសង កាស៊ីណូ និងអាជីវកម្មប្រហាក់ប្រហែល។ |
| ៦ | ការផលិត ការជួញដូរ ការបង្កាត់ពូជ ឬការកាន់កាប់សត្វ រុក្ខជាតិ ឬផលិតផលធម្មជាតិណាមួយ ដែលមានចែងដោយ អនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វព្រៃ និងរុក្ខជាតិជិតផុតពូជ (CITIES) ។ |
| ៧ | ការផលិត ឬការជួញដូរសារធាតុវិទ្យុសកម្ម។ |
| ៨ | ការផលិត ឬការជួញដូរ ឬការប្រើប្រាស់សារធាតុមិនរលាយហួសកម្រិត។ |
| ៩ | ការធ្វើអាជីវកម្មកាប់ព្រៃឈើលក្ខណៈពាណិជ្ជកម្ម ឬការទិញឧបករណ៍កាប់ឈើសម្រាប់ប្រើប្រាស់នៅក្នុងតំបន់ត្រូពិក។ |
| ១០ | ការផលិត ឬការជួញដូរឱសថ ដែលអន្តរជាតិបញ្ឈប់ ឬហាមឃាត់។ |
| ១១ | ការផលិត ឬការជួញដូរថ្នាំសម្លាប់សត្វល្អិត/ថ្នាំសម្លាប់ស្មៅដែលអន្តរជាតិបញ្ឈប់ ឬហាមឃាត់។ |
| ១២ | ការបង់សំណាញ់នេសាទនៅក្នុងសមុទ្រ ដែលមានប្រវែងលើសពី ២,៥ គ.ម។ |
| ១៣ | ការផលិត ឬការធ្វើសកម្មភាពដែលប៉ះពាល់ធ្ងន់ធ្ងរ ឬក្នុងទម្រង់កេងប្រវ័ញ្ចលើការងារដោយបង្ខំ/ប៉ះពាល់ធ្ងន់ធ្ងរលើពលកម្មកុមារ។ |
| ១៤ | ការផលិត ឬការជួញដូរផលិតផលដែលមានសារធាតុគីមី ប៉ូលីក្លូរីនប៊ីហ្វីនីល Polychlorinated Biphenyls (PCBs)។ |
| ១៥ | ការផលិត ឬការជួញដូរអាជីវកម្មណាដែលបំផ្លាញដល់ស្រទាប់អូហ្សូនត្រូវបានហាមឃាត់ដោយអន្តរជាតិ។ |
| ១៦ | ការផលិត ឬការជួញដូរឈើ ឬផលិតផលបានមកពីព្រៃឈើ។ |
| ១៧ | ការផលិត ការជួញដូរ ការស្តុកទុក ឬការដឹកជញ្ជូនសារធាតុគីមីដែលមានគ្រោះថ្នាក់លើសបរិមាណកំណត់ ឬការប្រើប្រាស់សារធាតុគីមីគ្រោះថ្នាក់ក្នុងពាណិជ្ជកម្ម។ សារធាតុគីមីដែលមានគ្រោះថ្នាក់រួមមាន៖ ប្រេងសាំង ប្រេងកាត និងផលិតផលប្រេងផ្សេងទៀត។ |
| ១៨ | ការផលិត ឬការធ្វើសកម្មភាពដែលប៉ះពាល់ដល់ដីកម្មសិទ្ធិ និងទីតាំងដែលមានតម្លៃរបស់សហគមន៍ ឬសហគមន៍ជនជាតិដើមភាគតិច ឬការទាមទារតាមផ្លូវច្បាប់ណាមួយដោយគ្មានឯកសារព្រមព្រៀងពេញលេញពីជនជាតិដើមភាគតិច ។ |
| ១៩ | សកម្មភាពអាជីវកម្មដែលបង្កឱ្យមានបញ្ហាជម្លោះដីធ្លី ការបាត់បង់ដីធ្លី ការបាត់បង់សិទ្ធិកាន់កាប់ដីធ្លី ការបាត់បង់ឱកាសក្នុងការទទួលអត្ថប្រយោជន៍ពីការបាត់បង់ដីធ្លី មិនអាចរស់នៅអាស្រ័យផល ឬប្រកបអាជីវកម្មបាន និងសកម្មភាពអាជីវកម្មដែលបង្កជម្លៀសពីតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត។ |
| ២០ | សកម្មភាពអាជីវកម្មណាមួយដែលពាក់ព័ន្ធនឹងរូបភាពអាសអាភាស ឬពេស្យាចារ។ |
| ២១ | ជំនួញដែលទាក់ទងនឹងសារធាតុពុល ដូចជាការបំភាយឧស្ម័នផ្ទះកញ្ចក់ (GHG) កាបូន (Co2) ការបំពុលទឹក និងការបំពុលដី។ |
| ២២ | គម្រោងដាំដុះនានា ដែលតម្រូវឱ្យមានការកាប់ទន្ទ្រានព្រៃធម្មជាតិ។ |
| ២៣ | ការជួញដូរឆ្លងដែននូវកាកសំណល់ លើកលែងតែការជួញដូរណាដែលអនុញ្ញាតដោយអនុសញ្ញាBALSE និងបទបញ្ញត្តិផ្សេងៗដែលបានចែង។ |
| ២៤ | សកម្មភាពអាជីវកម្មក្នុងការផលិត និងបង្កឱ្យមានកាកសំណល់រឹង និងរាវដែលមានទំហំធំធេង។ |
| ២៥ | សកម្មភាពអាជីវកម្មដែលអាចបង្កឱ្យមានការផ្ទុះ ឬបញ្ចេញធូលី ផ្សែង ក្លិនកខ្វក់ និងសំឡេងរំខានខ្លាំង ដែលបង្កឱ្យមានផលប៉ះពាល់ដល់សុខភាព សុវត្ថិភាពការងារ និងការរស់នៅប្រចាំថ្ងៃរបស់ប្រជាជននៅជុំវិញតំបន់ទីតាំងអាជីវកម្ម។ |
| ២៦ | សកម្មភាពអាជីវកម្មដែលមានការប្រើប្រាស់ ទឹក ក្រដាស អគ្គិសនីមានទំហំច្រើនដែលបណ្តាលឱ្យមានការរំខានទៅដល់អ្នកដែលរស់នៅក្បែរតំបន់ទីតាំងអាជីវកម្ម។ សកម្មភាពប៉ះពាល់ ឬកេងប្រវ័ញ្ចធនធានធម្មជាតិហួសហេតុ។ |
| ២៧ | ការផលិត និងការចែកចាយ ឬការចូលរួមក្នុងសកម្មភាពរើសអើងពូជសាសន៍ ប្រព័ន្ធផ្សព្វផ្សាយលើការប្រឆាំងលទ្ធិប្រជាធិបតេយ្យ ឬប្រព័ន្ធផ្សព្វផ្សាយណាដែលរើសអើងក្រុមណាមួយរបស់ប្រជាជន។ |
| ២៨ | វិស័យដែលជាប់ពាក់ព័ន្ធនឹងផលប៉ះពាល់តិចតួច មានហានិភ័យខ្ពស់ និង/ឬជាកម្មវត្ថុនៃការរំពឹងទុកណាមួយ ឧ. វិស័យអចលនទ្រព្យ។ |
| ២៩ | ការផលិត ឬសេវាកម្មណាមួយដែលត្រូវបានសន្មត់ ឬនាំឱ្យខូចខាតធ្ងន់ធ្ងរដល់បរិស្ថានធម្មជាតិ ហើយត្រូវហាមឃាត់ដោយច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។ |
| ៣០ | គម្រោងពាក់ព័ន្ធនឹងការសាងសង់ទំនប់វារីអគ្គិសនីទំហំធំដែលមានផលប៉ះពាល់ខ្លាំង និងមិនអាចកែប្រែត្រឡប់មកសភាពដើមវិញ។ |
| ៣១ | ការធ្វើគម្រោង ឬការធ្វើឱ្យប៉ះពាល់ ឬបាត់បង់សម្បត្តិបេតិកភណ្ឌពិភពលោក បេតិកភណ្ឌវប្បធម៌ ដូចជាទីសក្ការបូជា ដីអាស្រ័យផល ភូមិឋាន ឬសហគមន៍។ |
| ៣២ | ការធ្វើគម្រោង ឬការធ្វើឱ្យប៉ះពាល់ដល់ឧទ្យានជាតិ ឬតំបន់ការពារ ដែលមានចុះក្នុងបញ្ជីរបស់អង្គការសហប្រជាជាតិ។ |
| ៣៣ | ការដកចេញ ឬការសាងសង់គម្រោងរចនាសម្ព័ន្ធ ឬការធ្វើឱ្យប៉ះពាល់ដល់ តំបន់ការពារ មានកំណត់នៅផ្នែក ទី១, ២, ៣ និង៤ ដោយសហភាពអន្តរជាតិសម្រាប់ការអភិរក្សធម្មជាតិ។ |
| ៣៤ | សកម្មភាពអាជីវកម្មដែលប៉ះពាល់ដល់បរិស្ថានធ្ងន់ធ្ងរ ដែលបង្កឱ្យមានការបាត់បង់ជីវិត ទីជម្រក និងជំពូកសត្វគ្រប់ប្រភេទ។ សកម្មភាពបង្កឱ្យមានការកើនឡើងនូវប្រភេទសត្វចង្រៃ ការរុករាននូវប្រភេទសត្វចម្លែក ការរីករាលដាលជម្ងឺរាលត្បាត/អាសន្នរោគ។ |
| ៣៥ | មានទីតាំងនៅ ឬនៅជិតទីតាំងដែលងាយរងផលប៉ះពាល់ដល់តំបន់ជាតិ ឬភូមិសាស្ត្រសំខាន់ ដែលអាចបណ្តាលឱ្យមានផលប៉ះពាល់ដល់បរិស្ថាន។ |
| ៣៦ | សូកប៉ាន់ ឬទទួលសំណូក ដែលអាចបកស្រាយបានថាផ្តល់ឥទ្ធិពលដល់ការសម្រេចចិត្តអាជីវកម្ម ។ |
| ៣៧ | ចូលរួមវិភាគទានក្នុងនយោបាយ។ ឧទាហរណ៍៖ គណបក្សនយោបាយ ឬបេក្ខជនតំណាងរាស្ត្រ។ |

| | |
|---|---|
| ៣៨ | ប្រើប្រាស់ព័ត៌មាន ឬឯកសារសម្ងាត់ ឬព័ត៌មានដែលមិនតម្រូវឱ្យផ្សព្វផ្សាយជាសាធារណៈ។ |
| ៣៩ | បទល្មើសខាងផ្នែកហិរញ្ញវត្ថុ ឬសេដ្ឋកិច្ច រួមបញ្ចូលទាំងបទល្មើសដែលពាក់ព័ន្ធនឹងការសម្អាតប្រាក់។ |
| ៤០ | ការកត់ត្រា ឬរាយការណ៍នូវព័ត៌មានហិរញ្ញវត្ថុ ឬពន្ធខុសច្បាប់ ឬក្លែងបន្លំ។ |
| ៤១ | ប្រតិបត្តិការអាជីវកម្មដែលដាក់តម្លៃទំនិញ ឬសេវាកម្មទាប ឬខ្ពស់ហួសហេតុ។ |
| ៤២ | ឧបករណ៍ ឬវិស័យ ឬសេវាកម្មផ្សេងៗ ដែលរងទណ្ឌកម្មសេដ្ឋកិច្ចពីអង្គការសហប្រជាជាតិ សហភាពអឺរ៉ុប ឬប្រទេសបារាំង ដោយមិនអាស្រ័យលើទំហំបរិមាណ។ |
| ៤៣ | ការជួញដូរខុសច្បាប់ ឬសកម្មភាពដែលជួយសម្រួលដល់ការចរាចរណ៍ខុសច្បាប់នៃទ្រព្យសម្បត្តិវប្បធម៌។ |
| ៤៤ | សកម្មភាពខុសច្បាប់ដែលពាក់ព័ន្ធនឹងសរីរាង្គ ជាលិកា និងផលិតផលនៃរាងកាយមនុស្ស ឬសកម្មភាពវិស្វកម្មហ្សែនដែលត្រូវបានហាមឃាត់ដោយស្តង់ដាជីវវិទ្យាជាតិនៃប្រទេសបារាំង ឬនៃប្រទេសដែលជាម្ចាស់ផ្ទះ និងតាមស្តង់ដាអឺរ៉ុប ឬអន្តរជាតិដែលអាចអនុវត្តបាន។ |
| ៤៥ | គម្រោងផ្សេងៗ និងករណីការផ្តល់ហិរញ្ញប្បទានពីវិស័យឯកជន ដែលមានគោលបំណង និង/ឬវិធីសាស្ត្រប្រឆាំងនឹងសិទ្ធិមនុស្ស និងគាំទ្រហេតុផលដែលផ្ទុយយ៉ាងច្បាស់ពីគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីអាជីវកម្ម និងសិទ្ធិមនុស្ស។ |
| ៤៦ | ការផលិតថាមពលឥន្ទនៈហ្វូស៊ីលទាំងអស់ ( ក្រោម ៥០០តោនត្រូវបានរួមបញ្ចូល)។ |

# ការវាយតម្លៃ និងការយល់ដឹងពីហានិភ័យលើបរិស្ថាន និងសង្គម

ការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន និងសង្គម ត្រូវបានអនុវត្តលើគ្រប់ប្រភេទឥណទានទាំងអស់របស់ អិលអូអិលស៊ី។ សម្រាប់ឥណទានដែលមានទំហំទាបជាង ៣០.០០០ដុល្លារអាមេរិក ការយល់ដឹងទាក់ទងនឹងបរិស្ថាន និងសង្គមនឹងត្រូវបានលើកយកមកពិភាក្សាជាមួយអតិថិជនដើម្បីឱ្យអតិថិជនទទួលបាននូវការយល់ដឹងពាក់ព័ន្ធនឹងហានិភ័យ និងផ្តល់យោបល់ណែនាំដើម្បីធ្វើការកែលម្អឱ្យកាន់តែប្រសើរឡើង។

សម្រាប់ឥណទានសហគ្រាសធុនតូច និងមធ្យម (SME) ដែលមានទំហំចាប់ពី ៣០.០០០ដុល្លារអាមេរិក ការប្រើប្រាស់ឧបករណ៍វិភាគនឹងត្រូវអនុវត្តយ៉ាងពេញលេញនៅក្នុងដំណើរការផ្តល់ឥណទាន។ ការវាយតម្លៃលម្អិតនេះត្រូវបានធ្វើឡើងដើម្បីពិនិត្យមើលលើផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គម ថាតើស្ថិតនៅក្នុងកម្រិតទាប មធ្យម ឬខ្ពស់ជាមួយនឹងការផ្តល់យោបល់ណែនាំដើម្បីកែលម្អ។ ការបន្តអនុវត្តលើការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន និងសង្គមត្រូវបានត្រួតពិនិត្យជាប្រចាំ។

| ការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម | ចំនួនប្រាក់កម្ចី | សម្គាល់ |
|---|---|---|
| ទាប | ៨៤ | • ការគ្រប់គ្រងហានិភ័យរបស់អតិថិជនមានគុណភាពខ្ពស់។<br>• ហានិភ័យរបស់អតិថិជនមានកម្រិតទាប។ ដូច្នេះមិនតម្រូវឱ្យមានវិធានការអ្វីទេ។ |
| មធ្យម | ៥៨ | • គុណភាពនៃការគ្រប់គ្រងហានិភ័យរបស់អតិថិជនមានចាប់ពីកម្រិតមធ្យមទៅខ្ពស់។ |
| ខ្ពស់ | ០ | គ្មាន |
| សរុប | ១៤២ | |





ក្រាហ្វិករបស់យើងខាងក្រោមនេះបង្ហាញពីចំនួននៃផ្នែកហានិភ័យលើប្រាក់កម្ចីដែលបានវាយតម្លៃសម្រាប់ប្រភេទអាជីវកម្មដែលប្រឈមមុខនឹងផ្នែកផ្សេងៗនៃការប៉ះពាល់ដល់បរិស្ថានដូចជា៖




- បរិស្ថាន [E]
- បរិស្ថាន សុខភាព និងសុវត្ថិភាព [E] និង H&S]
- សុខភាព និងសុវត្ថិភាព [H&S] និង
- កម្លាំងពលកម្ម [L]

សរុបមក ផលប៉ះពាល់លើបរិស្ថាន និងសង្គមរបស់អតិថិជន អិលអូអិលស៊ី (ខេមបូឌា) មិនស្ថិតក្នុងហានិភ័យកម្រិតខ្ពស់នោះទេ។

## សិទ្ធិរបស់អតិថិជន



អិលអូអិលស៊ី បានបង្កើត និងបង្ហាញសិទ្ធិអតិថិជននៅលើគេហទំព័ររបស់ខ្លួន និងនៅលើថង់ច្រកឯកសារកម្ចីដែលផ្តល់ជូនគ្រប់អតិថិជន។ អតិថិជនត្រូវបានជូនដំណឹងយ៉ាងច្បាស់អំពីសិទ្ធិរបស់ពួកគេមុន ឬក្រោយពេលផ្តល់ប្រាក់កម្ចី។ អតិថិជន អិលអូអិលស៊ី ទាំងអស់ត្រូវបានផ្តល់សិទ្ធិដូចខាងក្រោម៖

- សិទ្ធិយល់ដឹងពីតម្លៃសេវាកម្ម និងលក្ខខណ្ឌប្រាក់កម្ចីទាំងអស់មុនពេលទទួលប្រាក់។
- សិទ្ធិមិនទទួលយកប្រាក់កម្ចី។
- សិទ្ធិតវ៉ា ឬសួរសំណួរដើម្បីបញ្ជាក់ពីសេវាកម្មផ្សេងៗរបស់ អិលអូអិលស៊ី។
- សិទ្ធិទទួលបានតារាងកាលវិភាគសងប្រាក់ និងឯកសារសំខាន់ផ្សេងៗនៅពេលទទួលប្រាក់កម្ចី និងបង្កាន់ដៃទទួលប្រាក់រាល់ពេលបង់ប្រាក់។
- សិទ្ធិទទួលបាននូវភាពស្មើគ្នា ការយកចិត្តទុកដាក់ និងការគោរពដោយគ្មានការរើសអើងពីបុគ្គលិក អិលអូអិលស៊ី ឡើយ។
- មានទំនុកចិត្តថា អិលអូអិលស៊ី នឹងរក្សាការសម្ងាត់ព័ត៌មានប្រាក់កម្ចី និងព័ត៌មានផ្ទាល់ខ្លួន។

## យន្តការនៃការដោះស្រាយបណ្តឹងតវ៉ា



អិលអូអិលស៊ី បានបង្កើតយន្តការនៃការដោះស្រាយបណ្តឹងតវ៉ាដ៏ទូលំទូលាយមួយ ដើម្បីជួយសម្រួលដល់អតិថិជនក្នុងការផ្តល់មតិកែលម្អ ឬបណ្តឹងតាមរយៈមធ្យោបាយផ្សេងៗ។ រាល់មតិកែលម្អ និងបណ្តឹងដែលទទួលបានត្រូវបានដោះស្រាយភ្លាមៗ និងអនុលោមតាមបទប្បញ្ញត្តិពាក់ព័ន្ធ។ អតិថិជនអាចធ្វើការផ្តល់មតិកែលម្អ និងបណ្តឹងរបស់ពួកគេតាមរយៈមធ្យាបាយដូចខាងក្រោម៖

- មធ្យោបាយ អិលអូអិលស៊ី៖ ប្រអប់ផ្តល់យោបល់, ជួបផ្ទាល់, លេខទូរសព្ទ Hotline (០២៣ ៩៩១ ៩៩០), អ៊ីម៉ែល (info@lolc.com.kh), គេហទំព័រ (www.lolc.com.kh), ហ្វេសប៊ុក (LOLC Cambodia)។
- បណ្តាញខាងក្រៅ៖ សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA): ០១៥ ៣៦៥ ២២២ និងធនាគារជាតិនៃកម្ពុជា (NBC): ០២៣ ៧២២ ៥៦៣ / ០២៣ ៧២២ ២២១។

# ការបណ្តុះវិន័យឥណទានតាមរយៈ A4 Metacard




អិលអូអិលស៊ី តែងតែផ្តល់តម្លៃលើការយល់ដឹងរបស់អតិថិជនអំពីលក្ខខណ្ឌផ្សេងៗ មុនពេលទទួលយកប្រាក់កម្ចី។ ដើម្បីគាំទ្រដល់អតិថិជនដែលការអប់រំរបស់គាត់នៅមានកម្រិត អិលអូអិលស៊ី បានផ្តល់នូវការបណ្តុះបណ្តាលវិន័យឥណទានដោយប្រើឧបករណ៍ជំនួយដូចជា A4 Metacard ដើម្បីឱ្យពួកគាត់យល់កាន់តែច្បាស់អំពីលក្ខខណ្ឌផ្សេងៗដូចជា លក្ខណៈពិសេសរបស់ផលិតផលប្រាក់កម្ចី អត្រាការប្រាក់ ចន្លោះពេលរង់ចាំទុនរយៈពេលខ្លី លក្ខខណ្ឌមួយចំនួន ព័ត៌មាននៅក្នុងកិច្ចព្រមព្រៀងប្រាក់កម្ចី តារាងសកម្មភាពដែលបានហាមឃាត់ដោយ អិលអូអិលស៊ី ការយល់ដឹងអំពីបរិស្ថាន និងសង្គមជាដើម។ លើសពីនេះ ការណែនាំជាវីដេអូនៃការប្រើប្រាស់ឧបករណ៍ជំនួយដូចជា A4-Metacard ត្រូវបានបង្ហាញនៅលើគេហទំព័ររបស់ អិលអូអិលស៊ី ផងដែរ។

# ការប្តេជ្ញាចិត្តរបស់ អិលអូអិលស៊ី ក្នុងការផ្តល់ប្រាក់កម្ចីប្រកបដោយទំនួលខុសត្រូវ

ស្របតាមការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះការអនុវត្តការផ្តល់ប្រាក់កម្ចីប្រកបដោយទំនួលខុសត្រូវ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី បានចូលរួមយ៉ាងសកម្មនៅក្នុងវគ្គបណ្តុះបណ្តាលស្តីពី ការផ្តល់ប្រាក់កម្ចីប្រកបដោយទំនួលខុសត្រូវ ដែលបង្កើតឡើងដោយវិទ្យាស្ថានធនាគារជាតិ និងហិរញ្ញវត្ថុ (IBF) ហើយមានការគាំទ្រពីធនាគារជាតិនៃកម្ពុជា (NBC) សមាគមធនាគារនៅកម្ពុជា (ABC) និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA)។ គិតត្រឹមខែធ្នូ ឆ្នាំ២០២៣ មានបុគ្គលិកចំនួន ១.៣០៨នាក់បានចូលរួមវគ្គបណ្តុះបណ្តាលនេះ។ វគ្គនេះត្រូវបានរៀបចំឡើងដើម្បីប្រកាន់ខ្ជាប់នូវក្របខ័ណ្ឌបទប្បញ្ញត្តិដ៏ទូលំទូលាយដែលបង្ហាញពីគោលការណ៍ និងការណែនាំសំខាន់ៗសម្រាប់ការផ្តល់ប្រាក់កម្ចីប្រកបដោយការទទួលខុសត្រូវនៅក្នុងវិស័យហិរញ្ញវត្ថុ។ អិលអូអិលស៊ី គ្រោងនឹងបញ្ជូនបុគ្គលិកដែលមិនទាន់បានចូលរួមវគ្គបណ្តុះបណ្តាលដ៏សំខាន់បែបនេះនៅដើមឆ្នាំ២០២៤។

តាមរយៈវគ្គនេះ បុគ្គលិកទទួលបានការយល់ដឹងដ៏មានតម្លៃចំពោះការអនុវត្តការផ្តល់ប្រាក់កម្ចីប្រកបដោយទំនួលខុសត្រូវ ដើម្បីការពារអតិថិជនពីឥរិយាបថហិរញ្ញវត្ថុនៃការផ្តល់ប្រាក់កម្ចីមិនសមរម្យ។

ទាំងអស់នេះបានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់ អិលអូអិលស៊ី ក្នុងការក្លាយជាស្ថាប័នផ្តល់ប្រាក់កម្ចីប្រកបដោយវិជ្ជាជីវៈ និងទំនួលខុសត្រូវ។





# ការចូលរួមជាមួយ UNITED NATIONS GLOBAL COMPACT (UNGC)

United Nations Global Compact (UNGC) គឺជាគំនិតផ្តួចផ្តើមចីរភាពនៃសាជីវកម្មដ៏ធំបំផុតរបស់ពិភពលោក។ ការអំពាវនាវដល់ក្រុមហ៊ុននានាឱ្យតម្រឹមយុទ្ធសាស្ត្រ និងប្រតិបត្តិការជាមួយគោលការណ៍សកលស្តីពីសិទ្ធិមនុស្ស ការងារ បរិស្ថាន និងការប្រឆាំងអំពើពុករលួយ និងចាត់វិធានការដែលជម្រុញគោលដៅសង្គម។ ការចង់បានរបស់ UNGC គឺដើម្បីពន្លឿន និងពង្រីកឥទ្ធិពលរួមនៃអាជីវកម្មជាសកល ដោយប្រកាន់ខ្ជាប់នូវគោលការណ៍ទាំងដប់ និងការផ្តល់នូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) តាមរយៈស្ថាប័ន និងប្រព័ន្ធអេកូឡូស៊ីដែលមានគណនេយ្យភាព ដែលអនុញ្ញាតឱ្យមានការផ្លាស់ប្តូរ។ គោលការណ៍ទាំងដប់ [1] រួមមាន៖

| |
|---|
| **សិទ្ធិមនុស្ស** |
| គោលការណ៍ ១៖ អាជីវកម្មគួរតែគាំទ្រ និងគោរពការការពារសិទ្ធិមនុស្សដែលត្រូវបានប្រកាសជាអន្តរជាតិ |
| គោលការណ៍ ២៖ អាជីវកម្មត្រូវប្រាកដថា មិនមានការពាក់ព័ន្ធក្នុងការរំលោភសិទ្ធិមនុស្ស |
| **កម្លាំងពលកម្ម** |
| គោលការណ៍ ៣៖ អាជីវកម្មគួរតែរក្សាសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម និងការទទួលស្គាល់ប្រកបដោយប្រសិទ្ធភាពនៃសិទ្ធិក្នុងការចរចាជាសមូហភាព |
| គោលការណ៍ ៤៖ អាជីវកម្មគួរតែលុបបំបាត់រាល់ទម្រង់នៃពលកម្មដោយបង្ខំ និងកំហិត |
| គោលការណ៍ ៥៖ អាជីវកម្មគួរតែលុបបំបាត់ពលកម្មកុមារប្រកបដោយប្រសិទ្ធភាព |
| គោលការណ៍ ៦៖ អាជីវកម្មគួរតែលុបបំបាត់ការរើសអើងទាក់ទងនឹងការងារ និងមុខរបរ |
| **បរិស្ថាន** |
| គោលការណ៍ ៧៖ អាជីវកម្មគួរតែលុបបំបាត់ការរើសអើងទាក់ទងនឹងការងារ និងមុខរបរ |
| គោលការណ៍ ៨៖ អាជីវកម្មគួរតែអនុវត្តគំនិតផ្តួចផ្តើមដើម្បីលើកកម្ពស់ការទទួលខុសត្រូវបរិស្ថានកាន់តែច្រើន |
| គោលការណ៍ ៩៖ អាជីវកម្មគួរតែលើកទឹកចិត្តដល់ការអភិវឌ្ឍ និងការផ្សព្វផ្សាយនៃបច្ចេកវិទ្យាដែលមិនប៉ះពាល់ដល់បរិស្ថាន |
| **ប្រឆាំងអំពើពុករលួយ** |
| គោលការណ៍ ១០៖ អាជីវកម្មគួរតែធ្វើការប្រឆាំងនឹងអំពើពុករលួយគ្រប់ទម្រង់ទាំងអស់ រួមទាំងការជំរិតទារប្រាក់ និងការសូកប៉ាន់ |

អិលអូអិលស៊ី ក៏បានចូលរួមជាមួយ UNGC ដែលឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់ អិលអូអិលស៊ី ចំពោះនិរន្តរភាព បរិស្ថាន និងសង្គម ដោយការជំរុញគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការអនុវត្តអាជីវកម្មប្រកបដោយការទទួលខុសត្រូវ។ ដូចគ្នានេះផងដែរ អិលអូអិលស៊ី អាចធ្វើឱ្យយុទ្ធសាស្ត្ររបស់ខ្លួនត្រូវជាមួយនឹងគោលការណ៍សកលរបស់ UNGC ស្តីពីសិទ្ធិមនុស្ស កម្លាំងពលកម្ម បរិស្ថាន និងការប្រឆាំងអំពើពុករលួយ។

[1] *https://unglobalcompact.org/what-is-gc/mission/principles*

# ការអនុលោមតាមគោលការណ៍ការពារអតិថិជន



- ឆ្នាំ២០១៥៖ ទទួលវិញ្ញាបនបត្រស្តីពីការការពារអតិថិជនលើកដំបូងពី SMART Campaign ដែលវាយតម្លៃដោយ M-CRIL។
- ឆ្នាំ២០១៨៖ ការចុះពិនិត្យឡើងវិញដោយ M-CRIL ជាលទ្ធផលវិញ្ញាបនបត្រស្តីពីការការពារអតិថិជនបន្តសុពលភាពរហូតដល់ ឆ្នាំ២០២០។
- ឆ្នាំ២០២២៖ ទទួលបានវិញ្ញាបនបត្រស្តីពីការការពារអតិថិជនកម្រិតមាសពី Cerise និង SPTF ដែលវាយតម្លៃដោយ MFR។







ដើម្បីធានាថាផលិតផល និងសេវាកម្មរបស់ អិលអូអិលស៊ី មិនបង្កគ្រោះថ្នាក់ ឬផលប៉ះពាល់ទៅដល់អតិថិជន បរិស្ថាន និងសង្គម អិលអូអិលស៊ី ប្តេជ្ញាគោរពតាមគោលការណ៍ការពារអតិថិជន ៨ ចំណុចដូចជា៖

### ការបង្កើត និងចែកចាយផលិតផលឱ្យបានសមស្រប៖

យើងធានាថានឹងយកចិត្តទុកដាក់ខ្លាំងលើការបង្កើតផលិតផល និងបណ្តាញចែកចាយដោយផ្អែកលើតម្រូវការជាក់ស្តែងរបស់អតិថិជននៅក្នុងលក្ខខណ្ឌមួយដែលមិនបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានដល់អតិថិជន។

### ការទប់ស្កាត់ការជំពាក់បំណុលវ័ណ្ឌក៖

យើងធានាថានឹងយកចិត្តទុកដាក់ខ្លាំងលើដំណើរការផ្តល់ឥណទានដើម្បីកំណត់បានថាអតិថិជនមានលទ្ធភាពសងត្រឡប់ដោយមិនឱ្យពួកគាត់ជំពាក់បំណុលវ័ណ្ឌក។ លើសពីនេះទៅទៀតយើងនឹងត្រួតពិនិត្យលើប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងដែលគាំទ្រដល់ការទប់ស្កាត់ការជំពាក់បំណុលវ័ណ្ឌក។

### តម្លាភាព៖

យើងផ្តល់ព័ត៌មានដែលមានភាពច្បាស់លាស់ គ្រប់គ្រាន់ និងទាន់ពេលវេលាទៅកាន់អតិថិជន និងប្តេជ្ញាប្រកាន់ខ្ជាប់នូវតម្លាភាពលើតម្លៃ រយៈពេលកម្ចី និងលក្ខខណ្ឌសម្រាប់គ្រប់ផលិតផលនិងសេវាកម្ម ដើម្បីឱ្យអតិថិជនយល់ច្បាស់ និងធ្វើការសម្រេចប្រកបដោយប្រសិទ្ធភាព។

### តម្លៃសមរម្យ៖

តម្លៃ និងលក្ខខណ្ឌដែលយើងបានកំណត់មានលក្ខណៈសមរម្យ និងជាតម្លៃប្រកួតប្រជែងក្នុងទីផ្សារអាចធ្វើឱ្យអតិថិជនទទួលយកបាន ហើយយើងក៏អាចទទួលបាននូវនិរន្តរភាពខាងផ្នែកប្រតិបត្តិការ និងហិរញ្ញវត្ថុ។

### ភាពស្មើគ្នា និងការផ្តល់តម្លៃអតិថិជន៖

យើងនឹងផ្តល់តម្លៃឱ្យអតិថិជនស្មើៗគ្នា និងមិនមានការរើសអើង ហើយរាល់បុគ្គលិកទាំងអស់សុទ្ធតែទទួលបាននូវការអប់រំយ៉ាងល្អទៅលើទិដ្ឋភាពផ្សេងៗ និងបរិយាបន្នដើម្បីបញ្ចៀសការរើសអើងទៅលើអតិថិជនដោយសារជាតិសាសន៍ ភេទ សាសនា ឬចរិតលក្ខណៈផ្សេងៗទៀត។

### ការរក្សាទិន្នន័យសម្ងាត់របស់អតិថិជន៖

យើងរក្សាព័ត៌មាន និងទិន្នន័យសម្ងាត់របស់អតិថិជន។ ព័ត៌មានទាំងអស់ត្រូវបានយកមកប្រើប្រាស់លុះត្រាតែមានការអនុញ្ញាតដោយច្បាប់ ឬការអនុញ្ញាតពីអតិថិជនផ្ទាល់។

### យន្តការនៃការដោះស្រាយបណ្តឹងតវ៉ា៖

យើងមានយន្តការនៃការដោះស្រាយបណ្តឹងតវ៉ាពីអតិថិជនក៏ដូចជាការផ្តល់មតិយោបល់ ឬព័ត៌មានត្រឡប់ពីអតិថិជន ហើយយើងតែងតែផ្តល់នូវដំណោះស្រាយទៅកាន់អតិថិជនវិញយ៉ាងទាន់ពេលវេលា និងមានភាពសមរម្យ។

### ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង៖

ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងមានការប្តេជ្ញាចិត្តចំពោះការការពារអតិថិជនដោយការប្រតិបត្តិដោយមានការគាំទ្រពីប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស (HR Systems)។

# ការយល់ដឹងអំពីការអប់រំផ្នែកហិរញ្ញវត្ថុ



បណ្តាញសក្តានុពលនៃការយល់ដឹងផ្នែកហិរញ្ញវត្ថុរបស់យើងរួមមាន៖

- ការបណ្តុះបណ្តាលក្នុងថ្នាក់
- ការបណ្តុះបណ្តាលក្នុងសហគមន៍
- ប្រព័ន្ធផ្សព្វផ្សាយតាមបណ្តាញសង្គម (ហ្វេសប៊ុក)
- សម្ភារផ្សព្វផ្សាយផ្សេងៗ
- យុទ្ធនាការផ្សេងៗទៀត

**សមិទ្ធផលដែល អិលអូអិលស៊ី (ខេមបូឌា) បានធ្វើដើម្បីចូលរួមចំណែកក្នុងការអប់រំចំណេះដឹងផ្នែកហិរញ្ញវត្ថុរួមមាន៖**

- គិតត្រឹមខែធ្នូ ឆ្នាំ២០២៣ អ្នកចូលរួមសរុបចំនួន ៦៣.០០៧នាក់ (៧៤% ឬ ៤៦,៩២៥ជាស្ត្រី) បានចូលរួមក្នុង**វគ្គបណ្តុះបណ្តាលស្តីពីចំណេះដឹងផ្នែកហិរញ្ញវត្ថុ**។ កម្មវិធីបណ្តុះបណ្តាលនេះបានទាក់ទាញប្រជាពលរដ្ឋជាច្រើន រួមទាំងអតិថិជន អ្នកភូមិ និស្សិតសាកលវិទ្យាល័យ និងកុមារ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែជំងឺរាតត្បាត COVID-19 ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២ វគ្គបណ្តុះបណ្តាលក្នុងថ្នាក់ត្រូវបានពន្យារពេល។

  នៅឆ្នាំ២០២៣ ការបណ្តុះបណ្តាលក្នុងថ្នាក់បានបន្តសម្រាប់សហគមន៍ដែលមានវគ្គសិក្សាសរុបចំនួន ២៣៧ និងមានអ្នកចូលរួមសរុបចំនួន ៤.២១៨នាក់ (៧៩% ឬ ៣.៣៣២នាក់ជាស្ត្រី)។ លើសពីនេះ និស្សិតសាកលវិទ្យាល័យបានចូលរួមក្នុងវគ្គសិក្សាចំនួនបួនដាច់ដោយឡែកពីគ្នា ជាមួយនឹងការចុះឈ្មោះចូលរួមសរុបចំនួន ២១០នាក់ (៧៤% ឬ ១៥៥នាក់ជាស្ត្រី)។

- **វីដេអូការយល់ដឹងអំពីចំណេះដឹងហិរញ្ញវត្ថុត្រូវបានផលិតឡើងដើម្បីផ្តល់សារចំណេះដឹងផ្នែកហិរញ្ញវត្ថុ**ដល់សាធារណជន/អតិថិជន។ គិតត្រឹមខែធ្នូ ឆ្នាំ២០២៣ វីដេអូខ្លីចំនួន ២៨ ត្រូវបានបង្ហោះនៅក្នុងគេហទំព័រហ្វេសប៊ុក ប្រព័ន្ធផ្សព្វផ្សាយដ៏ពេញនិយមផ្សេងៗ និងទំព័រហ្វេសប៊ុកផ្លូវការរបស់ អិលអូអិលស៊ី (LOLC Facebook Page)។ ជាលទ្ធផល ចំនួនអ្នកទស្សនាសរុបនៃវីដេអូទាំង២៦ គឺបានរហូតដល់ ១៦,២២ លាននាក់។

- អិលអូអិលស៊ី បានបង្កើត**សារអប់រំផ្នែកចំណេះដឹងហិរញ្ញវត្ថុ**ជាច្រើនដែលត្រូវបានចែករំលែកនៅលើគេហទំព័រ និងទំព័រហ្វេសប៊ុកផ្លូវការរបស់ អិលអូអិលស៊ី (LOLC Facebook Page) ដើម្បីបង្កើនការយល់ដឹងផ្នែកហិរញ្ញវត្ថុរបស់អតិថិជន និងសាធារណជនទូទៅតាមរយៈមធ្យោបាយឌីជីថល។







**មេរៀននៃការបណ្តុះបណ្តាលការយល់ដឹងអំពីការអប់រំហិរញ្ញវត្ថុគឺ៖**

- ការអភិវឌ្ឍន៍ផ្នត់គំនិត
- ចំណូល និង ចំណាយ
- ការសន្សំ និង ការវិនិយោគ
- ការគ្រប់គ្រងបំណុល
- ការគ្រប់គ្រងសាច់ប្រាក់
- ការគ្រប់គ្រងអាជីវកម្មខ្នាតតូច និងមធ្យម

**Financial Education Awareness Training Achievement:**




**សម្គាល់**

កក|ខខ : (កក) ចំនួនវគ្គបណ្តុះបណ្តាល | (ខខ) ចំនួនអ្នកចូលរួម

: សមិទ្ធិផលក្នុងឆ្នាំ២០២៣

: ផែនការសម្រាប់ឆ្នាំ២០២៤



# ទំនួលខុសត្រូវសង្គម និងសកម្មភាពសង្គមផ្សេងៗទៀត



**ព្រឹត្តិការណ៍សហគមន៍៖** គឺជាផ្នែកមួយនៃការរួមចំណែករបស់ អិលអូអិលស៊ី ទៅកាន់សង្គមដែលសាខារបស់ អិលអូអិលស៊ី មួយចំនួនត្រូវបានជ្រើសរើស និងតម្រូវឱ្យរៀបចំព្រឹត្តិការណ៍សហគមន៍នេះជារៀងរាល់ឆ្នាំ។ សម្រាប់ឆ្នាំ២០២៣ សាខាបានចូលរួមសកម្មភាពទាំងនោះរួមមាន៖

- ឧបត្ថម្ភកៅអីថ្ម ឬបង់អង្គុយលេង ដាំដើមឈើ សកម្មភាពក្នុងសាលារៀន ផ្តល់ធុងសម្រាម និងអំពូលសូឡា ដល់សហគមន៍ សាលារៀន វត្តអារាម និងដាក់តាមទីសាធារណៈ
- ផ្តល់សម្ភារសិក្សាដល់សិស្សានុសិស្ស ទិញសៀវភៅដាក់ក្នុងបណ្ណាល័យ ដើម្បីគាំទ្រការសិក្សារបស់សិស្សានុសិស្ស
- ការដាំដើមឈើ ក្នុងបរិវេណសាលារៀន វត្តអារាម និងទីតាំងសំខាន់ៗផ្សេងទៀត
- នាំយកគ្រឿងឧបភោគបរិភោគជូនដល់អតិថិជន និងប្រជាជនរងគ្រោះដោយសារទឹកជំនន់












**សកម្មភាពសង្គមផ្សេងៗទៀត៖** គឺជាការចូលរួមលើកកម្ពស់សង្គម ដែលបង្ហាញពីការប្តេជ្ញាចិត្តរបស់ អិលអូអិលស៊ី ក្នុងការរួមចំណែកនូវសកម្មភាពជាវិជ្ជមានដល់សង្គម និងបរិស្ថាន តាមរយៈបុគ្គលិក អតិថិជន និងសហគមន៍របស់ខ្លួន។ សកម្មភាពទាំងនោះត្រូវបានពិពណ៌នាខាងក្រោម៖

- ការចុះកិច្ចព្រមព្រៀង ជាមួយ ក្រុមហ៊ុន អេកូបាត អេនើជី ខេមបូឌា ដើម្បីចូលរួមចំណែកប្រមូលកាកសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក ដែលជាប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់បរិស្ថាន និងសុខភាពរបស់មនុស្ស ដែលសកម្មភាពរួមមាន៖
  ១. ដាក់ធុង (Battery Recycle Bin) សម្រាប់ប្រមូលសំណល់ថ្មពិល ឬថ្មទូរសព្ទជាដើម។ បុគ្គលិក និងអតិថិជនចូលរួមប្រមូលសំណល់ថ្មទាំងនោះដាក់ក្នុងធុង ដែលធុងនោះមានទីតាំងនៅការិយាល័យប្រតិបត្តិការ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា)។
  ២. ប្រមូលសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក (ទូរសព្ទ កុំព្យូទ័រ ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនព្រីន ម៉ាស៊ីនកូពី ម៉ាស៊ីនថត អាគុយជាដើម) ហើយប្រគល់ជូនទៅក្រុមហ៊ុន អេកូបាត អេនើជី ខេមបូឌា ដើម្បីប្រើប្រាស់បន្ត និងបំបែកកាកសំណល់ដោយមិនមានផលប៉ះពាល់ដល់បរិស្ថាន។
- ឧបត្ថម្ភកង់ និងសម្ភារសិក្សាដល់សិស្សានុសិស្ស ដើម្បីលើកកម្ពស់វិស័យអប់រំនៅកម្ពុជា និងលើកទឹកចិត្តពួកគាត់ឱ្យខិតខំសិក្សា។
- ផ្តល់ការអប់រំដល់អ្នកទទួលផលគម្រោង ភូមិមួយផលិតផលមួយ ស្តីពី "របៀបទទួលបានសេវាហិរញ្ញវត្ថុត្រឹមត្រូវ" នៅក្នុងខេត្តមួយចំនួន។
- បានចូលរួមចំណែកក្នុងការងារសង្គម តាមរយៈការប្រគល់ខិត្តប័ណ្ណក្នុងយុទ្ធនាការប្រឆាំងគ្រឿងញៀន និងសម្ភារផ្សព្វផ្សាយផ្សេងៗ ដល់អគ្គលេខាការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (NACD) ដើម្បីផ្សព្វផ្សាយការយល់ដឹងអំពីផលប៉ះពាល់ នៃគ្រឿងញៀនដល់សាធារណជន។





# យន្តការត្រួតពិនិត្យ និងតាមដានផលប៉ះពាល់លើបរិស្ថាន



ដើម្បីបង្កើតមូលដ្ឋានសម្រាប់ការវាស់វែងកិច្ចខិតខំប្រឹងប្រែងរបស់ អិលអូអិលស៊ី (ខេមបូឌា) ក្នុងការកាត់បន្ថយផលប៉ះពាល់បរិស្ថាន អិលអូអិលស៊ី (ខេមបូឌា) បានចាប់ផ្តើមធ្វើការកត់ត្រាតាមដានទៅលើការប្រើប្រាស់ធនធានដូចជា ការប្រើប្រាស់អគ្គិសនី ទឹក ប្រេងសាំង និងប្រេងម៉ាស៊ូត។ លទ្ធផលត្រូវបានបង្ហាញដូចខាងក្រោមហើយនឹងត្រូវបានប្រើប្រាស់សម្រាប់វាស់វែងលទ្ធផលនាពេលអនាគត។

| | ត្រីមាសទី១ ២០២៣ | ត្រីមាសទី២ ២០២៣ | ត្រីមាសទី៣ ២០២៣ | ត្រីមាសទី៤ ២០២៣ |
|---|---|---|---|---|
| **បុគ្គលិកសរុប** | ៣.៦០៥ | ៣.៥៩២ | ៣.៥៨៦ | ៣.៥៨៦ |
| អគ្គិសនី (គីឡូវ៉ាត់ម៉ោង) | ៥៥០.០៣៩ | ៦១០.៩៩០ | ៦៨៤.៧២៩ | ៦៥៩.៦៤៨ |
| អគ្គិសនី (គីឡូវ៉ាត់ម៉ោង) ក្នុងបុគ្គលិកម្នាក់ | ១៥២,៥៩ | ១៧០,១០ | ១៩០,៩៦ | ១៨៣,៩៣ |
| ទឹក (ម៉ែត្រគូប) | ១៦.៨០៩ | ១៦.៧៨៥ | ១៧.៩២៧ | ១៤.៤៥១ |
| ទឹក (ម៉ែត្រគូប) ក្នុងបុគ្គលិកម្នាក់ | ៤,៦៦ | ៤,៦៧ | ៥,០០ | ៤,០៣ |
| ប្រេងសាំង (លីត្រ) | ១២២.៥៨០ | ១០៣.២២៣ | ១០១.៣០១ | ៩៤.៨៧៤ |
| ប្រេងសាំង (លីត្រ) ក្នុងបុគ្គលិកម្នាក់ | ៣៤,០១ | ២៨,៧៤ | ២៨,២៥ | ២៦,៤៥ |
| ប្រេងម៉ាស៊ូត (លីត្រ) | ៧.៦៤៧ | ៧.៨៧១ | ៩.៥៥១ | ៦.៨១៥ |
| ប្រេងម៉ាស៊ូត (លីត្រ) ក្នុងបុគ្គលិកម្នាក់ | ២,១២ | ២,១៩ | ២,៦៦ | ១,៩០ |
| ក្រដាស | ១៣.១៤០ | ៧.៧៨០ | ៩.៥៧៧ | ៩.១៣៧ |
| ក្រដាស A4 (ដុំ) ក្នុងអតិថិជនម្នាក់ | ០,៧៤ | ០,៦៨ | ០,៦១ | ០,៧១ |

ក្នុងនាមជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដែលយល់ដឹងអំពីបរិស្ថាន អិលអូអិលស៊ី (ខេមបូឌា) បានខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយផលប៉ះពាល់ដល់បរិស្ថានរបស់ខ្លួនជាពិសេសតាមរយៈការប្រើប្រាស់ថាមពល (ចាំបាច់) ប្រកបដោយប្រសិទ្ធភាពពីត្រីមាសមួយ ទៅត្រីមាសមួយទៀត។



# ផលិតផលដែលជួយលើកកម្ពស់បរិស្ថាន និងសង្គម



គោលនយោបាយផ្ទៃក្នុងសម្រាប់ការត្រួតពិនិត្យលើបញ្ហាបរិស្ថាន និងសង្គមគឺជារឿងមួយ។ លើសពីនេះ ផលិតផលដែលមិនប៉ះពាល់ដល់បរិស្ថាន និងសង្គម ត្រូវបានបង្កើតឡើងដើម្បីគាំទ្រទៅកាន់អតិថិជន។

### កម្ចីគាំទ្របរិស្ថានៈ

បច្ចុប្បន្ននេះ អិលអូអិលស៊ី (ខេមបូឌា) កំពុងផ្តល់ប្រាក់កម្ចីគាំទ្របរិស្ថាន តាមរយៈផលិតផលដែលមានស្រាប់របស់ខ្លួនដូចជា សេវាភតិសន្យាហិរញ្ញវត្ថុ (FL) ប្រាក់កម្ចីប្រើប្រាស់ផ្ទាល់ខ្លួន (LIL) និងប្រាក់កម្ចីប្រើប្រាស់ផ្ទាល់ខ្លួន (LILAB)។

ជាមួយនឹងជំនួយបច្ចេកទេស និងឧបករណ៍ដើម្បីវាស់វែងផលប៉ះពាល់នៃការផ្តល់ប្រាក់កម្ចីគាំទ្របរិស្ថាន លើការកាត់បន្ថយការបំភាយឧស្ម័នកាបូនិក ($CO_2$) និងថាមពលដោយ GCPF តាមរយៈ responsAbility។ គិតត្រឹមខែធ្នូ ឆ្នាំ២០២៣ អតិថិជនប្រមាណ ១,៩ពាន់នាក់ កំពុងប្រើប្រាស់ផលិតផលកម្ចីគាំទ្របរិស្ថាន ដែលមានផលប័ត្រឥណទាន សរុបចំនួន ៥,៥លានដុល្លារអាមេរិក។ ជាការពិតណាស់ អិលអូអិលស៊ី (ខេមបូឌា) បានចូលរួមចំណែកក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនិកចំនួន ១០.១៣៧តោនឧស្ម័នកាបូនិក តាមរយៈផលិតផលកម្ចីគាំទ្របរិស្ថានទាំងនេះ។ លើសពីនេះទៅទៀត អិលអូអិលស៊ី (ខេមបូឌា) ត្រូវបានជ្រើសរើសជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឆ្នើមក្នុងការផ្តល់ប្រាក់កម្ចីគាំទ្របរិស្ថាន នៅដើមឆ្នាំ២០២១។

### ប្រាក់កម្ចីទឹកស្អាត និងអនាម័យៈ

អិលអូអិលស៊ី (ខេមបូឌា) បានបម្រើអតិថិជនជាមួយនឹងផលិតផលប្រាក់កម្ចីទឹកស្អាត និងអនាម័យតាំងពីឆ្នាំ២០១៦។ ប្រាក់កម្ចីទឹកស្អាត និងអនាម័យជួយពួកគេក្នុងការបង្កើនលទ្ធភាពប្រើប្រាស់ទឹកស្អាត និងអនាម័យ នៅក្នុងសហគមន៍របស់ពួកគេ។ គោលដៅគឺ គាំទ្រអតិថិជនដែលចង់សាងសង់ ឬជួសជុលបង្គន់អនាម័យ អណ្តូងទឹក ជីកស្រះស្តុកទឹក ឬទិញឧបករណ៍ចម្រោះទឹកជាដើម។ គិតត្រឹមខែធ្នូ ឆ្នាំ២០២៣ អតិថិជន ៤,៩ពាន់នាក់ កំពុងប្រើប្រាស់ផលិតផលប្រាក់កម្ចីទឹកស្អាត និងអនាម័យ ដែលមានផលប័ត្រឥណទានសរុបចំនួន ៧,២លានដុល្លារអាមេរិក។

### ប្រាក់កម្ចីកែលម្អគេហដ្ឋាន និងប្រាក់កម្ចីទិញផ្ទះ

ចាប់តាំងពីឆ្នាំ២០១៦ អិលអូអិលស៊ី (ខេមបូឌា) ក៏បានផ្តល់ប្រាក់កម្ចីសម្រាប់កែលម្អគេហដ្ឋាន (HIL) ដល់អតិថិជនទាំងឡាយណាដែលត្រូវការជួសជុល ឬកែលម្អផ្ទះបច្ចុប្បន្នរបស់ខ្លួន។ នៅឆ្នាំ២០១៩ អិលអូអិលស៊ី (ខេមបូឌា) បានបង្កើតផលិតផលងាយស្រួលថ្មីមួយហៅថា ប្រាក់កម្ចីទិញផ្ទះ (HL) សម្រាប់អតិថិជនដែលត្រូវការសាងសង់ ឬទិញផ្ទះថ្មី។ គិតត្រឹមខែធ្នូ ឆ្នាំ២០២៣ អិលអូអិលស៊ី (ខេមបូឌា) កំពុងផ្តល់ប្រាក់កម្ចីកែលម្អគេហដ្ឋាន និងប្រាក់កម្ចីទិញផ្ទះបែបនេះដល់អតិថិជនចំនួន ៩,៣ពាន់នាក់ នូវផលប័ត្រឥណទានសរុបចំនួន ៥៦,៧លានដុល្លារអាមេរិក។



មុនពេល



ក្រោយពេល



មុនពេល



ក្រោយពេល

# ការចូលរួមលើកកម្ពស់សង្គម



នៅពេលនិយាយអំពីការចូលរួមលើកកម្ពស់សង្គម អិលអូអិលស៊ី (ខេមបូឌា) ទទួលបានលទ្ធផលដូចខាងក្រោម៖

| អតិថិជនជាស្ត្រី៖ | អតិថិជននៅជនបទ៖ | អតិថិជនដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម៖ |
|---|---|---|
| ៧០% (អ្នកខ្ចី) | ៧៩% (អ្នកខ្ចី) | ៤៩% (អ្នកខ្ចី) |



## សន្ទស្សន៍នៃការចាកផុតពីភាពក្រីក្រ (PPI)៖

អិលអូអិលស៊ី (ខេមបូឌា) ប្រើប្រាស់ឧបករណ៍សន្ទស្សន៍នៃការចាកផុតពីភាពក្រីក្រ ដើម្បីវាស់វែងការចូលរួមលើកកម្ពស់ដល់អតិថិជនក្រីក្រ ហើយធានាថាផលិតផល និងសេវាកម្មដែលបានផ្តល់ទៅអតិថិជនត្រូវទៅនឹងតម្រូវការរបស់គាត់។ ក្នុងឆ្នាំ២០២៣ តាមរយៈការស្ទាបស្ទង់មតិលើអតិថិជនទំហំចំនួន ៣៨៤នាក់ ដោយប្រើឧបករណ៍សន្ទស្សន៍នៃការចាកផុតពីភាពក្រីក្រ (PPI) អិលអូអិលស៊ី បានកំណត់ប្រភេទអតិថិជនជា៤ដូចខាងក្រោម៖

### ប្រភេទនៃអតិថិជនក្រីក្ររបស់ អិលអូអិលស៊ី (ខេមបូឌា)

**ក្រខ្លាំង** (អតិថិជនក្រោមខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ)
៤,២៦%

**ក្រ** (អតិថិជនក្រោមខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ ១៥០%)
២១,៩៨%

**ចំណូលទាប** (អតិថិជនក្រោមខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ ចំណូល៥ដុល្លារ/ថ្ងៃ)
៥៣,៩៨%

**មិនក្រ** (អតិថិជនលើខ្សែបន្ទាត់ភាពក្រីក្រថ្នាក់ជាតិ ចំណូលលើស៥ដុល្លារ/ថ្ងៃ)
១៩,៧៨%

## បរិយាបន្នហិរញ្ញវត្ថុ៖

អិលអូអិលស៊ី (ខេមបូឌា) ជាស្ថាប័នដែលផ្តល់ឱ្យនូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុសម្បូរបែបដូចជា ផលិតផលឥណទាន ផលិតផលប្រាក់បញ្ញើ សាច់ប្រាក់ សេវាធនាគារចល័ត និងធានារ៉ាប់រងជាដើម ដែលមានតម្លៃសមរម្យ អាចបំពេញតម្រូវការរបស់អតិថិជន ហើយត្រូវនឹងសមត្ថភាពបង់សងរបស់អតិថិជន មិនមានការរើសអើង ដោយមានទំនួលខុសត្រូវ និងនិរន្តរភាព។

**សេវាធនាគារចល័ត iPay**
#ប្រតិ.៖ ២.៩៤៤.៨៩៩
#អ្នកប្រើ៖ ៨០.៤៨៦
ដុល្លារ៖ ៣០៤ លាន

**សេវាទូទាត់រហ័ស**
#ប្រតិ.៖ ១៨.៣១៤
ដុល្លារ៖ ១,២៤ លាន

**សេវាផ្ទេរមូលនិធិភ្លាម**
#ប្រតិ.៖ ៤៤.៣៨៦
ដុល្លារ៖ ៧៥ លាន

**ប្រព័ន្ធបាគង**
#អ្នកប្រើប្រាស់៖ ៥.៩៤០ នាក់
#ប្រតិ.៖ ១.៩២៤.២០៣
ដុល្លារ៖ ៣១៣ លាន

**ប័ណ្ណ ATM (CSS)**
#ប័ណ្ណ៖ ៥៦.៨២១
#ប្រតិ.៖ ៩៤៨.១១២
ដុល្លារ៖ ៥៥ លាន

**ប្រាក់កម្ចីជាក្រុម**
#អតិថិជន៖ ១៦៨.៧៩២
ដុល្លារ៖ ១៤០ លាន
ជាមធ្យម (ដុល្លារ)៖ ៨៣៣

**ប្រាក់កម្ចីឯកត្តជន**
#អតិថិជន៖ ១៩២.៥៧៩ នាក់
ដុល្លារ៖ ៦៣១ លាន
ជាមធ្យម (ដុល្លារ)៖ ៣.២៨០

**កម្ចីសហគ្រាសធុនតូច និងមធ្យម**
#អតិថិជន៖ ៣៥.៥៤៨ នាក់
ដុល្លារ៖ ៤៧៤ លាន
ជាមធ្យម (ដុល្លារ)៖ ១៣.៣៤០

**គណនីបញ្ញើសំចៃ**
#អតិថិជន៖ ៥០៥ ពាន់នាក់
ដុល្លារ៖ ៤៩ លាន
ជាមធ្យមភាគ (ដុល្លារ)៖ ៩៨

**គណនីបញ្ញើមានកាលកំណត់**
#អតិថិជន៖ ៩.៣២១ នាក់
ដុល្លារ៖ ៨៥៤ លាន
ជាមធ្យមភាគ (ដុល្លារ)៖ ៩១.៦២៧

**គណនីកុមារ**
#អតិថិជន៖ ៥.៧៥៧ នាក់
ដុល្លារ៖ ៤២៥.៧០៩
ជាមធ្យមភាគ (ដុល្លារ)៖ ៧៤

**ឥណទានធានារ៉ាប់រងជីវិត**
#អតិថិជន៖ ២០៣.០៥២
ព្រីមៀម (ដុល្លារ)៖
៤.៣០៥.៤៤៦

**ធានារ៉ាប់រងដំណាំស្រូវ**
#អតិថិជន៖ ១.៤៦៩ នាក់

**ធានារ៉ាប់រងយានយន្ត**
#អតិថិជន៖ ៣៤.០៥៧ នាក់
ព្រីមៀម (ដុល្លារ)
១.១៦៤.៣៦២

# អភិបាលកិច្ច



## ក្រមសីលធម៌អាជីវកម្ម

ទាំងនេះជាសក្ខីភាពដែលបង្ហាញថា អិលអូអិលស៊ី (ខេមបូឌា) បានបង្កើតយ៉ាងត្រឹមត្រូវនូវ ក្រមសីលធម៌ និងការអនុវត្តយ៉ាងហ្មត់ចត់ដោយបុគ្គលិករបស់ខ្លួន។ បុគ្គលិកទាំងអស់ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌នេះទាំងនៅក្នុង និងខាងក្រៅការិយាល័យ ព្រោះវាអាចប៉ះពាល់ដល់វិជ្ជាជីវៈ និងកេរ្តិ៍ឈ្មោះរបស់ អិលអូអិលស៊ី (ខេមបូឌា)។ លើសពីនេះទៅទៀត អិលអូអិលស៊ី (ខេមបូឌា) តែងតែគោរពតាមគោលការណ៍ណែនាំនៃការផ្តល់ប្រាក់កម្ចី។

## អភិបាលឯករាជ្យ

អិលអូអិលស៊ី (ខេមបូឌា) អនុលោមពេញលេញតាមការតម្រូវរបស់និយតករ ដោយមានអភិបាល ២នាក់ក្នុងចំណោម ៥នាក់ ជាអភិបាលឯករាជ្យ។ ជាងនេះទៅទៀត ភារកិច្ចចម្បងរបស់ពួកគេត្រូវធានាឱ្យមានតម្លាភាព និងភាពត្រឹមត្រូវនៃការអនុវត្តសេវាហិរញ្ញវត្ថុ និងក្រមសីលធម៌របស់គណៈគ្រប់គ្រង និងអភិបាល។



# ការវាយតម្លៃផលប៉ះពាល់របស់ អិលអូអិលស៊ី (ខេមបូឌា) នៅលើបរិស្ថាន និងសង្គម



## ការស្ទង់មតិអំពីផលប៉ះពាល់ចំពោះអតិថិជន អិលអូអិលស៊ី ដោយ OIKOCREDIT

### វិធីសាស្ត្រ

នៅខែឧសភា ឆ្នាំ២០២៣ អិលអូអិលស៊ី បានសហការជាមួយ Oikocredit ក្នុងកម្មវិធីយល់ឃើញដោយខ្លួនឯងរបស់អតិថិជន (Client Self-Perception) សម្រាប់ពីរឆ្នាំជាប់ៗគ្នា។ អិលអូអិលស៊ី បានសួរទៅកាន់អតិថិជនចំនួន ៧៦០នាក់ អំពីការផ្លាស់ប្តូរផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុដែលកើតឡើងក្នុងជីវិតរបស់ពួកគេនៅចន្លោះ ខែឧសភា ឆ្នាំ២០២២ ដល់ ខែឧសភា ឆ្នាំ២០២៣។

ការស្ទង់មតិនេះបានកំណត់គោលដៅអតិថិជនពី ៨សាខានៅទូទាំង ៤តំបន់សំខាន់ៗនៃសកម្មភាពអាជីវកម្មរបស់ អិលអូអិលស៊ី៖ ឆ្នេរ ធម្មតា ខ្ពង់រាប ភ្នំ និងទន្លេសាប។ លទ្ធផលពីអតិថិជនអាចទុកចិត្ត ៩៥% និង ៥% អាចនឹងមានកំហុស។អ្នកឆ្លើយតបត្រូវបានជ្រើសរើសតាមតំបន់ដោយយោងទៅតាមផលិតផល អិលអូអិលស៊ី ដែលពួកគេបានប្រើប្រាស់ និងយោងទៅតាមចំនួនវគ្គនៃប្រាក់កម្ចីរបស់ពួកគេជាមួយផងដែរ (បានប្រើប្រាស់ប្រាក់កម្ចីចាប់ពី ពីរវគ្គ ឬច្រើនជាងនេះត្រូវបានជ្រើសរើសដើម្បីចូលរួមឆ្លើយសំណួរ)។

អ្នកឆ្លើយតបការស្ទង់មតិត្រូវបានធ្វើឡើងដោយការហៅទូរសព្ទហើយក្រោយមកត្រូវបានបញ្ជាក់ដោយផ្នែកការស្រាវជ្រាវរបស់ អិលអូអិលស៊ី។ រយៈពេលជាមធ្យមសម្រាប់ការសម្ភាសនីមួយៗគឺ ១៥នាទី។

### ប្រជាសាស្ត្រនៃអ្នកឆ្លើយតប








### បទពិសោធន៍អតិថិជន

អ្នកឆ្លើយសំណួរចំនួន ៦៨៤នាក់ (៩០%) បាននិយាយថា អិលអូអិលស៊ី មានឥទ្ធិពលវិជ្ជមានទៅលើសុខុមាលភាពរបស់ពួកគេក្នុងរយៈពេល ១២ខែ។ នេះបង្ហាញពីឥទ្ធិពលវិជ្ជមានជានិរន្តរភាពនៃ អិលអូអិលស៊ី ទៅកាន់អតិថិជនរបស់ពួកគេ ជាពិសេសនៅពេលប្រៀបធៀបទៅនឹងការស្ទង់មតិ ឆ្នាំ២០២២ នៅពេលដែលក្នុងចំណោមអតិថិជន ៥៩៨នាក់ ៩១% បាននិយាយថា អិលអូអិលស៊ី មានឥទ្ធិពលវិជ្ជមានទៅលើសុខុមាលភាពរបស់ពួកគេ។

របាយការណ៍នេះបានបង្ហាញពីអ្នកឆ្លើយសំណួរ ៩០% គួរឱ្យកត់សម្គាល់ដែលបង្ហាញពីការពេញចិត្តរបស់ពួកគេចំពោះការរួមចំណែក របស់ អិលអូអិលស៊ី ចំពោះសុខុមាលភាពប្រសើរឡើងរបស់ពួកគេក្នុងរយៈពេល ១២ខែចុងក្រោយ។

### ឥទ្ធិពល អិលអូអិលស៊ី លើសុខុមាលភាពក្នុងរយៈ ១២ខែចុងក្រោយ (ចំនួន ៧៥៩នាក់)




### ចំណូល

អ្នកឆ្លើយសំណួរចំនួន ៥៤៩នាក់ (៧២% នៃចំនួនសរុប) បាននិយាយថា ចំណូលរបស់ពួកគេបានកើនឡើងនៅចន្លោះខែឧសភា ឆ្នាំ២០២២ ដល់ខែឧសភា ឆ្នាំ២០២៣។ លទ្ធផលនេះបង្ហាញពីស្ថានភាពប្រសើរឡើងបើប្រៀបធៀបទៅនឹងការស្ទង់មតិឆ្នាំ២០២២ នៅពេលដែលមានតែ ៣៨% នៃអ្នកឆ្លើយសំណួរបានបង្កើនប្រាក់ចំណូលរបស់ពួកគេបានកើនឡើងក្នុងរយៈពេល ១២ខែ។

ក្នុងចំណោមអ្នកឆ្លើយសំណួរចំនួន ៥៤៩នាក់ ដែលបានរាយការណ៍ពីការកើនឡើងនៃប្រាក់ចំណូល ៩៤% បាននិយាយថា អិលអូអិលស៊ី មានឥទ្ធិពលខ្លះក្នុងការកើនឡើងនៃប្រាក់ចំណូលនេះ។

ក្នុងចំណោមអ្នកឆ្លើយសំណួរចំនួន ៥៤៩ ដែលមានប្រាក់ចំណូលកើនឡើង ហើយតាមការពន្យល់ដ៏សាមញ្ញគឺថាអ្នកឆ្លើយតប "កើនឡើងនៃការលក់ផលិតផល និងសេវាកម្ម ដែលមានស្រាប់ "ដែលផ្តល់ដោយអាជីវកម្ម (៣៧%) និងដោយសារតែ "ការកើនឡើងនៃប្រាក់ខែពីការងារដែលមានស្រាប់" (២៤%)។

#### ចំណូលប្រែប្រួលក្នុងរយៈពេល ១២ខែ




#### នៅពេលប្រាក់ចំណូលកើនឡើង ដោយសារ អិលអូអិលស៊ី មែនទេ? (ចំនួន ៥៤៩នាក់)




ជារួមមានន័យថា៖ ខណៈពេលដែលអ្នកឆ្លើយសំណួរភាគច្រើនបានឆ្លើយពីការកើនឡើងនៃប្រាក់ចំណូល ៩០% នៃអ្នកឆ្លើយសរុបក៏បានបញ្ជាក់ថាប្រាក់ចំណូលរបស់ពួកគេគឺគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការចាំបាច់របស់ពួកគេក្នុងរយៈពេល ១២ខែចុងក្រោយនេះ។

៦០% នៃអ្នកឆ្លើយតបសរុបបានរាយការណ៍ថា ព្រឹត្តិការណ៍អាកាសធាតុមានប៉ះពាល់ដល់ប្រាក់ចំណូលរបស់ពួកគេក្នុងរយៈពេល ១២ខែ។ នេះគឺ ទាក់ទងខ្ពស់ជាពិសេសក្នុងចំណោមអ្នកឆ្លើយសំណួរ មកពីស្រុកកំរៀង (៩១%) សំឡូត (៨៣%) ព្រៃកប្បាស (៧៨%) និងមេសាង (៧៤%)។

ការសង្កេតដ៏គួរឱ្យចាប់អារម្មណ៍បំផុតមួយគឺ ការកើនឡើងយ៉ាងខ្លាំងនៃប្រាក់ចំណូលក្នុងរយៈពេល ១២ខែចុងក្រោយដែលត្រូវបានរាយការណ៍ដោយ ៧២% នៃអតិថិជន។ គួរឱ្យកត់សម្គាល់ ៩៤% នៃបុគ្គលទាំងនេះបានសន្និដ្ឋានថាកំណើននេះគឺដោយសារការគាំទ្ររបស់ អិលអូអិលស៊ី និងដំណោះស្រាយហិរញ្ញវត្ថុដែលសមស្រប។

## ការអភិវឌ្ឍន៍អាជីវកម្ម

អ្នកឆ្លើយសំណួរចំនួន៥០០នាក់(៦៦%នៃចំនួនសរុប)បាននិយាយថាពួកគេ គឺជាសហគ្រិន - ទាំងឯករាជ្យ ឬបន្ថែមបុគ្គលិកដែលមានប្រាក់ខែ។
អ្នកឆ្លើយ ៣២៣នាក់ (៤៣% នៃចំនួនសរុប) បាននិយាយថាពួកគេមានអាជីវកម្ម។
ក្នុងរយៈពេលជាង ១២ខែ អ្នកឆ្លើយសំណួរចំនួន ៣២៣នាក់ នេះបានពង្រីកអាជីវកម្មរបស់ពួកគេ៖

- ៦៣% បានបន្ថែមផលិតផល ឬសេវាកម្មថ្មីទៅក្នុងអាជីវកម្មរបស់ពួកគេ។
- ៤៧% បានទិញឧបករណ៍/គ្រឿងចក្រថ្មីសម្រាប់អាជីវកម្មរបស់ពួកគេ។
- ១០% ជួលបុគ្គលិកថ្មីក្នុងអាជីវកម្មរបស់ពួកគេ។
- ៧៤% បង្កើនការលក់នៅក្នុងអាជីវកម្មរបស់ពួកគេ។

## ប្រភពចំណូលនៃអ្នកឆ្លើយតប




យើងរីករាយដែលឃើញក្នុងរយៈពេល ១២ខែ ៦៤% នៃអតិថិជន ៥០០នាក់ដែលជាសហគ្រិនអាចពង្រីកអាជីវកម្មរបស់ពួកគេបាន មិនថាបន្ថែមផលិតផល និងសេវាកម្មថ្មីៗ ការវិនិយោគលើគ្រឿងម៉ាស៊ីន និងបរិក្ខារ បង្កើតការងារបន្ថែម និងបង្កើនការលក់របស់ពួកគេ។

## ការសន្សំ

អ្នកឆ្លើយសំណួរចំនួន ៤០៩នាក់ (៥៤% នៃចំនួនសរុប) បាននិយាយថាពួកគេមានប្រាក់សន្សំ។

ក្នុងចំណោមអ្នកឆ្លើយសំណួរចំនួន ៤០៩នាក់ ដែលមានការសន្សំ ៨០% បាននិយាយថាការសន្សំរបស់ពួកគេបានកើនឡើងក្នុងរយៈពេល ១២ខែ។ នេះបង្ហាញពីភាពប្រសើរឡើងបើប្រៀបធៀបទៅនឹងឆ្នាំ២០២២ នៅពេលដែល ៤៥% នៃអ្នកឆ្លើយតបដែលមានការសន្សំបាននិយាយថាការសន្សំរបស់ពួកគេបានកើនឡើងក្នុងរយៈពេល ១២ខែ។

លើសពីនេះទៅទៀត ក្នុងចំណោមអ្នកឆ្លើយសំណួរចំនួន ៤០៩នាក់ ដែលមានការសន្សំ ៥២% បាននិយាយថាពួកគេអាចចិញ្ចឹមខ្លួនឯងបានច្រើនជាង ៦ខែ ដោយប្រើតែប្រាក់សន្សំទាំងនោះប៉ុណ្ណោះ។

## ការសន្សំប្រែប្រួលក្នុងរយៈពេល ១២ខែ (៥៤% មានការសន្សំ)




របាយការណ៍បានបង្ហាញថាក្នុងចំណោមអតិថិជនដែលមានប្រាក់សន្សំ ៨០% នៃពួកគេដែលមានបទពិសោធន៍សន្សំបានពង្រីកការសន្សំរបស់ពួកគេកាលពីឆ្នាំមុន។ គុណសម្បត្តិដ៏គួរឱ្យកត់សម្គាល់នេះគូសបញ្ជាក់ពីសមត្ថភាពរបស់ អិលអូអិលស៊ី ក្នុងការបណ្តុះវិន័យហិរញ្ញវត្ថុ និងបណ្តុះស្ថិរភាពហិរញ្ញវត្ថុរយៈពេលវែងក្នុងចំណោមអតិថិជនរបស់ខ្លួន។

## សមត្ថភាពក្នុងការបំពេញតម្រូវការសុខភាព

អ្នកឆ្លើយតបចំនួន ៤៥៩នាក់ (៦០% នៃចំនួនសរុប) បាននិយាយថាសមត្ថភាពគ្រួសាររបស់ពួកគេក្នុងការទប់ទល់នឹងតម្រូវការសុខភាព និងការសង្គ្រោះបន្ទាន់បានប្រសើរឡើងក្នុងរយៈពេល ១២ខែ។ លទ្ធផលនេះបង្ហាញពីភាពប្រសើរឡើងបើប្រៀបធៀបទៅនឹងលទ្ធផល របស់ អិលអូអិលស៊ី ក្នុងឆ្នាំ២០២២ នៅពេលដែលសមាមាត្រតូចជាង ៣៨% បាននិយាយថាសមត្ថភាពទាំងនេះមានភាពប្រសើរឡើង។

## សមត្ថភាពក្នុងការទប់ទល់នឹងតម្រូវការសុខភាព/គ្រាអាសន្ន (ចំនួន ៧៦០នាក់)




ក្នុងរយៈពេល ១២ខែកន្លងមកនេះ អតិថិជន ៩០% បាននិយាយថា សមត្ថភាពគ្រួសាររបស់ពួកគេទំនងជាអាចទប់ទល់នឹងតម្រូវការសុខភាព និងភាពអាសន្ន ខណៈដែល ៦០% នៃអតិថិជនលើកឡើងថា "ប្រសើរឡើង"។






ក្នុងរយៈពេល ១២ខែកន្លងមកនេះ អតិថិជន ៩០% បាននិយាយថា សមត្ថភាពគ្រួសាររបស់ពួកគេទំនងជាអាចទប់ទល់នឹងតម្រូវការសុខភាព និងភាពអាសន្ន ខណៈដែល ៦០% នៃអតិថិជនលើកឡើងថា "ប្រសើរឡើង"។

## របាយការណ៍ផលប៉ះពាល់បរិស្ថាន និងសង្គមដែលដាក់ពិន្ទុដោយ responsAbility

អិលអូអិលស៊ី (ខេមបូឌា) មានការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការផ្តល់នូវព័ត៌មានឱ្យបានគ្រប់គ្រាន់ប្រកបដោយគុណភាព និងធ្វើការរាយការណ៍ឱ្យបានទាន់ពេលវេលាស្តីពី បរិស្ថាន និងសង្គម ទៅកាន់ដៃគូរបស់ខ្លួន (GCPF), ដែលជាហេតុធ្វើឱ្យ អិលអូអិលស៊ី (ខេមបូឌា) ទទួលបានជាលទ្ធផលដូចខាងក្រោម៖

### អិលអូអិលស៊ី ២០២២

ពិន្ទុនៃរបាយការណ៍ E&S ទទួលបាន ៥/៦

- ☐ ល្អប្រសើរ
- ☑ ល្អ
- ☐ មធ្យម
- ☐ ខ្សោយ

### ការវាយតម្លៃផ្អែកលើលក្ខណៈវិនិច្ឆ័យខាងក្រោម៖




| គុណភាព | បរិមាណ | ពេលវេលាកំណត់ និងការឆ្លើយតប |
|---|---|---|
| ការវាយតម្លៃគុណភាពសំដៅទៅលើភាពទូលំទូលាយ ការសង្ខេប ភាពពាក់ព័ន្ធនៃចម្លើយ និងឯកសារដែលបានឱ្យ។ | ពិន្ទុទៅលើការវាយតម្លៃគុណភាពសំដៅទៅលើបរិមាណព័ត៌មានដែលផ្តល់ដោយធានាថាសំណួរទាំងអស់ត្រូវបានឆ្លើយ និងឯកសារពាក់ព័ន្ធបានភ្ជាប់មកជាមួយទាំងអស់។ | ការកំណត់ពេលវេលា និងការឆ្លើយតបឱ្យបានទាន់ពេលបង្ហាញឱ្យឃើញថាពេលកំណត់ត្រូវបានគោរពនិងគ្រប់ចម្លើយដែលបានឆ្លើយគឺមានភាពត្រឹមត្រូវ។ |
| ពណ៌ក្រហម បង្ហាញថារបាយការណ៍ E&S មានភាពយឺត ហើយការឆ្លើយតបខ្សោយ។ | ពណ៌លឿង បង្ហាញថារបាយការណ៍មានភាពយឺតបន្តិច ហើយការឆ្លើយតបគឺមធ្យម។ | ពណ៌បៃតង បង្ហាញថាការរាយការណ៍ធ្វើបានទាន់ពេល ហើយការឆ្លើយតបគឺទាន់ពេល។ |

### ការប្រៀបធៀបជាមួយដៃគូ

#### ជាសកល




#### តាមតំបន់




## របាយការណ៍ផលប៉ះពាល់ដោយ Impact Investment Exchange (IIX)

ដោយមានការគាំទ្រពី IIX អិលអូអិលស៊ី បានធ្វើការស្ទង់មតិលើផលប៉ះពាល់លើ ទម្រង់របស់ IIX ដើម្បីបង្ហាញឱ្យឃើញផលប៉ះពាល់ជារៀងរាល់ឆ្នាំ។ ដើម្បីបង្កើតការវិភាគផលប៉ះពាល់នេះ មានការផ្ទៀងផ្ទាត់ដោយត្រូវបានធ្វើឡើងតាមប្រព័ន្ធអនឡាញ ដែលមានការស្ទង់មតិចំនួនពីរ គឺមួយត្រូវបញ្ចប់ដោយគណៈគ្រប់គ្រងរបស់ក្រុមហ៊ុន និងការស្ទង់មតិខ្លីមួយទៀតនឹងត្រូវបញ្ចប់ដោយស្ត្រីដែលជាអ្នកទទួលផល ១០០នាក់ របស់ អិលអូអិលស៊ី។

ការរកឃើញពីការស្ទង់មតិទាំងនេះ បានបង្កើតរបាយការណ៍ផលប៉ះពាល់របស់ អិលអូអិលស៊ី ដែលអ្នកអាចប្រើខាងក្នុង/ខាងក្រៅតាមតម្រូវការដោយ អិលអូអិលស៊ី (ខេមបូឌា)។ ខាងក្រោមនេះជាលទ្ធផលនៃការស្ទង់មតិ។







## ការសង្កេតផលប៉ះពាល់ទូទៅ

### ផលប៉ះពាល់ផ្ទាល់ដល់អតិថិជន

អិលអូអិលស៊ី សម្រេចបាននូវផលប៉ះពាល់សម្រាប់អតិថិជនរបស់ខ្លួនរួមមានដូចខាងក្រោម៖

- អាចទិញអាហារបានច្រើន/ល្អសម្រាប់ខ្លួនគេ
- បទពិសោធន៍នៃការពង្រឹងផ្នែកសុខភាពរបស់ពួកគេ
- បង្កើនជំនាញ និងចំណេះដឹង
- ប្រាក់ចំណូលរបស់អ្នកទទួលផលបានកើនឡើង
- មានអារម្មណ៍ថាមានសុវត្ថិភាពជាងមុនក្នុងការធ្វើដំណើរតែម្នាក់ឯង
- ជួបប្រទះគ្រោះថ្នាក់តិចតួច ឬមានសុវត្ថិភាពនៅជុំវិញពួកគេ
- មានទំនាក់ទំនងល្អប្រសើរជាមួយមនុស្សជុំវិញខ្លួន
- អាចប្រើប្រាស់ព័ត៌មានបានច្រើន
- មានទំនុកចិត្តច្រើន
- មានពេលវេលាដើម្បីធ្វើសកម្មភាព (កម្សាន្ត) ផ្សេងទៀត
- អាចគិតលើសពីតម្រូវការបន្ទាន់របស់ពួកគេ

### ផលប៉ះពាល់ដល់គ្រួសារ/សហគមន៍

អិលអូអិលស៊ី បានបង្កើតផលប៉ះពាល់ដល់គ្រួសារ និងសហគមន៍របស់អតិថិជន រួមទាំង៖

- កុមារអាចញ៉ាំអាហារបានច្រើន/ល្អជាងមុន
- សមាជិកគ្រួសារ/សហគមន៍មានអារម្មណ៍ថាមានសុវត្ថិភាពជាងមុនក្នុងការធ្វើដំណើរតែម្នាក់ឯង
- សមាជិកគ្រួសារ/សហគមន៍អាចទទួលបានព័ត៌មានបានច្រើន
- សមាជិកគ្រួសារ/សហគមន៍បានកែលម្អប្រភពទឹកនិងអនាម័យ
- សមាជិកគ្រួសារ/សហគមន៍បានជួបប្រទះគ្រោះថ្នាក់តិចជាងមុន ឬឧបទ្ទវហេតុស្រាល
- សមាជិកគ្រួសារ/សហគមន៍មានបទពិសោធន៍ក្នុងការពង្រឹងសុខភាពរបស់ពួកគេឱ្យល្អប្រសើរ
- ក្មេងៗនឹងមានពេលទៅសាលារៀន
- កូនស្រីនឹងទៅសាលាហើយមានពេលគ្រប់គ្រាន់ដើម្បីរៀន

## ការស្ទង់មតិការពេញចិត្តរបស់អតិថិជន

អិលអូអិលស៊ី តែងតែធ្វើការស្ទង់មតិលើការពេញចិត្តរបស់អតិថិជនជារៀងរាល់ឆ្នាំ ដើម្បីមើលពីកម្រិតនៃការពេញចិត្តរបស់គាត់បន្ទាប់ពីប្រើប្រាស់ផលិតផល និងសេវាកម្មរបស់ខ្លួន។ ការស្ទង់មតិនេះ បានកំណត់កម្រិតនៃការពេញចិត្តរបស់អតិថិជនលើផលិតផល និងសេវាកម្ម ព្រមទាំងប្រមូលបាននូវមតិកែលម្អ និងការតវ៉ារបស់អតិថិជន ដើម្បីស្វែងរកចំណុចខ្វះខាតសម្រាប់ការកែលម្អ និងការច្នៃប្រឌិតបង្កើតផលិតផល និងសេវាកម្មថ្មីៗជាដើម ដើម្បីបំពេញតាមតម្រូវការរបស់អតិថិជន។ ដូច្នេះការស្ទង់មតិលើការពេញចិត្តរបស់អតិថិជនពិតជាមានសារៈសំខាន់ និងបានក្លាយជាការពេញនិយមកាន់តែខ្លាំងឡើង ហើយខាងក្រោមនេះគឺជាព័ត៌មានប្រជាសាស្ត្រ និងលទ្ធផលនៃការស្ទង់មតិក្នុងឆ្នាំ២០២៣៖



# អតិថិជនជោគជ័យ





“ក្រោយពីបានប្រើប្រាស់កម្ចីពី អិលអូអិលស៊ី ជីវភាពគ្រួសាររបស់ខ្ញុំរីកចម្រើន និងប្រសើរជាងមុន ដែលមានរបរដ៏រឹងមាំ ហើយដំណាំក៏ទទួលបានផលល្អ ជាពិសេសខ្ញុំបានក្លាយជាឈ្មួញដ៏ស្ទាត់ជំនាញក្នុងការទិញលក់គោ ក្របី ព្រមទាំងមានដើមទុនគ្រប់គ្រាន់ដើម្បីបង្វិលក្នុងអាជីវកម្មផងដែរ។” ប្រសាសន៍របស់ **អ្នកមីង សាន ផាន** ដែលជាឈ្មួញជួញគោ ក្របី និងជាអ្នកដាំដំណាំម្រេច និងកៅស៊ូ ដែលស្ថិតនៅភូមិជីប៉ែន ឃុំស្រែចារ ស្រុកស្នួល ខេត្តក្រចេះ។



**លោកពូ លាង ឡាយ** មានមុខរបរជា អ្នកលក់ជីកសិកម្ម លក់អីវ៉ាន់ចាប់ហួយ និងជាភ្នាក់ងារផ្ទេរប្រាក់រហ័ស (ទ្រូម៉ាន់នី និងអ៊ីម៉ាន់នី) ដែលស្ថិតនៅភូមិដូនមាស៣ ឃុំស្រែចារ ស្រុកស្នួល ខេត្តក្រចេះ បានសម្តែងការពេញចិត្តលើផលិតផល និងសេវាកម្មរបស់ អិលអូអិលស៊ី ថា “ខ្ញុំពិតជាអរគុណដល់ប្រាក់កម្ចីរបស់ អិលអូអិលស៊ី ណាស់ដែលបានផ្លាស់ប្តូរជីវភាពរស់នៅរបស់ខ្ញុំ និងគ្រួសារឱ្យប្រសើរឡើងដូចសព្វថ្ងៃ។”

**អ្នកស្រី គង់ ធីតា** មានមុខរបរជា អ្នកធ្វើព្រះភូមិ នៅភូមិបន្ទាយដែក ឃុំអូរអំបិល ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ បានរៀបរាប់ពីការផ្លាស់ប្តូរក្នុងជីវិតគ្រួសាររបស់គាត់ចាប់តាំងពីប្រើប្រាស់ កម្ចីរបស់ អិលអូអិលស៊ី ពីឆ្នាំ២០១៦ ថា “អរគុណប្រាក់កម្ចីរបស់ អិសអូអិលស៊ី ខ្ញុំមានដើមទុនគ្រប់គ្រាន់ដើម្បីពង្រីកអាជីវកម្មរបស់ខ្ញុំ និងប្រាក់គ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ការសិក្សារបស់កូនខ្ញុំ។”



# ០៥.
# របាយការណ៍ហិរញ្ញវត្ថុ

## សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣


របាយការណ៍ក្រុមប្រឹក្សាភិបាល (១៣០)

របាយការណ៍សវនករឯករាជ្យ (១៣៤)

របាយការណ៍ហិរញ្ញវត្ថុ (១៣៧)


០៥.



# របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលសូមដាក់ជូនរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី (ហៅកាត់ថា "ក្រុមហ៊ុន") សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុ ("ទទួលប្រាក់បញ្ញើ និងផ្តល់ឥណទាន") ដល់ប្រជាជននៅតាមជនបទ មីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យម តាមរយៈការិយាល័យកណ្តាលនៅរាជធានីភ្នំពេញ និងសាខាផ្សេងៗទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ កម្មវត្ថុនៃអាជីវកម្មរបស់ក្រុមហ៊ុន គឺផ្តល់នូវសេវាផ្នែកហិរញ្ញវត្ថុដែលអាចទុកចិត្តបាន និងអាចទទួលយកបានដល់សហគ្រិនខ្នាតតូច និងសហគ្រាសធុនតូច និងមធ្យម។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ មានដូចខាងក្រោម៖

| | ២០២៣<br>ពាន់រៀល | ២០២២<br>ពាន់រៀល | ២០២៣<br>ដុល្លារអាមេរិក<br>(កំណត់សម្គាល់ ២.៤(iii)) | ២០២២<br>ដុល្លារអាមេរិក<br>(កំណត់សម្គាល់ ២.៤(iii)) |
|---|---|---|---|---|
| ប្រាក់ចំណេញមុនដកពន្ធ | ៣៣៩.០៩១.១១៥ | ៣០០.៩៦៥.៧៨៥ | ៨២.៥០៣.៩២២ | ៧៣.៦៣៩.៧៨១ |
| ចំណាយពន្ធលើប្រាក់ចំណេញ | (៦៩.០០៥.១១៣) | (៦១.០៧៨.១៧៦) | (១៦.៧៨៩.៥៦៥) | (១៤.៩៤៤.៥០១) |
| ប្រាក់ចំណេញសម្រាប់ការិយបរិច្ឆេទ | ២៧០.០៨៦.០០២ | ២៣៩.៨៨៧.៦០៩ | ៦៥.៧១៤.៣៥៧ | ៥៨.៦៩៥.២៨០ |

## ភាគលាភ

នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ក្រុមប្រឹក្សាភិបាលបានអនុម័តបែងចែកភាគលាភដែលត្រូវបង់ជូនភាគទុនិក មានចំនួន ១០.០៩៦.៩៨២ ពាន់រៀល (ឆ្នាំ២០២២៖ មិនមាន)។ ការបែងចែកភាគលាភនេះទទួលបានការអនុម័តពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៣ ហើយបានបង់ជូនភាគទុនិកនៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣។

នាពេលបន្ទាប់ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រុមប្រឹក្សាភិបាលបានអនុម័តភាគលាភដែលត្រូវបង់ជូនភាគទុនិក មានចំនួន ៥៣.៨៩៥.៩៣០ ពាន់រៀល។ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រុមហ៊ុនបានដាក់សំណើរសុំបែងចែកភាគលាភទៅកាន់ធនាគារជាតិនៃកម្ពុជា("NBC")។ នាកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ពុំមានការឆ្លើយតបពី NBC លើសំណើរសុំ របស់ក្រុមហ៊ុននៅឡើយទេ។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## ដើមទុន

នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ភាគហ៊ុនដែលបានចុះបញ្ជីសរុបរបស់ក្រុមហ៊ុន មានចំនួន ៤.២៤៣.៧៧៤ ហ៊ុន (ឆ្នាំ២០២២៖ ២.២៤៣.៧៧៤ ហ៊ុន) ដែលមានតម្លៃចារិក ១០០ ពាន់រៀល ក្នុងមួយហ៊ុន (ឆ្នាំ២០២២៖ ១០០ ពាន់រៀល)។

នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣ ក្រុមហ៊ុនបានទទួលការអនុម័តពីធនាគារជាតិនៃកម្ពុជា ("NBC") លើសំណើ ក្នុងការធ្វើមូលធនកម្មប្រាក់ចំណេញរក្សាទុកចំនួន ២០០.០០០ លានរៀល ដើម្បីបង្កើនដើមទុនរបស់ខ្លួន ហើយការធ្វើបច្ចុប្បន្នភាពដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនេះលើអនុស្សារណៈ និងលក្ខន្តិកៈ ("MoAA") របស់ក្រុមហ៊ុនបានទទួលការអនុម័តពីក្រសួងពាណិជ្ជកម្ម ("MoC") នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣។សូមមើលកំណត់សម្គាល់ ២២ សម្រាប់ព័ត៌មានលម្អិត។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តនៃទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ការខាតបង់ឥណទានដែលបានរំពឹងទុកទៅលើឥណទាន និងបុរេប្រទាន

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របនានា ដើម្បីបញ្ជាក់ថា វិធានការទាក់ទិនទៅនឹងការលុបចោលឥណទាន និងបុរេប្រទានអាក្រក់ និងការធ្វើសំវិធានធនសម្រាប់ការខាតបង់ឱនភាពនៃតម្លៃ ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថា រាល់ឥណទាន និងបុរេប្រទានអាក្រក់ទាំងអស់ត្រូវបានលុបចោល និងការធ្វើសំវិធានធនសម្រាប់ការខាតបង់ឥណទាន និងបុរេប្រទានអាក្រក់ និងសង្ស័យទាំងស្រុង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលអាចនឹងបណ្តាលឲ្យចំនួននៃការលប់ចោល ឬការធ្វើសំវិធានធន សម្រាប់ការខាតបង់ឱនភាពនៃតម្លៃលើឥណទាន និងបុរេប្រទាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះឡើយ។

## ទ្រព្យសកម្ម

នៅមុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មទាំងអស់ក្រៅពីបំណុល ដែលទំនងជាមិនអាចទទួលស្គាល់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ដូចដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន នឹងត្រូវបន្ថយនៅស្មើនឹងតម្លៃដែលគិតថានឹងអាចប្រមូលបានជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកលើកម្រិតនៃការយល់ដឹង ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវនោះទេ។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## វិធីសាស្ត្រវាយតម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង ហើយអាចនឹងធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ៖

(ក) ពុំមានការផ្លាស់ប្តូរលើទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលបានយកមកប្រើប្រាស់សម្រាប់ការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះមក និង

(ខ) ពុំមានបំណុលយថាហេតុណាមួយរបស់ក្រុមហ៊ុន ដែលបានកើតឡើងចាប់តាំងពីការិយបរិច្ឆេទហិរញ្ញវត្ថុមក ក្រៅពីបំណុលផ្សេងៗនៅក្នុងដំណើរការអាជីវកម្មធម្មតានោះទេ។

តាមមតិរបស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗរបស់ក្រុមហ៊ុន ដែលត្រូវបានទាមទារឲ្យសង ឬអាចនឹងត្រូវបានទាមទារឲ្យសងក្នុងរយៈពេល ១២ខែ បន្ទាប់ពីការិយបរិច្ឆេទហិរញ្ញវត្ថុ ដែលនឹងបង្កឲ្យមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលដែលដល់ថ្ងៃកំណត់នោះឡើយ។

## ការផ្លាស់ប្តូរនៃកាលៈទេសៈ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងអំពីកាលៈទេសៈណាមួយ ដែលមិនបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលអាចនឹងបណ្តាលឲ្យមានតួលេខនៃចំនួនណាមួយ ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ថាមានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាលយល់ឃើញថា លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។ ក្រុមប្រឹក្សាភិបាលយល់ឃើញថា នៅក្នុងចន្លោះពេលចាប់ពីចុងការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានសកម្មភាពប្រតិបត្តិការ ព្រឹត្តិការណ៍ ឬធាតុណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើង ដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទដែលរបាយការណ៍ត្រូវបានរៀបចំឡើងនោះទេ។





# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុ និងរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ រួមមាន៖

| | |
|---|---|
| លោក Brindley Chrishantha Gajanayake de Zylva | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក Indrajith Wijesiriwardana | សមាជិក |
| លោក Hans Michael Theodor Moormann | សមាជិក (បញ្ចប់អាណត្តិនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣) |
| លោក Chitral Nalin Wijesinha. Member | សមាជិក (តែងតាំងនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤) |
| លោក Dulip Rasika Samaraweera | សមាជិក |
| លោក Francisco Kankanamalage Conrad Prasad Nirosh Dias | សមាជិក |

## ភាគកម្មរបស់ក្រុមប្រឹក្សាភិបាល

ពុំមានអភិបាលណាម្នាក់កាន់កាប់ ឬមានការទាក់ទិននៅក្នុងភាគហ៊ុនរបស់ក្រុមហ៊ុនដោយផ្ទាល់ ឬដោយប្រយោល នៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ក្នុងអំឡុង និងនាចុងការិយបរិច្ឆេទនៃឆ្នាំហិរញ្ញវត្ថុនេះ ពុំមានកិច្ចព្រមព្រៀងណាមួយដែលក្រុមហ៊ុនជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះអាចផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាភិបាលណាម្នាក់ឲ្យទទួលបាននូវអត្ថប្រយោជន៍ តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬ សាជីវកម្មដទៃនោះទេ។

នៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍នេះ ពុំមានអភិបាលណាម្នាក់របស់ក្រុមហ៊ុនបានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានរួមបញ្ចូលនៅក្នុងបរិលាភសរុប ទទួលបាន ឬដល់កំណត់ទទួលបានដោយអភិបាល ដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬដោយក្រុមហ៊ុនពាក់ព័ន្ធជាមួយនឹងក្រុមហ៊ុន ដែលអភិបាលនោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុន ដែលអភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវលើរាល់ទិដ្ឋភាពជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "ស.រ.ទ.ហ.អ.ក")។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ (ត)

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ តម្រូវឲ្យក្រុមប្រឹក្សាភិបាល៖

i) អនុវត្តគោលការណ៍គណនេយ្យសមស្រប ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ស្មានសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលការណ៍ទាំងនោះឲ្យមានសង្គតិភាព។

ii) អនុវត្តតាមតម្រូវការក្នុងការលាតត្រដាងព័ត៌មានរបស់ ស.រ.ទ.ហ.អ.ក ឬប្រសិនបើមានការប្រាសចាកណាមួយក្នុងការបង្ហាញឲ្យមានភាពត្រឹមត្រូវ ការប្រាសចាកទាំងនោះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឲ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

iii) រក្សាទុកកំណត់ត្រាគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមួយប្រកបដោយប្រសិទ្ធភាព។

iv) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លុះត្រាតែមានភាពមិនសមស្របក្នុងការសន្មតថា ក្រុមហ៊ុននឹងបន្តប្រតិបត្តិការអាជីវកម្មនៅពេលអនាគតដ៏ខ្លី និង

v) គ្រប់គ្រងនិងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធភាព តាមរយៈការសម្រេចចិត្តជាសារវន្តទាំងអស់ដែលជះឥទ្ធិពលដល់ប្រតិបត្តិការ និងលទ្ធផលរបស់ក្រុមហ៊ុន ហើយត្រូវធានាថាផលប៉ះពាល់ទាំងនោះត្រូវបានឆ្លុះបញ្ចាំងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា ក្រុមហ៊ុនបានអនុវត្តតាមតម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុ

ខ្ញុំបាទ ក្នុងនាមក្រុមប្រឹក្សាភិបាល សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ ព្រមទាំងកំណត់សម្គាល់ទាំងឡាយ បានបង្ហាញនូវភាពត្រឹមត្រូវលើរាល់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក")។

*ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាល ដោយអនុលោមទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល៖*

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី LOLC (CAMBODIA) Plc. KINGDOM OF CAMBODIA

លោក Brindley Chrishantha Gajanayake de Zylva

*ប្រធានក្រុមប្រឹក្សាភិបាល*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៤

KPMG Cambodia Ltd
GIA Tower, Sopheak Mongkul Street, Phum 14
Sangkat Tonle Bassac, Khan Chamkar Mon
Phnom Penh, Cambodia
+855 (17) 666 537 / +855 (81) 533 999 | kpmg.com.kh

# របាយការណ៍របស់សវនករឯករាជ្យ
## ជូនចំពោះភាគទុនិករបស់
## អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

### *មតិសវនកម្ម*

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី (ហៅកាត់ថា "ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ដែលរួមមានគោលនយោបាយគណនេយ្យសារវន្ត ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗទៀត ដែលបានបង្ហាញនៅទំព័រទី១០ ដល់ទី១២២ (ហៅកាត់ថា "របាយការណ៍ហិរញ្ញវត្ថុ")។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ បានបង្ហាញនូវភាពត្រឹមត្រូវលើរាល់ទិដ្ឋភាពជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក")។

### *មូលដ្ឋាននៃមតិសវនកម្ម*

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាមស្តង់ដាទាំងនោះ ត្រូវបានពណ៌នាបន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពី *ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ* ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំ មានភាពឯករាជ្យពីក្រុមហ៊ុន ដោយស្របទៅតាមលក្ខខណ្ឌតម្រូវនៃក្រមសីលធម៌វិជ្ជាជីវៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវក្រមសីលធម៌វិជ្ជាជីវៈផ្សេងៗទៀតស្របតាមលក្ខខណ្ឌតម្រូវទាំងនេះ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបាន មានលក្ខណៈគ្រប់គ្រាន់ និងសមស្រប សម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។



KPMG Cambodia Ltd., a Cambodian single member private limited company and a member firm of the KPMG global organization of independent member firms affiliated with KPMG International Limited, a private English company limited by guarantee. All rights reserved.

### *ព័ត៌មានផ្សេងៗ*

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗរួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ដែលបានបង្ហាញនៅទំព័រទី១ ដល់ទី៥ និងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន ដែលរំពឹងថានឹងរួចរាល់ បន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ។ មតិសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំមិនធ្វើការផ្តល់នូវអំណះអំណាងណាមួយទៅលើព័ត៌មានផ្សេងៗនេះទេ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានអសង្គតិភាពជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំ នៅក្នុងការធ្វើសវនកម្ម ឬក៏ព័ត៌មានផ្សេងៗនេះ បង្ហាញនូវកំហុងឆ្គងជាសារវន្តដែរ ឬទេ។ ប្រសិនបើផ្អែកទៅលើការអានព័ត៌មានផ្សេងៗ អាចឲ្យយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗ នេះទេ។

### *បញ្ហាផ្សេងទៀត*

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ត្រូវបានធ្វើសវនកម្មដោយសវនករផ្សេង ហើយបានបញ្ចេញមតិនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ ថារបាយការណ៍ហិរញ្ញវត្ថុទាំងនោះមានភាពត្រឹមត្រូវ។

### *ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ចនៃរបាយការណ៍ហិរញ្ញវត្ថុ*

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាម ស.រ.ទ.អ.ហ.ក ហើយទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធ នូវបញ្ហាទាំងឡាយដែលទាក់ទិនទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀត ក្រៅពីធ្វើបែបនេះ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ព័ត៌មានហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

### *ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ*

គោលដៅរបស់យើងខ្ញុំ គឺទទួលបាននូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូល មិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករ ដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងមួយដែលមានកម្រិតខ្ពស់ ប៉ុន្តែវាមិនអាចធានាថា គ្រប់ពេលនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការបង្ហាញខុស អាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាមានលក្ខណៈសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងដោយឡែក ឬក៏រួមបញ្ចូលគ្នាអាចត្រូវបានរំពឹងទុកយ៉ាងសមហេតុផលថា នឹងជះឥទ្ធិពលដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយមក្នុងអំឡុងពេលធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការតាក់តែង និងអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យនៃការរកមិនឃើញនូវការបង្ហាញខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាងការបង្ហាញខុសដែលបណ្តាលមកពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំអាចទាក់ទិននឹងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ធ្វើការស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីតាក់តែងនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។
- ធ្វើការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យដែលក្រុមហ៊ុនបានអនុវត្ត និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធនានា ដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។
- ធ្វើការសន្និដ្ឋានលើ ភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើភាពមិនប្រាកដប្រជាជាសារវន្ត បានកើតមានឡើងពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចបង្កឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ក្រុមហ៊ុន ដើម្បីបន្តនិរន្តរភាពអាជីវកម្មដែរ ឬទេ។ ប្រសិនបើយើងខ្ញុំ ធ្វើការសន្និដ្ឋានថា មានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវទាញចំណាប់អារម្មណ៍ នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ លើការលាតត្រដាង ព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចធ្វើឲ្យក្រុមហ៊ុនបញ្ឈប់និរន្តរភាពនៃអាជីវកម្ម។

- ធ្វើការវាយតម្លៃលើការបង្ហាញ ទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដោយរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

យើងខ្ញុំ ផ្តល់ព័ត៌មាន ក្នុងចំណោមបញ្ហាផ្សេងៗ ជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ចស្តីពីវិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្ត ដោយរួមបញ្ចូលទាំងចំណុចខ្វះខាតជាសារវន្តក្នុងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា**

**ហ្គេក ឆាន**

*Partner*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៤

# អេលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | | ថ្ងៃទី៣១ ខែធ្នូ | | ថ្ងៃទី៣១ ខែធ្នូ | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ឆ្នាំ២០២៣ ពាន់រៀល | ឆ្នាំ២០២២ ពាន់រៀល | ឆ្នាំ២០២៣ ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) | ឆ្នាំ២០២២ ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤ | ១២៤.៣៧២.០០៨ | ១០៦.៨០៩.៨៥០ | ៣០.៤៩៦.០២៤ | ២៥.៩៤៣.៦១២ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅ ធនាគារជាតិនៃកម្ពុជា | ៥ | ១៣៤.១៩២.២២៤ | ១៩៤.៨៥៣.៣៩៣ | ៣២.៨៤៩.៩៩៤ | ៤៧.៣២៨.៩៧៦ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅ ធនាគារនានា | ៦ | ៦៧២.២៨៧.៤៨៦ | ៣៧១.៩៨៨.៩៤៩ | ១៦៤.៥៧៤.៦៦០ | ៩០.៣៥៤.៣៧២ |
| ទ្រព្យសកម្មហិរញ្ញវត្ថុតាមតម្លៃសមស្រប ក្នុងលទ្ធផលលម្អិតផ្សេងៗ | ៧ | ៦១.២៧៥ | ៦១.៧៥៥ | ១៥.០០០ | ១៥.០០០ |
| ឥណទាន និងបុរេប្រទាន តាមរំលស់ថ្លៃដើម | ៨ | ៥.០០៣.១៣៩.៣៧៦ | ៥.០០៦.៧២៤.៤៧៣ | ១.២២៤.៧៥៨.៧២១ | ១.២១៦.១០៩.៩០៤ |
| ប្រាក់តម្កល់តាមច្បាប់នៅ ធនាគារជាតិនៃកម្ពុជា | ៩ | ៣៧១.៦១១.៧៦១ | ២៩០.៨១៣.០០០ | ៩០.៩៦៩.៨៣១ | ៧០.៦៣៧.១១៤ |
| ទ្រព្យ និងបរិក្ខារ | ១០ | ១២.១៩៥.៥១៦ | ៦.៨៩៥.១២៤ | ២.៩៧៣.១៩៨ | ១.៦៦២.៦៤៩ |
| សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | ១១ | ២៨.៦៦១.០១០ | ២៨.៣៦៤.០៣៩ | ៧.០១៦.១៥៩ | ៦.៨៨៩.៤៩២ |
| ទ្រព្យសកម្មអរូបី | ១២ | ៧.៨១៨.០៩៤ | ៨.២៩០.៣៣៥ | ១.៩១៣.៨៥៤ | ២.០១៣.៦៨៣ |
| ពន្ធពន្យារជាទ្រព្យសកម្ម - សុទ្ធ | ១៣ | ២៩.៦២៧.៩០៨ | ៣៨.៩៩៤.១៩៣ | ៧.២៥២.៨៥៤ | ៩.៤៥៩.៣៥០ |
| ទ្រព្យសកម្មផ្សេងៗ | ១៤ | ២០.៦៧៩.១១៣ | ២១.៦១១.៧៩៤ | ៥.០៦២.២០៧ | ៥.២៤៩.៤០៤ |
| **ទ្រព្យសកម្មសរុប** | | ៦.៤០៤.៥៩៩.៧៧១ | ៦.០៧៥.៣០៦.៨៥៥ | ១.៥៦៧.៨៣២.៥០២ | ១.៤៧៥.៦៦៣.៥៥៦ |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | ១៥ | ១៩៣.៥៧៥.៨៦២ | ១២១.៩៦០.៦៥២ | ៤៧.៣៨៦.៩៩២ | ២៩.៦២៣.៦៧១ |
| ប្រាក់បញ្ញើរបស់អតិថិជន | ១៦ | ៣.៤៩៨.៩២៨.៥៧៥ | ៣.០៣៦.៩៩៦.៧៥៥ | ៨៥៦.៥៣០.៨៦៣ | ៧៣៧.៥៥០.៨២៧ |
| ប្រាក់កម្ចី | ១៧ | ៨៨៤.០៩៦.១០០ | ១.២៦៩.៦៥០.៥៤៣ | ២១៦.៤២៤.៩៩៤ | ៣០៨.៣៩២.១៦៥ |
| បំណុលភតិសន្យា | ១១ | ២៧.៨៨១.៦៦៦ | ២៦.៣៤១.៧២៧ | ៦.៧២៧.៩៥៨ | ៦.៣៩៨.២៨២ |
| បំណុលពន្ធលើប្រាក់ចំណេញ | ១៨ | ៥០.៣៣៩.៥៩២ | ៦៤.៦៧៨.០៣៩ | ១២.៣២៣.០៣៤ | ១៥.៧០៩.៩៩២ |
| អត្ថប្រយោជន៍បុគ្គលិក | ១៩ | ២.០៩៩.២៩០ | ២.៣១០.៣២៥ | ៥១៣.៩០២ | ៥៦១.១៦៧ |
| បំណុលផ្សេងៗ | ២០ | ៣៩.២៦៣.០៦៤ | ៤៤.៦២០.១១៩ | ៩.៦១១.៥២១ | ១០.៨៣៨.០២០ |
| អនុបំណុល | ២១ | ២៥៣.៧៥៣.១៧៥ | ៣១៤.១៧៩.២៦៨ | ៦២.១១៨.២៨០ | ៧៦.៣១២.៦៧១ |
| **បំណុលសរុប** | | ៤.៩៤៩.៥៣៧.៣២៤ | ៤.៨៨០.២៣៧.៤២៨ | ១.២១១.៦៣៧.០៩៤ | ១.១៨៥.៣៨៦.៧៩៥ |

## អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

### របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (ត)
### នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់សម្គាល់ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ពាន់រៀល | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ពាន់រៀល | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) |
|---|---|---|---|---|---|
| **មូលធន** | | | | | |
| ដើមទុន | ២២ក | ៤២៤.៣៧៧.៤០០ | ២២៤.៣៧៧.៤០០ | ១០៣.៩៦៩.២១៨ | ៥៥.៤៦០.៨៥០ |
| ប្រាក់ចំណេញរក្សាទុក | | ៦២៣.២០៣.២៥០ | ៥៩០.២៧៦.៩១១ | ១៥៣.០៤៨.៨៣០ | ១៤៤.៩៣៦.៨២៥ |
| ទុនបម្រុងទូទៅ | | ៣៨០.៤១៥.១១៦ | ៣៨០.៤១៥.១១៦ | ៩៣.៧៦៨.៩៥១ | ៩៣.៧៦៨.៩៥១ |
| ទុនបម្រុងតាមបទបញ្ញត្តិ | ២៣ | ២១.៩៣៨.០៤០ | - | ៥.៣៦៧.៧៦១ | - |
| ទុនបម្រុងផ្សេងៗ | ២៤ | ៥.១២៤.៦៤១ | - | ១.២៥៤.៥០២ | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | (១.២១៣.៨០៤) | (៣.៨៨៩.៨៦៥) |
| **មូលធនសរុប** | | ១.៤៥៥.០៥៨.៤៤៧ | ១.១៩៥.០៦៩.៤២៧ | ៣៥៦.១៩៥.៤៥៨ | ២៩០.២៧៦.៧៦១ |
| **បំណុល និងមូលធនសរុប** | | ៦.៤០៤.៥៩៥.៧៧១ | ៦.០៧៥.៣០៦.៨៥៥ | ១.៥៦៧.៨៣២.៥០២ | ១.៤៧៥.៦៦៣.៥៥៦ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។





## អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

### របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ
### សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់សម្គាល់ | ២០២៣ ពាន់រៀល | ២០២២ ពាន់រៀល | ២០២៣ ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) | ២០២២ ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) |
|---|---|---|---|---|---|
| ចំណូលពីការប្រាក់ | ២៥ | ៨៩១.១០៥.៩៤៤ | ៨៦៤.៦៥៣.១២៣ | ២១៦.៨១៤.០៩៨ | ២១១.៥៦១.៨១១ |
| ចំណាយលើការប្រាក់ | ២៥ | (៣៥៤.២១៦.៤៣៧) | (៣០៦.៣០៧.៨៨០) | (៨៦.១៨៤.០៤៨) | (៧៤.៩៤៦.៨៧៥) |
| **ចំណូលពីការប្រាក់សុទ្ធ** | | ៥៣៦.៨៨៩.៥០៧ | ៥៥៨.៣៤៥.២៤៣ | ១៣០.៦៣០.០៥០ | ១៣៦.៦១៤.៩៣៦ |
| ចំណូលពីកម្រៃ និងជើងសា | ២៦ | ២២.២២២.៩១៧ | ២៧.០៧២.១០៥ | ៥.៤០៧.០៣៦ | ៦.៦២៣.៩៥៥ |
| ចំណាយលើកម្រៃ និងជើងសា | ២៦ | (៨៣២.០៣៤) | (៨៩៨.៩៤៣) | (២០២.៤៤១) | (២១៩.៩៥២) |
| **ចំណូលពីកម្រៃ និងជើងសាសុទ្ធ** | | ២១.៣៩០.៨៨៣ | ២៦.១៧៣.១៦២ | ៥.២០៤.៥៩៥ | ៦.៤០៤.០០៣ |
| ចំណូលប្រតិបត្តិការផ្សេងៗ | | ៥.៦៧១.០២៨ | ៣.៧២០.៥៤៦ | ១.៣៧៩.៨១២ | ៩១០.៣៣៧ |
| ចំណេញ/(ខាត) ផ្សេងៗ - សុទ្ធ | | ២.៨៩២.៩១២ | (១.៨៥២.០១៣) | ៧០៣.៨៧២ | (៤៥៣.១៤៧) |
| ការបង្វិលត្រឡប់មកវិញ/(ខាត) ពីការថយចុះតម្លៃឥណទាន | ២៧ | ១៩.៦០០.៣៥៨ | (៦៨.៨១៣.២៨៧) | ៤.៧៦៨.៩៤៤ | (១៦.៨៣៧.១១៥) |
| ការខាតបង់សុទ្ធលើការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម | | (២៩.៨៤៩.៦៨៦) | (៥.០៩១.៣១១) | (៧.២៦២.៦៩៧) | (១.២៤៥.៧៣៣) |
| **ខាតពីប្រតិបត្តិការផ្សេងៗសុទ្ធ** | | (១.៦៨៥.៣៨៨) | (៧២.០៣៦.០៦៥) | (៤១០.០៦៩) | (១៧.៦២៥.៦៥៨) |
| ចំណាយបុគ្គលិក | ២៨ | (១៤៨.៤៧១.៦៧៩) | (១៤៤.០៨៧.១៤៥) | (៣៦.១២៤.៤៩៦) | (៣៥.២៥៤.៩៩០) |
| ចំណាយរំលស់ | ២៩ | (១៤.២០១.១៦៦) | (១២.៥១១.១៨៧) | (៣.៤៥៥.២៧២) | (៣.០៦១.២១៥) |
| ចំណាយប្រតិបត្តិការផ្សេងៗ | ៣០ | (៥៤.៨៣១.០៩២) | (៥៤.៩១៨.២២៣) | (១៣.៣៤០.៨៨៦) | (១៣.៤៣៧.២៩៥) |
| **ប្រាក់ចំណេញមុនដកពន្ធលើប្រាក់ចំណេញ** | | ៣៣៩.០៩១.១១៥ | ៣០០.៩៦៥.៧៨៥ | ៨២.៥០៣.៩២២ | ៧៣.៦៣៩.៧៨១ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ៣១ | (៦៩.០០៥.១១៣) | (៦១.០៧៨.១៧៦) | (១៦.៧៨៩.៥៦៥) | (១៤.៩៤៤.៥០១) |
| **ប្រាក់ចំណេញសម្រាប់ការិយបរិច្ឆេទ** | | ២៧០.០៨៦.០០២ | ២៣៩.៨៨៧.៦០៩ | ៦៥.៧១៤.៣៥៧ | ៥៨.៦៩៥.២៨០ |
| លទ្ធផលលម្អិតផ្សេងៗ៖ | | | | | |
| *ធាតុដែលមិនត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញក្នុងចំណេញ ឬខាត* | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | ២.៦៧៦.០៦១ | (២.៨៧៦.៥០១) |
| ចំណូលលម្អិតផ្សេងៗសម្រាប់ការិយបរិច្ឆេទ-ដកពន្ធរួច | | - | - | ២.៦៧៦.០៦១ | (២.៨៧៦.៥០១) |
| **លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | | ២៧០.០៨៦.០០២ | ២៣៩.៨៨៧.៦០៩ | ៦៨.៣៩០.៤១៨ | ៥៥.៨១៨.៧៧៩ |
| **ប្រាក់ចំណេញសុទ្ធត្រូវបែងចែកជូន៖** | | | | | |
| ភាគទុនិករបស់ក្រុមហ៊ុន | | ២៧០.០៨៦.០០២ | ២៣៩.៨៨៧.៦០៩ | ៦៥.៧១៤.៣៥៧ | ៥៨.៦៩៥.២៨០ |
| **លទ្ធផលលម្អិតសរុបត្រូវបែងចែកជូន៖** | | | | | |
| ភាគទុនិករបស់ក្រុមហ៊ុន | | ២៧០.០៨៦.០០២ | ២៣៩.៨៨៧.៦០៩ | ៦៨.៣៩០.៤១៨ | ៥៥.៨១៨.៧៧៩ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

របាយការណ៍ស្តីពីបម្រែបម្រួលមូលធន
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

**ត្រូវបែងចែកជូនភាគទុនិករបស់ក្រុមហ៊ុន**

| | ដើមទុន ពាន់រៀល | ប្រាក់ចំណេញរក្សាទុក ពាន់រៀល | ទុនបម្រុងទូទៅ ពាន់រៀល | ទុនបម្រុងតាមបទប្បញ្ញត្តិ ពាន់រៀល | ទុនបម្រុងផ្សេងៗ ពាន់រៀល | ទុនបម្រុងពីការប្តូររូបិយប័ណ្ណ ពាន់រៀល | សរុប ពាន់រៀល | ដើមទុន ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) | ប្រាក់ចំណេញរក្សាទុក ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) | ទុនបម្រុងទូទៅ ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) | ទុនបម្រុងតាមបទប្បញ្ញត្តិ ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) | ទុនបម្រុងផ្សេងៗ ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) | ទុនបម្រុងពីការប្តូររូបិយប័ណ្ណ ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) | សរុប ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | ២២៤.៣៧៧.៤០០ | ៣៥០.៣៨៩.៣០២ | ៣៨០.៤១៥.១១៦ | - | - | - | ៩៥៥.១៨១.៨១៨ | ៥៥.៨៦០.៨៥០ | ៨៦.២៤១.៥៥៥ | ៩៣.៧៦៨.៩៥១ | - | - | (១.០១៣.៣៧៤) | ២៣៤.៨៥៧.៩៨២ |
| ប្រាក់ចំណេញសម្រាប់ការិយបរិច្ឆេទ | - | ២៣៩.៨៨៧.៦០៩ | - | - | - | - | ២៣៩.៨៨៧.៦០៩ | - | ៥៨.៦៩៥.២៨០ | - | - | - | - | ៥៨.៦៩៥.២៨០ |
| លទ្ធផលលម្អិតផ្សេងៗ – លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | - | - | - | (២.៨៧៦.៥០១) | (២.៨៧៦.៥០១) |
| **លទ្ធផលលម្អិតសរុប សម្រាប់ការិយបរិច្ឆេទ** | - | ២៣៩.៨៨៧.៦០៩ | - | - | - | - | ២៣៩.៨៨៧.៦០៩ | - | ៥៨.៦៩៥.២៨០ | - | - | - | (២.៨៧៦.៥០១) | ៥៥.៨១៨.៧៧៩ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | ២២៤.៣៧៧.៤០០ | ៥៩០.២៧៦.៩១១ | ៣៨០.៤១៥.១១៦ | - | - | - | ១.១៩៥.០៦៩.៤២៧ | ៥៥.៨៦០.៨៥០ | ១៤៤.៩៣៦.៨២៥ | ៩៣.៧៦៨.៩៥១ | - | - | (៣.៨៨៩.៨៧៥) | ២៩០.២៧៦.៧៦១ |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣** | ២២៤.៣៧៧.៤០០ | ៥៩០.២៧៦.៩១១ | ៣៨០.៤១៥.១១៦ | - | - | - | ១.១៩៥.០៦៩.៤២៧ | ៥៥.៨៦០.៨៥០ | ១៤៤.៩៣៦.៨២៥ | ៩៣.៧៦៨.៩៥១ | - | - | (៣.៨៨៩.៨៧៥) | ២៩០.២៧៦.៧៦១ |
| ប្រាក់ចំណេញសម្រាប់ការិយបរិច្ឆេទ | - | ២៧០.០៨៦.០០២ | - | - | - | - | ២៧០.០៨៦.០០២ | - | ៦៥.៧១៤.៣៥៧ | - | - | - | - | ៦៥.៧១៤.៣៥៧ |
| លទ្ធផលលម្អិតផ្សេងៗ – លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | - | - | - | ២.៦៧៦.០៦១ | ២.៦៧៦.០៦១ |
| **លទ្ធផលលម្អិតសរុប សម្រាប់ការិយបរិច្ឆេទ** | - | ២៧០.០៨៦.០០២ | - | - | - | - | ២៧០.០៨៦.០០២ | - | ៦៥.៧១៤.៣៥៧ | - | - | - | ២.៦៧៦.០៦១ | ៦៨.៣៩០.៤១៨ |
| **ប្រតិបត្តិការជាមួយភាគទុនិកក្នុង សមាសភាពជាម្ចាស់ក្រុមហ៊ុន៖** | | | | | | | | | | | | | | |
| ផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅ ដើមទុន (កំណត់សម្គាល់ ២២ក) | ២០០.០០០.០០០ | (២០០.០០០.០០០) | - | - | - | - | - | ៤៨.៥០៨.៣៦៨ | (៤៨.៥០៨.៣៦៨) | - | - | - | - | - |
| ភាគលាភ (កំណត់សម្គាល់ ២២ខ) | - | (១០.០៩៦.៨៤២) | - | - | - | - | (១០.០៩៦.៨៤២) | - | (២.៤៧១.៧២១) | - | - | - | - | (២.៤៧១.៧២១) |
| ផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅ ទុនបម្រុងតាមបទប្បញ្ញត្តិ (កំណត់សម្គាល់ ២៣) | - | (២១.៩៣៨.០៤០) | - | ២១.៩៣៨.០៤០ | - | - | - | - | (៥.៣៦៧.៧៦១) | - | ៥.៣៦៧.៧៦១ | - | - | - |
| ផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅ ទុនបម្រុងផ្សេងៗ (កំណត់សម្គាល់ ២៤) | - | (៥.១២៤.៦៤១) | - | - | ៥.១២៤.៦៤១ | - | - | - | (១.២៥៤.៥០២) | - | - | ១.២៥៤.៥០២ | - | - |
| **ប្រតិបត្តិការសរុបជាមួយភាគទុនិក** | ២០០.០០០.០០០ | (២៣៧.១៥៩.៦៦៣) | - | ២១.៩៣៨.០៤០ | ៥.១២៤.៦៤១ | - | (១០.០៩៦.៨៤២) | ៤៨.៥០៨.៣៦៨ | (៥៧.៦០២.៣៥២) | - | ៥.៣៦៧.៧៦១ | ១.២៥៤.៥០២ | - | (២.៤៧១.៧២១) |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | ៤២៤.៣៧៧.៤០០ | ៦២៣.២០៣.២៥០ | ៣៨០.៤១៥.១១៦ | ២១.៩៣៨.០៤០ | ៥.១២៤.៦៤១ | - | ១.៤៥៥.០៥៨.៥៨៧ | ១០៣.៨៦៩.២១៨ | ១៥៣.០៤៨.៨៣០ | ៩៣.៧៦៨.៩៥១ | ៥.៣៦៧.៧៦១ | ១.២៥៤.៥០២ | (១.២១៣.៨០៤) | ៣៥៦.១៩៥.៤៥៨ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។



## អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

របាយការណ៍លំហូរទឹកប្រាក់
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់សម្គាល់ | ២០២៣ ពាន់រៀល | ២០២២ ពាន់រៀល | ២០២៣ ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) | ២០២២ ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) |
|---|---|---|---|---|---|
| **លំហូរទឹកប្រាក់បានពីសកម្មភាពប្រតិបត្តិការ** | | | | | |
| សាច់ប្រាក់ទទួលបានពី/ (ប្រើប្រាស់ក្នុង)ប្រតិបត្តិការ | ៣៣(ក) | ២៥៦.២៨១.៧៨២ | (៤១៥.៩៧៦.៩៨៨) | ៦២.៣៥៥.៦៦៦ | (១០១.៧៨០.៥១១) |
| ការប្រាក់បានទទួល | | ៨៩០.៦០៧.៧០៤ | ៨៧០.៥១៥.៦៨៣ | ២១៦.៦៩២.៨៧៣ | ២១២.៩៩៦.២៥២ |
| ការប្រាក់បានបង់ | | (៣៨០.៨០៧.១០៤) | (២៨០.២០៥.៩៩១) | (៩២.៦២៤.១១៣) | (៦៨.៥៦០.៣០១) |
| ពន្ធលើប្រាក់ចំណេញបានបង់ | ១៨ | (៧៤.០២៧.៣២៥) | (៦៣.៨៨៣.៣៧៨) | (១៨.០១១.៥១៥) | (១៥.៦៣០.៨៧៣) |
| អត្ថប្រយោជន៍បុគ្គលិកត្រូវបានបង់ | | (៧.៣៥៥.០២០) | (៧.៨៩១.៩៥៣) | (១.៧៨៩.៥៩២) | (១.៩២០.៩៦០) |
| **សាច់ប្រាក់សុទ្ធទទួលបានពី សកម្មភាពប្រតិបត្តិការ** | | ៧២៥.១០០.០៩១ | ១០៣.០០៧.៥៥៣ | ១៧៦.៤២៣.៣៦៩ | ២៥.២០៣.៧០៨ |
| **លំហូរទឹកប្រាក់បានពីសកម្មភាពវិនិយោគ** | | | | | |
| ប្រាក់តម្កល់ និងប្រាក់តម្កល់នៅ ធនាគារជាតិនៃកម្ពុជា | | (២៦៩.៥៦០) | (២.១៦៧.៧០១) | (៦៥.៥៨៦) | (៥៣០.៣៨៩) |
| ការទិញទ្រព្យនិងបរិក្ខារ | ១០ | (៩.២៥៦.៦០៥) | (៣.៩៩៦.៥០១) | (២.២៥២.២១៥) | (៩៧៧.៨៥៧) |
| ការទិញទ្រព្យសកម្មអរូបី | ១២ | (៣.០២៤.៩២៦) | (៥០៣.៣២៩) | (៧៣៥.៩៩២) | (១២៣.១៥៤) |
| សាច់ប្រាក់បានពីការលក់ទ្រព្យនិងបរិក្ខារ | | ៥៥០.៨៥៨ | ៤១១.២៥៩ | ១៣៤.០២៩ | ១០០.៦២៦ |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង សកម្មភាពវិនិយោគ** | | (១២.០០០.២៣៣) | (៦.២៥៦.២៧២) | (២.៩១៩.៧៦៤) | (១.៥៣០.៧៧៤) |
| **លំហូរទឹកប្រាក់បានពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | ៣៣(ខ) | ៩៧.៣៦៥.០៣២ | ៥៨៨.៨៩៥.២៣៣ | ២៣.៦៨៩.៧៨៩ | ១៤៣.៩១២.១២០ |
| ការទូទាត់ប្រាក់កម្ចី | ៣៣(ខ) | (៤៧៩.៦១៩.២១៥) | (៤៥១.២៧៦.៧៨៤) | (១១៦.៦៩៥.៦៧៣) | (១១០.៤១៧.៦៦៣) |
| សាច់ប្រាក់ទទួលបានពីអនុបំណុល | ៣៣(ខ) | - | ៧០.០២២.៧៥១ | - | ១៧.១៣៣.០៤៤ |
| ការទូទាត់អនុបំណុល | ៣៣(ខ) | (៥៤.៣៨២.៨០០) | (២៦.២៣៦.០០០) | (១៣.២៣១.៨២៥) | (៦.៤១៥.៣៧៩) |
| ការទូទាត់មូលបត្របំណុល | ៣៣(ខ) | - | (៨០.៥០៨.៧៨៣) | - | (១៩.៦៩៧.៧៦៩) |
| ការទូទាត់លើប្រតិបត្តិការ | ៣៣(ខ) | (២៩០.៥១៨) | (៦.០០០.៩១៥) | (៧០.៦៨៦) | (១.៤៦៨.២៩៣) |
| ការទូទាត់ភាគលាភទៅភាគទុនិក | ៣៣(ខ) | (១០.០៩៦.៨៤២) | - | (២.៤៥៦.៦៨៧) | - |
| ចំណែកប្រាក់ដើមក្នុងការទូទាត់ភតិសន្យា | ៣៣(ខ) | (៥.៩៣១.២៣៦) | (៥.៨៣០.៩៥៧) | (១.៤៤៣.១២៣) | (១.៤២៦.៧០៤) |
| **សាច់ប្រាក់សុទ្ធ (ប្រើប្រាស់ក្នុង)/ ទទួលបានពីសកម្មភាពហិរញ្ញប្បទាន** | | (៤៥២.៩៥៥.៧១៨) | ៨៥.០៧២.៥៤៥ | (១១០.២០៨.២០៥) | ២០.៨១៥.៤០២ |

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## របាយការណ៍លំហូរទឹកប្រាក់ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់សម្គាល់ | ២០២៣ ពាន់រៀល | ២០២២ ពាន់រៀល | ២០២៣ ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) | ២០២២ ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) |
|---|---|---|---|---|---|
| **ការកើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | ២៦០.១៤៤.០៩០ | ១៨១.៨២៣.៨២៦ | ៦៣.២៩៥.៤០០ | ៤៤.៤៨៨.៣៣៦ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ** | | ៦៧២.១៨៣.៧២៣ | ៤៩០.៣៥៩.៨៩៧ | ១៦៣.២៧០.២៧៥ | ១២០.៣៦៣.២៥៤ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | ១.៦៦៦.៣៤៨ | (១.៥៨១.៣១៥) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ** | ៣២ | ៩៣២.៣២៧.៨១៣ | ៦៧២.១៨៣.៧២៣ | ២២៨.២៣២.០២៣ | ១៦៣.២៧០.២៧៥ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។





# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

កំណត់សម្គាល់ទាំងនេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ហើយគួរតែត្រូវបានអានជាមួយគ្នានឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ។

### ១. ព័ត៌មានទូទៅ

ក្រុមហ៊ុន អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី (អតីត ធនាគារ ភូមិ (ខេមបូឌា) អិលធីឌី) (ហៅកាត់ថា "ក្រុមហ៊ុន") គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលមានចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា ដោយបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ជាក្រុមហ៊ុនសាធារណៈទទួលខុសត្រូវមានកម្រិត ដែលមានវិញ្ញាបនបត្រចុះបញ្ជីលេខ Co.១៩១៣E/២០០២ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០២ និងបានប្តូរទៅវិញ្ញាបនបត្រថ្មីលេខ ០០០១២៨២៩ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥។

នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ("MDI") ពីធនាគារជាតិ នៃ កម្ពុជា (ហៅកាត់ថា "NBC") ដើម្បីធ្វើប្រតិបត្តិការទទួលប្រាក់បញ្ញើពីអតិថិជន។

ក្រុមហ៊ុនត្រូវបានកាន់កាប់ដោយ LOLC Asia Private Limited (មានទីតាំងស្ថិតនៅប្រទេសសិង្ហបុរី) និង TPC-ESOP Co., Ltd ភាគហ៊ុនក្នុងចំនួន ៩៦,៩៧% និង ៣,០៣%រៀងៗគ្នា។

សកម្មភាពចម្បងរបស់ក្រុមហ៊ុនគឺការផ្តល់សេវាមីក្រូហិរញ្ញវត្ថុ (ទទួលប្រាក់បញ្ញើ និងផ្តល់ប្រាក់កម្ចី) ជូនប្រជាពលរដ្ឋនៅតាមតំបន់ជនបទ មីក្រូសហគ្រាស ក៏ដូចជា សហគ្រាសធុនតូច និងមធ្យម តាមរយៈការិយាល័យកណ្តាលរបស់ខ្លួននៅរាជធានីភ្នំពេញ និងតាមបណ្តាសាខាផ្សេងៗទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គោលបំណងនៃអាជីវកម្មរបស់ក្រុមហ៊ុនគឺផ្តល់នូវសេវាផ្នែកហិរញ្ញវត្ថុដែលមានទំនុកចិត្ត និងអាចទទួលយកបាន ជូនដល់សហគ្រិននៃសហគ្រាសធុនតូច ក៏ដូចជាសហគ្រាសធុនតូច និងមធ្យម។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ក្រុមហ៊ុនមានការិយាល័យចំនួន ៨៣ ទីតាំង (៨២ សាខា និងការិយាល័យកណ្តាលមួយនៅរាជធានីភ្នំពេញ)។ ការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុន មានទីតាំងស្ថិតនៅអគារលេខ ៦៦៦B ផ្លូវលេខ ២៧១ សង្កាត់បឹងទំពុន ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រុមប្រឹក្សាភិបាលបានអនុម័តឲ្យចេញផ្សាយ របាយការណ៍ហិរញ្ញវត្ថុនេះ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤។

### ២. គោលនយោបាយគណនេយ្យសារវន្ត

គោលការណ៍គណនេយ្យសារវន្តដែលបានប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញខាងក្រោម។ គោលនយោបាយទាំងនេះ ត្រូវបានអនុវត្តដោយសង្គតិភាពនៅគ្រប់កាលបរិច្ឆេទដែលបានដាក់បង្ហាញទាំងអស់ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

## ២. គោលនយោបាយគណនេយ្យសារវន្ត (ត)

### ២.១ ការផ្លាស់ប្តូរគោលនយោបាយគណនេយ្យសារវន្ត

**(i) ពន្ធពន្យារពាក់ព័ន្ធនឹងទ្រព្យសកម្ម និងបំណុលដែលកើតចេញពីប្រតិបត្តិការតែមួយ**

ក្រុមហ៊ុនបានអនុវត្ត ***ពន្ធពន្យារទាក់ទងនឹងទ្រព្យសកម្ម និងបំណុលដែលកើតចេញពីប្រតិបត្តិការតែមួយ (វិសោធនកម្មលើ ស.គ.អ.ក ១២)*** ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣។ វិសោធនកម្មនេះ បង្រួមវិសាលភាពលើការលើកលែងការទទួលស្គាល់ជាលើកដំបូង ដោយមិនរាប់បញ្ចូលនូវប្រតិបត្តិការដែលបង្កើតឲ្យមានភាពខុសគ្នាបណ្ដោះអាសន្ន ដែលមានតម្លៃស្មើគ្នា និងកាត់កងគ្នាបាន ឧទាហរណ៍ដូចជាភតិសន្យា។ ចំពោះប្រតិបត្តិការភតិសន្យា ពន្ធពន្យារជាទ្រព្យសកម្ម និងបំណុលដែលពាក់ព័ន្ធ នឹងត្រូវទទួលស្គាល់នៅដើមការិយបរិច្ឆេទមុនបង្អស់សម្រាប់ជាតួលេខប្រៀបធៀប ដែលផលប៉ះពាល់បង្គរនឹងត្រូវបានធ្វើនិយ័តកម្មទៅក្នុងគណនីប្រាក់ចំណេញរក្សាទុក ឬធាតុផ្សេងទៀតនៃគណនីមូលធន នាកាលបរិច្ឆេទនោះ។ សម្រាប់ប្រតិបត្តិការផ្សេងៗទៀត វិសោធនកម្មនេះ នឹងអនុវត្តចំពោះប្រតិបត្តិការដែលកើតឡើងបន្ទាប់ពីដើមការិយបរិច្ឆេទមុនបង្អស់ដែលបានបង្ហាញ។

ក្រុមហ៊ុន ពីមុនទទួលស្គាល់ពន្ធពន្យារដែលកើតចេញពីភតិសន្យាដោយប្រើប្រាស់វិធី "តភ្ជាប់គ្នា" ដែលមានលទ្ធផលស្រដៀងគ្នានឹងវិសោធនកម្មនេះ លើកលែងតែផលប៉ះពាល់លើតួលេខពន្ធពន្យារជាទ្រព្យសកម្ម ឬបំណុលជាពន្ធពន្យារត្រូវបានទទួលស្គាល់លើមូលដ្ឋានសុទ្ធ។ យោងលើវិសោធនកម្មនេះ ក្រុមហ៊ុនទទួលស្គាល់ពន្ធពន្យារជាទ្រព្យសកម្ម ដែលពាក់ព័ន្ធនឹងបំណុលភតិសន្យា ដាច់ដោយឡែកពី ពន្ធពន្យារជាបំណុលដែលពាក់ព័ន្ធនឹងសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម។ នៅក្រោមវិសោធនកម្ម ពុំមានផលប៉ះពាល់លើគណនីប្រាក់ចំណេញរក្សាទុក នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២ បន្ទាប់ពីការអនុវត្តវិសោធនកម្មនេះទេ។

**(ii) ព័ត៌មានគោលនយោបាយគណនេយ្យសារវន្ត**

ក្រុមហ៊ុន ក៏អនុវត្តការបង្ហាញនៃគោលនយោបាយគណនេយ្យ (វិសោធនកម្មលើ ស.គ.អ.ក ១ និងសេចក្តីថ្លែងការណ៍ ស.រ.ទ.ហ.អ.ក លេខ ២) ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣។ ទោះបីជាវិសោធនកម្មនេះមិនមានការផ្លាស់ប្តូរគោលនយោបាយក៏ដោយ ក៏ប៉ុន្តែវាប៉ះពាល់ដល់ព័ត៌មានគោលនយោបាយគណនេយ្យដែលត្រូវបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

វិសោធនកម្មនេះ តម្រូវឲ្យបង្ហាញគោលនយោបាយគណនេយ្យដែលមានភាពជា "សារវន្ត" ជាជាង "ភាពសំខាន់"។ វិសោធនកម្មនេះ ក៏ណែនាំការប្រើប្រាស់ភាពជាសារវន្ត ក្នុងការបង្ហាញគោលនយោបាយគណនេយ្យដែលជួយដល់អង្គភាពឲ្យបង្ហាញនូវព័ត៌មានគោលនយោបាយគណនេយ្យដែលមានប្រយោជន៍ និងជាក់លាក់របស់ខ្លួនទៅកាន់អ្នកប្រើប្រាស់ដែលត្រូវយល់ពីព័ត៌មានផ្សេងៗនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។




# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

## ២. គោលនយោបាយគណនេយ្យសារវន្ត (ត)


### ២.១ ការផ្លាស់ប្តូរគោលនយោបាយគណនេយ្យសារវន្ត (ត)

**(ii) ព័ត៌មានគោលនយោបាយគណនេយ្យសារវន្ត (ត)**

អ្នកគ្រប់គ្រង បានត្រួតពិនិត្យគោលនយោបាយគណនេយ្យ និងធ្វើបច្ចុប្បន្នភាពព័ត៌មានដែលបានបង្ហាញក្នុងកំណត់សម្គាល់ ២ គោលនយោបាយគណនេយ្យសារវន្ត (ឆ្នាំ២០២២៖ សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ) នៅក្នុងករណីមួយចំនួនស្របតាមវិសោធនកម្ម។

### ២.២ មូលដ្ឋាននៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក") ដែលផ្អែកទាំងស្រុងទៅតាមស្តង់ដាទាំងអស់ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ រួមទាំងបំណកស្រាយ និងវិសោធនកម្មផ្សេងៗ ដែលអាចកើតមានក្នុងកាលៈទេសៈណាមួយចំពោះស្តង់ដានីមួយៗ។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំតាមវិធីសាស្ត្រថ្លៃដើម លើកលែងតែទ្រព្យសកម្មហិរញ្ញវត្ថុ ជាឧបករណ៍មូលធន ដែលត្រូវបានវាស់វែងតាមតម្លៃសមស្រប។

ក្រុមហ៊ុនលាតត្រដាងចំនួនទឹកប្រាក់នៃទ្រព្យសកម្ម និងបំណុលនីមួយៗ ដែលរំពឹងថាត្រូវប្រមូលមកវិញ ឬត្រូវទូទាត់ក្នុង រយៈពេលមិនលើស ១២ខែ បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ជារយៈពេលខ្លី ហើយចំនួនដែលលើសពី ១២ខែ បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍ជារយៈពេលវែង។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលស្របទៅតាម ស.រ.ទ.ហ.អ.ក តម្រូវឲ្យប្រើប្រាស់ការប៉ាន់ស្មានគណនេយ្យជាក់លាក់សំខាន់ៗ។ ហើយវាក៏តម្រូវឲ្យអ្នកគ្រប់គ្រងធ្វើការវិនិច្ឆ័យរបស់ខ្លួន នៅក្នុងដំណើរការនៃការអនុវត្តគោលការណ៍គណនេយ្យនេះផងដែរ។ ផ្នែកដែលទាក់ទងនឹងការវិនិច្ឆ័យ ឬភាពស្មុគស្មាញក្នុងកម្រិតខ្ពស់ ឬផ្នែកដែលការសន្មត និងការប៉ាន់ស្មានមានលក្ខណៈជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ៣។

### ២.៣ ស្តង់ដាថ្មី និងបំណកស្រាយ

**ស្តង់ដាគណនេយ្យដែលបានចេញផ្សាយ ប៉ុន្តែមិនទាន់ចូលជាធរមាន**

ស្តង់ដាគណនេយ្យថ្មី និងវិសោធនកម្មមួយចំនួន ដែលនឹងត្រូវចូលជាធរមាន សម្រាប់របាយការណ៍ប្រចាំឆ្នាំ ឬនៅបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ ដែលអាចអនុញ្ញាតឲ្យអនុវត្តមុនថ្ងៃចូលជាធរមាននេះ ទោះជាយ៉ាងណាក៏ដោយ ក្រុមហ៊ុនមិនទាន់អនុវត្តស្តង់ដាគណនេយ្យថ្មី ឬវិសោធនកម្មទាំងនេះក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនៅឡើយទេ។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

## ២. គោលនយោបាយគណនេយ្យសារវន្ត (ត)

### ២.៣ ស្តង់ដាថ្មី និងបំណកស្រាយ (ត)

| កាលបរិច្ឆេទចូលជាធរមាន | ស្តង់ដាគណនេយ្យថ្មី ឬវិសោធនកម្ម |
|---|---|
| ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ | ការចាត់ថ្នាក់បំណុលរយៈពេលខ្លី ឬរយៈពេលវែង (វិសោធនកម្មលើ ស.គ.អ.ក ១) |
| | បំណុលរយៈពេលវែងដែលមានលក្ខខណ្ឌកំហិត (វិសោធនកម្មលើ ស.គ.អ.ក ១) |
| | ការរៀបចំហិរញ្ញប្បទានរបស់អ្នកផ្គត់ផ្គង់ (វិសោធនកម្មលើ ស.គ.អ.ក ៧ និង ស.រ.ហ.អ.ក ៧) |
| | បំណុលភតិសន្យាក្នុងប្រតិបត្តិការលក់ និងជួលត្រឡប់វិញ (វិសោធនកម្មលើ ស.រ.ហ.អ.ក ១៦) |
| ថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ | កង្វះខាតនៃការដោះដូរ (វិសោធនកម្មទៅ ស.គ.អ.ក ២១) |

### ២.៤ ការប្តូររូបិយប័ណ្ណបរទេស

#### (i) រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់បង្ហាញ

គណនីទាំងអស់ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានវាស់តម្លៃដោយប្រើប្រាស់រូបិយប័ណ្ណក្នុងបរិយាកាសសេដ្ឋកិច្ចចម្បងដែលក្រុមហ៊ុនធ្វើប្រតិបត្តិការ (ហៅកាត់ថា រូបិយប័ណ្ណមុខងារ)។ ក្រុមហ៊ុនកំណត់យកប្រាក់រៀល "រៀល" ជារូបិយប័ណ្ណមុខងារ ដោយសារប្រាក់រៀលមានឥទ្ធិពលជាសារវន្តចំពោះប្រតិបត្តិការរបស់ក្រុមហ៊ុន។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជាប្រាក់រៀល ដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន។ ចំនួនទឹកប្រាក់ទាំងអស់ត្រូវបានបង្គត់ទៅជិតមួយពាន់រៀល លើកលែងតែមានការបង្ហាញផ្សេងទៀត។

#### (ii) ប្រតិបត្តិការ និងសមតុល្យ

ប្រតិបត្តិការជារូបិយប័ណ្ណបរទេសផ្សេងៗ ត្រូវបានកត់ត្រាទៅជារូបិយប័ណ្ណមុខងារ តាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណបរទេស ដែលបណ្តាលមកពីការទូទាត់តាមប្រតិបត្តិការបែបនេះ និងពីការប្តូរទ្រព្យសកម្ម និងបំណុលរូបិយវត្ថុនានាដែលកំណត់ជារូបិយប័ណ្ណផ្សេងៗ តាមអត្រាប្តូរប្រាក់នាចុងការិយបរិច្ឆេទ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។

ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណបរទេស ដែលពាក់ព័ន្ធនឹងប្រាក់កម្ចី ត្រូវបានបង្ហាញនៅក្នុងចំណេញ ឬខាត ក្នុងចំណាយការប្រាក់។ ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណបរទេសផ្សេងៗទៀតទាំងអស់ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត តាមមូលដ្ឋានចំនួនសុទ្ធក្នុងខ្ទង់ "ចំណេញ/(ខាត) ផ្សេងៗ - សុទ្ធ"។






អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

២. គោលនយោបាយគណនេយ្យសារវន្ត (ត)


### ២.៤ ការប្តូររូបិយប័ណ្ណបរទេស (ត)

#### (iii) ការបង្ហាញជាប្រាក់ដុល្លារអាមេរិក

ការប្តូរពីប្រាក់រៀលទៅជាប្រាក់ដុល្លារអាមេរិក គឺសម្រាប់តែការប្រើប្រាស់របស់អ្នកគ្រប់គ្រងតែប៉ុណ្ណោះ ហើយការប្តូរប្រាក់នេះ គឺផ្អែកលើអត្រាប្តូរប្រាក់ផ្លូវការដែលផ្សព្វផ្សាយដោយធនាគារជាតិនៃកម្ពុជា គិតត្រឹមកាលបរិច្ឆេទរាយការណ៍ និងអត្រាមធ្យមសម្រាប់ក្នុងការិយបរិច្ឆេទ។ ការប្តូររូបិយប័ណ្ណពីប្រាក់រៀលទៅជាប្រាក់ដុល្លារអាមេរិក បំពេញតាមតម្រូវការបង្ហាញព័ត៌មាន ដោយអនុលោមតាមច្បាប់ ស្តីពីគណនេយ្យ និងសវនកម្ម ហើយការប្តូររូបិយប័ណ្ណនេះធ្វើឡើងដោយអនុលោមទៅតាមវិធីសាស្ត្រ ប្តូររូបិយបណ្ណ័នៃ ស.គ.អ.ក ២១ – *ឥទ្ធិពលនៃការប្រែប្រួលអត្រាប្តូររូបិយប័ណ្ណបរទេស*។

ទ្រព្យសកម្ម និងបំណុល ត្រូវបានប្តូរជាប្រាក់ដុល្លារអាមេរិកតាមអត្រានាកាលបរិច្ឆេទរាយការណ៍ ហើយគណនីដើមទុន ត្រូវបានប្តូរតាមអត្រាប្រវត្តិសាស្ត្រ។ របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ និងរបាយការណ៍លំហូរទឹកប្រាក់ ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិកដោយប្រើប្រាស់អត្រាមធ្យមនៅក្នុងការិយបរិច្ឆេទ ដែលអត្រានោះត្រូវបានចាត់ទុកថា មានកម្រិតប្រហាក់ប្រហែលទៅនឹងអត្រាប្តូររូបិយប័ណ្ណនាថ្ងៃប្រតិបត្តិការ ពីព្រោះអត្រានេះ មិនមានការកែប្រែជាសារវន្តក្នុងអំឡុងការិយបរិច្ឆេទ។ ភាពលម្អៀងដែលកើតឡើងពីការប្តូររូបិយប័ណ្ណ ត្រូវបានទទួលស្គាល់ជា "ទុនបម្រុងពីការប្តូររូបិយប័ណ្ណ" នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ។

ក្រុមហ៊ុនបានប្រើអត្រាប្តូរប្រាក់ផ្លូវការដែលផ្សព្វផ្សាយដោយធនាគារជាតិនៃកម្ពុជា។ គិតត្រឹមកាលបរិច្ឆេទរាយការណ៍អត្រាមធ្យម និងអត្រានាកាលបរិច្ឆេទរាយការណ៍ទៅតាមអត្រាប្តូរប្រាក់ដូចខាងក្រោម៖

| | | អត្រានាកាលបរិច្ឆេទរាយការណ៍ | អត្រាមធ្យម |
|---|---|---|---|
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | ១ ដុល្លារអាមេរិក = | ៤.០៨៥ រៀល | ៤.១១០ រៀល |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | ១ ដុល្លារអាមេរិក = | ៤.១១៧ រៀល | ៤.០៨៧ រៀល |

ការកែសម្រួលនេះ មិនគួរត្រូវបានយកមកបកស្រាយថា តួលេខប្រាក់រៀលនេះ ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ឬគួរត្រូវបានប្តូរជាប្រាក់ដុល្លារអាមេរិក ឬនឹងត្រូវបានប្តូរជាប្រាក់ដុល្លារអាមេរិក នាពេលអនាគតតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

## ២. គោលនយោបាយគណនេយ្យសារវន្ត (ត)

### ២.៥ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

ក្នុងការបង្ហាញរបាយការណ៍លំហូរទឹកប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមាន សាច់ប្រាក់ក្នុងដៃ ប្រាក់បញ្ញើ និងប្រាក់បញ្ញើមិនជាប់កំហិត និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា និងធនាគារនានា និងការវិនិយោគសាច់ប្រាក់ងាយស្រួលរយៈពេលខ្លីផ្សេងៗ ដែលមានកាលកំណត់ដំបូងបីខែ ឬតិចជាង ដែលក្រុមហ៊ុនមាន លទ្ធភាពពេញលេញក្នុងការដកប្រាក់មកប្រើក្នុងគោលបំណងទូទៅ ទៅតាមការចាំបាច់ និងមានហានិភ័យនៃការប្រែប្រួលតម្លៃតិចតួច និងឥណទានវិបារូបន៍។ ឥណទានវិបារូបន៍ ត្រូវបានបង្ហាញក្រោមខ្ចង់ប្រាក់កម្ចី ក្នុងបំណុលរយៈពេលខ្លី នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា និងធនាគារនានា ត្រូវបានកត់ត្រាតាមរំលស់ថ្លៃដើម នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

### ២.៦ ឧបករណ៍ហិរញ្ញវត្ថុ

#### (ក) ការទទួលស្គាល់

ក្រុមហ៊ុនទទួលស្គាល់ជាលើកដំបូងនូវឥណទាន និងបុរេប្រទាន ប្រាក់បញ្ញើប្រាក់កម្ចី និងអនុបំណុល នៅកាលបរិច្ឆេទដែលកើតមានប្រតិបត្តិការ។ រាល់ឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទាំងអស់ ត្រូវបានទទួលស្គាល់នៅកាលបរិច្ឆេទជួញដូរដែលជាកាលបរិច្ឆេទដែលក្រុមហ៊ុនក្លាយជាភាគីនៃបទប្បញ្ញត្តិកិច្ចសន្យានៃឧបករណ៍។

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងលើកដំបូងតាមតម្លៃសមស្រប បូកនឹងចំណាយប្រតិបត្តិការ ដែលកើតពីការទិញ ឬបោះផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ សម្រាប់ធាតុមិនវាស់វែងតាម FVTPL។

#### (ខ) ការចាត់ចំណាត់ថ្នាក់

**ទ្រព្យសកម្មហិរញ្ញវត្ថុ**

នៅក្នុងការទទួលស្គាល់ដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់តាមការវាស់វែងតាម រំលស់ថ្លៃដើម តម្លៃសមស្របតាមលទ្ធផលលម្អិតផ្សេងៗ FVOCI ឬតម្លៃសមស្របតាមចំណេញ ឬខាត FVTPL។

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ប្រសិនបើវាបំពេញទៅនឹងលក្ខខណ្ឌដូចខាងក្រោម ហើយមិនត្រូវបានកំណត់ជា FVTPL នោះទេ៖

- ទ្រព្យសកម្មដែលមាននៅក្នុងគំរូអាជីវកម្ម ក្នុងគោលបំណងរក្សាទុកដើម្បីការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និង
- លក្ខខណ្ឌកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់នូវកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរទឹកប្រាក់ គឺជាការទូទាត់តែប្រាក់ដើម និងការប្រាក់ ("SPPI")។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

## ២. គោលនយោបាយគណនេយ្យសារវន្ត (ត)

### ២.៦ ឧបករណ៍ហិរញ្ញវត្ថុ (ត)

#### (ខ) ការចាត់ចំណាត់ថ្នាក់ (ត)

**ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)**

ឧបករណ៍បំណុល ត្រូវបានវាស់វែងតាម FVOCI លុះត្រាតែវាបានបំពេញនឹងលក្ខខណ្ឌទាំងពីរដូចខាងក្រោម ហើយមិនត្រូវបានកំណត់ជា FVTPL នោះទេ៖

- ទ្រព្យសកម្មដែលមាននៅក្នុងគំរូអាជីវកម្ម ក្នុងគោលបំណងរក្សាទុកដើម្បីការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និងលក់ទ្រព្យសកម្មហិរញ្ញវត្ថុ និង
- លក្ខខណ្ឌកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់នូវកាលបរិច្ឆេទជាក់លាក់ ចំពោះលំហូរទឹកប្រាក់ដែលជា SPPI។

សម្រាប់ការទទួលស្គាល់លើការវិនិយោគលើមូលធនជាលើកដំបូង ដែលមិនត្រូវបានរក្សាទុកសម្រាប់ការជួញដូរ ត្រូវតែជ្រើសរើសការបង្ហាញពីការប្រែប្រួលនាពេលបន្ទាប់តាមរយៈលទ្ធផលលម្អិតផ្សេងៗ។ ការជ្រើសរើសនេះ ធ្វើឡើងដោយផ្អែកតាមការវិនិយោគនីមួយៗ។

ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ផ្សេងទៀតត្រូវបានចាត់ថ្នាក់តាមការវាស់វែងតាម FVTPL។

លើសពីនេះ សម្រាប់ការទទួលស្គាល់ជាលើកដំបូង ក្រុមហ៊ុនអាចនឹងកំណត់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបំពេញតាមលក្ខខណ្ឌក្នុងការវាស់វែងតាមរំលស់ថ្លៃដើម ឬតាម FVOCI ប្រសិនបើវាស់វែងតាម FVTPL នឹងលុបបំបាត់ ឬកាត់បន្ថយ ជាសារវន្តនូវភាពមិនស្របគ្នានៃគណនេយ្យដែលនឹងកើតឡើង។

**ការវាយតម្លៃគំរូអាជីវកម្ម**

ក្រុមហ៊ុន ធ្វើការវាយតម្លៃអំពីគោលបំណងនៃគំរូអាជីវកម្ម លើទ្រព្យសកម្មក្នុងកម្រិតសំណុំឥណទាននីមួយៗ ដោយសារតែវាឆ្លុះបញ្ចាំងយ៉ាងល្អបំផុតពីវិធីដែលក្រុមហ៊ុន គ្រប់គ្រងអាជីវកម្ម និងវិធីដែលព័ត៌មានត្រូវបានផ្តល់ដល់គណៈគ្រប់គ្រង។ ព័ត៌មានដែលត្រូវបានពិចារណា រួមមាន៖

- គោលនយោបាយ និងគោលបំណងដែលបានបញ្ជាក់សម្រាប់សំណុំឥណទាន និងអនុវត្តនូវគោលនយោបាយទាំងនោះ។ ជាពិសេសថាតើយុទ្ធសាស្ត្ររបស់អ្នកគ្រប់គ្រង ផ្តោតលើការស្វែងរកចំណូលការប្រាក់តាមកិច្ចសន្យារក្សានូវទម្រង់អត្រាការប្រាក់ជាក់លាក់មួយ ផ្គូរផ្គងរយៈពេល នៃទ្រព្យសកម្មហិរញ្ញវត្ថុទៅនឹងរយៈពេលនៃបំណុលដែលផ្តល់មូលនិធិដល់ទ្រព្យសកម្មទាំងនោះ ឬទទួលបានលំហូរទឹកប្រាក់តាមរយៈការលក់ទ្រព្យសកម្ម

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

## ២. គោលនយោបាយគណនេយ្យសារវន្ត (ត)

### ២.៦ ឧបករណ៍ហិរញ្ញវត្ថុ (ត)

**(ខ) ការចាត់ចំណាត់ថ្នាក់ (ត)**

**ការវាយតម្លៃគំរូអាជីវកម្ម (ត)**

- របៀបក្នុងការវាយតម្លៃលទ្ធផលនៃសំណុំឥណទាន និងរាយការណ៍ទៅអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុន
- ហានិភ័យដែលជះឥទ្ធិពលដល់ការអនុវត្តគំរូអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុដែលមាននៅក្នុងគំរូអាជីវកម្មនោះ) និងយុទ្ធសាស្ត្ររបស់វាស្តីពីរបៀបដែលហានិភ័យទាំងនោះត្រូវបានគ្រប់គ្រង
- របៀបដែលអ្នកគ្រប់គ្រងអាជីវកម្មទទួលបានការទូទាត់ (ឧទាហរណ៍៖ តើការទូទាត់សំណងផ្អែកលើតម្លៃសមស្របនៃទ្រព្យសកម្មដែលបានគ្រប់គ្រង ឬសាច់ប្រាក់តាមកិច្ចសន្យាដែលបានប្រមូល) និង
- ភាពញឹកញាប់ បរិមាណ និងពេលវេលានៃការលក់ក្នុងការិយបរិច្ឆេទមុន ហេតុផលសម្រាប់ការលក់ និងការរំពឹងទុករបស់វាអំពីសកម្មភាពលក់នាពេលអនាគត។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានអំពីសកម្មភាពលក់មិនត្រូវបានគេពិចារណាដាច់ដោយឡែកនោះទេ ប៉ុន្តែជាផ្នែកមួយនៃការវាយតម្លៃជារួមអំពីរបៀបដែលគោលបំណងរបស់ធនាគារ សម្រាប់ការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានសម្រេច និងរបៀបដែលលំហូរទឹកប្រាក់បានកើតឡើង។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលរក្សាទុកសម្រាប់ការជួញដូរ ឬគ្រប់គ្រង ហើយប្រតិបត្តិការរបស់ពួកគេត្រូវបានវាយតម្លៃ ដោយផ្អែកលើមូលដ្ឋានតម្លៃសមស្របត្រូវបានវាស់វែងតាម FVTPL ដោយសារតែវាមិនត្រូវបានធ្វើឡើងដើម្បីប្រមូល លំហូរទឹកប្រាក់តាមកិច្ចសន្យា ឬរក្សាទុកទាំងពីរដើម្បីប្រមូលលំហូរទឹកប្រាក់តាមកិច្ចសន្យា និងលក់ទ្រព្យសកម្មហិរញ្ញវត្ថុទេ។

**ការវាយតម្លៃថាតើលំហូរទឹកប្រាក់តាមកិច្ចសន្យា គឺសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់**

សម្រាប់គោលបំណងនៃការវាយតម្លៃនេះ "ប្រាក់ដើម" ត្រូវបានកំណត់ថាជាតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុ លើការទទួលស្គាល់ជាលើកដំបូង។ "ការប្រាក់" ត្រូវបានកំណត់ថាជាតម្លៃតបស្នងសម្រាប់ពេលវេលានៃតម្លៃទឹកប្រាក់ និងសម្រាប់ហានិភ័យឥណទានដែលទាក់ទងនឹងចំនួនទឹកប្រាក់ដើមដែលមិនទាន់សង ក្នុងអំឡុងពេលជាក់លាក់ណាមួយ និងសម្រាប់ហានិភ័យ និងចំណាយលើប្រាក់កម្ចីជាមូលដ្ឋានផ្សេងទៀត (ឧទាហរណ៍ ហានិភ័យសាច់ប្រាក់ងាយស្រួល និងចំណាយរដ្ឋបាល) ក៏ដូចជា កម្រិតប្រាក់ចំណេញ។





# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

## ២. គោលនយោបាយគណនេយ្យសារវន្ត (ត)

### ២.៦ ឧបករណ៍ហិរញ្ញវត្ថុ (ត)

**(ខ) ការចាត់ចំណាត់ថ្នាក់ (ត)**

**ការវាយតម្លៃថាតើលំហូរទឹកប្រាក់តាមកិច្ចសន្យា គឺសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ (ត)**

ក្រុមហ៊ុនធ្វើការពិចារណាលក្ខខណ្ឌនៃកិច្ចសន្យានៃឧបករណ៍ ក្នុងការវាយតម្លៃថាតើលំហូរទឹកប្រាក់តាមកិច្ចសន្យាគឺ សម្រាប់តែទូទាត់ប្រាក់ដើម និងការប្រាក់ដែរ ឬទេ ។ ទាំងនេះរួមបញ្ចូលទាំងការវាយតម្លៃ ថាតើទ្រព្យសកម្មហិរញ្ញវត្ថុមានលក្ខខណ្ឌកិច្ចសន្យាដែលអាចផ្លាស់ប្តូរពេលវេលា ឬបរិមាណនៃលំហូរទឹកប្រាក់តាមកិច្ចសន្យា ដែលវានឹងមិនបំពេញតាមលក្ខខណ្ឌនេះ។ ក្នុងការវាយតម្លៃ ក្រុមហ៊ុនពិចារណាលើ៖

- ព្រឹត្តិការណ៍ជាយថាភាពដែលអាចផ្លាស់ប្តូរចំនួន និងរយៈពេលនៃលំហូរទឹកប្រាក់
- លក្ខខណ្ឌពិសេស
- លក្ខខណ្ឌបង់ប្រាក់ជាមុន និងពន្យារពេល
- លក្ខខណ្ឌដាក់កម្រិតក្រុមហ៊ុន ដើម្បីទាមទារលំហូរទឹកប្រាក់ពីទ្រព្យសកម្មជាក់លាក់មួយ (ឧទាហរណ៍ ឥណទានមិនមានជម្រើស) និង
- លក្ខណៈពិសេសដែលកែប្រែតម្លៃតបស្នងអំពីពេលវេលានៃតម្លៃទឹកប្រាក់ (ឧទាហរណ៍ ការកំណត់អត្រាការប្រាក់ឡើងវិញតាមកាលកំណត់)។

**ការចាត់ចំណាត់ថ្នាក់ឡើងវិញ**

ទ្រព្យសកម្មហិរញ្ញវត្ថុ មិនត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញ បន្ទាប់ពីការទទួលស្គាល់តម្លៃដំបូងឡើយ លើកលែងតែ ក្នុងអំឡុងពេលដែលក្រុមហ៊ុនផ្លាស់ប្តូរគំរូអាជីវកម្មរបស់ខ្លួន ក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

**(គ) ការឈប់ទទួលស្គាល់**

**ទ្រព្យសកម្មហិរញ្ញវត្ថុ**

ក្រុមហ៊ុនបានឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិក្នុងកិច្ចសន្យាក្នុងការទទួលបាននូវលំហូរទឹកប្រាក់ ពីទ្រព្យសកម្មហិរញ្ញវត្ថុផុតកំណត់ ឬត្រូវបានផ្ទេរចេញ ហើយក្រុមហ៊ុនបានផ្ទេររាល់ហានិភ័យ និងអត្ថប្រយោជន៍នៃភាពជាម្ចាស់កម្មសិទ្ធិនៃទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់។ ចំណេញ ឬខាតលើការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមតម្លៃរំលស់ ត្រូវបានទទួលស្គាល់ជា ចំណេញ ឬខាត នៅពេលដែលទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានឈប់ទទួលស្គាល់។ រាប់បញ្ចូលទាំងចំនួនទឹកប្រាក់ដែលបានលុបចោល និងបង្វិលត្រឡប់មកវិញនៃសំណងបន្ទាប់ពីការលុបចោល។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

## ២. គោលនយោបាយគណនេយ្យសារវន្ត (ត)

### ២.៦ ឧបករណ៍ហិរញ្ញវត្ថុ (ត)

**(គ) ការឈប់ទទួលស្គាល់ (ត)**

**ទ្រព្យសកម្មហិរញ្ញវត្ថុ**

ចំពោះការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ភាពលម្អៀងរវាងតម្លៃយោងរបស់ទ្រព្យសកម្ម (ឬតម្លៃយោងដែលជាចំណែកនៃទ្រព្យសកម្មដែលឈប់ទទួលស្គាល់) និងផលបូកនៃ (i) តម្លៃតបស្នងដែលទទួលបាន (រាប់បញ្ចូលទាំងទ្រព្យសកម្មថ្មីដែលទទួលបាន ដកបំណុលថ្មីដែលទទួលយក) និង (ii) ចំណេញ ឬខាតដែលបានទទួលស្គាល់ក្នុង OCI ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។

**បំណុលហិរញ្ញវត្ថុ**

ក្រុមហ៊ុនឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលកាតព្វកិច្ចតាមកិច្ចសន្យាត្រូវបានរំសាយ ឬលុបចោល ឬផុតកំណត់។

**(ឃ) ការវាស់វែង**

នាពេលទទួលស្គាល់លើកដំបូង ក្រុមហ៊ុនវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុតាមតម្លៃសមស្រប បូកបន្ថែមជាមួយនឹងចំណាយប្រតិបត្តិការផ្សេងៗ ដែលបានចំណាយផ្ទាល់ក្នុងការទិញទ្រព្យសកម្មហិរញ្ញវត្ថុ ក្នុងករណីដែលទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានវាស់វែងតាមតម្លៃសមស្របក្នុងចំណេញ ឬខាត (FVPL)។ ចំណាយប្រតិបត្តិការ នៃទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានកត់ត្រាតាម FVPL ត្រូវបានកត់ត្រាជាចំណាយក្នុងចំណេញ ឬខាត។ បន្ទាប់ពីការទទួលស្គាល់លើកដំបូងភ្លាម សំវិធានធនសម្រាប់ការខាតបង់ឥណទានដែលបានរំពឹងទុក (ECL) ត្រូវបានទទួលស្គាល់សម្រាប់ទ្រព្យសកម្មវាស់វែងតាមរំលស់ថ្លៃដើម ដែលធ្វើឲ្យមានការខាតតាមគណនេយ្យមួយត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាត នៅពេលទ្រព្យសកម្មមួយត្រូវបានបង្កើតឡើងថ្មី។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានដេរីវេ ត្រូវបានគេគិតទៅលើចំនួនរបស់វាទាំងស្រុង នៅពេលធ្វើការកំណត់លំហូរទឹកប្រាក់របស់វាសម្រាប់តែទូទាត់ប្រាក់ដើម និងការប្រាក់។

*ឧបករណ៍បំណុល*

ការវាស់វែងបន្តបន្ទាប់នៃឧបករណ៍បំណុលគឺអាស្រ័យទៅលើគំរូអាជីវកម្មរបស់ក្រុមហ៊ុន ក្នុងការគ្រប់គ្រងទ្រព្យសកម្ម និងលក្ខណៈនៃលំហូរទឹកប្រាក់របស់ទ្រព្យសកម្មនោះ។ ក្រុមហ៊ុនធ្វើចំណាត់ថ្នាក់ឧបករណ៍បំណុលរបស់ខ្លួន ជាទ្រព្យសកម្មហិរញ្ញវត្ថុដែលបានវាស់វែងតាមរំលស់ថ្លៃដើម។





អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

២. គោលនយោបាយគណនេយ្យសារវន្ត (ត)

២.៦ ឧបករណ៍ហិរញ្ញវត្ថុ (ត)

**(ឃ) ការវាស់វែង (ត)**

*ឧបករណ៍បំណុល (ត)*

រំលស់ថ្លៃដើម៖ ទ្រព្យសកម្មដែលត្រូវបានកាន់កាប់សម្រាប់ការប្រមូលលំហូរទឹកប្រាក់ក្នុងកិច្ចសន្យា ដែលលំហូរទឹកប្រាក់នោះ គឺសម្រាប់តែទូទាត់ប្រាក់ដើម និងការប្រាក់ (SPPI) ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម។ តម្លៃយោងនៃទ្រព្យសកម្មទាំងនេះ ត្រូវបានកែតម្រូវទៅតាមសំវិធានធនសម្រាប់ការខាតបង់ឥណទានដែលបានរំពឹងទុក ត្រូវបានទទួលស្គាល់។ ចំណូលការប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុទាំងនេះ ត្រូវបានដាក់បញ្ចូលនៅក្នុងចំណូលការប្រាក់ ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។

*ឧបករណ៍មូលធន*

ក្រុមហ៊ុន ធ្វើការវាស់វែងបន្តបន្ទាប់ឧបករណ៍មូលធនទាំងអស់ តាមតម្លៃសមស្រប។ ប្រសិនបើអ្នកគ្រប់គ្រងក្រុមហ៊ុនជ្រើសរើសការបង្ហាញចំណេញ ឬខាតនៃតម្លៃសមស្របចំពោះការវិនិយោគមូលធនក្នុង OCI នោះនឹងមិនមានការអនុញ្ញាតឲ្យធ្វើចំណាត់ថ្នាក់ឡើងវិញចំពោះចំណេញ ឬខាតនៃតម្លៃសមស្របទៅក្នុងចំណេញ ឬខាតទេ បន្ទាប់ការឈប់ទទួលស្គាល់ការវិនិយោគនោះ។ ភាគលាភបានពីការវិនិយោគប្រភេទនេះ ត្រូវបានបន្តទទួលស្គាល់ក្នុងចំណេញ ឬខាតជាចំណូលផ្សេងៗ នៅពេលដែលក្រុមហ៊ុនមានសិទ្ធិទទួលការទូទាត់នោះ។ ការខាតដែលបណ្តាលមកពីការខាតបង់ឱនភាពនៃតម្លៃ (និងបង្វិលត្រឡប់មកវិញ ពីការខាតបង់ឱនភាពនៃតម្លៃ) ចំពោះការវិនិយោគមូលធន វាស់វែងតាម FVOCI មិនត្រូវបានរាយការណ៍ដាច់ដោយឡែកពីការប្រែប្រួលតម្លៃសមស្របទេ។

**(ង) ឱនភាពនៃតម្លៃ**

ក្រុមហ៊ុនវាយតម្លៃការខាតបង់ឥណទានដែលបានរំពឹងទុក (ECL) តាមមូលដ្ឋានព្យាករនាពេលអនាគតដែលទាក់ទង ជាមួយនឹងឧបករណ៍បំណុលរបស់ខ្លួនដែលវាស់វែងតាមរំលស់ថ្លៃដើម។ ក្រុមហ៊ុនទទួលស្គាល់សំវិធានធនសម្រាប់ការខាតបង់ចំពោះការខាតប្រភេទនេះ នាកាលបរិច្ឆេទរាយការណ៍។ ការវាស់វែង ECL ឆ្លុះបញ្ចាំងពី៖

- ចំនួនលម្អៀង និងចំនួនដែលបានថ្លឹងប្រូបាប ដែលត្រូវបានកំណត់ដោយធ្វើការវាយតម្លៃលើលទ្ធភាពដែលអាចកើតឡើងមួយចំនួន
- ពេលវេលានៃតម្លៃទឹកប្រាក់ និង
- ព័ត៌មានដែលមានភាពសមហេតុផល និងមានការគាំទ្រ ដែលអាចរកបានដោយពុំចាំបាច់មានការចំណាយ និងការខំប្រឹងប្រែងលើសលប់ នាកាលបរិច្ឆេទរាយការណ៍ អំពីព្រឹត្តិការណ៍នាពេលបច្ចុប្បន្ន និងការព្យាករអំពីលក្ខខណ្ឌនាពេលអនាគត។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

## ២. គោលនយោបាយគណនេយ្យសារវន្ត (ត)

### ២.៦ ឧបករណ៍ហិរញ្ញវត្ថុ (ត)

#### (ង) ឱនភាពនៃតម្លៃ (ត)

ក្រុមហ៊ុនបានអនុវត្តវិធីសាស្ត្របីដំណាក់កាល ចំពោះការវាស់វែងការខាតបង់ឥណទានដែលបានរំពឹងទុក សម្រាប់ឧបករណ៍បំណុលដែលវាស់វែងតាមរំលស់ថ្លៃដើម។

វិធីសាស្ត្របីដំណាក់កាលដែលផ្អែកទៅលើបម្រែបម្រួលហានិភ័យឥណទាន ចាប់តាំងពីការទទួលស្គាល់លើកដំបូង មានដូចខាងក្រោម៖

(ក) ដំណាក់កាលទី១៖ ECL ១២ខែ

ដំណាក់កាលទី១ រួមបញ្ចូលនូវទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមិនមានកំណើនហានិភ័យឥណទានគួរឲ្យកត់សម្គាល់ ចាប់តាំងពីការទទួលស្គាល់លើកដំបូង ឬមានហានិភ័យឥណទានកម្រិតទាប នាកាលបរិច្ឆេទរាយការណ៍។ ECL ១២ខែ ត្រូវបានទទួលស្គាល់ ហើយចំណូលការប្រាក់ត្រូវបានគណនាតាមចំនួនតម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ។

(ខ) ដំណាក់កាលទី២៖ ECL ពេញមួយអាយុកាល – មិនមានឱនភាពនៃតម្លៃឥណទាន

ដំណាក់កាលទី២ រួមមាន ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានកំណើនហានិភ័យឥណទានជាសារវន្តចាប់តាំងពីការទទួលស្គាល់លើកដំបូង (លើកលែងតែ វាមានហានិភ័យឥណទានទាប នាកាលបរិច្ឆេទរាយការណ៍) ប៉ុន្តែមិនមានភ័ស្តុតាងជាក់ស្តែងបង្ហាញពីការថយចុះតម្លៃ។ ECL ពេញមួយអាយុកាលត្រូវបានទទួលស្គាល់ ហើយចំណូលការប្រាក់ ត្រូវបានគណនាតាមចំនួនតម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ។

(គ) ដំណាក់កាលទី៣៖ ECL ពេញមួយអាយុកាល – មានការថយចុះតម្លៃឥណទាន

ដំណាក់កាលទី៣ រួមមាន ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានភ័ស្តុតាងជាក់ស្តែងបង្ហាញពីឱនភាពនៃតម្លៃនាកាលបរិច្ឆេទរាយការណ៍។ ECL ពេញមួយអាយុកាលត្រូវបានទទួលស្គាល់ ហើយចំណូលការប្រាក់ត្រូវបានគណនាតាមចំនួនតម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ។

#### (ច) បំណុលហិរញ្ញវត្ថុ

បំណុលហិរញ្ញវត្ថុ ត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុនក្លាយជាភាគីមួយ នៅក្នុងកិច្ចសន្យានៃឧបករណ៍ណាមួយ។ បំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួមមាន ប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ ប្រាក់បញ្ញើរបស់អតិថិជន ប្រាក់កម្ចី អនុបំណុល និងបំណុលហិរញ្ញវត្ថុផ្សេងៗ។

បំណុលហិរញ្ញវត្ថុ ត្រូវបានទទួលស្គាល់លើកដំបូងតាមតម្លៃសមស្រប ដកចំណាយប្រតិបត្តិការ ចំពោះបំណុលប្រតិបត្តិការទាំងអស់ដែលមិនវាស់វែងតាមតម្លៃសមស្របក្នុងចំណេញ ឬខាត។





អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

២. គោលនយោបាយគណនេយ្យសារវន្ត (ត)

២.៦ ឧបករណ៍ហិរញ្ញវត្ថុ (ត)

#### (ច) បំណុលហិរញ្ញវត្ថុ (ត)

បំណុលហិរញ្ញវត្ថុ ដែលមិនត្រូវបានចាត់ថ្នាក់តាមតម្លៃសមស្របក្នុងចំណេញ ឬខាត ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម។ បំណុលហិរញ្ញវត្ថុវាស់វែងតាមថ្លៃដើមដករំលស់ មានដូចជា ប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ ប្រាក់បញ្ញើរបស់អតិថិជន ប្រាក់កម្ចី អនុបំណុល និងបំណុលផ្សេងៗ។

បំណុលហិរញ្ញវត្ថុត្រូវឈប់ទទួលស្គាល់ នៅពេលដែលវាត្រូវបានបង្វិលអស់ ឬត្រូវបានព្រមព្រៀងឲ្យបញ្ឈប់ការសងប្រាក់តទៅទៀត។

#### (ឆ) ការកាត់កងឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កង ហើយចំនួនទឹកប្រាក់សុទ្ធបន្ទាប់ពីកាត់កងត្រូវបានរាយការណ៍នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលក្រុមហ៊ុនមានសិទ្ធិតាមផ្លូវច្បាប់ក្នុងការកាត់កងចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ ហើយក្រុមហ៊ុនមានបំណងនឹងទូទាត់តាមមូលដ្ឋានចំនួនទឹកប្រាក់សុទ្ធ ឬមានបំណងទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

### ២.៧ ទ្រព្យ និងបរិក្ខារ

ទ្រព្យ និងបរិក្ខារ ត្រូវបានរាយការណ៍តាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់ឱនភាពនៃតម្លៃ។ ថ្លៃដើមរួមមាន ចំណាយផ្ទាល់ផ្សេងៗ ដែលបានចំណាយក្នុងការទិញទ្រព្យនោះ។

ចំណាយបន្តបន្ទាប់ផ្សេងៗ ត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យនោះ ឬត្រូវបានទទួលស្គាល់ជាទ្រព្យដាច់ដោយឡែកតាមការសមស្រប តែនៅពេលដែលមានភាពប្រាកដថាផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតនៃទ្រព្យនោះនឹងហូរចូលមកក្នុងក្រុមហ៊ុន ហើយថ្លៃដើមនៃទ្រព្យនោះអាចត្រូវបានវាស់វែងគួរឲ្យជឿជាក់បានតែប៉ុណ្ណោះ។ រាល់ចំណាយលើការជួសជុល និងការថែទាំផ្សេងៗទៀតទាំងអស់ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងចំណេញ ឬខាត ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុដែលប្រតិបត្តិការនោះបានកើតឡើង។

ទ្រព្យសកម្មកំពុងដំណើរការមិនត្រូវបានដករំលស់ទេ។ ការដករំលស់លើទ្រព្យ និងបរិក្ខារ ត្រូវបានកត់ត្រាជាបន្ទុកក្នុងចំណេញ ឬខាត តាមមូលដ្ឋានរំលស់ថេរ អាស្រ័យទៅតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មាននៃទ្រព្យនោះតាមអត្រា ដូចខាងក្រោម៖

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

## ២. គោលនយោបាយគណនេយ្យសារវន្ត (ត)

### ២.៧ ទ្រព្យ និងបរិក្ខារ (ត)

| | ឆ្នាំ |
|---|---|
| ការកែលម្អទ្រព្យជួល | រយៈពេលណាមួយដែលខ្លីជាងរវាងថិរវេលាជួលក្នុងកិច្ចសន្យា និងអាយុកាលសេដ្ឋកិច្ចរបស់វា |
| សង្ហារិម និងបរិក្ខារការិយាល័យ | ៣ - ៥ |
| បរិក្ខារកុំព្យូទ័រ | ៣ |
| យានយន្ត | ៣ - ៥ |

ការរំលស់លើទ្រព្យសកម្មកំពុងដំណើរការ ចាប់ផ្តើមឡើងនៅពេលដែលទ្រព្យសកម្មមានភាពរួចរាល់សម្រាប់ការប្រើប្រាស់។ អាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មត្រូវបានត្រួតពិនិត្យ និងកែតម្រូវតាមការសមស្របនាចុងការិយបរិច្ឆេទនៃរយៈពេលរាយការណ៍នីមួយៗ។

ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្មណាមួយ លើសពីតម្លៃដែលអាចស្រង់មកវិញបាន វាត្រូវបានកត់ត្រាបន្ថយភ្លាមឲ្យនៅត្រឹមតម្លៃប៉ាន់ស្មានដែលអាចស្រង់មកវិញបាន។

ចំណេញ និងខាតពីការលក់ទ្រព្យ និងបរិក្ខារ ត្រូវបានកំណត់ដោយធ្វើការប្រៀបធៀបសាច់ប្រាក់បានពីការលក់ និងតម្លៃយោង ហើយត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត។

### ២.៨ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីដែលរួមមានអាជ្ញាប័ណ្ណ និងកម្មវិធីកុំព្យូទ័រដែលបានទិញ និងចំណាយពាក់ព័ន្ធផ្សេងៗ ត្រូវបានរាយការណ៍តាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់ឱនភាពនៃតម្លៃ។ អាជ្ញាប័ណ្ណ និងកម្មវិធីកុំព្យូទ័រដែលបានទិញ ត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើមដែលបានកើតឡើង ក្នុងការទិញកម្មវិធីជាក់លាក់នោះមកប្រើប្រាស់។ ថ្លៃដើមត្រូវបានធ្វើរំលស់តាមវិធីសាស្ត្ររំលស់ថេរ ក្នុងរយៈពេលចាប់ពី ៥ឆ្នាំ ទៅ ២០ឆ្នាំ។

ទ្រព្យសកម្មអរូបីកំពុងដំណើរការមិនត្រូវបានដករំលស់ទេ។ ចំណាយនានាពាក់ព័ន្ធនឹងការថែទាំទ្រព្យសកម្មអរូបី ត្រូវបានទទួលស្គាល់ជាចំណាយ នៅពេលដែលមានប្រតិបត្តិការនោះបានកើតឡើង។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

## ២. គោលនយោបាយគណនេយ្យសារវន្ត (ត)

### ២.៩ ឱនភាពនៃតម្លៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មទាំងឡាយណាដែលមានអាយុកាលប្រើប្រាស់មិនកំណត់ មិនត្រូវបានរំលស់ទេ និងត្រូវបានត្រួតពិនិត្យជារៀងរាល់ឆ្នាំសម្រាប់ឱនភាពនៃតម្លៃរបស់វា នៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈណាមួយ បង្ហាញថាតម្លៃយោងរបស់វានឹងមិនអាចប្រមូលមកវិញបាន។ ការខាតបង់ឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់តាមចំនួនលម្អៀងរវាងតម្លៃយោងនៃទ្រព្យនោះ ធៀបជាមួយតម្លៃដែលអាចប្រមូលមកវិញបាន។ តម្លៃដែលអាចប្រមូលមកវិញបានគឺជាតម្លៃមួយណាដែលខ្ពស់ជាងគេរវាងតម្លៃសមស្របនៃទ្រព្យនោះ ដកចំណាយដើម្បីលក់ចេញ និងតម្លៃនៅប្រើប្រាស់។ សម្រាប់គោលបំណងក្នុងការវាយតម្លៃលើឱនភាពនៃតម្លៃទ្រព្យសកម្ម ត្រូវបានដាក់បញ្ចូលគ្នាជាក្រុមតូចៗ ដែលអាចកំណត់អត្តសញ្ញាណលំហូរទឹកប្រាក់ដាច់ដោយឡែកពីគ្នាបាន ដោយលំហូរទឹកប្រាក់ទាំងនេះមិនពឹងផ្អែកខ្លាំងលើលំហូរទឹកប្រាក់នៃទ្រព្យសកម្មផ្សេងទៀត ឬក្រុមនៃទ្រព្យសកម្ម (ឯកតាបង្កើតសាច់ប្រាក់)។ ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលទទួលរងនូវឱនភាពនៃតម្លៃ ត្រូវបានពិនិត្យសម្រាប់ការត្រលប់មកវិញនៃឱនភាពនៃតម្លៃដែលអាចកើតមាននៅចុងការិយបរិច្ឆេទរាយការណ៍នីមួយៗ។

ការខាតបង់ឱនភាពនៃតម្លៃណាមួយ ត្រូវបានកត់ត្រាជាបន្ទុកក្នុងចំណេញ ឬខាត ក្នុងការិយបរិច្ឆេទដែលប្រតិបត្តិការនោះបានកើតឡើង។ ការកត់ត្រាត្រលប់មកវិញនៃការខាតបង់ឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាត ទៅតាមចំនួនតម្លៃយោងនៃទ្រព្យសកម្មនោះ មិនលើសតម្លៃយោងដែលបានកំណត់កាត់កងជាមួយនឹងរំលស់សុទ្ធ ពុំមានការខាតបង់ឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ឡើយ។

### ២.១០ ភតិសន្យា

*ក្រុមហ៊ុនជាភាគីអ្នកជួល*

នៅពេលចាប់ផ្តើមកិច្ចសន្យា ក្រុមហ៊ុនវាយតម្លៃថាតើកិច្ចសន្យានោះ ឬខ្លឹមសាររបស់វាជាភតិសន្យាដែរ ឬទេ។ កិច្ចសន្យាមួយ ឬខ្លឹមសារនៃកិច្ចសន្យាមួយ ត្រូវបានចាត់ទុកថាជាភតិសន្យា ប្រសិនបើកិច្ចសន្យានោះផ្តល់សិទ្ធិក្នុងការគ្រប់គ្រង ការប្រើប្រាស់ទ្រព្យសកម្មដែលត្រូវបានកំណត់មួយ ក្នុងរយៈពេលណាមួយជាថ្នូរនឹងការបង់ប្រាក់។

កិច្ចសន្យាអាចមានទាំងធាតុភតិសន្យា និងធាតុមិនមែនភតិសន្យា។ ក្រុមហ៊ុនបានបែងចែកសាច់ប្រាក់ក្នុងកិច្ចសន្យាជាធាតុភតិសន្យា និងធាតុមិនមែនភតិសន្យា អាស្រ័យទៅតាមថ្លៃឈ្នួលដែលពាក់ព័ន្ធរបស់វា។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

## ២. គោលនយោបាយគណនេយ្យសារវន្ត (ត)

### ២.១០ ភតិសន្យា (ត)

*ក្រុមហ៊ុនជាភាគីអ្នកជួល (ត)*

លក្ខខណ្ឌក្នុងភតិសន្យា ត្រូវបានចរចាឡើងវិញតាមមូលដ្ឋានដាច់ដោយឡែក និងមានលក្ខខណ្ឌខុសៗពីគ្នា។ កិច្ចព្រមព្រៀងភតិសន្យាមិនបានបណ្តាលឲ្យមានកិច្ចសន្យាណាមួយ ក្រៅពីអត្ថប្រយោជន៍ដែលបានធានានៅក្នុងទ្រព្យសកម្មភតិសន្យា ដែលត្រូវបានកាន់កាប់ដោយភាគីម្ចាស់ជួលនោះទេ។ ទ្រព្យសកម្មដែលត្រូវបានជួល អាចនឹងមិនត្រូវបានប្រើប្រាស់ជាទ្រព្យធានាក្នុងការខ្ចីប្រាក់ទេ។

ភតិសន្យា ត្រូវបានទទួលស្គាល់ជាសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម និងជាបំណុលពាក់ព័ន្ធនាកាលបរិច្ឆេទដែលទ្រព្យសកម្មដែលបានជួលសម្រាប់ប្រើប្រាស់។

ទ្រព្យសកម្ម និងបំណុលដែលកើតពីភតិសន្យា ត្រូវបានទទួលស្គាល់ជាលើកដំបូងតាមមូលដ្ឋានតម្លៃបច្ចុប្បន្ន។

**(i) បំណុលភតិសន្យា**

បំណុលភតិសន្យារួមបញ្ចូលនូវតម្លៃបច្ចុប្បន្នសុទ្ធនៃការទូទាត់ភតិសន្យាថេរ (រួមទាំង ការបង់ប្រាក់ថេរផ្សេងៗ) ដកនឹងការលើកទឹកចិត្តផ្សេងៗ សម្រាប់ការជួលដែលត្រូវទទួលបាន។

ការទូទាត់ភតិសន្យា ដែលត្រូវធ្វើឡើងក្រោមជម្រើសដែលអាចពន្យាររយៈពេលបាន ប្រកបដោយភាពសមហេតុផល ត្រូវបានរួមបញ្ចូលនៅក្នុងការវាស់វែងបំណុល។

ការទូទាត់ភតិសន្យា ត្រូវបានធ្វើអប្បហារ ដោយប្រើអត្រាជាក់ស្តែងក្នុងភតិសន្យា។ ប្រសិនបើអត្រាការប្រាក់មិនអាចកំណត់បានដោយភាពងាយស្រួលនោះ ដែលជាទូទៅចំពោះករណីភតិសន្យានៅក្នុងក្រុមហ៊ុនភាគីអ្នកជួលត្រូវបានប្រើប្រាស់អត្រាកំណើនប្រាក់កម្ចីនោះ ហើយវាគឺជាអត្រាដែលភាគីអ្នកជួលនីមួយៗ ត្រូវចំណាយ ដើម្បីទទួលបានប្រាក់កម្ចីដែលមានភាពចាំបាច់ ដើម្បីទទួលបានទ្រព្យសកម្មដែលមានតម្លៃប្រហាក់ប្រហែលនឹងទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ នៅក្នុងបរិយាកាសសេដ្ឋកិច្ចស្រដៀងគ្នា ជាមួយនឹងលក្ខខណ្ឌ និងការធានាប្រហាក់ប្រហែលគ្នា។

ដើម្បីកំណត់អត្រាកំណើនប្រាក់កម្ចី ក្រុមហ៊ុនអាចធ្វើទៅបានដោយប្រើហិរញ្ញប្បទានភាគីទីបីដែលទទួលបានពីភាគីអ្នកជួលនីមួយៗ គឺជាចំណុចចាប់ផ្តើម ហើយកែតម្រូវលើការផ្លាស់ប្តូរលក្ខខណ្ឌហិរញ្ញប្បទានចាប់តាំងពីហិរញ្ញប្បទានភាគីទីបីទទួលបាន។




# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

## ២. គោលនយោបាយគណនេយ្យសារវន្ត (ត)

### ២.១០ ភតិសន្យា (ត)

*ក្រុមហ៊ុនជាភាគីអ្នកជួល (ត)*


**(i) បំណុលភតិសន្យា (ត)**

ការទូទាត់ភតិសន្យាត្រូវបានបែងចែករវាងប្រាក់ដើម និងចំណាយការប្រាក់។ ចំណាយការប្រាក់ត្រូវបានទទួលស្គាល់ជាបន្ទុកក្នុងចំណេញ-ខាត ក្នុងរយៈពេលនៃភតិសន្យានោះ ដើម្បីបង្កើតអត្រាការប្រាក់ថេរតាមកាលកំណត់មួយ លើចំនួនសមតុល្យបំណុលដែលនៅសល់ក្នុងការិយបរិច្ឆេទនីមួយៗ។

**(ii) សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម**

សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានកត់ត្រាជាដំបូងតាមថ្លៃដើម ដែលរួមមាន៖

- ចំនួនទឹកប្រាក់ដែលបានវាស់វែងដំបូងនៃបំណុលភតិសន្យា
- រាល់ការទូទាត់ភតិសន្យាដែលធ្វើឡើងនៅថ្ងៃចាប់ផ្តើមភតិសន្យា ឬមុនថ្ងៃចាប់ផ្តើមភតិសន្យាដកការលើកទឹកចិត្តផ្សេងៗ ដែលទទួលបានពីភិតសន្យា
- ថ្លៃដើមផ្ទាល់ដំបូង និង
- ចំណាយសម្រាប់ការជួសជុលឡើងវិញ ប្រសិនបើមាន

សិទ្ធិប្រើប្រាស់ទ្រព្យសកម្មជាទូទៅ ត្រូវបានដករំលស់ តាមមូលដ្ឋានរំលស់ថេរលើរយៈពេលណាមួយដែលខ្លីជាង រវាងអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម និងរយៈពេលជួល។ ប្រសិនបើក្រុមហ៊ុនមានបំណងចង់ទិញយកទ្រព្យសកម្មនោះ សិទ្ធិប្រើប្រាស់ទ្រព្យសកម្មត្រូវបានរំលស់ទៅលើអាយុកាលប្រើប្រាស់ជាមូលដ្ឋានរបស់ទ្រព្យសកម្មនោះ។

បន្ទាប់មកសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានវាស់វែងដោយផ្អែកលើតម្លៃដើម ដករំលស់បង្គរ និងការខាតបង់ឱនភាពនៃតម្លៃបង្គរ ប្រសិនបើមាន។

**(iii) ការលើកលែងនៃការទទួលស្គាល់ផ្សេងៗ**

ការទូទាត់នានាដែលពាក់ព័ន្ធនឹងភតិសន្យាដែលមានរយៈពេលខ្លី និងភតិសន្យាដែលមានតម្លៃទាប ត្រូវបានទទួលស្គាល់ជាចំណាយ នៅក្នុងរបាយការណ៍ចំណេញ ឬខាត ដោយផ្អែកលើវិធីសាស្ត្ររំលស់ថេរ។ ភតិសន្យារយៈពេលខ្លី រួមមានការជួលម៉ូតូ ការជួលរថយន្ត និងការជួលផ្ទះសម្រាប់បុគ្គលិក។ ភតិសន្យាដែលមានតម្លៃទាបរួមមានខ្ទង់តូចៗនៃបរិក្ខារការិយាល័យ។

# អេសអេសប៊ី (ខេមបូឌា) ភីអិលស៊ី

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

## ២. គោលនយោបាយគណនេយ្យសារវន្ត (ត)

### ២.១១ ពន្ធលើប្រាក់ចំណេញ

ចំណាយពន្ធលើប្រាក់ចំណេញរួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ។ ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត លើកលែងតែពន្ធនេះទាក់ទងទៅនឹងធាតុដែលត្រូវទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន ឬលទ្ធផលលម្អិតផ្សេងៗ។

ក្រុមហ៊ុនបានកំណត់ថា ការប្រាក់ និងការដាក់ពិន័យទាក់ទងនឹងពន្ធលើប្រាក់ចំណេញរួមបញ្ចូលបំណាកស្រាយពន្ធមិនច្បាស់លាស់ មិនបំពេញទៅនឹងនិយមន័យនៃពន្ធលើប្រាក់ចំណេញ ដូច្នេះហើយវាត្រូវបានកត់ត្រាក្រោមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ស.គ.អ.ក ៣៧ *សំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ* ហើយត្រូវបានទទួលស្គាល់ការចំណាយដែលពាក់ព័ន្ធទាំងនេះ នៅក្នុង "ចំណាយ-ផ្សេងៗ"។

*(i) ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ*

ពន្ធប្រចាំឆ្នាំ គឺជាពន្ធដែលរំពឹងថាត្រូវបង់ ឬត្រូវទទួល លើប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំ ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទ៏នៅកាលបរិច្ឆេទរាយការណ៍ ហើយធ្វើនិយ័តកម្មជាមួយបំណុលពន្ធពីការិយបរិច្ឆេទមុនៗ។ វាត្រូវបានវាស់វែងដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទ៏នៅកាលបរិច្ឆេទរាយការណ៍។

ពន្ធជាទ្រព្យសកម្ម និងបំណុលពន្ធប្រចាំឆ្នាំ អាចកាត់កងគ្នាបានក្នុងករណីវាបំពេញលក្ខខណ្ឌជាក់លាក់ណាមួយ។

*(ii) ពន្ធពន្យារ*

ពន្ធពន្យារ ត្រូវបានទទួលស្គាល់ដោយផ្អែកលើភាពលម្អៀងបណ្តោះអាសន្ន រវាងតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងសម្រាប់ការគិតពន្ធ។

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់ចំពោះការខាតបង់ពន្ធមិនទាន់បានប្រើប្រាស់ និងភាពលម្អៀងបណ្តោះអាសន្នដែលអាចកាត់កងបាន ត្រឹមកម្រិតដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតអាចប្រើប្រាស់សម្រាប់កាត់កងជាមួយភាពលម្អៀងបណ្តោះអាសន្ននោះបាន។ ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ និងត្រូវបានកាត់បន្ថយក្នុងករណីមិនអាចប្រើប្រាស់នូវអត្ថប្រយោជន៍ពន្ធទាំងនោះបាន។ ការកាត់បន្ថយនោះត្រូវកត់ត្រាបញ្ច្រាសមកវិញនៅពេលដែលប្រាក់ចំណេញជាប់ពន្ធ នាពេលអនាគតមានលក្ខណៈប្រសើរឡើង។




# អេសអេសប៊ី (ខេមបូឌា) ភីអិលស៊ី

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

## ២. គោលនយោបាយគណនេយ្យសារវន្ត (ត)


### ២.១១ ពន្ធលើប្រាក់ចំណេញ (ត)

*(ii) ពន្ធពន្យារ (ត)*

ពន្ធពន្យារជាទ្រព្យសកម្មដែលបានមិនបានទទួលស្គាល់ ត្រូវបានវាយតម្លៃឡើងវិញនាកាលបរិច្ឆេទរាយការណ៍នីមួយៗ និងត្រូវបានទទួលស្គាល់ប្រសិនបើវាអាចមានលទ្ធភាពផ្តល់នូវប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតពេលដែលវាអាច យកមកកាត់កង ឬអាចប្រើប្រាស់បាន។

ពន្ធពន្យារ ត្រូវបានវាស់វែងតាមអត្រាពន្ធដែលរំពឹងថានឹងត្រូវបានអនុវត្តចំពោះភាពខុសគ្នាបណ្តោះអាសន្ននៅពេលដែលវាបញ្ច្រាស ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទ៏នៅកាលបរិច្ឆេទរាយការណ៍។

ការវាស់វែងនៃពន្ធពន្យារ ឆ្លុះបញ្ចាំងពីពន្ធដែលក្រុមហ៊ុនរំពឹងថាអាចប្រើប្រាស់បាន ឬអាចកាត់កងបាននូវតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល នៅកាលបរិច្ឆេទរាយការណ៍។

ពន្ធពន្យារជាទ្រព្យសកម្ម និងពន្ធពន្យារជាបំណុល អាចកាត់កងគ្នាបានក្នុងករណីវាបំពេញលក្ខខណ្ឌជាក់លាក់ណាមួយ។

### ២.១២ សំវិធានធន

សំវិធានធនត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល ហើយវាទំនងជាអាចតម្រូវឲ្យមានការចំណាយធនធានដើម្បីទូទាត់កាតព្វកិច្ចនោះ ហើយចំនួនទឹកប្រាក់ត្រូវបានប៉ាន់ស្មានគួរឲ្យជឿជាក់បាន។

នៅពេលដែលមានកាតព្វកិច្ចស្រដៀងគ្នាច្រើន កម្រិតនៃលំហូរចេញដើម្បីទូទាត់កាតព្វកិច្ចនោះ ត្រូវបានកំណត់ដោយគិតទៅលើចំណាត់ថ្នាក់នៃកាតព្វកិច្ចទាំងមូល។ សំវិធានធនត្រូវបានទទួលស្គាល់ទោះបីជាកម្រិតនៃលំហូរចេញដើម្បីទូទាត់កាតព្វកិច្ចនោះមានចំនួនតូចក៏ដោយ។

សំវិធានធនត្រូវបានគណនាតាមតម្លៃបច្ចុប្បន្ននៃចំណាយដែលត្រូវទូទាត់កាតព្វកិច្ចនោះ ដោយប្រើអត្រាមុនដកពន្ធ ដើម្បីឆ្លុះបញ្ចាំងការវាយតម្លៃទីផ្សារបច្ចុប្បននៃតម្លៃពេលវេលា និងហានិភ័យជាក់លាក់ផ្សេងៗនៃកាតព្វកិច្ចនោះ។ ការកើនឡើងនៃសំវិធានធនដោយសារពេលវេលាដែលបានកន្លងផុត ត្រូវបានទទួលស្គាល់ជាចំណាយការប្រាក់។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ២. គោលនយោបាយគណនេយ្យសារវន្ត (ត)

### ២.១៣ ទុនបម្រុងតាមបទប្បញ្ញត្តិ

ទុនបម្រុងតាមបទប្បញ្ញត្តិ ត្រូវបានបង្កើតលើភាពខុសគ្នារវាងសំវិធានធន ស្របតាម ស.រ.ទ.ហ.អ.ក និងសំវិធានធនតាមបទប្បញ្ញត្តិ អនុលោមទៅតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ៧-០១៧-៣៤៤ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ និងសារាចរណែនាំ លេខ ធ៧-០១៨-០០១ ស.រ.ច.ណ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ិមភែរមិន សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ ស្របតាមប្រការ ៧៣ គ្រឹះស្ថានត្រូវប្រៀបធៀបសំវិធានធន ដែលគណនាតាមប្រការ ៤៩ ដល់ប្រការ ៧១ ជាមួយនឹងសំវិធានធនដែលគណនាតាមប្រការ ៧២ និងត្រូវបានកត់ត្រាដូចខាងក្រោម៖

(i) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិ ដែលគណនាតាមប្រការ ៧២ ទាបជាងសំវិធានធនដែលគណនាតាមប្រការ ៤៩ ដល់ប្រការ ៧១ នោះគ្រឹះស្ថានត្រូវកត់ត្រាសំវិធានធន ដែលត្រូវគណនាអនុលោមតាម ស.រ.ទ.ហ.អ.ក និង

(ii) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិ ដែលគណនាតាមប្រការ ៧២ ខ្ពស់ជាងសំវិធានធនដែលគណនាតាមប្រការ ៤៩ ដល់ប្រការ ៧១ នោះគ្រឹះស្ថានត្រូវកត់ត្រាសំវិធានធន ដែលត្រូវគណនាតាម ស.រ.ទ.ហ.អ.ក និងផ្ទេរចំនួនលម្អៀងនោះពីប្រាក់ចំណេញរក្សាទុក ឬគណនីខាតបង្គរទៅក្នុងទុនបម្រុងតាមបទប្បញ្ញត្តិ ក្នុងមូលធនរបស់ភាគទុនិកនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

ទុនបម្រុងតាមបទប្បញ្ញត្តិ មិនត្រូវបានបញ្ចូលក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ក្រុមហ៊ុនឡើយ។

### ២.១៤ ទុនបម្រុងទូទៅ

ទុនបម្រុងទូទៅត្រូវបានបង្កើតឡើងសម្រាប់ហានិភ័យហិរញ្ញវត្ថុទូទៅរបស់ក្រុមហ៊ុន។ ក្រុមប្រឹក្សាភិបាលអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការប្រើប្រាស់ និងថែរក្សាទុនបម្រុងទូទៅ ដោយផ្ទេរចេញពីប្រាក់ចំណេញរក្សាទុក។

### ២.១៥ ទុនបម្រុងផ្សេងៗ

ទុនបម្រុងផ្សេងៗ ត្រូវបានបង្កើតឡើងសម្រាប់ភាពខុសគ្នារវាងឱនភាពនៃតម្លៃឥណទាន និងបុរេប្រទាន ដោយអនុលោមតាម ស.រ.ទ.ហ.អ.ក ឬសំវិធានធនរបស់ធនាគារជាតិនៃកម្ពុជា ("NBC") នៅពេលដែលទំហំណាមួយខ្ពស់ជាង និងសំវិធានធននៃប្រាក់កម្ចីដោយគ្របដណ្តប់សមាមាត្រហានិភ័យ ១០០% នៃក្រុមឥណទានមិនដំណើរការ ឬក្រុមឥណទានមានហានិភ័យ "PAR ៩០ថ្ងៃ" ស្របតាមលក្ខខណ្ឌរបស់ម្ចាស់បំណុល។ ក្រុមហ៊ុនកត់ត្រា៖

(i) ក្នុងករណីដែលឱនភាពនៃតម្លៃឥណទាន និងបុរេប្រទាន ស្របតាម ស.រ.ទ.ហ.អ.ក ខ្ពស់ជាងក្រុមឥណទានមិនដំណើការ "NPL" ក្រុមហ៊ុនកត់ត្រាសំវិធានធនដែលបានគណនាដោយអនុលោមតាម ស.រ.ទ.ហ.អ.ក និង



# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ២. គោលនយោបាយគណនេយ្យសារវន្ត (ត)

### ២.១៥ ទុនបម្រុងផ្សេងៗ (ត)

(ii) ក្នុងករណីដែលឱនភាពនៃតម្លៃឥណទាន និងបុរេប្រទាន ស្របតាម ស.រ.ទ.ហ.អ.ក ទាបជាងក្រុមឥណទានមិនដំណើការ "NPL" ក្រុមហ៊ុនកត់ត្រាសំវិធានធន គណនាដោយអនុលោមតាម ស.រ.ទ.ហ.អ.ក ហើយផ្ទេរចំនួនលម្អៀងពីប្រាក់ចំណេញរក្សាទុក ឬគណនីខាតបង្គរទៅក្នុងទុនបម្រុងផ្សេងៗ នៅក្នុងមូលធនរបស់ភាគទុនិកនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (ក្រុមហ៊ុនបានផ្តល់អទិភាពក្នុងការផ្ទេរចំនួនលម្អៀងទៅគណនីទុនបម្រុងតាមបទបញ្ញាតិជាមុន ហើយផ្ទេរចំនួនលម្អៀងដែលនៅសល់ ទៅទុនបម្រុងផ្សេងៗ ប្រសិនបើមាន)។

### ២.១៦ អត្ថប្រយោជន៍និយោជិត

(i) អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី

អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី ត្រូវបានកត់ត្រាបង្គរក្នុងការិយបរិច្ឆេទដែលនិយោជិតបានបម្រើការងារឲ្យក្រុមហ៊ុន។

(ii) កាតព្វកិច្ចសោធននិវត្តន៍

ក្រុមហ៊ុនបង់វិភាគទានប្រចាំខែ ជាប្រាក់សោធននិវត្តន៍តាមរបបភាគទានជាកាតព្វកិច្ច ទៅបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) ដែលជាផ្នែកសាធារណៈរដ្ឋបាលនៃរបបសន្តិសុខសង្គម សម្រាប់សោធននិវត្តន៍ក្នុងប្រទេសកម្ពុជា។ ក្រុមហ៊ុនមិនមានកាតព្វកិច្ចបង់ប្រាក់បន្ថែមទៀតទេ នៅពេលដែលបានបង់វិភាគទាននេះរួច។ វិភាគទានត្រូវបានកត់ត្រាជាចំណាយអត្ថប្រយោជន៍និយោជិត នៅពេលដល់ថ្ងៃកំណត់។

(iii) អត្ថប្រយោជន៍និយោជិតរយៈពេលវែង -ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ

នៅខែមិថុនា ឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើវិសោធនកម្មលើច្បាប់ស្តីពីការងារ ដែលណែនាំពីគម្រោងការទូទាត់ប្រាក់បំណាច់អតីតភាពការងារ។ បន្ទាប់មកនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ប្រកាសលេខ ៤៤៣ ក.ប/ប្រ.ក.ខ.ល ត្រូវបានចេញផ្សាយ ដោយបានផ្តល់នូវគោលការណ៍ណែនាំស្តីពីការអនុវត្តច្បាប់នេះ។ អនុលោមទៅតាមច្បាប់/ប្រកាស តម្រូវឲ្យអង្គភាពនីមួយៗទូទាត់ប្រាក់បំណាច់អតីតភាពការងារឲ្យនិយោជិតដែលមានកិច្ចសន្យាការងារមិនមានថិរវេលាកំណត់ ដូចខាងក្រោម៖

- ប្រាក់បំណាច់ការងារប្រចាំឆ្នាំ - ចូលជាធរមានក្នុងខែមករា ឆ្នាំ២០១៩ - ស្មើនឹង ១៥ថ្ងៃ នៃប្រាក់បៀវត្សរ៍ប្រចាំខែរបស់និយោជិត និងអត្ថប្រយោជន៍ក្នុងឆ្នាំនីមួយៗគិតជាមធ្យម ដែលត្រូវទូទាត់រៀងរាល់ ៦ខែម្តង នៅថ្ងៃទី៣០ ខែមិថុនា និងថ្ងៃទី៣១ ខែធ្នូ (៧,៥ថ្ងៃ ក្នុងការទូទាត់ម្តងៗ)។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

## ២. គោលនយោបាយគណនេយ្យសារវន្ត (ត)

### ២.១៦ អត្ថប្រយោជន៍និយោជិត (ត)

(iii) អត្ថប្រយោជន៍និយោជិតរយៈពេលវែង - ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ (ត)

- ការបើកប្រាក់បំណាច់អតីតភាពការងាររំឭក - និយោជិតមានសិទ្ធិទទួលបានប្រាក់បំណាច់អតីតភាពការងាររំឭកស្មើនឹង ១៥ថ្ងៃ នៃប្រាក់បៀវត្សរ៍របស់ពួកគេក្នុងមួយឆ្នាំ គិតចាប់តាំងពីថ្ងៃចូលបម្រើការងាររហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ហើយនៅតែបន្តការងារជាមួយក្រុមហ៊ុន។ ការបើកប្រាក់បំណាច់អតីតភាពការងាររំឭក អាស្រ័យទៅតាមចំនួនឆ្នាំអតីតភាពការងាររបស់បុគ្គលិកម្នាក់ៗ ហើយមិនត្រូវលើសពី ៦ខែ នៃប្រាក់បៀវត្សរ៍ជុលមធ្យមទេ។ នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញសេចក្តីណែនាំលេខ ០៤២/១៩ ក.ប/ស.ណ.ន.ខ.ល ដើម្បីពន្យារពេលការបើកប្រាក់បំណាច់អតីតភាពការងាររំឭក ដែលនឹងត្រូវទូទាត់ឲ្យចំនួនបីថ្ងៃ ក្នុងខែមិថុនា និងខែធ្នូ ចាប់ផ្តើមនៅ ខែធ្នូ ឆ្នាំ២០២១។

ការទូទាត់ប្រាក់បំណាច់ការងារប្រចាំឆ្នាំ ត្រូវបានចាត់ទុកថាជាអត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី ហើយវាត្រូវបានកត់ត្រាបង្គរក្នុងឆ្នាំដែលនិយោជិតបានបម្រើការងារឲ្យក្រុមហ៊ុន។

ការបើកប្រាក់បំណាច់អតីតភាពការងាររំឭក ត្រូវបានចាត់ថ្នាក់ជាអត្ថប្រយោជន៍និយោជិតរយៈពេលវែង។ បំណុលប្រាក់បំណាច់អតីតភាពការងាររំឭក ត្រូវបានទទួលស្គាល់តាមតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចដែលបានកំណត់ នាការិយបរិច្ឆេទរាយការណ៍។ កាតព្វកិច្ចនោះកើតឡើងនៅពេលដែលបុគ្គលិកបានប្រើការងារឲ្យក្រុមហ៊ុន ហើយក្រុមហ៊ុនរំពឹងថាត្រូវបង់ក្នុងការិយបរិច្ឆេទរាយការណ៍នាពេលអនាគត។ តម្លៃបច្ចុប្បន្ននៃការបើកប្រាក់បំណាច់អតីតភាពការងាររំឭក ត្រូវបានកំណត់ដោយធ្វើអប្បហារលើចំនួនទឹកប្រាក់ត្រូវទូទាត់នាពេលអនាគតប៉ាន់ស្មាន ដោយយោងទៅតាមសញ្ញាប័ណ្ណសាជីវកម្មដែលមានគុណភាពខ្ពស់នៃរូបិយប័ណ្ណរបស់បំណុលនោះ។

### ២.១៧ ចំណូល និងចំណាយការប្រាក់

ចំណូល និងចំណាយការប្រាក់ពីឧបករណ៍ហិរញ្ញវត្ថុ ដែលវាស់វែងតាមរំលស់ថ្លៃដើម ត្រូវបានទទួលស្គាល់នៅក្នុង 'ចំណូលការប្រាក់' និង 'ចំណាយការប្រាក់' រៀងគ្នានៅក្នុងរបាយការណ៍ចំណេញ ឬខាត ដោយប្រើវិធីសាស្រ្តការប្រាក់ប្រសិទ្ធភាព។






# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

## ២. គោលនយោបាយគណនេយ្យសារវន្ត (ត)


### ២.១៧ ចំណូល និងចំណាយការប្រាក់ (ត)

វិធីសាស្រ្តការប្រាក់ប្រសិទ្ធភាព គឺជាវិធីសាស្រ្តក្នុងការគណនារំលស់ថ្លៃដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុមួយ ឬបំណុល ហិរញ្ញវត្ថុមួយ និងជាវិធីសាស្រ្តក្នុងការបែងចែកចំណូលការប្រាក់ ឬចំណាយការប្រាក់ទៅតាមរយៈពេលដែលពាក់ព័ន្ធ។ អត្រាការប្រាក់ប្រសិទ្ធភាព គឺជាអត្រាដែលធ្វើអប្បហារជាក់ស្តែងចំពោះការទូទាត់សាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត ការទទួលប្រាក់ក្នុងរយៈពេលនៃអាយុកាលប៉ាន់ស្មានរបស់ឧបករណ៍ហិរញ្ញវត្ថុ ឬក្នុងរយៈពេលណាមួយដែលខ្លីជាងទៅតាមការសមស្របចំពោះតម្លៃយោងសុទ្ធរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។ នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាព ក្រុមហ៊ុនបានគិតគូអំពីរាល់លក្ខខណ្ឌក្នុងកិច្ចសន្យាទាំងអស់នៃឧបករណ៍ហិរញ្ញវត្ថុ និងបានរួមបញ្ចូលនូវកម្រៃ ឬចំណាយបន្ថែមនានា ដែលបានចំណាយដោយផ្ទាល់ចំពោះឧបករណ៍មួយ ហើយវាជាផ្នែកមួយនៃអត្រាការប្រាក់ប្រសិទ្ធភាព ប៉ុន្តែមិនរួមបញ្ចូលការខាតបង់ឥណទានដែលរំពឹងទុក។

ចំណូលការប្រាក់ ត្រូវបានគណនាតាមអត្រាការប្រាក់ប្រសិទ្ធភាព ទៅក្នុងតម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ លើកលែងតែចំពោះ៖

- ការទិញ ឬទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៅពេលដំបូង ("POCI") ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដែលត្រូវបានកែតម្រូវនូវហានិភ័យ ផ្អែកលើរំលស់ថ្លៃដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុនោះ។
- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនមែនជា POCI ប៉ុន្តែមានឱនភាពតម្លៃនៅពេលបន្ទាប់ (ឬដំណាក់កាលទី៣) ចំណូលការប្រាក់ ត្រូវបានគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពផ្អែកលើរំលស់ថ្លៃដើមរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ (ឧទាហរណ៍ សំវិធានធនលើការខាតបង់នៃឥណទានរំពឹងទុកសុទ្ធ)។

### ២.១៨ ចំណូល និងកម្រៃជើងសា

ចំណូល និងកម្រៃជើងសារត្រូវបានទទួលស្គាល់ជាចំណូល នៅពេលដែលវាបានបំពេញតាមគំរូលក្ខខណ្ឌទាំងអស់ (កាតព្វកិច្ចនៃដំណើរការត្រូវបានទទួលយក ហើយការគ្រប់គ្រងត្រូវបានផ្ទេរក្នុងពេលវេលាណាមួយ ឬចំណុចនៃពេលវេលាណាមួយ)។

កម្រៃនៃកិច្ចសន្យាឥណទាន និងបុរេប្រទានដែលនឹងត្រូវដកដោយអតិថិជន ត្រូវបានពន្យារ (រួមជាមួយនឹងការចំណាយផ្ទាល់ដែលពាក់ព័ន្ធ) ហើយប្រាក់ចំណូលក្លាយជាផ្នែកមួយនៃអត្រាការប្រាក់ប្រសិទ្ធភាព នៃឧបករណ៍ ហិរញ្ញវត្ថុ ត្រូវបានទទួលស្គាល់ជានិយ័តកម្មលើអត្រាការប្រាក់ប្រសិទ្ធភាពនៅលើឧបករណ៍ហិរញ្ញវត្ថុនោះ។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

### ៣. ការប៉ាន់ស្មានគណនេយ្យ និងការវិនិច្ឆ័យសំខាន់ៗ

ក្រុមហ៊ុនធ្វើការវិនិច្ឆ័យ និងការប៉ាន់ស្មានដែលពាក់ព័ន្ធនឹងអនាគត។ តាមនិយមន័យ ការប៉ាន់ស្មានគណនេយ្យនឹងកម្រស្មើនឹងលទ្ធផលជាក់ស្តែងដែលពាក់ព័ន្ធ។ ដើម្បីលើកកម្ពស់ខ្លឹមសារព័ត៌មាននៃការប៉ាន់ស្មានអថេរសំខាន់ៗមួយចំនួន ដែលត្រូវបានគេរំពឹងថានឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធផល និងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ការប៉ាន់ស្មាន និងការសន្មតដែលមានហានិភ័យជាសារវន្ត ដែលអាចបណ្តាលឲ្យមានការកែតម្រូវជាសារវន្តលើតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុបន្ទាប់ ត្រូវបានពណ៌នាដូចខាងក្រោម៖

#### (i) សំវិធានធនលើការខាតបង់ឥណទានដែលបានរំពឹងទុកទៅលើឥណទាន និងបុរេប្រទានវាស់វែងតាមរំលស់ថ្លៃដើម

ព័ត៌មានអំពីការវិនិច្ឆ័យ ដែលបានធ្វើឡើងក្នុងការអនុវត្តគោលនយោបាយគណនេយ្យដែលមានផលប៉ះពាល់ជាសារវន្តលើចំនួនទឹកប្រាក់ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញក្នុងកំណត់សម្គាល់ដូចខាងក្រោម។

- ការចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ៖ ការវាយតម្លៃគំរូអាជីវកម្មដែលទ្រព្យសកម្មទាំងនោះត្រូវបានកាន់កាប់ និងការវាយតម្លៃថាតើលក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាការទូទាត់តែប្រាក់ដើម និងការប្រាក់ ("SPPI") លើចំនួនប្រាក់ដើមដែលនៅសល់។
- ការបង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ថាតើហានិភ័យឥណទានទ្រព្យសកម្ម ហិរញ្ញវត្ថុបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់ដំបូង ដោយកំណត់វិធីសាស្រ្តសម្រាប់បញ្ចូលព័ត៌មានព្យាករនាពេលអនាគតទៅក្នុងការវាស់វែងការខាតបង់ឥណទានដែលបានរំពឹងទុក ("ECL") និងការជ្រើសរើស និងការអនុម័តលើគំរូដែលប្រើដើម្បីវាស់វែងការខាតបង់ឥណទានដែលបានរំពឹងទុក។

ព័ត៌មានអំពីភាពមិនប្រាកដប្រជានៃការសន្មត និងការប៉ាន់ស្មាន ដែលមានហានិភ័យជាសារវន្ត ដែលអាចធ្វើឲ្យមាននិយ័តកម្មលើតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនាពេលបន្ទាប់ ត្រូវបានបញ្ចូលក្នុងកំណត់សម្គាល់ ដូចខាងក្រោម។

- ការកំណត់តម្លៃសមស្របលើឧបករណ៍ហិរញ្ញវត្ថុដែលមានធាតុចូលដែលមិនអាចអង្កេតបានជាសារវន្ត។
- ឱនភាពនៃតម្លៃលើឧបករណ៍ហិរញ្ញវត្ថុ៖ ការកំណត់នូវធាតុចូលទៅក្នុងគំរូនៃការវាស់វែងលើ ECL រួមទាំងការបញ្ចូលព័ត៌មាននៃការព្យាករអំពីអនាគត។





# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

### ៣. ការប៉ាន់ស្មានគណនេយ្យ និងការវិនិច្ឆ័យសំខាន់ៗ (ត)

| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា៖ | | | | |
| គណនីសន្សំ (កំណត់សម្គាល់៦) | ២០៣.៨៣៨.៨៣៦ | ១៩៦.៩០៨.៨៦១ | ៤៩.៨០១.៤២៩ | ៣៥.៦៨៣.៣៧៦ |
| គណនីចរន្ត (កំណត់សម្គាល់៦) | ២៧២.៨៧៦.២៥១ | ១៧៥.១៩៩.៨៧៧ | ៦៦.៨០០.៣០៦ | ៤២.៥៤៩.៧៦៣ |
| ប្រាក់បញ្ញើមានកាលកំណត់ ដែលមានកាលកំណត់បីខែឬតិចជាង (កំណត់សម្គាល់៦) | ២០២.៧២២.០១៤ | ៥២.៩៧៤.៥៤២ | ៤៩.៥០៣.៥៥៣ | ១២.៨៦១.២៦៨ |
| | ៩៣២.៣២៧.៨១៣ | ៦៧២.១៨៣.៧២៣ | ២២៨.២៣២.០២៣ | ១៦៣.២៧០.២៧៥ |

### ៣៣. ព័ត៌មានអំពីលំហូរទឹកប្រាក់

ក. លំហូរទឹកប្រាក់ពីប្រតិបត្តិការ

| | ២០២៣ ពាន់រៀល | ២០២២ ពាន់រៀល | ២០២៣ ដុល្លារអាមេរិក (កំណត់សម្គាល់ ២៤(iii)) | ២០២២ ដុល្លារអាមេរិក (កំណត់សម្គាល់ ២៤(iii)) |
|---|---|---|---|---|
| ប្រាក់ចំណេញមុនដកពន្ធលើប្រាក់ចំណេញ | ៣៣៩.០៩១.១១៥ | ៣០០.៩៦៥.៧៨៥ | ៨២.៥០៣.៩២២ | ៧៣.៦៣៩.៧៨១ |
| *និយ័តភាពលើ៖* | | | | |
| រំលស់ទ្រព្យសកម្ម និងបរិក្ខារនិងរំលស់ទ្រព្យសកម្មអរូបី (កំណត់សម្គាល់ ២៩) | ១៤២០១.១៦៦ | ១២.៥១១.១៨៧ | ៣.៤៥៥.២៧២ | ៣.០៦១.២១៥ |

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

### ៣៣. ព័ត៌មានអំពីលំហូរទឹកប្រាក់ (ត)

#### ក. លំហូរទឹកប្រាក់ពីប្រតិបត្តិការ (ត)

| | ២០២៣<br>ពាន់រៀល | ២០២២<br>ពាន់រៀល | ២០២៣<br>ដុល្លារអាមេរិក<br>(កំណត់សម្គាល់ ២.៤(iii)) | ២០២២<br>ដុល្លារអាមេរិក<br>(កំណត់សម្គាល់ ២.៤(iii)) |
|---|---|---|---|---|
| *និយ័តភាពលើ៖(ត)* | | | | |
| ខាតលើឱនភាពនៃតម្លៃ | | | | |
| ឥណទាន (កំណត់សម្គាល់ ២៧) | (១៩.៦០០.៣៥៨) | ៦៨.៨១៣.២៨៧ | (៤.៧៦៨.៩៤៩) | ១៦.៨៣៧.១១៥ |
| ខាតសុទ្ធលើការឈប់ទទួលស្គាល់ | | | | |
| ទ្រព្យសកម្មហិរញ្ញវត្ថុតាមរំលស់ | | | | |
| ថ្លៃដើម | ២៩.៨៤៩.៦៨៦ | ៥.០៩១.៣១១ | ៧.២៦២.៦៩៧ | ១.២៤៥.៧៣៣ |
| ចំណេញលើការលក់ទ្រព្យ និងបរិក្ខារ | (៥៣៥.០៩៥) | (៣៣២.០២៥) | (១៣០.១៩៣) | (៨១.២៣៩) |
| ការលុបចោលនៃទ្រព្យសកម្មអរូបី | - | ១១៨.១៩៨ | - | ២៨.៩២០ |
| សំវិធានធននៃអត្ថប្រយោជន៍ | | | | |
| របស់និយោជិត | ៧.១៤៣.៩៨១ | ៧.៣០៣.១៧១ | ១.៧៣៨.១៩៥ | ១.៧៨៦.៩២៧ |
| ចំណេញពីការប្តូររូបិយប័ណ្ណ | | | | |
| មិនទាន់ទទួលស្គាល់ | (២.៤៥២.៧០០) | (៤.៤៣៩.៨៦៥) | (៥៩៦.៧៦៤) | (១.០៨៦.៣៣៨) |
| ចំណូលពីការប្រាក់សុទ្ធ | | | | |
| (កំណត់សម្គាល់ ២៥) | (៥៣៦.៨៨៩.៥០៧) | (៥៥៨.៣៩៥.២៤៣) | (១៣០.៦៣០.០៥០) | (១៣៦.៦១៤.៩៣៦) |
| *បម្រែបម្រួលដើមទុនបង្វិល៖* | | | | |
| ប្រាក់បម្រុងកាតព្វកិច្ច | (៨០.៧៩៨.៧៦១) | (៧១.១៥៨.៧៧០) | (១៩.៦៥៩.០៦៦) | (១៧.៤១១.០០៣) |
| ឥណទាន និងបុរេប្រទាន | (៥.៨៩៦.៩៤៩) | (៩៣៩.៥៩៣.៧៨០) | (១.៤៣៤.៧៨០) | (២២៩.៨៩៨.១៦០) |
| ទ្រព្យសកម្មផ្សេងៗ | ៩៣២.៦៨១ | (២.៣៣៧.៦១៥) | ២២៦.៩៣០ | (៥៧១.៩៦៤) |
| ប្រាក់បញ្ញើរបស់ធនាគារ និង | | | | |
| គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | ៦៩.០៣៣.៥៤៥ | (៧២.៥៣៣.៣២៧) | ១៦.៧៩៦.៤៨៣ | (១៧.៧៤៧.៣២៧) |
| ប្រាក់បញ្ញើរបស់អតិថិជន | ៤៤៧.៥៦០.០២៨ | ៨៣៣.៥១១.៦៩១ | ១០៨.៨៩៥.៣៨៤ | ២០៣.៩៤២.១៨០ |
| បំណុលផ្សេងៗ | (៥.៣៥៧.០៥៥) | ៤.៤៩៩.០៤៧ | (១.៣០៣.៤២០) | ១.០៨៤.៥៨៥ |
| សាច់ប្រាក់ទទួលបានពី/(ប្រើប្រាស់ក្នុង) | | | | |
| ប្រតិបត្តិការ | ២៥៦.២៨១.៧៨២ | (៤១៥.៩៧៦.៩៤៨) | ៦២.៣៥៥.៦៦៦ | (១០១.៧៨០.៥១១) |

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

### ៣៣. ព័ត៌មានអំពីលំហូរទឹកប្រាក់ (ត)

#### ខ. ការផ្ទៀងផ្ទាត់បំណុលសុទ្ធ

ផ្នែកនេះបង្ហាញពីការវិភាគបំណុលសុទ្ធ និងបម្រែបម្រួលបំណុលសុទ្ធ សម្រាប់ការិយបរិច្ឆេទនីមួយៗដែលបានបង្ហាញ។

| **បំណុលសុទ្ធ** | ២០២៣<br>ពាន់រៀល | ២០២២<br>ពាន់រៀល | ២០២៣<br>ដុល្លារអាមេរិក<br>(កំណត់សម្គាល់ ២.៤(iii)) | ២០២២<br>ដុល្លារអាមេរិក<br>(កំណត់សម្គាល់ ២.៤(iii)) |
|---|---|---|---|---|
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ៩៣២.៣២៧.៨១៣ | ៦៧២.១៨៣.៧២៣ | ២២៨.២៣២.០២៣ | ១៦៣.២៧០.២៧៥ |
| ប្រាក់កម្ចី | (៨៨៤.០៩៦.១០០) | (១.២៦៩.៦៥០.៥៤៣) | (២១៦.៤២៤.៩៩៤) | (៣០៨.៣៩២.១៦៥) |
| អនុបំណុល | (២៥៣.៧៥៣.១៧៥) | (៣១៤.១៧៩.២៦៨) | (៦២.១១៨.២៨០) | (៧៦.៣១២.៦៧១) |
| បំណុលភតិសន្យា | (២៧.៤៨១.៦៦៦) | (២៦.៣៤១.៧២៧) | (៦.៧២៧.៤៥៨) | (៦.៣៩៨.២៨២) |
| បំណុលសុទ្ធ | (២៣៣.០០៣.១២៨) | (៩៣៧.៩៨៧.៨១៥) | (៥៧.០៣៨.៧០៩) | (២២៧.៨៣២.៨៤៣) |
| សាច់ប្រាក់ និងការវិនិយោគ | | | | |
| សាច់ប្រាក់ងាយស្រួល | ៩៣២.៣២៧.៨១៣ | ៦៧២.១៨៣.៧២៣ | ២២៨.២៣២.០២៣ | ១៦៣.២៧០.២៧៥ |
| បំណុលដុល–អត្រាការប្រាក់ថេរ | (១.១៦៥.៣៣០.៩៤១) | (១.៦០៥.៩១៧.២២៩) | (២៨៥.២៧០.៧៣២) | (៣៨៩.៩៤៨.៣១៩) |
| បំណុលដុល–អត្រាការប្រាក់អថេរ | - | (៤.៧៥៤.៣០៩) | - | (១.១៥៤.៧៩៩) |
| បំណុលសុទ្ធ | (២៣៣.០០៣.១២៨) | (៩៣៧.៩៨៧.៨១៥) | (៥៧.០៣៨.៧០៩) | (២២៧.៨៣២.៨៤៣) |

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ៣៣. ព័ត៌មានអំពីលំហូរទឹកប្រាក់ (ត)

### ខ. ការផ្ទៀងផ្ទាត់បំណុលសុទ្ធ (ត)

| | ប្រាក់កម្ចី ពាន់រៀល | ភតិសន្យា ពាន់រៀល | អនុបំណុល ពាន់រៀល | មូលបត្របំណុល ពាន់រៀល | សរុបរង ពាន់រៀល | សាច់ប្រាក់ ពាន់រៀល | សរុប ពាន់រៀល |
|---|---|---|---|---|---|---|---|
| **បំណុលសុទ្ធនាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣** | (១.២៦៩.៦៥០.៥៤៣) | (២៦.៣៤១.៧២៧) | (៣១៤.១៧៩.២៦៨) | - | (១.៦១០.១៧១.៥៣៨) | ៦៧២.១៨៣.៧២៣ | (៩៣៧.៩៨៧.៨១៥) |
| លំហូរទឹកប្រាក់ | ៣៨២.៥៤៤.៧០០ | ៥.៩៣១.២៣៦ | ៥៤.៣៨២.៨០០ | - | ៤៤២.៨៥៨.៧៣៦ | ២៦០.១៩៤.០៩០ | ៧០៣.០០២.៨២៧ |
| ភតិសន្យាថ្មី | - | (៦.៧៦៩.៨៥៦) | - | - | (៦.៧៦៩.៨៥៦) | - | (៦.៧៦៩.៨៥៦) |
| និយ័តកម្មលើការប្តូររូបិយប័ណ្ណបរទេស | ៤.០៩២.៨០៨ | ២១២.៩៧៤ | ១.៣១៦.១០៣ | - | ៥.៦២១.៨៨៥ | - | ៥.៦២១.៨៨៥ |
| បម្រែបម្រួលផ្សេងៗ (i) | (១.០៨៣.០៦៥) | (៥១៤.២៩៣) | ៤.៧២៧.១៩០ | - | ៣.១២៩.៨៣២ | - | ៣.១២៩.៨៣២ |
| **បំណុលសុទ្ធនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | (៨៨៤.០៩៦.១០០) | (២៧.៤៨១.៦៦៦) | (២៥៣.៧៥៣.១៧៥) | - | (១.១៦៥.៣៣០.៩៤១) | ៩៣២.៣២៧.៨១៣ | (២៣៣.០០៣.១២៨) |
| គិតជាដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) | (២១៦.៤២៤.៩៩៤) | (៦.៧២៧.៤៥៨) | (៦២.១១៨.២៨០) | - | (២៨៥.២៧០.៧៣២) | ២២៨.២៣២.០២៣ | (៥៧.០៣៨.៧០៩) |
| **បំណុលសុទ្ធនាថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | (១.១៥២.១១២.៨២០) | (២៥.២២៨.៤២៨) | (២៥២.៦០០.០៤៣) | (៨១.៧៤១.១៧៥) | (១.៥១១.៦៨២.៤៦៦) | ៤៩០.៣៥៩.៨៩៧ | (១.០២១.៣២២.៥៦៩) |
| លំហូរទឹកប្រាក់ | (១២៨.៤២៣.២៨៤) | ៥.៨៣០.៩៥៧ | (៤២.៨៨៥.០០០) | ៨០.៥០៤.៧៨៣ | (៨៥.០៧២.៥៤៥) | ១៨១.៨២៣.៨២៦ | ៩៦.៧៥១.២៨១ |
| ភតិសន្យាថ្មី | - | (៦.១៦១.១៩៤) | - | - | (៦.១៦១.១៩៤) | - | (៦.១៦១.១៩៤) |
| និយ័តកម្មលើការប្តូររូបិយប័ណ្ណបរទេស | (៣.៧៥៣.៧៣៨) | (២៧២.៤៥៣) | (៣.៣០១.៣៧៣) | ១៣.២៨៤ | (៧.៣១៤.២៨០) | - | (៧.៣១៤.២៨០) |
| បម្រែបម្រួលផ្សេងៗ (i) | ១៤.៦៣៩.២៩៩ | (៥១០.៦៥៩) | (១៥.២៩២.៨៥២) | ១.២២៣.១០៨ | ៥៨.៨៩៦ | - | ៥៨.៨៩៦ |
| **បំណុលសុទ្ធនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | (១.២៦៩.៦៥០.៥៤៣) | (២៦.៣៤១.៧២៧) | (៣១៤.១៧៩.២៦៨) | - | (១.៦១០.១៧១.៥៣៨) | ៦៧២.១៨៣.៧២៣ | (៩៣៧.៩៨៧.៨១៥) |
| គិតជាដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) | (៣០៨.៣៩២.១៦៥) | (៦.៣៩៨.២៨២) | (៧៦.៣១២.៦៧១) | - | (៣៩១.១០៣.១១៨) | ១៦៣.២៧០.២៧៥ | (២២៧.៨៣២.៨៤៣) |

(i) បម្រែបម្រួលផ្សេងៗរួមបញ្ចូលនូវបម្រែបម្រួលមិនមែនសាច់ប្រាក់ ដែលរួមមាន ចំណាយការប្រាក់បង្គរដែលត្រូវបានបង្ហាញជាលំហូរទឹកប្រាក់ប្រតិបត្តិការ ក្នុងរបាយការណ៍លំហូរទឹកប្រាក់នៅពេលបានទូទាត់ប្រាក់។





# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ៣៤. បំណុលយថាហេតុ និងកិច្ចសន្យាផ្សេងៗ

### ក. កិច្ចសន្យាផ្តល់ឥណទាន និងកិច្ចសន្យាធានា

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ក្រុមហ៊ុនមិនមានកិច្ចសន្យាណាមួយនៃឧបករណ៍ហិរញ្ញវត្ថុ ដែលត្រូវផ្តល់ឥណទានឲ្យអតិថិជន ការធានា និងហ្វាស៊ីលីធីផ្សេងៗទេ។

### ខ. កិច្ចសន្យាភតិសន្យា

ក្រុមហ៊ុនបានទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យាចំពោះកិច្ចសន្យាភតិសន្យាដែលក្រុមហ៊ុនជាភាគីអ្នកជួល លើកលែងតែភតិសន្យាទាំងឡាយណាដែលមានរយៈពេលខ្លី និងភតិសន្យាដែលមានតម្លៃទាប សូមមើលកំណត់សម្គាល់ ២.១០ និងកំណត់សម្គាល់ ១១ សម្រាប់ព័ត៌មានបន្ថែម។ កិច្ចសន្យាភតិសន្យាដែលមានរយៈពេលខ្លី និងភតិសន្យាដែលមានតម្លៃទាប មានដូចខាងក្រោម៖

| | ថ្ងៃទី៣១ ខែធ្នូ | | ថ្ងៃទី៣១ ខែធ្នូ | |
|---|---|---|---|---|
| | ឆ្នាំ២០២៣ ពាន់រៀល | ឆ្នាំ២០២២ ពាន់រៀល | ឆ្នាំ២០២៣ ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) | ឆ្នាំ២០២២ ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) |
| រយៈពេល១ឆ្នាំ | ៨១.៩០៥ | ១៦៧.៣៥៦ | ១៩.៩២៨ | ៤០.៦៥០ |

### គ. កិច្ចសន្យាទាក់ទងនឹងការទិញទ្រព្យសកម្ម

| | ២០២៣ ពាន់រៀល | ២០២២ ពាន់រៀល | ២០២៣ ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) | ២០២២ ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) |
|---|---|---|---|---|
| *ទ្រព្យសកម្មអរូបី៖* | | | | |
| រយៈពេល ១ឆ្នាំ | ៣.១៩៥.៩៥០ | ៥.៨១១.៥០៤ | ៧៧០.០០០ | ១.៤១១.៥៨៧ |
| ពីលើសពី ១ឆ្នាំ ទៅ៥ឆ្នាំ | ១៨០.៩៧៥ | ៣.៩១៦.៩១៤ | ៤៤.៣០២ | ៩៥១.៤០០ |
| | ៣.៣២៦.៩២៥ | ៩.៧២៨.៩១៨ | ៨១៤.៣០២ | ២.៣៦២.៩៨៧ |

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

## ៣៥. ប្រតិបត្តិការសម្ព័ន្ធញាតិ

នៅក្នុងដំណើរការអាជីវកម្មធម្មតា ក្រុមហ៊ុនមានប្រតិបត្តិការមួយចំនួនជាមួយសម្ព័ន្ធញាតិ។ ទំហំប្រតិបត្តិការសមតុល្យដែលនៅមិនទាន់ទូទាត់នាចុងការិយបរិច្ឆេទ ព្រមទាំងចំណូល និងចំណាយ ពាក់ព័ន្ធក្នុងការិយបរិច្ឆេទនេះ មានដូចខាងក្រោម៖

### ក. សម្ព័ន្ធញាតិ និងទំនាក់ទំនង

សម្ព័ន្ធញាតិរបស់ក្រុមហ៊ុន មានដូចខាងក្រោម៖

| ទំនាក់ទំនង | សម្ព័ន្ធញាតិ |
|---|---|
| ក្រុមហ៊ុនមេធំបង្អស់ | ក្រុមហ៊ុន LOLC Holdings Plc. |
| ភាគទុនិក | ក្រុមហ៊ុន LOLC Asia Private Limited |
| | ក្រុមហ៊ុន TPC-ESOP Co.. Ltd. |
| សម្ព័ន្ធញាតិ | អង្គភាពដែលស្ថិតនៅក្រោមក្រុមហ៊ុនមេតែមួយ |
| បុគ្គលិកគណៈគ្រប់គ្រងសំខាន់ៗ | អភិបាលទាំងអស់របស់ក្រុមហ៊ុន ជាអ្នកដែលធ្វើការសម្រេចចិត្តសំខាន់ៗ ចំពោះគោលដៅជាយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន និងបុគ្គលិកគណៈគ្រប់គ្រងជាន់ខ្ពស់ (រួមទាំងសមាជិកគ្រួសារជិតស្និទ្ធរបស់ពួកគេ)។ |

### ខ. ឥណទាន និងបុរេប្រទានផ្តល់ដល់បុគ្គលិកគ្រប់គ្រងសំខាន់ៗ

| | ២០២៣<br>ពាន់រៀល | ២០២២<br>ពាន់រៀល | ២០២៣<br>ដុល្លារអាមេរិក<br>(កំណត់សម្គាល់ ២.៤(iii)) | ២០២២<br>ដុល្លារអាមេរិក<br>(កំណត់សម្គាល់ ២.៤(iii)) |
|---|---|---|---|---|
| ឥណទានផ្តល់ដល់បុគ្គលិក គណៈគ្រប់គ្រងសំខាន់ៗ | ៤.៣៦៩.៦៤៤ | ២.៧២៥.៥៧៦ | ១.០៦៩.៦៨០ | ៦៦២.០៣០ |
| ចំណូលពីការប្រាក់ | ២៥៩.១៦០ | ២៥៣.៤៥៩ | ៦៣.០៥៦ | ៦២.០១៦ |

ឥណទាន និងបុរេប្រទានផ្តល់ដល់បុគ្គលិកគណៈគ្រប់គ្រងសំខាន់ៗ មានការធានា និងមានអត្រាការប្រាក់ពី ៦,៧៨% ទៅ ១៤,៤០% (ឆ្នាំ២០២២៖ ៨,៣០% ទៅ ១២,០០%) ក្នុងមួយឆ្នាំ។ សំវិធានធនលើការខាតបង់ឥណទានដែលបានរំពឹងទុក សម្រាប់ឥណទានផ្តល់ដល់សម្ព័ន្ធញាតិ ត្រូវបានទទួលស្គាល់ក្នុងអំឡុងការិយបរិច្ឆេទមានចំនួន ៤.៥៤១ ពាន់រៀល (ឆ្នាំ២០២២៖ ៤.១៨៤ ពាន់រៀល)។




# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

## ៣៥. ប្រតិបត្តិការសម្ព័ន្ធញាតិ (ត)

### គ. គណនីត្រូវទូទាត់ទៅសម្ព័ន្ធញាតិ

| | ២០២៣<br>ពាន់រៀល | ២០២២<br>ពាន់រៀល | ២០២៣<br>ដុល្លារអាមេរិក<br>(កំណត់សម្គាល់ ២.៤(iii)) | ២០២២<br>ដុល្លារអាមេរិក<br>(កំណត់សម្គាល់ ២.៤(iii)) |
|---|---|---|---|---|
| គណនីត្រូវទូទាត់ទៅក្រុមហ៊ុន សម្ព័ន្ធញាតិ | ១.១៤០.៧៨១ | ៤៨០.០១៧ | ២៧៩.២៦១ | ១១៦.៥៩៤ |

គណនីត្រូវទូទាត់ទៅក្រុមហ៊ុនសម្ព័ន្ធញាតិ ពុំមានការធានា និងពុំមានការប្រាក់ទេ។

### ឃ. ប្រាក់បញ្ញើពីសម្ព័ន្ធញាតិ

| | ថ្ងៃទី៣១ ខែធ្នូ | | ថ្ងៃទី៣១ ខែធ្នូ | |
|---|---|---|---|---|
| | ឆ្នាំ២០២៣<br>ពាន់រៀល | ឆ្នាំ២០២២<br>ពាន់រៀល | ឆ្នាំ២០២៣<br>ដុល្លារអាមេរិក<br>(កំណត់សម្គាល់ ២.៤(iii)) | ឆ្នាំ២០២២<br>ដុល្លារអាមេរិក<br>(កំណត់សម្គាល់ ២.៤(iii)) |
| ភាគទុនិក | ៩៥.៧៧១ | ២១៥.២១១ | ២៣.៤៤៥ | ៥២.២៧៤ |
| ក្រុមប្រឹក្សាភិបាល | ១.៩៣៦.៥៣៩ | ១.៧០៦.៦៩៨ | ៤៧៤.០៦១ | ៤១៤.៥៤៩ |
| គណៈគ្រប់គ្រងសំខាន់ៗ | ១៣.៩១២.៤៦៤ | ៩.០៣០.៤៩២ | ៣.៤០៥.៧៤៤ | ២.១៩៣.៤៦៤ |
| ក្រុមហ៊ុនសម្ព័ន្ធញាតិ | ១៨៧.០០៣ | ១.៧១០.៧៦៣ | ៤៥.៧៧៨ | ៤១៥.៥៣៦ |
| | ១៦.១៣១.៧៧៧ | ១២.៦៦៣.១៦៤ | ៣.៩៤៩.០២៨ | ៣.០៧៥.៨២៣ |
| ការប្រាក់ដែលត្រូវបង់ | ៤០៣.៨១២ | ១៨៧.១៨៧ | ៩៨.៨៥២ | ៤៥.៤៦៧ |
| ចំណាយលើការប្រាក់ | ៨៧៨.៨០៥ | ៤៩៣.៦៦២ | ២១៣.៨២១ | ១២០.៧៨៨ |

អត្រាការប្រាក់ប្រចាំឆ្នាំ ក្នុងអំឡុងការិយបរិច្ឆេទនេះ មានដូចខាងក្រោម៖

| | ថ្ងៃទី៣១ ខែធ្នូ | |
|---|---|---|
| | ឆ្នាំ២០២៣ | ឆ្នាំ២០២២ |
| ភាគទុនិក | ៣,០០%-៨,៥០% | ៣,០០% |
| ក្រុមប្រឹក្សាភិបាល | ៣,០០%-៨,៧៥% | ៣,០០%–៧,៩០% |
| គណៈគ្រប់គ្រងសំខាន់ៗ | ១,០០%–៩,១៣% | ១,០០%–៩,០០% |
| ក្រុមហ៊ុនសម្ព័ន្ធញាតិ | ១,០០%–៣,០០% | ៣,០០% |

## អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

### ៣៥. ប្រតិបត្តិការសម្ព័ន្ធញាតិ (ត)

#### ង. ប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ

| | ២០២៣<br>ពាន់រៀល | ២០២២<br>ពាន់រៀល | ២០២៣<br>ដុល្លារអាមេរិក<br>(កំណត់សម្គាល់ ២.៤(iii)) | ២០២២<br>ដុល្លារអាមេរិក<br>(កំណត់សម្គាល់ ២.៤(iii)) |
|---|---|---|---|---|
| *(i) ចំណូលពីក្រុមហ៊ុនសម្ព័ន្ធញាតិ៖* | | | | |
| ចំណូលពីការជួល | ៥៧.៩៥១ | ៦៥.៧១៩ | ១៤.១០០ | ១៦.០៨០ |
| ចំណូលពីកម្រៃសេវាគ្រប់គ្រង | ១៩០.៣៣០ | ២០២.៤៥៨ | ៤៦.៣០៩ | ៤៩.៥៣៧ |
| ចំណូលពីកម្រៃសេវាកម្ម ផ្នែកព័ត៌មានវិទ្យា | ៧១.៨៣០ | ១៩.៨៥១ | ១៧.៤៧៧ | ៤.៨៥៧ |
| | ៣២០.១១១ | ២៨៨.០២៨ | ៧៧.៨៨៦ | ៧០.៤៧៤ |
| *(ii) ចំណាយ/ការទូទាត់ទៅក្រុមហ៊ុនសម្ព័ន្ធញាតិ៖* | | | | |
| កម្រៃអាជ្ញាប័ណ្ណ | ៦៣០.៨៣៦ | ៥៥១.២៧១ | ១៥៣.៤៨៨ | ១៣៤.៨៨៤ |
| កម្រៃលើការប្រឹក្សា និង ការគាំទ្រផ្នែកព័ត៌មានវិទ្យា | ៨៥៤.៨៣៧ | ៧៥៥.៦៩៨ | ២០៧.៩៩២ | ១៨៤.៩០៣ |
| ចំណាយលើការជួល | ៦.៧៨២ | ២៦.៩៧៤ | ១.៦៥០ | ៦.៦០០ |
| ចំណូលពីកម្រៃជើងសា | ៤.៣៦២.៣៦៦ | ១.៦៩៣.៨១៨ | ១.០៦១.៥០៣ | ៤១៤.៤៤០ |
| | ៥.៨៥៤.៨២១ | ៣.០២៧.៧៦១ | ១.៤២៤.៦៣៣ | ៧៤០.៨២៧ |

ប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ ត្រូវបានធ្វើឡើងក្នុងលក្ខខណ្ឌពាណិជ្ជកម្មធម្មតា និងតាមអត្រាទីផ្សារ។

#### ឆ. ប្រាក់លាភការរបស់អ្នកគ្រប់គ្រងសំខាន់ៗ

| | ២០២៣<br>ពាន់រៀល | ២០២២<br>ពាន់រៀល | ២០២៣<br>ដុល្លារអាមេរិក<br>(កំណត់សម្គាល់ ២.៤(iii)) | ២០២២<br>ដុល្លារអាមេរិក<br>(កំណត់សម្គាល់ ២.៤(iii)) |
|---|---|---|---|---|
| កម្រៃរបស់អភិបាល | ៧៨៩.៨២៥ | ៧៣៥.៥១៥ | ១៩២.១៧២ | ១៧៩.៩៦៥ |
| ប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍ផ្សេងៗ របស់គណៈគ្រប់គ្រងសំខាន់ៗ | ១២.៦០៥.៩៨៧ | ១១.៣១០.៦២៥ | ៣.០៦៧.១៥០ | ២.៧៦៧.៤៦៤ |
| | ១៣.៣៩៥.៨១២ | ១២.០៤៦.១៤០ | ៣.២៥៩.៣២២ | ២.៩៤៧.៤២៩ |





## អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

### ៣៦. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

ក្រុមហ៊ុនបានរួមបញ្ចូលការគ្រប់គ្រងហានិភ័យជាផ្នែកមួយនៃអាជីវកម្ម ប្រតិបត្តិការ និងដំណើរនៃការសម្រេចចិត្តរបស់ក្រុមហ៊ុន។ ក្នុងការធ្វើឲ្យប្រាកដថាក្រុមហ៊ុនសម្រេចបាននូវផលចំណេញខ្ពស់បំផុត ទន្ទឹមនឹងពេលធ្វើប្រតិបត្តិការក្នុងបរិយាកាសអាជីវកម្មល្អ ក្រុមការងារផ្នែកគ្រប់គ្រងហានិភ័យបានចូលរួមតាំងពីដំណាក់កាលដំបូងក្នុងដំណើរការទទួលយកហានិភ័យ ដោយផ្តល់នូវការចូលរួមដោយឯករាជ្យ រួមមានរបាយការណ៍វាយតម្លៃពាក់ព័ន្ធ ការវាយតម្លៃឥណទាន ការវាយតម្លៃលើផលិតផលថ្មី និងកំណត់បរិមាណតម្រូវការដើមទុន។ ការចូលរួមទាំងនេះជួយជម្រុញឲ្យផ្នែកអាជីវកម្មផ្សេងៗធ្វើការ វាយតម្លៃហានិភ័យធៀបនឹងផលចំណេញក្នុងផែនការអាជីវកម្មរបស់ពួកគេ ដូចនេះធ្វើឲ្យហានិភ័យត្រូវបានកំណត់តម្លៃសមស្របពាក់ព័ន្ធនឹងផលចំណេញ។

ជាទូទៅ គោលដៅនៃសកម្មភាពក្នុងការគ្រប់គ្រងហានិភ័យរបស់ក្រុមហ៊ុន គឺដើម្បី៖

- កំណត់ពីហានិភ័យផ្សេងៗ និងតម្រូវការដើមទុន
- ធានាថាសកម្មភាពទទួលយកហានិភ័យ មានភាពស្របគ្នាជាមួយនឹងគោលការណ៍ហានិភ័យ ហើយស្ថានភាពនៃបណ្តុំហានិភ័យ គឺស្ថិតក្នុងកម្រិតហានិភ័យ ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល និង
- បង្កើតតម្លៃរបស់ភាគទុនិក តាមរយៈក្របខណ្ឌនៃការគ្រប់គ្រងហានិភ័យដ៏ល្អ។

## អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

### ៣៦. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

| | ថ្ងៃទី៣១ ខែធ្នូ | | ថ្ងៃទី៣១ ខែធ្នូ | |
|---|---|---|---|---|
| | ឆ្នាំ២០២៣ | ឆ្នាំ២០២២ | ឆ្នាំ២០២៣ | ឆ្នាំ២០២២ |
| | ពាន់រៀល | ពាន់រៀល | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| | | | (កំណត់សម្គាល់ ២.៤(iii)) | (កំណត់សម្គាល់ ២.៤(iii)) |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែង តាមរំលស់ថ្លៃដើម | | | | |
| សាច់ប្រាក់ក្នុងដៃ | ១២៤.៣៧២.០០៨ | ១០៦.៨០៩.៨៥០ | ៣០.៩៧៦.០២៤ | ២៥.៩៤៣.៦១២ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារជាតិនៃកម្ពុជា | ១៣៤.១៩២.២២៤ | ១៩៤.៨៥៣.៣៩៣ | ៣២.៨៩៩.៩៩៤ | ៤៧.៣២៨.៩៧៦ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារនានា | ៦៧២.២៨៧.៤៨៦ | ៣៧១.៩៨៨.៩៥៩ | ១៦៤.៥៧៤.៦៦០ | ៩០.៣៥៤.៣៧២ |
| ឥណទាន និងបុរេប្រទាន តាមរំលស់ថ្លៃដើម | ៥.០០៣.១៣៩.៣៧៦ | ៥.០០៦.៧២៤.៤៧៣ | ១.២២៤.៧៥៨.៧២១ | ១.២១៦.១០៩.៩០៤ |
| ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗ | ៥.៤០៦.០៧៤ | ៤.៦៩១.៥៦៤ | ១.៣២៣.៣៩៦ | ១.១៣៩.៥៥៩ |
| | ៥.៩៣៩.៣៩៧.១៦៨ | ៥.៦៨៥.០៦៨.២២៩ | ១.៤៥៣.៩៥២.៧៩៥ | ១.៣៨០.៨៧៦.៤២៣ |
| ទ្រព្យសកម្មហិរញ្ញវត្ថុតាមតម្លៃ សមស្របក្នុងលទ្ធផលលម្អិតផ្សេងៗ | ៦១.២៧៥ | ៦១.៧៥៥ | ១៥.០០០ | ១៥.០០០ |
| ទ្រព្យសកម្មហិរញ្ញវត្ថុសរុប | ៥.៩៣៩.៤៥៨.៤៤៣ | ៥.៦៨៥.១២៩.៩៨៤ | ១.៤៥៣.៩៦៧.៧៩៥ | ១.៣៨០.៨៩១.៤២៣ |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| បំណុលហិរញ្ញវត្ថុតាមរំលស់ថ្លៃដើម | | | | |
| ប្រាក់បញ្ញើរបស់ធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | ១៩៣.៥៧៥.៨៦២ | ១២១.៩៦០.៦៥២ | ៤៧.៣៨៦.៩៩២ | ២៩.៦២៣.៦៧១ |
| ប្រាក់បញ្ញើរបស់អតិថិជន | ៣.៤៩៨.៩២៨.៥៧៥ | ៣.០៣៦.៤៩៦.៧៥៥ | ៨៥៦.៥៣០.៨៦៣ | ៧៣៧.៥៥០.៨២៧ |
| ប្រាក់កម្ចី | ៨៨៩.០៩៦.១០០ | ១.២៦៩.៦៥០.៥៤៣ | ២១៦.៤២៤.៩៩៩ | ៣០៨.៣៩២.១៦៥ |
| អនុបំណុល | ២៥៣.៧៥៣.១៧៥ | ៣១៤.១៧៩.២៦៨ | ៦២.១១៨.២៨០ | ៧៦.៣១២.៦៧១ |
| បំណុលភតិសន្យា | ២៧.៤៨១.៦៦៦ | ២៦.៣៩១.៧២៧ | ៦.៧២៧.៤៥៨ | ៦.៣៩៨.២៨២ |
| បំណុលហិរញ្ញវត្ថុផ្សេងៗ | ៤.១១៤.៨៩៩ | ៣.៤០១.៥០៣ | ១.០០៧.៣១៩ | ៨២៦.២០៩ |
| បំណុលហិរញ្ញវត្ថុសរុប | ៤.៨៦១.៩៥០.២៧៧ | ៤.៧៧២.០៣០.៤៤៨ | ១.១៩០.១៩៥.៩០៦ | ១.១៥៩.១០៣.៨២៥ |
| ទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធ | ១.០៧៧.៥០៨.១៦៦ | ៩១៣.០៩៩.៥៣៦ | ២៦៣.៧៧១.៨៨៩ | ២២១.៧៨៧.៥៩៨ |





## អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

### ៣៦. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

#### ៣៦.១ ហានិភ័យឥណទាន

ហានិភ័យឥណទានគឺជាហានិភ័យដែលធ្វើឲ្យមានការខាតបង់ផ្នែកហិរញ្ញវត្ថុ ប្រសិនបើអតិថិជនរបស់ក្រុមហ៊ុន ឬភាគីដៃគូក្នុងទីផ្សារ ខកខានមិនបានបំពេញកាតព្វកិច្ចសងប្រាក់ទៅតាមកិច្ចសន្យាឲ្យក្រុមហ៊ុន។ ហានិភ័យឥណទានកើតមកពីប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា និងធនាគារ ឥណទាន និងបុរេប្រទាន ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗ កិច្ចសន្យាផ្តល់ឥណទាន និងកិច្ចសន្យាធានាផ្នែកហិរញ្ញវត្ថុ។ ហានិភ័យឥណទានភាគច្រើនកើតមកពីសកម្មភាពផ្តល់ប្រាក់កម្ចី។

#### (ក) ការវាស់វែងហានិភ័យឥណទាន

ហានិភ័យឥណទានត្រូវបានគ្រប់គ្រងតាមមូលដ្ឋានជាក្រុម។

ចំពោះឥណទាន និងបុរេប្រទាន និងកិច្ចសន្យាផ្តល់ឥណទាន ការប៉ាន់ស្មានហានិភ័យឥណទានក្នុងគោលដៅគ្រប់គ្រងហានិភ័យ តម្រូវឲ្យប្រើប្រាស់គំរូ ដោយសារហានិភ័យមានភាពខុសប្លែកគ្នាទៅតាមបម្រែបម្រួលលក្ខខណ្ឌលើទីផ្សារលំហូរទឹកប្រាក់រំពឹងទុក និងពេលវេលាដែលកន្លងផុត។ ការវាយតម្លៃហានិភ័យឥណទាននៃសំណុំឥណទានមួយ តម្រូវឲ្យមានការប៉ាន់ស្មានបន្ថែមទៀត ដូចជា លទ្ធភាពនៃការមិនសងប្រាក់នៃអនុបាតការខាតបង់ពាក់ព័ន្ធ និងការមិនសងប្រាក់ទៅវិញទៅមករវាងភាគីដៃគូ។ ក្រុមហ៊ុនវាស់វែងហានិភ័យឥណទានដោយប្រើប្រូបាបនៃការមិនសងប្រាក់ (PD) ចំនួនដែលមានហានិភ័យមិនសង (EAD) និងការខាតបង់នៅពេលមិនមានការសងប្រាក់ (LGD) ក្នុងការវាស់វែងការខាតបង់ឥណទានរំពឹងទុក (ECL) ក្រោម ស.រ.ទ.ហ.អ.ក ៩។

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា និងធនាគារត្រូវបានចាត់ទុកថាជាហានិភ័យឥណទានទាប។ ការវាយតម្លៃឥណទាននៃទ្រព្យសកម្មទាំងនេះត្រូវបានត្រួតពិនិត្យសម្រាប់ឱនភាពនៃតម្លៃឥណទាន។ ការវាស់វែងសម្រាប់ឱនភាពនៃតម្លៃ ត្រូវបានកំណត់ចំពោះការខាតបង់ឥណទានដែលរំពឹងទុករយៈពេល១២ខែ។ ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗ ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ត្រូវបានត្រួតពិនិត្យសម្រាប់ឱនភាពនៃតម្លៃចំណាត់ថ្នាក់ឥណទាន ហើយការវាស់វែងនៃឱនភាពនៃតម្លៃនេះអនុវត្តតាមវិធីសាស្ត្របីដំណាក់កាលនៅក្នុងកំណត់សម្គាល់ ៣៦.១ (គ)។

#### (ខ) ការគ្រប់គ្រងកម្រិតហានិភ័យ និងគោលនយោបាយកាត់បន្ថយហានិភ័យ

ក្រុមហ៊ុនធ្វើប្រតិបត្តិការ និងផ្តល់ឥណទាន និងបុរេប្រទានជូនអតិថិជនជាឯកត្តជន ឬសហគ្រាសនានាក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនគ្រប់គ្រងកម្រិតហានិភ័យ និងផ្តោតការយកចិត្តទុកដាក់លើហានិភ័យឥណទាន នៅពេលដែលហានិភ័យត្រូវបានរកឃើញ។

## អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

### ៣៦. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

#### ៣៦.១ ហានិភ័យឥណទាន (ត)

(ខ) ការគ្រប់គ្រងកម្រិតហានិភ័យ និងគោលនយោបាយកាត់បន្ថយហានិភ័យ (ត)

ក្រុមហ៊ុនបានប្រើប្រាស់គោលការណ៍ និងការអនុវត្តជាច្រើន ដើម្បីកាត់បន្ថយហានិភ័យឥណទាន។ គោលការណ៍ដែលមានប្រសិទ្ធភាពបំផុតក្នុងចំណោមគោលការណ៍ទាំងអស់នេះ គឺការធានាដោយដាក់វត្ថុបញ្ចាំលើឥណទាន និងបុរេប្រទានផ្តល់ជូន អតិថិជន ដែលជាការអនុវត្តទូទៅ។ ក្រុមហ៊ុនអនុវត្តគោលការណ៍ណែនាំស្តីពីការទទួលយកនូវចំណាត់ថ្នាក់ជាក់លាក់នៃវត្ថុបញ្ចាំ ឬការកាត់បន្ថយហានិភ័យឥណទាន។ ប្រភេទនៃវត្ថុបញ្ចាំសំខាន់ៗ ដើម្បីធានាឥណទាន និងបុរេប្រទានអតិថិជន មានដូចជា៖

- វត្ថុបញ្ចាំជាទ្រព្យសកម្មក្នុងលក្ខណៈជាលំនៅដ្ឋាន (មានដីធ្លី អគារ និងទ្រព្យសកម្មផ្សេងៗ)
- ចលនទ្រព្យ
- សាច់ប្រាក់ក្នុងទម្រង់ជាប្រាក់បញ្ញើមានកាលកំណត់ ប្រសិនបើមាន

(គ) គោលនយោបាយឱនភាពនៃតម្លៃ (ការខាតបង់ឥណទានដែលបានរំពឹងទុក)

ការវាស់វែងសំវិធានធនសម្រាប់ការខាតបង់ឥណទានដែលបានរំពឹងទុក ក្រោមវិធីសាស្ត្របីដំណាក់កាលរបស់ ស.រ.ហ.អ.ក ៩ គឺដើម្បីទទួលស្គាល់សំវិធានធនសម្រាប់ការខាតបង់ឥណទានដែលបានរំពឹងទុកពេញមួយអាយុកាល ចំពោះឧបករណ៍ហិរញ្ញវត្ថុដែលមានកំណើនហានិភ័យឥណទានជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង ឬឧបករណ៍ហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃឥណទាន នាកាលបរិច្ឆេទរាយការណ៍។ ឧបករណ៍ហិរញ្ញវត្ថុដែលមិនទាន់មានឱនភាពនៃតម្លៃគួរឲ្យកត់សម្គាល់ក្នុងហានិភ័យឥណទាននឹងត្រូវបានទទួលស្គាល់ក្នុងសំវិធានធនសម្រាប់ការខាតបង់ឥណទានដែលបានរំពឹងទុក ១២ខែ។

ក្រោមវិធីសាស្ត្របីដំណាក់កាល ឧបករណ៍ហិរញ្ញវត្ថុត្រូវបានបែងចែកជាបីដំណាក់កាល អាស្រ័យទៅតាមបម្រែបម្រួលដែលពាក់ព័ន្ធ នៅក្នុងហានិភ័យឥណទាន។

- ដំណាក់កាលទី១ រួមមានឧបករណ៍ហិរញ្ញវត្ថុដែលមិនមានកំណើនហានិភ័យឥណទានជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង និងមិនមានឱនភាពនៃតម្លៃឥណទាននាកាលបរិច្ឆេទរាយការណ៍។ ចំពោះទ្រព្យសកម្មទាំងនេះ ត្រូវបានទទួលស្គាល់ក្នុងសំវិធានធនសម្រាប់ការខាតបង់ឥណទានដែលបានរំពឹងទុក ១២ខែ។





## អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

### ៣៦. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

#### ៣៦.១ ហានិភ័យឥណទាន (ត)

(គ) គោលនយោបាយឱនភាពនៃតម្លៃ (ការខាតបង់ឥណទានដែលបានរំពឹងទុក) (ត)

- ដំណាក់កាលទី២ រួមមានឧបករណ៍ហិរញ្ញវត្ថុដែលមានកំណើនហានិភ័យឥណទានជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង ប៉ុន្តែមិនមានភស្តុតាងជាក់ស្តែងបង្ហាញថាមានឱនភាពនៃតម្លៃ។ ចំពោះទ្រព្យសកម្មទាំងនេះ ត្រូវបានទទួលស្គាល់ក្នុងសំវិធានធនសម្រាប់ការខាតបង់ឥណទានដែលបានរំពឹងទុកពេញមួយអាយុកាល។
- ដំណាក់កាលទី៣ រួមមានឧបករណ៍ហិរញ្ញវត្ថុដែលមានភស្តុតាងជាក់ស្តែងបង្ហាញថាមានឱនភាពនៃតម្លៃនាកាលបរិច្ឆេទរាយការណ៍។ ចំពោះទ្រព្យសកម្មទាំងនេះ ត្រូវបានទទួលស្គាល់ក្នុងសំវិធានធនសម្រាប់ការខាតបង់ឥណទានដែលបានរំពឹងទុកពេញមួយអាយុកាល។
- ការទិញទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃឥណទាន ឬទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃឥណទានពីដំបូង គឺជាទ្រព្យសកម្មហិរញ្ញវត្ថុទាំងឡាយណាដែលមានឱនភាពនៃតម្លៃ ឥណទាន ចាប់តាំងពីការទទួលស្គាល់លើកដំបូង។ សំវិធានធនសម្រាប់ការខាតបង់ឥណទានដែលបានរំពឹងទុកតែងតែត្រូវបានវាស់វែងតាមមូលដ្ឋានពេញមួយអាយុកាល (ដំណាក់កាលទី ៣)។

ការវិនិច្ឆ័យ និងការសន្មតសំខាន់ៗ ដែលក្រុមហ៊ុនបានអនុវត្តទៅតាមតម្រូវការនានារបស់ស្តង់ដា ក្នុងការវាស់វែងសំវិធានធន មានដូចខាងក្រោម៖

(i) កំណើនហានិភ័យឥណទានជាសារវន្ត ("SICR")

ការប៉ាន់ស្មាន SICR គឺជាការវិភាគពហុកត្តា និងការវិភាគជារួម អាស្រ័យទៅលើការរួមបញ្ចូលគ្នារវាងបរិមាណ និង/ឬ គុណភាពនៃព័ត៌មាន។ ដើម្បីកំណត់ថាតើហានិភ័យនៃការមិនសងប្រាក់ចំពោះឥណទាន/ហិរញ្ញប្បទានបានកើនឡើងជាសារវន្ត ឬទេចាប់តាំងពីការទទួលស្គាល់លើកដំបូង ហានិភ័យនៃការមិនសងប្រាក់នាពេលបច្ចុប្បន្ន ត្រូវបានប្រៀបធៀបជាមួយនឹងហានិភ័យនៃការមិនសងប្រាក់នាពេលទទួលស្គាល់លើកដំបូង។ កូនបំណុលម្នាក់ ត្រូវបានចាត់ទុកថាមានកំណើនហានិភ័យឥណទានជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង ប្រសិនបើហួសកាលកំណត់សងលើសពី ៣០ថ្ងៃសម្រាប់ហ្វាស៊ីលីធីរយៈខ្លី និងហួសកាលកំណត់សងលើសពី ៩០ថ្ងៃ សម្រាប់ហ្វាស៊ីលីធីរយៈវែង។

# អេសអេចអេចស៊ី (ខេមបូឌា) ភីអេលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ៣៦. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៦.១ ហានិភ័យឥណទាន (ត)

**(គ) គោលនយោបាយឱនភាពនៃតម្លៃ (ការខាតបង់ឥណទានដែលបានរំពឹងទុក) (ត)**

(ii) និយមន័យនៃការមិនសងប្រាក់ និងឱនភាពនៃតម្លៃឥណទាន

ក្រុមហ៊ុនកំណត់ថាឧបករណ៍ហិរញ្ញវត្ថុមួយស្ថិតក្នុងចំណាត់ថ្នាក់មិនសងប្រាក់ និងមានឱនភាពនៃតម្លៃឥណទាន នៅពេលដែលឧបករណ៍ហិរញ្ញវត្ថុនោះស្របទៅតាមលក្ខណៈវិនិច្ឆ័យណាមួយ ដូចខាងក្រោម៖

- ប្រាក់ដើម ឬការប្រាក់ ឬទាំងប្រាក់ដើម និងការប្រាក់នៃឥណទាន ហួសកំណត់សងលើសពី៩០ថ្ងៃ ឬ ៣ខែ ឬ
- ចំនួនទឹកប្រាក់ហួសកាលកំណត់សង ឬចំនួនទឹកប្រាក់ដែលនៅមិនទាន់ទូទាត់ លើសពីកម្រិតដែលបានអនុម័តក្នុងរយៈពេល ៩០ថ្ងៃ ឬ ៣ខែ ឬតិចជាងនេះ នោះការបង្ហាញអំពីចំណុចខ្សោយនៃឥណទានត្រូវបានទម្លាក់ចំណាត់ថ្នាក់ទៅក្នុងចំណាត់ថ្នាក់ហានិភ័យខ្ពស់ដែលមានឱនភាពនៃតម្លៃ ឬ
- នៅពេលដែលអ្នកជាប់កាតព្វកិច្ច/គូភាគីឥណទានជាមួយក្រុមហ៊ុន ហើយកាតព្វកិច្ចឆ្លងត្រូវបានអនុវត្តការវាយតម្លៃនៃសំវិធានធន គឺត្រូវបានទាមទារនៅក្រោមការលុបចោលកាតព្វកិច្ចបំណុលមួយបង្កឲ្យមានការពន្យារលើកាតព្វកិច្ចបំណុលផ្សេងទៀត (ឆ្លងលំនាំដើម)។ នៅពេលដែលមិនមានសិទ្ធិកំណត់ឃ្លានេះទេ ការវាយតម្លៃនៃសំវិធានធន ចាំបាច់ត្រូវអនុវត្តលើកម្រិតឥណទានឯកត្តជនជំនួសឲ្យកម្រិតអ្នកជាប់កាតព្វកិច្ចរួម/គូភាគី។
- ការលុបចោល/ជម្រះបញ្ជីគណនី។

(iii) ការវាស់វែង (ECL - លទ្ធផលវិធីសាស្ត្រក្នុងការសន្មត និងការប៉ាន់ស្មាន)

ECL ត្រូវបានវាស់វែងតាមមូលដ្ឋាន ១២ខែ ឬតាមមូលដ្ឋានពេញមួយអាយុកាល អាស្រ័យទៅតាមកំណើនហានិភ័យ ឥណទានជាសារវន្តដែលបានកើតឡើង ចាប់តាំងពីការទទួលស្គាល់លើកដំបូង ឬប្រសិនបើទ្រព្យសកម្មមួយត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃឥណទាន។ ECL ត្រូវបានវាយតម្លៃ និងវាស់វែងតាមមូលដ្ឋានរួម។

ចំពោះការវាយតម្លៃប្រមូលផ្តុំ ECL ត្រូវបានកំណត់ដោយធ្វើការប៉ាន់ស្មាន PD LGD និង EAD សម្រាប់ខែបន្ទាប់នាពេលអនាគត និងសម្រាប់ផ្នែករួម។ ធាតុទាំងបីនេះត្រូវបានគុណបញ្ចូលគ្នាដើម្បីគណនារក ECL សម្រាប់ឆ្នាំនីមួយៗនាពេលអនាគត ដែលបន្ទាប់មកត្រូវបានធ្វើអប្បហារត្រឡប់ទៅវិញនាកាលបរិច្ឆេទរាយការណ៍ និងត្រូវបានបូកបញ្ចូលគ្នាវិញ។ អត្រាអប្បហារដែលត្រូវបានប្រើក្នុងការគណនា ECL គឺជាអត្រាការប្រាក់មានប្រសិទ្ធភាពដំបូង ឬអត្រាដែលប្រហាក់ប្រហែល។


# អេសអេចអេចស៊ី (ខេមបូឌា) ភីអេលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ៣៦. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៦.១ ហានិភ័យឥណទាន (ត)

**(គ) គោលនយោបាយឱនភាពនៃតម្លៃ (ការខាតបង់ឥណទានដែលបានរំពឹងទុក) (ត)**


(iii) ការវាស់វែង (ECL - លទ្ធផលវិធីសាស្ត្រក្នុងការសន្មត និងការប៉ាន់ស្មាន) (ត)

*ប្រូបាបនៃការមិនសងប្រាក់*

PD គឺជាលទ្ធភាពដែលអតិថិជនម្នាក់មិនសងប្រាក់ចំពោះកាតព្វកិច្ចហិរញ្ញវត្ថុរបស់ខ្លួន ក្នុងរយៈពេល ១២ខែបន្ទាប់ (PD១២ខែ) ឬក្នុងរយៈពេលពេញមួយអាយុកាលដែលនៅសល់ (PD ពេញមួយអាយុកាល) របស់កាតព្វកិច្ចនោះ។

PD ១២ខែ និង PD ពេញមួយអាយុកាល គឺជាប្រូបាបរំពឹងទុកនៃចំណុចពេលនៃការមិនសងប្រាក់ ក្នុងរយៈពេល ១២ខែបន្ទាប់ និងរយៈពេលដែលនៅសល់នៃឧបករណ៍ហិរញ្ញវត្ថុ ដោយផ្អែកទៅលើលក្ខខណ្ឌនានាដែលមាននាកាលបរិច្ឆេទរាយការណ៍ និងលក្ខខណ្ឌសេដ្ឋកិច្ចនាពេលអនាគត ដែលប៉ះពាល់ដល់ហានិភ័យឥណទាន។

PD ត្រូវបានទាញយកមកដោយប្រើអត្រាមិនសងប្រាក់ក្នុងពេលកន្លងមក ដោយធ្វើនិយ័តកម្មទៅតាមព័ត៌មានព្យាករនាពេលអនាគត និងឆ្លុះបញ្ចាំងពីតថភាពសមាសធាតុនៃសំណុំឥណទាន និងទិន្នន័យទីផ្សារ។

ប្រភេទឥណទានទាំងឡាយណាដែលមិនមាន ទិន្នន័យនៃការមិនសងប្រាក់គ្រប់គ្រាន់ នោះគេប្រើប្រាស់ proxy PD ព្យាករនាពេលអនាគត។

*ចំនួនដែលមានហានិភ័យនៃការមិនសងប្រាក់*

EAD គឺជាចំនួនទឹកប្រាក់សរុបដែលក្រុមហ៊ុនមានហានិភ័យ នៅពេលដែលកូនបំណុលមិនសងប្រាក់ដែលនៅជំពាក់។

ចំពោះផលិតផលដែលត្រូវដករំលស់ និងឥណទានដែលត្រូវសងប្រាក់ទាំងស្រុង EAD ១២ខែ ឬពេញមួយអាយុកាល ត្រូវបានកំណត់អាស្រ័យទៅតាមទិន្នន័យការបង់ប្រាក់រំពឹងទុក ដែលជាការសងប្រាក់ក្នុងកិច្ចសន្យាដែលអ្នកខ្ចីប្រាក់នៅជំពាក់ ក្នុងរយៈពេល ១២ខែ ឬរយៈពេលកំណត់ដែលនៅសល់។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

## ៣៦. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៦.១ ហានិភ័យឥណទាន (ត)

**(គ) គោលនយោបាយឱនភាពនៃតម្លៃ (ការខាតបង់ឥណទានដែលបានរំពឹងទុក) (ត)**

(iii) ការវាស់វែង (ECL - លទ្ធផលវិធីសាស្ត្រក្នុងការសន្មត និងការប៉ាន់ស្មាន) (ត)

*ការខាតបង់នៅពេលដែលមិនមានការសងប្រាក់ (Loss Given Default)*

LGD គឺជាការរំពឹងទុករបស់ក្រុមហ៊ុនអំពីកំណើននៃការខាតបង់ចំពោះហានិភ័យនៃការមិនសងប្រាក់។ LGD មានភាពខុសប្លែកគ្នា អាស្រ័យទៅតាមប្រភេទភាគីដៃគូ ប្រភេទ និងអតីតភាពនៃសំណង និងទ្រព្យបញ្ចាំដែលមាន ឬការគាំទ្រឥណទានផ្សេងៗ។ LGD ត្រូវបានបង្ហាញដោយភាគរយនៃការខាតបង់ក្នុងមួយឯកតាហានិភ័យនាចំណុចពេលមិនសងប្រាក់។ LGD គឺជាភាគរយនៃការខាតបង់ដែលរំពឹងថាត្រូវបានបង្កើតឡើង ប្រសិនបើមានការមិនសងប្រាក់កើតឡើង លើរយៈពេលពេញមួយអាយុកាលរំពឹងទុកដែលនៅសល់របស់ឥណទាន។

LGDs ត្រូវបានកំណត់ដោយផ្អែកទៅលើកត្តាមួយចំនួន ដែលមានផលប៉ះពាល់ចំពោះទឹកប្រាក់ដែលប្រមូលបានមកវិញបន្ទាប់ពីការមិនសងប្រាក់មានច្រើនជាង ៩០%។ កត្តាទាំងនេះមានភាពខុសប្លែកពីគ្នាអាស្រ័យទៅតាមប្រភេទផលិតផល។

ចំពោះប្រភេទឥណទានដែលមិនមានទិន្នន័យមិនសងប្រាក់គ្រប់គ្រាន់ proxy LGD ត្រូវបានប្រើប្រាស់។

ការសន្មតដែលជាមូលដ្ឋានសម្រាប់ការគណនា ECL ត្រូវបានតាមដាន និងត្រួតពិនិត្យជាបន្តបន្ទាប់។ មិនមានការប្រែប្រួលជាសារវន្តណាមួយចំពោះវិធីសាស្ត្រនៃការប៉ាន់ស្មាន ឬការសន្មតជាក់លាក់ណាមួយ ត្រូវបានធ្វើឡើងក្នុងអំឡុងការិបរិច្ឆេទរាយការណ៍នេះទេ។

(iv) ព័ត៌មានព្យាករនាពេលអនាគតដែលត្រូវបានបញ្ចូលទៅក្នុងគំរូ ECL

ការគណនា ECL ត្រូវបានបញ្ចូលនូវព័ត៌មាននាពេលអនាគត។ ក្រុមហ៊ុនបានអនុវត្តការវិភាគក្នុងគ្រាមុន និងបានកត់សម្គាល់នូវអញ្ញត្រសេដ្ឋកិច្ចសំខាន់ៗដែលមានផលប៉ះពាល់លើហានិភ័យឥណទាន និងការខាតបង់ឥណទានដែលបានរំពឹងទុក សម្រាប់ប្រភេទឥណទាននីមួយៗ។





# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

## ៣៦. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៦.១ ហានិភ័យឥណទាន (ត)

**(គ) គោលនយោបាយឱនភាពនៃតម្លៃ (ការខាតបង់ឥណទានដែលបានរំពឹងទុក) (ត)**

(iv) ព័ត៌មានព្យាករនាពេលអនាគតដែលត្រូវបានបញ្ចូលទៅក្នុងគំរូ ECL (ត)

អញ្ញត្រសេដ្ឋកិច្ចសំខាន់ៗ និងផលប៉ះពាល់ពាក់ព័ន្ធរបស់វាចំពោះ PD មានភាពខុសប្លែកគ្នាទៅតាមឧបករណ៍ហិរញ្ញវត្ថុ។ ការវិនិច្ឆ័យរបស់អ្នកឯកទេស ក៏ត្រូវបានអនុវត្តនៅក្នុងដំណើរការនេះផងដែរ។ ការព្យាករក្នុងគ្រាកន្លងមកចំពោះអញ្ញត្រសេដ្ឋកិច្ចទាំងនេះ (សេណារីយ៉ូសេដ្ឋកិច្ចមូលដ្ឋាន) ត្រូវបានដកស្រង់ប្រភពមកពីការស្រាវជ្រាវខាងក្រៅ។ ផលប៉ះពាល់នៃអញ្ញត្រសេដ្ឋកិច្ចទាំងនេះ ចំពោះ PD ត្រូវបានកំណត់ដោយការអនុវត្តការវិភាគស្ថិតិត្រឡប់ថយក្រោយ ដើម្បីស្វែងយល់អំពីបម្រែបម្រួលនៃផលប៉ះពាល់នៅក្នុងអញ្ញត្រទាំងនេះដែលធ្លាប់មានប្រវត្តិនៃអត្រាមិនសងប្រាក់ នៅពេលដែល LGD ផ្អែកលើប្រវត្តិនៃការប្រមូលប្រាក់បានមកវិញបន្ទាប់ពីការមិនសងប្រាក់ និងអាស្រ័យទៅលើការពិចារណារបស់ក្រុមហ៊ុនចំពោះការប៉ាន់ស្មានតម្លៃវត្ថុបញ្ចាំតាមរយៈការកាត់បន្ថយវត្ថុបញ្ចាំ លើកលែងតែ ប្រភេទឥណទានជាក្រុម ដែលត្រូវបានដាក់បញ្ចូលនូវព័ត៌មានព្យាករនាពេលអនាគត និង EAD គឺផ្អែកលើទិន្នន័យការទូទាត់រំពឹងទុក។

បន្ថែមពីលើសេណារីយ៉ូដែលពឹងផ្អែកទៅលើសេដ្ឋកិច្ច ក្រុមហ៊ុនពិចារណាទៅលើលទ្ធភាពនៃសេណារីយ៉ូផ្សេងៗទៀត ជាមួយនឹងការការថ្លឹងសេណារីយ៉ូ។ ចំនួននៃសេណារីយ៉ូផ្សេងៗដែលត្រូវបានប្រើប្រាស់ត្រូវបានកំណត់ដោយពឹងផ្អែកទៅលើការវិភាគប្រភេទផលិតផលចម្បងនីមួយៗ ដើម្បីធានាថាមិនមានភាពមិនស្របគ្នា។ ចំនួនសេណារីយ៉ូ និងលទ្ធផលសន្មតរបស់វាត្រូវបានវាយតម្លៃនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ។ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ក្រុមហ៊ុនបានសន្និដ្ឋានថាមានសេណារីយ៉ូចំនួនបីដែលចាប់បាន ភាពមិនស្របគ្នាយ៉ាងសមស្រប។ ការថ្លឹងសេណារីយ៉ូ ត្រូវបានកំណត់ដោយការផ្គុំបញ្ចូលគ្នានៃការវិភាគស្ថិតិ និងការវិនិច្ឆ័យរបស់អ្នកជំនាញខាងផ្នែកឥណទាន ដោយគិតទៅលើលទ្ធភាពដែលអាចកើតមានឡើងមួយចំនួនដែលមានសេណារីយ៉ូនីមួយៗជាតំណាង។

ដើម្បីពិចារណាពីឥទ្ធិពលនៃការផ្លាស់ប្តូរនៅក្នុងសេដ្ឋកិច្ច និងបរិយាកាសខាងក្រៅលើឥណទាន និងបុរេប្រទានរបស់ក្រុមហ៊ុន អ្នកគ្រប់គ្រងបន្តពិនិត្យឡើងវិញនូវអថេរម៉ាក្រូសេដ្ឋកិច្ចជារៀងរាល់ត្រីមាស ដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន នៅក្នុងគំរូនាពេលអនាគតរបស់ក្រុមហ៊ុន។ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ អ្នកគ្រប់គ្រងបានធ្វើបច្ចុប្បន្នភាពអញ្ញត្រម៉ាក្រូសេដ្ឋកិច្ចចុងក្រោយបំផុតដែលមានរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។

## អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

### ៣៦. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

#### ៣៦.១ ហានិភ័យឥណទាន (ត)

(គ) គោលនយោបាយឱនភាពនៃតម្លៃ (ការខាតបង់ឥណទានដែលបានរំពឹងទុក) (ត)

(iv) ព័ត៌មាននាពេលអនាគតដែលត្រូវបានបញ្ចូលទៅក្នុងគំរូ ECL (ត)

ដោយបានឆ្លុះបញ្ចាំងពីលក្ខខណ្ឌសេដ្ឋកិច្ចចុងក្រោយបំផុតទៅក្នុងគំរូ ECL ដែលមានស្រាប់ អ្នកគ្រប់គ្រងកំណត់ថា ភាគរយនៃការថ្លឹងប្រូបាបសេណារីយ៉ូ គឺ ៧០% (ឆ្នាំ២០២២៖ ៦០%) សម្រាប់ករណីមូលដ្ឋាន ១៥% (ឆ្នាំ២០២២៖ ១០%) សម្រាប់ករណីល្អបំផុត និង ១៥% (ឆ្នាំ២០២២៖ ៣០%) សម្រាប់ករណីអាក្រក់បំផុត បានឆ្លុះបញ្ចាំងអំពីការព្យាករអំពីអនាគតនៃសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន ដែលត្រូវបានស្រង់ប្រភពមកពីវិទ្យាស្ថានស្រាវជ្រាវខាងក្រៅ។

ជាមួយនឹងការព្យាករផ្នែកសេដ្ឋកិច្ច ការធ្វើគម្រោង និងលទ្ធភាពដែលអាចកើតមានឡើងនានា គឺប្រឈមនឹងភាពមិនច្បាស់លាស់ពាក់ព័ន្ធក្នុងកម្រិតខ្ពស់ ដូចនេះ លទ្ធផលជាក់ស្តែងអាចមានភាពខុសគ្នាជាសារវន្តពីការធ្វើគម្រោងទាំងនេះ។ ក្រុមហ៊ុនពិចារណាទៅលើការព្យាករទាំងនេះ ដើម្បីបង្ហាញពីការប៉ាន់ស្មានល្អបំផុតទៅលើលទ្ធភាពដែលអាចកើតមានឡើង និងបានធ្វើការវិភាគទៅលើ ភាពមិនស្របគ្នា និងភាពមិនស៊ីមេទ្រីគ្នានៃប្រភេទឥណទានខុសៗគ្នារបស់ក្រុមហ៊ុន ដើម្បីកំណត់ថាសេណារីយ៉ូដែលត្រូវបានជ្រើសរើស គឺជាតំណាងដ៏សមស្របចំពោះសេណារីយ៉ូនានាដែលអាចកើតមានឡើង។

ផលប៉ះពាល់របស់ ECL មានដូចខាងក្រោម៖

| | ECL ឆ្នាំ២០២៣ ផ្អែកលើម៉ូដែលថ្មី ពាន់រៀល | ECL ឆ្នាំ២០២៣ ផ្អែកលើម៉ូដែលចាស់ ពាន់រៀល | ផលប៉ះពាល់លើ ប្រាក់ចំណេញមុនដកពន្ធលើប្រាក់ចំណេញ ពាន់រៀល |
|---|---|---|---|
| ឥណទានជាក្រុម | ៣២.៩៩៣.៦២១ | ៤០.៣៧៣.២៨២ | (៧.៣៧៩.៦៦១) |
| ឥណទានឯកត្តជន | ៥៥.៧៨៦.៩៤៣ | ៧៩.០៣២.៦៦៣ | (២៣.២៤៥.៧២០) |
| ឥណទានផ្តល់ដល់បុគ្គលិក | ៦១.៦២៤ | ៨០.៨០០ | (១៩.១៧៦) |
| **សរុប** | **៨៨.៨៤២.១៨៨** | **១១៩.៤៨៦.៧៤៥** | **(៣០.៦៤៤.៥៥៧)** |



## អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

### ៣៦. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

#### ៣៦.១ ហានិភ័យឥណទាន (ត)

(គ) គោលនយោបាយឱនភាពនៃតម្លៃ (ការខាតបង់ឥណទានដែលបានរំពឹងទុក) (ត)

(iv) ព័ត៌មាននាពេលអនាគតដែលត្រូវបានបញ្ចូលទៅក្នុងគំរូ ECL (ត)

*ការសន្មតអញ្ញត្រម៉ាក្រូសេដ្ឋកិច្ច*

ការថ្លឹងដែលត្រូវបានកំណត់ចំពោះសេណារីយ៉ូសេដ្ឋកិច្ចនីមួយៗ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ មានដូចខាងក្រោម៖

| | មូលដ្ឋាន % | ល្អបំផុត % | អាក្រក់បំផុត % |
|---|---|---|---|
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | | | |
| ការថ្លឹងប្រូបាបសេណារីយ៉ូ | ៧០% | ១៥% | ១៥% |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | | |
| ការថ្លឹងប្រូបាបសេណារីយ៉ូ | ៦០% | ១០% | ៣០% |

*ការវិភាគភាពរំញោច*

ក្រុមហ៊ុនបានប្រើអញ្ញត្រម៉ាក្រូសេដ្ឋកិច្ចខុសគ្នាជាគូ ចំពោះប្រភេទឥណទាននីមួយៗ ផ្អែកទៅតាមលទ្ធផលនៃការវិភាគស្ថិតិត្រឡប់ថយក្រោយ និងការវិនិច្ឆ័យរបស់អ្នកជំនាញ ដែលធ្វើឲ្យមានភាពច្បាស់លាស់ផ្នែកអាជីវកម្ម។ ក្រុមហ៊ុនធ្វើតេស្ត លើស្ថិតិជាប្រចាំ ទៅលើគំរូនាពេលអនាគតរបស់ក្រុមហ៊ុន និងបានធ្វើបច្ចុប្បន្នកម្មចំពោះគូនៃអញ្ញត្រម៉ាក្រូសេដ្ឋកិច្ច ដែលសមស្របសម្រាប់ការប្រើប្រាស់ ដោយផ្អែកទៅលើទិន្នន័យផ្អែកគុណភាព និងបរិមាណចុងក្រោយបំផុតដែលមាន។ គូនៃអញ្ញត្រម៉ាក្រូសេដ្ឋកិច្ចដែលបានប្រើប្រាស់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ មានដូចខាងក្រោម៖

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ៣៦. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៦.១ ហានិភ័យឥណទាន (ត)

(ត) គោលនយោបាយឱនភាពនៃតម្លៃ (ការខាតបង់ឥណទានដែលបានរំពឹងទុក) (ត)

(iv) ព័ត៌មាននាពេលអនាគតដែលត្រូវបានបញ្ចូលទៅក្នុងគំរូ ECL (ត)

*ការវិភាគភាពរំញោច (ត)*

| គំរូ | ប្រភេទឥណទាន | ២០២៣ | ២០២២ |
|---|---|---|---|
| PD | ឥណទានជាក្រុម | ភាពបាត់បង់ការងារ | ផលិតផលដុលក្នុងស្រុកសរុប ថេរឆ្នាំ ២០០០ |
| | | ការចំណាយលើការប្រើប្រាស់ផ្ទាល់ខ្លួន | ការវិនិយោគផ្ទាល់ពីបរទេស (% នៃ ផលិតផលដុលក្នុងស្រុកសរុប) |
| | ឥណទានឯកត្តជន | ដុល្លារអាមេរិក | ផលិតផលដុលក្នុងស្រុកសរុប ថេរឆ្នាំ ២០០០ |
| | | ការវិនិយោគផ្ទាល់ពីបរទេស (% នៃ ផលិតផលដុលក្នុងស្រុកសរុប) | ការវិនិយោគផ្ទាល់ពីបរទេស (% នៃ ផលិតផលដុលក្នុងស្រុកសរុប) |
| | ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន | ភាពបាត់បង់ការងារ | ផលិតផលដុលក្នុងស្រុកសរុប ថេរឆ្នាំ ២០០០ |
| | | G&S ផលិតផលដុលក្នុងស្រុកសរុប | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅកម្ពុជាទាំងអស់ ២០១០=១០០ |
| | ឥណទានកែលម្អគេហដ្ឋាន | ការវិនិយោគផ្ទាល់ពីបរទេស (% នៃ ផលិតផលដុលក្នុងស្រុកសរុប) | ការវិនិយោគផ្ទាល់ពីបរទេស (% នៃ ផលិតផលដុលក្នុងស្រុកសរុប) |
| | | ដុល្លារអាមេរិក | គ្មាន |
| | ឥណទានតាមរដូវកាល | សមតុល្យគណនីចរន្ត ផលិតផលដុលក្នុងស្រុកសរុប | ការនាំចេញសរុប |
| | | ការវិនិយោគផ្ទាល់ពីបរទេស (% នៃ ផលិតផលដុលក្នុងស្រុកសរុប) | ឥណទានអត្រាការប្រាក់ ១២ ខែ |
| | ឥណទានធុនតូច និងមធ្យម | ផលិតផលដុលក្នុងស្រុកសរុបថេរឆ្នាំ ២០០០ | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅប្រទេសកម្ពុជា (កត្តាមានបញ្ហាទាំងអស់នៅលើទីផ្សារ) |
| | ឥណទានផ្តល់ដល់បុគ្គលិក | ប្រេងឆៅ brent | ផលិតផលដុលក្នុងស្រុកសរុបថេរឆ្នាំ ២០០០ |
| | | ការចំណាយលើការប្រើប្រាស់ផ្ទាល់ខ្លួន | ការវិនិយោគផ្ទាល់ពីបរទេស (% នៃ ផលិតផលដុលក្នុងស្រុកសរុប) |
| LGD | ឥណទានជាក្រុម | គ្មាន | ការនាំចេញសរុប |
| | | គ្មាន | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅកម្ពុជាទាំងអស់ ២០១០=១០០ |






# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ៣៦. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៦.១ ហានិភ័យឥណទាន (ត)

(ត) គោលនយោបាយឱនភាពនៃតម្លៃ (ការខាតបង់ឥណទានដែលបានរំពឹងទុក) (ត)

(iv) ព័ត៌មាននាពេលអនាគតដែលត្រូវបានបញ្ចូលទៅក្នុងគំរូ ECL (ត)

*ការវិភាគភាពរំញោច (ត)*


តារាងខាងក្រោមនេះ គឺជាបម្រែបម្រួលដែលបានប៉ាន់ស្មានចំពោះ ECL សម្រាប់ការិបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដែលបណ្តាលមកពីការប្រែប្រួលអញ្ញត្រម៉ាក្រូសេដ្ឋកិច្ចពីការសន្មតជាក់ស្តែងដែលបានប្រើប្រាស់។ ការប្រែប្រួលអញ្ញត្រម៉ាក្រូសេដ្ឋកិច្ច ("MEVs") ត្រូវបានកំណត់ឲ្យប្រែប្រួលជាមួយនឹងគូរបស់វា ហើយវាត្រូវបានវិភាគរកចន្លោះនៃភាពប្រែប្រួលក្នុងគម្លាតស្តង់ដាមួយ ដែលជាលក្ខខណ្ឌផ្នែកស្ថិតិក្នុងការព្យាករអញ្ញត្រពីអញ្ញត្រម៉ាក្រូសេដ្ឋកិច្ចដែលបានព្យាកររួច។

| | ECL | | ECL | |
|---|---|---|---|---|
| | ២០២៣ ពាន់រៀល | ២០២២ ពាន់រៀល | ២០២៣ ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) | ២០២២ ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) |
| **ឥណទានជាក្រុម** | | | | |
| អញ្ញត្របន្ថែមទៅក្នុង MEVs | ១.៣៧១.១៩២ | ៧.៦៨៦.៨៧២ | ៣៣៥.៦៥៣ | ១.៨៦៧.១០៥ |
| អញ្ញត្រកាត់ចេញពី MEVs | ៥.២២០.២៥៩ | (១៥.១១៣.០២៥) | ១.២៧៧.៩០៩ | (៣.៦៧០.៨៨៣) |
| **ឥណទានឯកត្តជន** | | | | |
| អញ្ញត្របន្ថែមទៅក្នុង MEVs | ១.២៨១.៤៧៨ | ៤.៤០៦.៧៥៣ | ៣១៣.៧០៣ | ១.០៧០.៣៨០ |
| អញ្ញត្រកាត់ចេញពី MEVs | ១.២៨១.៤៧៨ | (៥.៤៩៧.៧៤២) | ៣១៣.៧០៣ | (១.៣៣៥.៣៧៦) |
| **ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន** | | | | |
| អញ្ញត្របន្ថែមទៅក្នុង MEVs | (៤.២២១.៥៧០) | ៤៥១.០៦២ | (១.០៣៣.៤៣២) | ១០៩.៥៦១ |
| អញ្ញត្រកាត់ចេញពី MEVs | ២.៨០៩.២៩៦ | (៥២៦.៨៤៣) | ៦៨៧.៧១០ | (១២៧.៩៦៨) |
| **ឥណទានកែលម្អគេហដ្ឋាន** | | | | |
| អញ្ញត្របន្ថែមទៅក្នុង MEVs | (២៤.៥៩២) | ៣៧៥.៩២៩ | (៦.០២០) | ៩១.៣១១ |
| អញ្ញត្រកាត់ចេញពី MEVs | ២១.៦៩២ | (៤៩៤.៩៦០) | ៥.៣១០ | (១២០.២២៣) |

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ៣៦. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៦.១ ហានិភ័យឥណទាន (ត)

**(គ) គោលនយោបាយឱនភាពនៃតម្លៃ (ការខាតបង់ឥណទានដែលបានរំពឹងទុក) (ត)**

(iv) ព័ត៌មាននាពេលអនាគតដែលត្រូវបានបញ្ចូលទៅក្នុងគំរូ ECL (ត)

*ការវិភាគភាពរំញោច (ត)*

| | ECL | | ECL | |
|---|---|---|---|---|
| | ២០២៣ ពាន់រៀល | ២០២២ ពាន់រៀល | ២០២៣ ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) | ២០២២ ដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) |
| **ឥណទានតាមរដូវកាល** | | | | |
| អញ្ញត្របន្ថែមទៅក្នុង MEVs | ៨៦៤.១៨១ | (១.៣២១) | ២១១.៥៥០ | (៣២១) |
| អញ្ញត្រកាត់ចេញពី MEVs | ៧៨៣.២៩១ | ២៤៧ | ១៩១.៧៤៨ | ៦០ |
| **ឥណទាន SME** | | | | |
| អញ្ញត្របន្ថែមទៅក្នុង MEVs | ២.៩២២.៣២៨ | ៤.០១៧.២៣៨ | ៧១៥.៣៨០ | ៩៧៥.៧៦៨ |
| អញ្ញត្រកាត់ចេញពី MEVs | (៦.០៦៦.៥៣៧) | (៨.០៧៥.១១៦) | (១.៤៨៥.០៧៦) | (១.៩៦១.៤០៨) |
| **ឥណទានបុគ្គលិក** | | | | |
| អញ្ញត្របន្ថែមទៅក្នុង MEVs | ២.៨៣៩ | ១៣.៨៣០ | ៦៩៥ | ៣.៣៥៩ |
| អញ្ញត្រកាត់ចេញពី MEVs | (៣.០៩៦) | (២៦.៣៩៧) | (៧៥៨) | (៦.៤១២) |

(v) ការដាក់ហានិភ័យជាក្រុម ចំពោះ ECL វាស់វែងតាមមូលដ្ឋានប្រមូលផ្តុំ

ចំពោះសំវិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុក ដែលយកគំរូតាមមូលដ្ឋានប្រមូលផ្តុំការប្រមូលផ្តុំហានិភ័យ ត្រូវបានធ្វើឡើងតាមមូលដ្ឋាននៃលក្ខណៈហានិភ័យជារួម ក៏ធ្វើបែបនេះហានិភ័យដែលស្ថិតនៅក្នុងក្រុមតែមួយគឺមានភាពដូចគ្នា។

ក្នុងការដាក់ជាក្រុម តម្រូវឲ្យមានព័ត៌មានគ្រប់គ្រាន់សម្រាប់ក្រុម ដើម្បីអាចប្រមូលស្ថិតិបាន។ ប្រសិនបើមិនមានព័ត៌មានផ្ទៃក្នុងគ្រប់គ្រាន់ទេ នោះក្រុមហ៊ុនបានពិចារណាទៅលើទិន្នន័យគោលខាងក្នុង/ខាងក្រៅបន្ថែមដើម្បីប្រើប្រាស់សម្រាប់ការធ្វើគំរូ។

ភាពសមស្របក្នុងការដាក់ជាក្រុម ត្រូវបានតាមដាន និងត្រួតពិនិត្យលើមូលដ្ឋានកាលកំណត់ដោយហានិភ័យឥណទាន។





អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

៣៦. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

៣៦.១ ហានិភ័យឥណទាន (ត)

(គ) គោលនយោបាយឱនភាពនៃតម្លៃ (ការខាតបង់ឥណទានដែលបានរំពឹងទុក) (ត)

(vi) គោលការណ៍ជម្រះចេញពីបញ្ជី

ការជម្រះចេញពីបញ្ជី ត្រូវបានធ្វើឡើងនៅពេលដែលសកម្មភាពនានាក្នុងការប្រមូលប្រាក់ ត្រូវបានធ្វើឡើងគ្រប់មធ្យោបាយរួចហើយ ឬនៅពេលដែលការប្រមូលប្រាក់បន្ថែមទៀតមិនអាចធ្វើទៅបាន ឬមិនអាចទទួលយកបានដោយភាពសមស្រប។ នៅពេលដែលឥណទាន ឬឧបករណ៍បំណុលត្រូវបានចាត់ទុកថាមិនអាចប្រមូលបាន វាត្រូវបានជម្រះចេញពីបញ្ជីក្នុងគណនីសំវិធានធន ឬគណនីថយចុះតម្លៃដែលពាក់ព័ន្ធ។ ឥណទាននោះត្រូវបានជម្រះចេញពីបញ្ជីទាំងស្រុង ឬត្រូវបានជម្រះចេញពីបញ្ជីមួយផ្នែកបន្ទាប់ពីគិតពិចារណាទៅលើតម្លៃដែលអាចលក់បានជាក់ស្តែងរបស់ទ្រព្យបញ្ចាំ (ប្រសិនបើមាន) និងនៅពេលដែលការ វិនិច្ឆ័យរបស់គណៈគ្រប់គ្រងយល់ឃើញថា មិនមានលទ្ធភាពក្នុងការប្រមូលប្រាក់មកវិញទេ។ ឥណទានដែលត្រូវជម្រះចេញពីបញ្ជីទាំងអស់ ត្រូវតែមានការអនុម័តដោយក្រុមប្រឹក្សាភិបាល ឬអាជ្ញាធរដែលបានទទួលសិទ្ធិ។

(vii) ការកែប្រែឥណទានឡើងវិញ

នៅពេលដែលមានការចរចាឡើងវិញ ឬបានកែប្រែលំហូរទឹកប្រាក់ក្នុងកិច្ចសន្យានៃឥណទានអតិថិជនឡើងវិញ។ នៅពេលដែលមានហេតុការណ៍នេះកើតឡើង ក្រុមហ៊ុនវាយតម្លៃថាតើខ្លឹមសារនៃលក្ខខណ្ឌថ្មីមានភាពខុសគ្នាជាសារវន្តពីលក្ខខណ្ឌដំបូង ឬទេ។ ក្រុមហ៊ុនធ្វើបែបនេះដោយគិតពិចារណាទៅលើកត្តាផ្សេងៗក្នុងចំណោមកត្តាជាច្រើន ដូចខាងក្រោម៖

- ប្រសិនបើអ្នកខ្ចីប្រាក់មានផលវិបាកផ្នែកហិរញ្ញវត្ថុ ហើយការកែប្រែពិតជាអាចជួយកាត់បន្ថយលំហូរទឹកប្រាក់ក្នុងកិច្ចសន្យា ឲ្យនៅត្រឹមចំនួនដែលអ្នកខ្ចីប្រាក់រំពឹងថាមានលទ្ធភាពបង់ប្រាក់។
- ថាតើមានលក្ខខណ្ឌថ្មីសំខាន់ៗត្រូវបានណែនាំ ដូចជាការបែងចែកប្រាក់ចំណេញ/ផលចំណេញដែលផ្អែកលើមូលធន ដែលមានផលប៉ះពាល់ជាសារវន្តលើទិន្នន័យហានិភ័យរបស់ឥណទាននោះ។
- ការពន្យារពេលឥណទានជាក់លាក់ នៅពេលដែលអ្នកខ្ចីប្រាក់មិនមានផលវិបាកផ្នែកហិរញ្ញវត្ថុ។
- ការប្រែប្រួលអត្រាការប្រាក់ជាក់លាក់។
- ការផ្លាស់ប្តូរប្រភេទរូបិយប័ណ្ណរបស់ឥណទាន។
- ការដាក់បញ្ចូលទ្រព្យបញ្ចាំ ការធានាផ្សេងៗ ឬការពង្រីកទំហំឥណទាន ដែលមានផលបះពាល់ជាសារវន្តលើហានិភ័យនៃឥណទាននោះ។

## អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

### ៣៦. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

#### ៣៦.១ ហានិភ័យឥណទាន (ត)

**(គ) គោលនយោបាយឱនភាពនៃតម្លៃ (ការខាតបង់ឥណទានរំពឹងទុក) (ត)**

(vii) ការកែប្រែឥណទានឡើងវិញ (ត)

បន្ទាប់ពីបានធ្វើការកែប្រែរួចហើយ ហានិភ័យនៃការមិនសងប្រាក់ពាក់ព័ន្ធនឹងឥណទានទាំងនេះ ត្រូវបានវាយតម្លៃនាកាលបរិច្ឆេទរាយការណ៍ និងត្រូវបានប្រៀបធៀបជាមួយនឹងហានិភ័យក្រោមលក្ខខណ្ឌដើមនៅពេលទទួលស្គាល់ដំបូង នៅពេលដែលការកែប្រែមិនមានភាពជាសារវន្ត ហើយមិនបណ្តាលឲ្យមានការឈប់ទទួលស្គាល់ឥណទានដំបូង។ ក្រុមហ៊ុនតាមដានដំណើរការទ្រព្យសកម្មដែលបានកែប្រែជាបន្តបន្ទាប់។ ក្រុមហ៊ុនអាចកំណត់ថាហានិភ័យឥណទាន ត្រូវបានកែលម្អគួរឲ្យកត់សម្គាល់ បន្ទាប់ពីការរៀបចំឡើងវិញរួច ដូចនេះទ្រព្យសកម្មនោះត្រូវបានដកចេញពីដំណាក់កាលទី៣ ឬដំណាក់កាលទី២ (ECL ពេញមួយអាយុកាល) មកដំណាក់កាលទី១ (ECL ១២ខែ) វិញ។ ករណីនេះគឺសម្រាប់តែទ្រព្យសកម្មដែលមានដំណើរការល្អស្របទៅតាមលក្ខខណ្ឌថ្មី ក្នុងរយៈពេល ៦ខែបន្តបន្ទាប់ ឬលើសពីនេះ។

**(ឃ) ហានិភ័យឥណទានអតិបរមាមុនពេលរឹបអូសវត្ថុបញ្ចាំ ឬមុនពេលពង្រីកឥណទានផ្សេងៗ**

ហានិភ័យឥណទានអតិបរមា ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ គឺស្មើនឹងតម្លៃយោងរបស់វា។ ចំពោះបំណុលយថាហេតុ ហានិភ័យឥណទានអតិបរមាគឺស្មើនឹងចំនួនទឹកប្រាក់អតិបរមាដែលក្រុមហ៊ុនត្រូវបង់ ប្រសិនបើកាតព្វកិច្ចនៃឧបករណ៍ដែលបានចេញផ្សាយត្រូវបានគេស្នើឲ្យបង់។ តារាងខាងក្រោមនេះ បង្ហាញពីហានិភ័យឥណទានអតិបរមាចំពោះក្រុមហ៊ុន ចំពោះឧបករណ៍ហិរញ្ញវត្ថុដែលដែលប្រឈមនឹងឱនភាពនៃតម្លៃ៖

| | ២០២៣<br>ពាន់រៀល | ២០២២<br>ពាន់រៀល | ២០២៣<br>ដុល្លារអាមេរិក<br>(កំណត់សម្គាល់ ២.៤(iii)) | ២០២២<br>ដុល្លារអាមេរិក<br>(កំណត់សម្គាល់ ២.៤(iii)) |
|---|---|---|---|---|
| ហានិភ័យឥណទានពាក់ព័ន្ធនឹង ទ្រព្យសកម្មក្នុងតារាងតុល្យការះ | | | | |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារនានា | ៦៧២.២៨៧.៤៨៦ | ៣៧១.៩៨៨.៩៩៩ | ១៦៤.៥៧៤.៦៦០ | ៩០.៣៥៤.៣៧២ |
| ឥណទាន និងបុរេប្រទានវាស់វែង តាមរំលស់ថ្លៃដើម | ៥.០០៣.១៣៩.៣៧៦ | ៥.០០៦.៧២៤.៤៧៣ | ១.២២៤.៧៥៨.៧២១ | ១.២១៦.១០៩.៩០៤ |
| ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗ | ៥.៤០៦.០៧៤ | ៤.៦៩១.៥៦៤ | ១.៣២៣.៣៩៦ | ១.១៣៩.៥៥៩ |
| ហានិភ័យឥណទានអតិបរមាសរុប ដែលមានឱនភាពនៃតម្លៃ | ៥.៦៨០.៨៣២.៩៣៦ | ៥.៣៨៣.៤០៤.៩៨៦ | ១.៣៩០.៦៥៦.៧៧៧ | ១.៣០៧.៦០៣.៨៣៥ |





## អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

### ៣៦. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

#### ៣៦.១ ហានិភ័យឥណទាន (ត)

**(ឃ) ហានិភ័យឥណទានអតិបរមាមុនពេលរឹបអូសវត្ថុបញ្ចាំ ឬមុនពេលពង្រីកឥណទានផ្សេងៗ (ត)**

តារាងខាងលើនេះបង្ហាញពីសេណារីយ៉ូដែលអាក្រក់បំផុតនៃហានិភ័យឥណទានរបស់ក្រុមហ៊ុន ដោយមិនបានគិតដល់ទ្រព្យបញ្ចាំដែលបានកាន់កាប់ និង/ឬ ការពង្រីកឥណទានផ្សេងៗទេ។ ហានិភ័យខាងលើគឺផ្អែកទៅលើតម្លៃយោងសុទ្ធ។ ដូចបានបង្ហាញខាងលើ ៨៨% (២០២២៖ ៩៤%) នៃហានិភ័យឥណទានអតិបរមាសរុបកើតមកពីឥណទាន និងបុរេប្រទាន។ អ្នកគ្រប់គ្រងជឿជាក់លើលទ្ធភាពរបស់ខ្លួនក្នុងការបន្តការគ្រប់គ្រង និងរក្សាហានិភ័យឥណទានដែលកើតមកពីឥណទាន និងបុរេប្រទានរបស់ក្រុមហ៊ុន ឲ្យស្ថិតក្នុងកម្រិតអប្បបរមាតាមវិធីដូចខាងក្រោម៖

- ស្ទើរតែគ្រប់ឥណទាន និងបុរេប្រទានទាំងអស់ ត្រូវបានធានាដោយទ្រព្យបញ្ចាំ ហើយទ្រព្យបញ្ចាំមានតម្លៃក្នុងចន្លោះពី ៥០% ទៅ ៨០% នៃឥណទាន។
- ក្រុមហ៊ុនមាននីតិវិធីវាយតម្លៃឥណទានសមស្រប មុនពេលផ្តល់ឥណទាន និងបុរេប្រទានជូនអតិថិជន។
- ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារទាំងអស់ ត្រូវបានផ្ញើនៅធនាគារក្នុងស្រុក ហើយអ្នកគ្រប់គ្រងបានធ្វើការវាយតម្លៃហានិភ័យសមស្រប ហើយជឿជាក់ថាក្រុមហ៊ុនមិនមានការខាតបង់ជាសារវន្តពីធនាគារក្នុងស្រុកទាំងនេះទេ។

**(ង) គុណភាពឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុ**

ក្រុមហ៊ុនវាយតម្លៃគុណភាពឥណទាន នៃឥណទាន និងបុរេប្រទាន និងហិរញ្ញប្បទាន ដោយប្រើវិធីសាស្ត្រវាយតម្លៃចំណាត់ថ្នាក់ផ្ទៃក្នុង ដែលត្រូវបានតាក់តែងឡើងយ៉ាងសមស្របជាមួយនឹងប្រភេទផលិតផល និងភាគីដៃគូផ្សេងៗគ្នា។ វិធីសាស្ត្រទាំងនេះត្រូវបានបង្កើតឡើងផ្ទៃក្នុងក្រុមហ៊ុន និងបានគួបផ្សំជាមួយនឹងការវិភាគស្ថិតិ រួមជាមួយនឹងការវិនិច្ឆ័យរបស់បុគ្គលិកផ្នែកឥណទាន។

## អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

### ៣៦. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

#### ៣៦.១ ហានិភ័យឥណទាន (ត)

(ង) គុណភាពឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

ការពណ៌នាពីគុណភាពឥណទាន ត្រូវបានសង្ខេបដូចខាងក្រោម៖

| គុណភាពឥណទាន | ពណ៌នា |
|---|---|
| ការតាមដានស្តង់ដា | អ្នកជាប់កាតព្វកិច្ចក្នុងប្រភេទនេះ បង្ហាញពីសមត្ថភាពរឹងមាំក្នុងការបំពេញកាតព្វកិច្ចសងប្រាក់។<br>ក្រុមហ៊ុនតាមដានអ្នកជាប់បំណុលក្នុងប្រភេទនេះ ទៅតាមស្ថានភាពនៃការសងប្រាក់យឺតយ៉ាវ។ អ្នកជាប់កាតព្វកិច្ចដែលសងប្រាក់ហួសកាលកំណត់សងតិចជាង ៣០ថ្ងៃ ក្នុងកិច្ចសន្យាសងប្រាក់ទាំងចំពោះ ហ្វាស៊ីលីធីរយៈពេលខ្លី និងហ្វាស៊ីលីធីរយៈពេលវែង គឺស្ថិតនៅក្នុងការតាមដានស្តង់ដា។ |
| ការតាមដានពិសេស | អ្នកជាប់កាតព្វកិច្ចក្នុងប្រភេទនេះ មានសមត្ថភាពមធ្យមក្នុងការបំពេញកាតព្វកិច្ចសងប្រាក់។<br>ក្រុមហ៊ុនតាមដានអ្នកជាប់បំណុលក្នុងប្រភេទនេះ ទៅតាមស្ថានភាពនៃការសងប្រាក់យឺតយ៉ាវ។ អ្នកជាប់កាតព្វកិច្ចដែលសងប្រាក់ហួសកាលកំណត់សង ៣០ថ្ងៃ ក្នុងកិច្ចសន្យាសងប្រាក់។ |
| ការមិនសងប្រាក់/ឱនភាពនៃតម្លៃឥណទាន | អ្នកជាប់កាតព្វកិច្ចត្រូវបានវាយតម្លៃថាមានការថយចុះតម្លៃ។ |

អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី
កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣
៣៦. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)
៣៦.១ ហានិភ័យឥណទាន (ត)
(ង) គុណភាពឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

គុណភាពឥណទាននៃឧបករណ៍ហិរញ្ញវត្ថុក្រៅពីឥណទាន និងបុរេប្រទាន និងហិរញ្ញប្បទាន ត្រូវបានកំណត់ដោយផ្អែក ទៅលើចំណាត់ថ្នាក់របស់ភាគីដៃគូ ដែលត្រូវបានកំណត់ថាមានតម្លៃស្មើនឹងអត្រារបស់ភ្នាក់ងារវាយតម្លៃចំណាត់ថ្នាក់អន្តរជាតិផ្សេងៗ ដូចខាងក្រោម៖

| គុណភាពឥណទាន | ពណ៌នា |
|---|---|
| អធិបតេយ្យ | សំដៅដល់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលចេញដោយធនាគារកណ្តាល/រដ្ឋបាល ឬត្រូវបានធានាដោយធនាគារកណ្តាល/រដ្ឋបាល។ |
| ចំណាត់ថ្នាក់វិនិយោគ | សំដៅដល់គុណភាពឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលអ្នកចេញផ្សាយមានលទ្ធភាពបំពេញ កាតព្វកិច្ចសងបំណុល ហើយអ្នកកាន់កាប់សញ្ញាប័ណ្ណមានហានិភ័យឥណទានទាប ចំពោះការមិន សងប្រាក់។ |
| មិនមានចំណាត់ថ្នាក់វិនិយោគ | សំដៅដល់គុណភាពឥណទានកម្រិតទាបនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានការប្រឈមខ្ពស់នឹងហានិភ័យនៃការមិនសងប្រាក់។ |
| មិនមានចំណាត់ថ្នាក់ | សំដៅដល់ទ្រព្យសកម្មហិរញ្ញវត្ថុដែលបច្ចុប្បន្ននេះ មិនមានចំណាត់ថ្នាក់ទេ អាស្រ័យដោយមិនមានគំរូចំណាត់ថ្នាក់។ |
| ថយចុះតម្លៃឥណទាន | សំដៅដល់ទ្រព្យសកម្មដែលមានការថយចុះតម្លៃ។ |

# ឯិលអូឯិលស៊ី (ខេមបូឌា) ភីអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ៣៦. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៦.១ ហានិភ័យឥណទាន (ត)

(ង) គុណភាពឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

តារាងខាងក្រោមនេះបង្ហាញពីការវិភាគហានិភ័យឥណទាន តាមដំណាក់កាលរួមជាមួយនឹងសំវិធានធន ECL៖

| | ២០២៣ | | | | ២០២២ | | | |
|---|---|---|---|---|---|---|---|---|
| | ECL ១២ខែ ពាន់រៀល | ECL ពេញមួយអាយុកាល-មិនមានឱនភាពនៃតម្លៃឥណទាន ពាន់រៀល | ECL ពេញមួយអាយុកាល-មានឱនភាពនៃតម្លៃឥណទាន ពាន់រៀល | សរុប ពាន់រៀល | ECL ១២ខែ ពាន់រៀល | ECL ពេញមួយអាយុកាល-មិនមានឱនភាពនៃតម្លៃឥណទាន ពាន់រៀល | ECL ពេញមួយអាយុកាល-មានឱនភាពនៃតម្លៃឥណទាន ពាន់រៀល | សរុប ពាន់រៀល |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា | | | | | | | | |
| មានចំណាត់ថ្នាក់វិនិយោគ | ២០០.៨៣២.១៥៨ | - | - | ២០០.៨៣២.១៥៨ | ១២៨.០១៤.៧៦៦ | - | - | ១២៨.០១៤.៧៦៦ |
| មិនមានចំណាត់ថ្នាក់វិនិយោគ | ៤៧៧.៧០៧.៩៤៣ | - | - | ៤៧៧.៧០៧.៩៤៣ | ២៤៧.០១២.៦៧៤ | - | - | ២៤៧.០១២.៦៧៤ |
| តម្លៃយោងដុល | ៦៧៨.៥៤០.១០១ | - | - | ៦៧៨.៥៤០.១០១ | ៣៧៥.០២៧.៤៤០ | - | - | ៣៧៥.០២៧.៤៤០ |
| ដកៈ ការខាតបង់ឥណទានរំពឹងទុក | (៦.២៥២.៦១៥) | - | - | (៦.២៥២.៦១៥) | (៣.០៣៨.៤៩១) | - | - | (៣.០៣៨.៤៩១) |
| តម្លៃយោងសុទ្ធ | ៦៧២.២៨៧.៤៨៦ | - | - | ៦៧២.២៨៧.៤៨៦ | ៣៧១.៩៨៨.៩៤៩ | - | - | ៣៧១.៩៨៨.៩៤៩ |
| គិតជាដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) | ១៦៤.៥៧៤.៦៦០ | - | - | ១៦៤.៥៧៤.៦៦០ | ៩០.៣៥៤.៣៧២ | - | - | ៩០.៣៥៤.៣៧២ |





# ឯិលអូឯិលស៊ី (ខេមបូឌា) ភីអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ៣៦. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៦.១ ហានិភ័យឥណទាន (ត)

(ង) គុណភាពឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

តារាងខាងក្រោមនេះបង្ហាញពីការវិភាគហានិភ័យឥណទាន តាមដំណាក់កាលរួមជាមួយនឹងសំវិធានធន ECL៖ (ត)

| | ២០២៣ | | | | ២០២២ | | | |
|---|---|---|---|---|---|---|---|---|
| | ECL ១២ខែ ពាន់រៀល | ECL ពេញមួយអាយុកាល-មិនមានឱនភាពនៃតម្លៃឥណទាន ពាន់រៀល | ECL ពេញមួយអាយុកាល-មានឱនភាពនៃតម្លៃឥណទាន ពាន់រៀល | សរុប ពាន់រៀល | ECL ១២ខែ ពាន់រៀល | ECL ពេញមួយអាយុកាល-មិនមានឱនភាពនៃតម្លៃឥណទាន ពាន់រៀល | ECL ពេញមួយអាយុកាល-មានឱនភាពនៃតម្លៃឥណទាន ពាន់រៀល | សរុប ពាន់រៀល |
| ឥណទាន និងបុរេប្រទានវាស់វែងតាមរំលស់ថ្លៃដើម | | | | | | | | |
| ការតាមដានស្តង់ដា | ៤.៩២១.៦៨៧.៦៩០ | - | - | ៤.៩២១.៦៨៧.៦៩០ | ៤.៩៤៨.៩៣៩.៨៨៦ | - | - | ៤.៩៤៨.៩៣៩.៨៨៦ |
| ការតាមដានពិសេស | - | ៥០.៣៨១.៧៩២ | - | ៥០.៣៨១.៧៩២ | - | ៧៣.៨៩០.៦៩៨ | - | ៧៣.៨៩០.៦៩៨ |
| ការមិនសងប្រាក់ | - | - | ១១៩.៩១២.០៨១ | ១១៩.៩១២.០៨១ | - | - | ១៣៥.៩១២.០៤០ | ១៣៥.៩១២.០៤០ |
| តម្លៃយោងដុល | ៤.៩២១.៦៨៧.៦៩០ | ៥០.៣៨១.៧៩២ | ១១៩.៩១២.០៨១ | ៥.០៩១.៩៨១.៥៦៣ | ៤.៩៤៨.៩៣៩.៨៨៦ | ៧៣.៨៩០.៦៩៨ | ១៣៥.៩១២.០៤០ | ៥.១៥៨.៦៩២.៦២៤ |
| ដកៈ ការខាតបង់ឥណទានរំពឹងទុក | (២៣.៤៤៧.២៧៥) | (៥.៧៧១.២៧១) | (៥៩.៦២៣.៦៤១) | (៨៨.៨៤២.១៨៧) | (៥៧.៩៨៤.០៦១) | (១០.២១៣.៤០៩) | (៨៣.៨១០.៦៨១) | (១៥១.៩៦៨.១៥១) |
| តម្លៃយោងសុទ្ធ | ៤.៨៩៨.២៤០.៤១៥ | ៤៤.៦១០.៥២១ | ៦០.២៨៨.៤៤០ | ៥.០០៣.១៣៩.៣៧៦ | ៤.៨៩០.៩៩៥.៨២៥ | ៦៣.៦២៧.២៨៩ | ៥២.១០១.៣៥៩ | ៥.០០៦.៧២៤.៤៧៣ |
| គិតជាដុល្លារអាមេរិក (កំណត់សម្គាល់ ២.៤(iii)) | ១.១៩៩.០៧៩.៦៦១ | ១០.៩២០.៥៦៨ | ១៤.៧៥៨.៤៩២ | ១.២២៤.៧៥៨.៧២១ | ១.១៨៧.៩៩៩.៩៥៧ | ១៥.៤៥៤.៧៧០ | ១២.៦៥៥.១៧៧ | ១.២១៦.១០៩.៩០៤ |

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ៣៦. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### ៣៦.១ ហានិភ័យឥណទាន (ត)

### (ច) សំវិធានធនសម្រាប់ការខាតបង់

(i) ការផ្ទៀងផ្ទាត់ការខាតបង់ឥណទានដែលបានរំពឹងទុក – ឥណទាន និងបុរេប្រទានវាស់វែងតាមរំលស់ថ្លៃដើម

| | ២០២៣ | | | |
|---|---|---|---|---|
